ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

កំពង់ផែស្វយ័តក្រុងព្រះសីហនុ
Sihanoukville Autonomous Port

# របាយការណ៍ប្រចាំឆ្នាំ ២០១៧



# ចក្ខុវិស័យ

ក្លាយជាមជ្ឈមណ្ឌលផ្គត់ផ្គង់ និងចែកចាយទំនិញឈានមុខគេនៅកម្ពុជា។

# បេសកកម្ម

ធានាបំពេញតាមតម្រូវការរបស់អតិថិជន តាមរយៈការបង្កើនគុណភាពសេវាកម្ម ប្រតិបត្តិការឆាប់រហ័ស និងតម្លៃសមស្រប។



# ព័ត៌មានហិរញ្ញវត្ថុសង្ខេប

| បរិយាយ | | ៣១ ធ្នូ ២០១៧ (ពាន់រៀល) | ៣១ ធ្នូ ២០១៦ (ពាន់រៀល) |
|---|---|---|---|
| **ស្ថានភាពហិរញ្ញវត្ថុ** | | | |
| ទ្រព្យសកម្មសរុប | | ១.២៨០.៥១០.០៣៨ | ១.០៨២.៩៣១.៦៤៧ |
| បំណុលសរុប | | ៦៣៣.៨៩៩.៤៨៤ | ៥៤៨.៣១៨.៦៣៦ |
| មូលធនសរុប | | ៦៤៦.៦១០.៥៥៤ | ៥៣៤.៦១៣.០១១ |
| **លទ្ធផលហិរញ្ញវត្ថុ** | | **ឆ្នាំ២០១៧** | **ឆ្នាំ២០១៦** |
| ចំណូលសរុប | | ២២៧.៣៩៧.៨៣៥ | ២០៨.៩៨១.២៤៩ |
| ចំណេញមុនបង់ពន្ធ | | ៣៧.៨៥៤.៦៣២ | ៣៥.៨៤៦.១៧៥ |
| ចំណេញសុទ្ធក្រោយបង់ពន្ធ | | ២៥.១៣៩.៣១៦ | ២៦.៧២០.៤៧២ |
| **អនុបាតហិរញ្ញវត្ថុ** | | | |
| អនុបាតសន្ទនីយភាព | អនុបាតចរន្ត | ២,៦១ | ២,០៦ |
| | អនុបាតចរន្តលឿន | ២,៤៩ | ១,៨៨ |
| អនុបាតចំណេញភាព | ផលចំណេញក្នុងមួយឯកតាទ្រព្យសកម្ម | ១,៩៦% | ២,៤៧% |
| | ផលចំណេញក្នុងមួយឯកតាមូលធន | ៣,៨៩% | ៥,០០% |
| | គំលាតចំណេញដុល | ២៥,៦៨% | ២៦,១៣% |
| | គំលាតចំណេញភាព | ១១,០៦% | ១២,៧៩% |
| | ចំណេញក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ (រៀល) | ៣២៨,៤០% | ៤១៥,៣៧% |

# ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេបប្រចាំឆ្នាំ២០១៧

## ស្ថានភាពហិរញ្ញវត្ថុ (ពាន់រៀល)




## ចំណេញប្រចាំឆ្នាំ ២០១៧ និង ២០១៦






## ភាគហ៊ុនិករបស់ កសស

| ល.រ | ប្រភេទមូលបត្រកម្មសិទ្ធិ | ភាគហ៊ុនិក | ចំនួនមូលបត្រកាន់កាប់ | ភាគរយ |
|---|---|---|---|---|
| ១ | មូលបត្រកម្មសិទ្ធិគ្មានសិទ្ធបោះឆ្នោតប្រភេទ "ក" | រដ្ឋតំណាងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ៣៦៤.៥៣០.៨៦១ | ៨០,៩៥% |
| ២ | មូលបត្រកម្មសិទ្ធិមានសិទ្ធបោះឆ្នោតប្រភេទ "ខ" | រដ្ឋតំណាងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ៦៤.៣២៨.៩៧៥ | ១៤,២៩% |
| ៣ | មូលបត្រកម្មសិទ្ធិមានសិទ្ធបោះឆ្នោតប្រភេទ "គ" | ឯកជន | ២១.៤៤២.៩៩២ | ៤,៧៦% |
| សរុប | | | ៤៥០.៣០២.៨២៨ | ១០០% |

## ❖ ភាគហ៊ុនិកកាន់កាប់មូលបត្រកម្មសិទ្ធិប្រភេទ "គ" របស់ កសស

| ល.រ | ភាគហ៊ុនិក | ចំនួនមូលបត្រកាន់កាប់ | ភាគរយ |
|---|---|---|---|
| ១ | ESOP | ២.១៤៤.២៩៩ | ១០% |
| ២ | JICA | ១១.៥៧៩.២១៦ | ៥៤% |
| ៣ | ភាគហ៊ុនិកឯកជនដទៃទៀត | ៧.៧១៩.៤៧៧ | ៣៦% |
| សរុប | | | ១០០% |




## បំរែបំរួលថ្លៃភាគហ៊ុន និងទំហំជួញដូរ



# សមាសភាពក្រុមប្រឹក្សាភិបាល



**ឯកឧត្តម លូ គឹមឈន់**
ប្រធានអគ្គនាយក



**ឯកឧត្តម តឹករ៉េត សំរេច**
តំណាងទីស្តីការគណៈរដ្ឋមន្ត្រី



**ឯកឧត្តម ផាន់ ផល្លា**
តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ



**ឯកឧត្តម យន្ត មីន**
តំណាងអាជ្ញាធរខេត្តព្រះសីហនុ



**ឯកឧត្តម ស៊ុយ សាន**
តំណាងក្រសួងសាធារណការ និងដឹកជញ្ជូន



**ឯកឧត្តម សុខ សុភ័ក្រ្ត**
តំណាងក្រសួងពាណិជ្ជកម្ម



**លោក លូ លីខេង**
តំណាងនិយោជិតកម្មករ
កំពង់ផែស្វយ័តក្រុងព្រះសីហនុ

# សេចក្តីថ្លែងរបស់ប្រធានអគ្គនាយក



"ជួសមុខឱ្យ ក្រុមប្រឹក្សាភិបាលរបស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ (**កសស**) ខ្ញុំមានកិត្តិយស និងក្តីសោមនស្សរីករាយ ក្នុងការបង្ហាញជូននូវរបាយការណ៍អាជីវកម្ម និងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ២០១៧ របស់ **កសស** សម្រាប់ការិយបរិច្ឆេទ បញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧" ។

ដោយមានការគាំទ្រយ៉ាងមុតមាំពីរាជរដ្ឋាភិបាល ក៏ដូចជាក្រសួងអាណាព្យាបាលទាំងពីរ **កសស** បានបន្តការវិវឌ្ឍន៍យ៉ាងខ្លាំងក្លាដើម្បីបម្រើសកម្មភាពធុរកិច្ចរបស់ខ្លួន ជាលទ្ធផលនៅក្នុងឆ្នាំ២០១៧នេះ **កសស** ទទួលបានប្រាក់ចំណូលសរុបចំនួន ២២៧.៣៩៧.៨៣៥.000រៀល និងទទួលបានប្រាក់ចំណេញសុទ្ធក្នុងការិយបរិច្ឆេទ សរុបចំនួន ២៥.១៣៩.៣១៦.000រៀល។ បើប្រៀបធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៦ ប្រាក់ចំណូលបានកើនឡើង ចំនួន ១៨.៤១៦.៥៨៦.000រៀល គឺស្មើនឹង ៨,៨១% ចំណែកប្រាក់ចំណេញសុទ្ធក្រោយបង់ពន្ធមានការថយចុះ ចំនួន ១.៥៨១.១៥៦.000រៀល គឺស្មើនឹង ៥,៩២% ដោយសារចំណេញពីអត្រាប្តូរប្រាក់យ៉េនមានការថយចុះ។ ក្នុងឆ្នាំ២០១៧នេះ កុងតឺន័រដែលបានឆ្លងកាត់ **កសស** មានចំនួន ៤៥៩.៨៣៩ TEUs ពោលគឺ កើនចំនួន ៥៩.៦៥២ TEUs ស្មើនឹង ១៤,៩១% បើធៀបនឹងឆ្នាំ២០១៦។ ជាលទ្ធផលចំណេញ ក្នុងមួយឯកតាមូលបត្រកម្មសិទ្ធមានចំនួន ៣២៨,៤0 រៀល សម្រាប់ ឆ្នាំ២០១៧ នេះ។

**កសស** នឹងបន្តកិច្ចខិតខំប្រឹងប្រែង ដើម្បីបំពេញសេវាកម្ម អាជីវកម្មឱ្យកាន់តែប្រសើរ និងសម្រេចបានលទ្ធផលខ្ពស់ជាប្រយោជន៍ដល់ភាគហ៊ុនិករបស់ខ្លួន។ **កសស** បានពង្រឹងប្រសិទ្ធភាពការងារ និងការកសាងហេដ្ឋារចនាសម្ព័ន្ធបន្ថែមទៀត ដើម្បីឆ្លើយតបនឹងកំណើនតម្រូវការសេវាកម្មរបស់អតិថិជន និងការរីកចម្រើនសេដ្ឋកិច្ចជាតិ។ ជាក់ស្តែងការអភិវឌ្ឍចំណតផែពហុបំណងសម្រេចបានប្រហែល ៩៤,00% ហើយបើគិតមកត្រឹមដំណាច់ឆ្នាំ២០១៧នេះ។ ចំណតផែពហុបំណងមានគោលដៅចូលរួមលើកកម្ពស់វិស័យ កសិកម្ម កសិឧស្សាហកម្ម ឧស្សាហកម្ម ពាណិជ្ជកម្ម និងពិសេសដើម្បីគាំទ្រដល់ការនាំចេញផលិតផល កសិកម្មរបស់កម្ពុជាដូចជា អង្ករ ចំណិតដំឡូងមីស្ងួត និងទំនិញរាយ ដែលជាការឆ្លើយតបចំពោះយុទ្ធសាស្រ្ត ពង្រីកទីផ្សារនាំអង្ករចេញរបស់រាជរដ្ឋាភិបាលកម្ពុជា ក៏ដូចជាការផ្តល់សេវាភស្តុភាដល់ការរុករកប្រេងក្នុងដែនសមុទ្រកម្ពុជា ។ ក្រៅពីនេះ ចំណតផែពហុបំណងក៏មានគោលដៅលើការនាំចូលធ្យូងថ្មដែលប្រើប្រាស់ក្នុងការផលិតថាមពលអគ្គិសនី និងស៊ីម៉ងត៍ផងដែរ ។

## ➤ ដើម្បីឆ្លើយតបនឹងការកើនឡើងនៃបរិមាណទំនិញឆ្លងកាត់ ក៏ដូចជាតម្រូវការសេវាកម្មរបស់អតិថិជន កសស មានទិសដៅការងារចម្បងៗដូចខាងក្រោម៖

- អនុវត្តបន្តការងារតាមផែនការដែលបានគ្រោងទុកសម្រាប់ឆ្នាំ ២០១៨
- រក្សានូវឧត្តមភាពនៃភាពប្រកួតប្រជែងរបស់ខ្លួន ដោយធានានូវគុណភាពសេវាកម្ម តម្លៃប្រកួតប្រជែង ប្រសិទ្ធភាពការងារ និងការកសាងទំនុកចិត្តជូនអតិថិជន
- ពង្រឹងសមត្ថភាពបុគ្គលិកលើការគ្រប់គ្រង និងបច្ចេកទេស ដើម្បីឆ្លើយតបឱ្យបានទាន់ពេលវេលា ចំពោះកំណើនតំរូវការសេវាកម្មរបស់កំពង់ផែ
- បន្តអនុវត្ត និងតាមដានការអភិវឌ្ឍចំណតផែពហុបំណង ដើម្បីឱ្យសម្រេចបានតាមផែនការ
- ជួសជុល ថែទាំ និងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផែ និងគ្រឿងចក្របន្ថែមទៀត ដើម្បីរក្សាឧត្តមភាពប្រកួតប្រជែង និងលើកកំពស់សមត្ថភាពលើកដាក់ទំនិញរបស់ខ្លួន
- ពង្រឹងកិច្ចសហប្រតិបត្តិការជាយុទ្ធសាស្រ្តជាមួយកំពង់ផែក្នុងប្រទេស និងក្នុងតំបន់
- ពង្រឹងអភិបាលកិច្ចគ្រប់គ្រង តាមរយៈការបង្កើតគណៈកម្មាធិការសំខាន់ៗ
- ចូលរួមក្នុងសកម្មភាពអភិវឌ្ឍសហគមន៍មូលដ្ឋាន និងលើកកំពស់សុខមាលភាពសង្គម

## ➤ ការអនុវត្តការងាររបស់ក្រុមប្រឹក្សាភិបាល

នៅក្នុងឆ្នាំ២០១៧ នេះក្រុមប្រឹក្សាភិបាលបានធ្វើការជួបប្រជុំចំនួន ០២ លើក និងបាន សម្រេចការងារដូចខាងក្រោម៖

***សម័យប្រជុំក្រុមប្រឹក្សាភិបាល អាណត្តិទី ៦ លើក ទី ៤ នា ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០១៧***

កិច្ចប្រជុំបានពិនិត្យ និងសម្រេចលើចំនុចដូចខាងក្រោម៖

- ឯកភាពលើរបាយការណ៍លទ្ធផលការងារអាជីវកម្ម **កសស** ឆមាសទី១ ឆ្នាំ២០១៧
- ឯកភាពលើរបាយការណ៍ស្តីពីវឌ្ឍនភាពនៃការងារអនុវត្តគម្រោងអភិវឌ្ឍចំណតផែពហុបំណង ក្រោមឥណទានសម្បទានជប៉ុន JICA លេខ CP-P10
- ឯកភាពលើរបាយការណ៍ហិរញ្ញវត្ថុសម្រាប់ការិយបរិច្ឆេទ ឆ្នាំ២០១៦ ដែលបានត្រួតពិនិត្យដោយក្រុមហ៊ុនសវនកម្មឯករាជ្យ Price WaterHouseCoopers (Cambodia) Ltd (PWC )
- ពិនិត្យនិងអនុម័តទិញដីសម្រាប់ធ្វើជា Inland Container Depot (ICD)។
- ពិនិត្យនិងពិភាក្សាលើការវិនិយោគសាងសង់កំពង់ផែទេសចរ។

***សម័យប្រជុំក្រុមប្រឹក្សាភិបាល អាណត្តិទី ៦ លើក ទី ៥ នា ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៧***

កិច្ចប្រជុំបានពិនិត្យ និងសម្រេចលើចំនុចដូចខាងក្រោម៖

- ឯកភាពលើរបាយការណ៍លទ្ធផលការងារអាជីវកម្ម **កសស** ១០ខែ ឆ្នាំ២០១៧
- ឯកភាពលើរបាយការណ៍ស្តីពីវឌ្ឍនភាពនៃការងារអនុវត្តគម្រោងអភិវឌ្ឍចំណតផែពហុបំណង ក្រោម ឥណទានសម្បទានជប៉ុន JICA លេខ CP-P10
- ឯកភាពលើរបាយការណ៍ហិរញ្ញវត្ថុសម្រាប់ត្រីមាសទី៣ ឆ្នាំ២០១៧ ដែលបានត្រួតពិនិត្យដោយក្រុមហ៊ុនសវនកម្មឯករាជ្យ Price Water House Coopers (Cambodia) Ltd (PWC)

- របាយការណ៍ស្តីពីវឌ្ឍនភាព ក្រោយពេលដែល **កសស** បានបោះផ្សាយលក់មូលបត្រជាសាធារណៈ នៅផ្សារមូលបត្រកម្ពុជា និងសកម្មភាពការងារបន្ត។ ក្រុមប្រឹក្សាភិបាលបានឯកភាពលើលក្ខណ្ឌ និងគុណវឌ្ឍិ នៃការជ្រើសរើសអភិបាលឯករាជ្យនិង អភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជន និងការគ្រោងពេលវេលានៃការធ្វើមហាសន្និបាតភាគហ៊ុនិកលើកទី១។
- ពិនិត្យនិងអនុម័តគម្រោងផែនការអាជីវកម្ម (សេវាកម្ម) ហិរញ្ញវត្ថុ **កសស** ឆ្នាំ២០១៨។

## សេចក្តីថ្លែងអំណរគុណ

ជាថ្មីម្តងទៀត យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះរាជរដ្ឋាភិបាលកម្ពុជា ដែលដឹកនាំដោយសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងអាណាព្យាបាលទាំងពីរ គឺក្រសួងសាធារណៈការ និងដឹកជញ្ជូន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលជានិច្ចកាលតែងតែគាំទ្រ និងទុកចិត្តដល់សកម្មភាពការងាររបស់ **កសស** រៀងរហូតមក ។

ថ្ងៃ ១០ កើត ខែ ចេត្រ ឆ្នាំ រកា នព្វស័ក ព.ស.២៥៦១
ខេត្តព្រះសីហនុ, ថ្ងៃ ទី ២៦ ខែ មីនា គ.ស.២០១៨
**ប្រធានអគ្គនាយក**

**លូ_គីមឈន់**

# មាតិកា


ទស្សនវិស័យ និងបេសកកម្ម ..... i
ព័ត៌មានហិរញ្ញវត្ថុសង្ខេប ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប ..... ii
សមាសភាពក្រុមប្រឹក្សាភិបាល ..... vi
សេចក្តីថ្លែងរបស់ប្រធានអគ្គនាយក ..... vi

**ផ្នែកទី ១ : ព័ត៌មានពាក់ព័ន្ធនឹងកំពង់ផែស្វយ័តក្រុងព្រះសីហនុ ..... ២**

១- ព័ត៌មានទូទៅអំពីកំពង់ផែស្វយ័តក្រុងព្រះសីហនុ ..... ៣
២- ដំណើរការធុរកិច្ចសង្ខេប ..... ៣
៣- ស្ថានភាពទីផ្សារ ..... ៦
៤- ស្ថានភាពប្រកួតប្រជែង ..... ១០
៥- ផែនការអនាគត ..... ១១

**ផ្នែកទី ២ : ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច ..... ២០**

១- លទ្ធផលប្រតិបត្តិការធុរកិច្ច ដោយរួមបញ្ចូលព័ត៌មានធុរកិច្ចតាមផ្នែក ..... ២១
២- ការប្រែប្រួលសំខាន់ៗពាក់ព័ន្ធនឹងប្រតិបត្តិការធុរកិច្ច ..... ២៤
៣- រចនាសម្ព័ន្ធចំណូល ..... ២៤

**ផ្នែកទី ៣ : អភិបាលកិច្ចសាជីវកម្ម ..... ២៥**

១- ភាគហ៊ុនិក ..... ២៦
២- អង្គការលេខ ..... ៣១
៣- ក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការនានា ..... ៣២
៤- បុគ្គលិកជាន់ខ្ពស់ ..... ៤៤
៥- ការជាប់ពាក់ព័ន្ធរបស់អភិបាល និងបុគ្គលិកជាន់ខ្ពស់ក្នុងដំណើរការផ្លូវច្បាប់ ..... ៦៨
៦- លាភការ ឬប្រាក់បំណាច់ចំពោះអភិបាល និងបុគ្គលិកជាន់ខ្ពស់ ..... ៦៩
៧- ក្រមសីលធម៌សម្រាប់អភិបាល និងបុគ្គលិកជាន់ខ្ពស់ ..... ៧១

**ផ្នែកទី ៤ : ព័ត៌មានអំពីការជួញដូរមូលបត្ររបស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ ..... ៧៦**

១- ព័ត៌មានអំពីមូលបត្រកម្មសិទ្ធ ..... ៧៧
២- ថ្លៃ និងបរិមាណជួញដូរ ..... ៧៧

**ផ្នែកទី ៥ : របាយការណ៍សវនកម្មរបស់សវនករផ្ទៃក្នុងលើការត្រួតពិនិត្យផ្ទៃក្នុង**..............................៧៨

**ផ្នែកទី ៦ : របាយការណ៍ហិរញ្ញវត្ថុដែលបានពិនិត្យឡើងវិញដោយសវនករឯករាជ្យ**.......................៩០

**ផ្នែកទី ៧ : ព័ត៌មានអំពីប្រតិបត្តិការជាមួយភាគីជាប់ពាក់ព័ន្ធ** ....................................................១៥៤

១- ប្រតិបត្តិការជាមួយភាគហ៊ុនិក...........................................................................១៥៥

២- ប្រតិបត្តិការសំខាន់ៗជាមួយអភិបាល ឬបុគ្គលិកជាន់ខ្ពស់ ឬប្រតិបត្តិការសំខាន់ៗជាមួយបុគ្គល ដែលអភិបាល ឬបុគ្គលិកជាន់ខ្ពស់មានផលប្រយោជន៍

៣- ប្រតិបត្តិការសំខាន់ៗជាមួយសមាជិកគ្រួសារផ្ទាល់របស់អភិបាល និងបុគ្គលិកជាន់ខ្ពស់.........១៥៧

៤- ប្រតិបត្តិការសំខាន់ៗជាមួយបុគ្គលដែលមានទំនាក់ទំនងជាមួយអភិបាលរបស់កំពង់ផែស្វយ័ត ក្រុងព្រះសីហនុ ក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬក្រុមហ៊ុនហូលឌីងរបស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ ដែលទំនាក់ទំនងរបស់បុគ្គលទាំងនោះកើតមាននៅក្នុងប្រតិបត្តិការ ឬការចាត់ចែងណាមួយ ដែលធ្វើឡើងដោយកំពង់ផែស្វយ័តក្រុងព្រះសីហនុ......................................................១៥៧

៥- ប្រតិបត្តិការសំខាន់ៗជាមួយបុគ្គលធ្លាប់ជាអភិបាល ឬបុគ្គលជាប់ពាក់ព័ន្ធជាមួយបុគ្គលធ្លាប់ជា អភិបាលក្នុងរយៈពេល ០២ (ពីរ) ឆ្នាំចុងក្រោយ........................................................១៥៧

៦- ប្រតិបត្តិការសំខាន់ៗជាមួយអភិបាលដែលទទួលបានផលប្រយោជន៍ ឬកម្រៃវិជ្ជាជីវៈសម្រាប់សេវា ដែលខ្លួនបានផ្តល់តាមរយៈក្រុមហ៊ុនណាមួយ ដល់កំពង់ផែស្វយ័តក្រុងព្រះសីហនុ..............១៥៧

៧- ប្រតិបត្តិការសំខាន់ៗជាមួយភាគីជាប់ពាក់ព័ន្ធផ្សេងទៀត...............................................១៥៧

**ផ្នែកទី ៨ : ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង** ........................................................១៥៨

១-ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ ....................................................................................១៥៩

២-កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេញ..............................................................១៦៩

៣-ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល ..........................................................១៧០

៤-ផលប៉ះពាល់នៃការប្តូររូបិយបណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ (Commodity).......................១៧០

៥-ផលប៉ះពាល់នៃអតិផរណា .......................................................................................១៧០

៦-គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុ របស់រដ្ឋាភិបាល..................................១៧១

**ផ្នែកទី ៩ : ព័ត៌មានចាំបាច់ផ្សេងទៀតសម្រាប់ការពារវិនិយោគិន**.............................................១៧២

ហត្ថលេខារបស់អភិបាលកំពង់ស្វយ័តក្រុងព្រះសីហនុ....................................................១៧៤



# ផ្នែកទី ១

## ព័ត៌មានពាក់ព័ន្ធនឹងកំពង់ផែស្វយ័តក្រុងព្រះសីហនុ

## ១- ព័ត៌មានទូទៅអំពីកំពង់ផែស្វយ័តក្រុងព្រះសីហនុ

ឈ្មោះក្រុមហ៊ុនជាអក្សរខ្មែរ៖ **កំពង់ផែស្វយ័តក្រុងព្រះសីហនុ (កសស)**

ឈ្មោះក្រុមហ៊ុនជាអក្សរ (ឡាតាំង)៖ PORT AUTONOME DE SIHANOUKVILLE "PAS"

ឈ្មោះក្រុមហ៊ុនជាអក្សរ (អង់គ្លេស)៖ SIHANOUKVILLE AUTONOMOUS PORT

អក្សរកូដ៖ KH1000060009

អាសយដ្ឋាន៖ **តិរៈវិថីសម្តេចអគ្គមហាសេនាបតីតេជោហ៊ុនសែន សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ព្រះរាជាណាចក្រកម្ពុជា។**

លេខទូរស័ព្ទ៖ **(៨៥៥) ៣៤ ៩៣៣ ៤១៦ /៩៣៣ ៥១១**

លេខទូរសារ៖ **(៨៥៥) ៣៤ ៩៣ ៣ ៦៩៣**

គេហទំព័រ៖ www.pas.gov.kh

អ៊ីម៉ែល៖ pasinfo@pas.gov.kh

លេខវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម៖ **Co.៤៧៨៤ Et / ២០១៧** កាលបរិច្ឆេទ៖ **២១ កុម្ភៈ ២០១៧**

លេខអាជ្ញាបណ្ណអាជីវកម្ម៖ **០១៥៩ ពណ.ចបព** កាលបរិច្ឆេទ៖ **២២ កុម្ភៈ ២០១៧**

សេចក្តីសម្រេចអនុញ្ញាតនិងចុះបញ្ជីឯកសារផ្តល់ព័ត៌មានលេខ៖ **០៥៨/១៧/គ.ម.ក/ស.ស.រ**

កាលបរិច្ឆេទ៖ **០៩ ឧសភា ២០១៧**

ឈ្មោះបុគ្គលតំណាងបុគ្គលបោះផ្សាយ៖ **ឯកឧត្តម លូ គឹមឈន់**

## ២- ដំណើរការធុរកិច្ចសង្ខេប

កំពង់ផែស្វយ័តក្រុងព្រះសីហនុ គឺជាកំពង់ផែសមុទ្រអន្តរជាតិទឹកជ្រៅតែមួយគត់នៅព្រះរាជាណាចក្រកម្ពុជា ដែលកំពុងធ្វើអាជីវកម្មលើផ្ទៃដីប្រមាណ ១២៥ ហិកតា។ ដោយស្ថិតនៅតាមបណ្តោយឆ្នេរនៃព្រះរាជាណាចក្រកម្ពុជា ក្នុងឈូងសមុទ្រថៃ **កសស** ទទួលបានភាពអនុគ្រោះពីធម្មជាតិ ដោយទទួលបានលក្ខខណ្ឌប្រតិបត្តិការយ៉ាងរលូនពេញមួយឆ្នាំ ដោយមានទឹកសមុទ្រស្ងប់ស្ងាត់ល្អ និងពុំមានព្យុះធំៗឡើយ ។

**កសស** ត្រូវបានតភ្ជាប់ដោយបណ្តាញដឹកជញ្ជូនចំរុះ។ តាមផ្លូវគោក **កសស** ត្រូវបានតភ្ជាប់ដោយ ផ្លូវជាតិសំខាន់ៗពីរ គឺផ្លូវជាតិលេខ ៤ ដែលមានប្រវែង ២២៦ គីឡូម៉ែត្រ ពីរាជធានីភ្នំពេញ និងផ្លូវជាតិលេខ ៣ ដែលកាត់តាមទីរួមខេត្តកំពត ដែលមានប្រវែង ២៤៤ គីឡូម៉ែត្រ។ **កសស** ក៏ត្រូវតភ្ជាប់ដោយខ្សែរថភ្លើងភាគខាងត្បូងពីភ្នំពេញ កាត់តាមខេត្តកំពត ដែលមានប្រវែង ២៦៤ គីឡូម៉ែត្រ។ ចំណែកតាមផ្លូវអាកាស **កសស** ត្រូវបានតភ្ជាប់ទៅខេត្តសៀមរាប និងរាជធានីភ្នំពេញដោយអាកាសយានដ្ឋានអន្តរជាតិខេត្តព្រះសីហនុ ។

ក្នុងនាមជាប្រតិបត្តិករផែ **កសស** ត្រូវបំពេញអាជីវកម្ម និងសេវាកម្មដូចខាងក្រោម៖

កណ្តាធារកិច្ច នាំនាវាចេញ-ចូល និងផ្តល់ភស្តុភាដល់នាវា

លើកដាក់ ផ្ទេរ-ផ្ទុក ទំនិញ
ស្តុកទំនិញ នៅឃ្លាំង និងទីលាន
ដឹកជញ្ជូនទំនិញ
តំបន់សេដ្ឋកិច្ចពិសេស



កសស មានចំណតផែសរុបប្រវែង ១.៣៣០ ម៉ែត្រ ដោយចែកជា ៩ ចំណតដូចខាងក្រោម៖

| ល.រ | ឈ្មោះស្ថានីយ៍ | ប្រភេទទំនិញ | បណ្តោយ (ម៉ែត្រ) | ទទឹង (ម៉ែត្រ) | ចំណត |
|---|---|---|---|---|---|
| ១ | ស្ថានីយ៍ផែអ្នកដំណើរ (ចំណតផែចាស់) | អ្នកដំណើរ និងទំនិញរាយ | ២៩០ | ២៨ | លេខ ១ និង លេខ ៣៖ ជម្រៅ ៩ម៉ែត្រ ដល់ ១៣ម៉ែត្រ សម្រាប់នាវាដែលមានជម្រៅបាត ៨,៥ម៉ែត្រ ចូលចតបាន ។ លេខ ២ និង លេខ ៤៖ ជម្រៅ ៦,៥ម៉ែត្រ ដល់ ៨ម៉ែត្រ សម្រាប់នាវាដែលមានជម្រៅបាត ៧ម៉ែត្រ ចូលចតបាន ។ |
| ២ | ស្ថានីយ៍ផែថ្មី | កុងតឺន័រ | ៣៥០ | ៥០០ | លេខ ៥ (ផ្នែកខាងលិច) និង លេខ ៦ (ផ្នែកខាងកើត)៖ ជម្រៅ ១០ម៉ែត្រ សម្រាប់នាវាដែលមានជម្រៅបាតក្រោម ៨,៥ម៉ែត្រ ចូលចតបាន ។ |
| ៣ | ស្ថានីយ៍ផែកុងតឺន័រ | កុងតឺន័រ | ៤០០ | ៣៥០ | លេខ ៧ និង លេខ ៨៖ ជម្រៅ ១១ម៉ែត្រ សម្រាប់នាវាដែលមានជម្រៅបាតក្រោម ៨,៥ ម៉ែត្រ ចូលចតបាន ។ |
| ៤ | ស្ថានីយ៍ផែថ្ម | ដឹកប្រេង | ៥៣ | ៥ | ចំណតផែប្រេង៖ ជម្រៅ ៤,៥ ម៉ែត្រ ហើយមានប្រវែង សរុបក្រោម ៨០ម៉ែត្រ ។ ឧបករណ៍ទាក់ពួរកៃច្នៃ ត្រូវបានរៀបចំសម្រាប់ នាវាប្រេងដែលមានជម្រៅបាតក្រោម ៦ម៉ែត្រ និងប្រវែងក្រោម ១១០ម៉ែត្រ ធ្វើការចូលចតបាន ។ |

### ស្ថានីយ៍រថភ្លើងដឹកកុងតឺន័រ

ក្រៅពីចំណតផែខាងលើ ដោយសហការជាមួយក្រុមហ៊ុន Toll (Cambodia) Co., Ltd **កសស** ក៏មានប្រតិបត្តិការប្រព័ន្ធផ្លូវដែក និងទីលានផ្ទុកទំនិញកុងតឺន័រក្នុងបរិវេណកំពង់ផែដើម្បីឱ្យអតិថិជន ឬម្ចាស់ ទំនិញអាចដឹកជញ្ជូនទៅវិញទៅមកពី **កសស** ទៅភ្នំពេញ។ **កសស** បានជួលដីបរិវេណនេះទៅឱ្យក្រុមហ៊ុន Toll (Cambodia) Co., Ltd ហើយផ្តល់សេវាកម្មលើកដាក់កុងតឺន័រទៅលើ និងចុះពីរថភ្លើង ។

### តំបន់សេដ្ឋកិច្ចពិសេសកំពង់ផែស្វយ័តក្រុងព្រះសីហនុ

ក្រៅពីអាជីវកម្ម សេវាកម្មខាងលើ **កសស** ក៏ប្រតិបត្តិដំណើរការតំបន់សេដ្ឋកិច្ចពិសេសកំពង់ផែស្វយ័តក្រុងព្រះសីហនុ ដែលមានទំហំប្រមាណ ៦៤ ហិកតា ដែលបានកសាងឡើងតាមបទដ្ឋានប្រទេសជប៉ុន ។



## ៣- ស្ថានភាពទីផ្សារ

ស្ថានភាពទីផ្សាររបស់ **កសស** គឺពឹងផ្អែកយ៉ាងខ្លាំងទៅលើចរាចរណ៍កុងតឺន័រ យើងសង្កេតឃើញថាសម្រាប់ឆ្នាំ២០១៧នេះ មានលក្ខណៈល្អប្រសើរបើប្រៀបធៀបទៅឆ្នាំ២០១៦ បរិមាណកុងតឺន័រ (TEUs) គឺមានកំណើនប្រមាណ ១៤,៩១% និងកើនឡើង ៩,២៣% បើធៀបនឹងផែនការឆ្នាំ២០១៧ ។ បើពិនិត្យមើលទៅលើបរិមាណកុងតឺន័រនាំចេញ និងនាំចូលឆ្លងកាត់ **កសស** កុងតឺន័រនាំចូលសម្រាប់ឆ្នាំ២០១៧ មានកំណើន ៣៥.១១៤TEUs ស្មើនឹង ១៧,៦៩% បើធៀបនឹងឆ្នាំ២០១៦ ចំណែកបរិមាណកុងតឺន័រនាំចេញ មានកំណើន ២៤,៥៣៨TEUs ស្មើនឹង ១២,១៧% ។ យោងទៅលើខ្សែកោងកុងតឺន័រឆ្លងកាត់ **កសស** យើងសង្កេតឃើញថា

សម្រាប់ឆ្នាំ២០១៧នេះ ចំនួនកុងតឺន័រមានកំណើនគ្រប់ត្រីមាសបើធៀបនឹងចំនួនកុងតឺន័រតាមត្រីមាសសម្រាប់ឆ្នាំមុនៗ ហើយខ្សែកោងនេះមានកំណើនជារៀងរាល់ឆ្នាំ នេះបញ្ជាក់ពីស្ថានភាពទីផ្សាររបស់ **កសស** មានភាពល្អប្រសើរ ។







ចាប់តាំងពីឆ្នាំ២០១៤ រហូតដល់បច្ចុប្បន្ន មានចរាចរកុងតឺន័រមួយចំនួនដឹងតាមរយៈរថភ្លើងឆ្លងកាត់ **កសស** ដែលបានជួយសម្រួលមួយផ្នែកលើស្ថានភាពចរាចរណ៍ផ្លូវជាលេខ ៤ ក៏ដូចជាផ្តល់នូវជម្រើសសម្រាប់អតិថិជនរបស់ **កសស** ក្នុងការដឹកទំនិញចេញ-ចូលកំពុងផែ ។ យើងសង្កេតឃើញថា បរិមាណកុងតឺន័រដឹកតាមរថភ្លើងឆ្លងកាត់ **កសស** មានកំណើនពីមួយឆ្នាំទៅមួយឆ្នាំ ជាក់ស្តែងសម្រាប់ឆ្នាំ២០១៧ ទាំងនាំចេញនាំចូលមានចំនួន ៤១.៥៨៩ TEUs កើនឡើង ៣១.៩៦% ស្មើនឹង ១០.០៧៥ TEUs បើធៀបនឹងឆ្នាំ២០១៦ ដែលមានចំនួន ៣១.៥២៣ TEUs ។




បើគិតពីបរិមាណទំនិញចរាចរណ៍ឆ្លងកាត់ **កសស** វិញ ឆ្នាំ២០១៧នេះ មានកំណើន ៨,០៣% ស្មើនឹង ៣២៤.៤៨៤តោន បើធៀបឆ្នាំ២០១៦ និងកើនឡើង ១២០.៦៣៩តោន ស្មើនឹង ២,៨៤% បើធៀបនឹងផែនការឆ្នាំ ២០១៧ វិញ ។




ជាក់ស្តែង ពិនិត្យទៅលើប្រភេទទំនិញនាំចេញដែលមានបរិមាណសរុប ១.១៧៧.៧៤៦តោន សម្រាប់ឆ្នាំ២០១៧ ក្នុងនោះទំនិញជាប្រភេទសំលៀកបំពាក់មាន ៣៤,៤១% អង្ករមាន ៣៤,០៥% រីឯទំនិញទូទៅដូចជាឈើកែច្នៃ ស្បែកជើង ស្រោមជើង សំពត់ខ្មែរ និងក្រណាត់ជាដើមមាន ៣០,៩០% និងដំឡូងមីមាន ០,៦៤% នៃបរិមាណទំនិញនាំចេញសរុបរបស់ **កសស**។




ចំណែកទំនិញនាំចូលដែលឆ្លងកាត់ **កសស** វិញមានបរិមាណ ៣.១៨៦.៨៩២តោន សម្រាប់ឆ្នាំ២០១៧ ក្នុងនោះប្រេងឥន្ធនៈមានបរិមាណច្រើនជាងគេប្រមាណ ៤០% នៃបរិមាណទំនិញនាំចូលសរុប ។ ចំពោះទំនិញជាប្រភេទក្រណាត់មានទំហំ ១៥,៧០% ចំណែកសំលៀកបំពាក់មាន ៤,៣២% គ្រឿងម៉ាស៊ីនមាន ៣,៨៩% ធ្យូងថ្មមានប្រមាណ ១,៥៦% រីឯលោហៈធាតុមាន ០,៥៥% និងទំនិញទូទៅមានប្រមាណ ៣៤,០១% នៃបរិមាណនាំចូលសរុប ។



## ៤- ស្ថានភាពប្រកួតប្រជែង

**កសស** នៅតែរក្សាបានឧត្តមភាពប្រកួតប្រជែងរបស់ខ្លួន ដោយសារកត្តាមួយចំនួនដូចខាងក្រោម៖

*លក្ខណៈអំណោយផលនៃទីតាំងភូមិសាស្ត្រ*

**កសស** ស្ថិតក្នុងឆកសមុទ្រខេត្តព្រះសីហនុដែលផ្តល់ភាពងាយស្រួលក្នុងការដឹកជញ្ជូនទៅកាន់ ទីផ្សារអន្តរជាតិសំខាន់ៗ ។ ការដឹកជញ្ជូនពី **កសស** ទៅកាន់កំពង់ផែក្នុងអាស៊ីប៉ាស៊ីហ្វិច ពុំចាំបាច់ ឆ្លងកាត់ចំណតផែមេក្នុងតំបន់ឡើយ ពោលគឺ ការដឹកជញ្ជូនអាចធ្វើឡើងដោយផ្ទាល់តែម្តង ។ ក្រៅពីនេះ ការដឹកជញ្ជូនក៏មានភាពងាយស្រួលផងដែរទៅកាន់កំពង់ផែហុងកុង ឬសិង្ហបុរី ដែលជាច្រកទ្វារទៅកាន់ទីផ្សារអឺរ៉ុប និងសហរដ្ឋអាមេរិក ។

មិនងាយរងគ្រោះដោយកត្តាធម្មជាតិ ដូចជា ព្យុះធំៗ រញ្ជួយដីជាដើម ដោយសារឆកសមុទ្រនេះមានអំណោយផលស្រាប់ពីធម្មជាតិ ។

ចំណតផ្ទេរមិនតម្រូវឱ្យមានការបូមស្តារខ្សាច់ ឬកករច្រើនឡើយ ដែលនេះអាចធ្វើឱ្យ **កសស** មិនចាំ បាច់ចំណាយច្រើនលើការបូមស្តារឃ្លង ឬផ្លូវនាវាឡើយ ។

*ហេដ្ឋារចនាសម្ព័ន្ធសម្បូរបែប និងទំនើប*

**កសស** មានបំពាក់នូវគ្រប់ហេដ្ឋារចនាសម្ព័ន្ធសម្រាប់បំរើឱ្យប្រតិបត្តិការអាជីវកម្មរបស់ខ្លួន ដូចជា ប្រព័ន្ធគ្រប់គ្រងចរាចរណ៍នាវា VTMS ជាដើម។ បច្ចុប្បន្នសមត្ថភាពលើកដាក់កុងតឺន័ររបស់ **កសស** បានកើនឡើងរហូតដល់ ៦៥០.០០០ TEUs ក្រោយពីបំពាក់រថស្ទូចចល័តលើគែមផែ (QC) ចំនួន ០២ គ្រឿង បន្ថែមទៀត។ កត្តានេះបានជំរុញផលិតភាពរបស់ **កសស** ឱ្យកើនជាងមុន និងកាត់បន្ថយពេលវេលាកកស្ទះទំនិញ។

*លើកកំពស់ប្រសិទ្ធភាពការងារ*

ប្រសិទ្ធការងារត្រូវបានលើកកម្ពស់ តាមរយៈការពង្រឹងការគ្រប់គ្រង ដោយអនុវត្តអភិបាលកិច្ចល្អ ក្រោយពេលចុះបញ្ជីលក់មូលបត្រ ។

ការប្រើប្រាស់បច្ចេកវិទ្យាទំនើបក្នុងការអនុវត្តការងារ ដោយមានការគាំទ្រពីបំពាក់បរិក្ខារផែ បន្ថែម ដូចជា រថចល័តលើទីលានផែ និងរថចល័តលើគែមផែជាដើម ។

ការបណ្តុះបណ្តាល និងការលើកទឹកចិត្តរបស់ថ្នាក់ដឹកនាំចំពោះបុគ្គលិក និយោជិក ពិសេសអនុវត្តការងារផ្ទាល់ដើម្បីពង្រឹងស្មារតី និងកំលាំងចិត្តក្នុងកិច្ចខិតខំប្រឹងប្រែងបំពេញសេវាកម្មជូនអតិថិជន។

*តម្លៃសេវាកម្មមានលក្ខណៈប្រកួតប្រជែង*

**កសស** នៅរក្សាតម្លៃសេវាកម្មរបស់ខ្លួនឱ្យមានលក្ខណៈប្រកួតប្រជែង ជាការទាក់ទាញអតិថិជនគួបផ្សំនឹងការពង្រឹងគុណភាពសេវាកម្មរបស់ខ្លួន ។

*រក្សាទំនាក់ទំនងល្អជាមួយភាគីពាក់ព័ន្ធ*

**កសស** បានរក្សាទំនាក់ទំនងល្អជាមួយអតិថិជនរបស់ខ្លួន ដោយព្យាយាមបំពេញតាមតម្រូវការរបស់អតិថិជន ទទួលយកយោបល់និងការរិះគន់ក្នុងន័យស្ថាបនា ដើម្បីស្វែងយល់ពីចំនុចខ្វះខាតរបស់ខ្លួនក្នុងទិសដៅកែលម្អបន្ថែមទៀត ។

**កសស** ក៏រក្សាកិច្ចសហប្រតិបត្តិការជាមួយកំពង់ផែក្នុងតំបន់ ក្នុងការចែកចាយព័ត៌មាន និងបទពិសោធន៍គ្នាទៅវិញទៅមក ដើម្បីលើកស្ទួយសេវាកម្មរបស់ខ្លួន ។

## ៥- ផែនការអនាគត

### *ផែនការអភិវឌ្ឍន៍រយៈពេលខ្លី-មធ្យម-វែង របស់ កសស រួមមាន៖*

#### គម្រោងអភិវឌ្ឍន៍ចំណតផែពហុបំណងកំពង់ផែក្រុងព្រះសីហនុ (ប្រាក់កម្ចីលេខ: CP-P10):

ចាប់ពីឆ្នាំ២០១៥ ដល់ ឆ្នាំ២០១៨ គឺ គម្រោងអភិវឌ្ឍន៍ចំណតផែពហុបំណងកំពង់ផែក្រុងព្រះសីហនុ ។ ចំណតផែពហុបំណងបានចាប់ផ្តើមសាងសង់ក្នុងឆ្នាំ២០១៥ ហើយគ្រោងបញ្ចប់ក្នុងឆ្នាំ២០១៨ ។ ចំណតផែនេះមានប្រវែង បណ្តោយ ៣៣០ម៉ែត្រ និងជម្រៅទឹក ១៣,៥ម៉ែត្រ សម្រាប់ប្រតិបត្តិការលើកដាក់ទំនិញរាយ និងទំនិញទូទៅ ដើម្បីជម្រុញលើកទឹកចិត្តដល់ការនាំចេញផលិតផលកសិកម្មកម្ពុជា ចំណាំងឈើ ចំណិតជំឡូងមីក្រៀម ជាពិសេស ដើម្បីឆ្លើយតបនឹងការពង្រីកយុទ្ធសាស្ត្រនាំអង្ករចេញរបស់រាជរដ្ឋាភិបាលកម្ពុជា និងការសាងសង់មូលដ្ឋានភស្តុភារកម្ម ការផ្គត់ផ្គង់ប្រេងបម្រើឱ្យសេវារុករករ៉ែប្រេងក្នុងដែនសមុទ្រកម្ពុជា ក៏ដូចជាជួយជម្រុញដល់កំណើនសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា ។

**គិតត្រឹមដំណាច់ឆ្នាំ២០១៧ នេះ ការសាងសង់ចំណតផែពហុបំណងបានសម្រេច ៩៤,០០% នៃផែនការគ្រោងទុក ហើយគ្រោងនឹងដាក់ឱ្យប្រតិបត្តិការនៅពាក់កណ្តាលឆ្នាំ២០១៨។**

| សេចក្តីសង្ខេបគម្រោង | |
|---|---|
| រយៈពេលសាងសង់ | ចាប់ពីខែមករា ឆ្នាំ២០១៥ ដល់ ខែកញ្ញា ឆ្នាំ២០១៨ (៤៤ខែ) |
| គោលបំណងនៃគម្រោង | ដើម្បីបង្កើនសមត្ថភាពកំពង់ផែក្រុងព្រះសីហនុ ដែលជាកំពង់ផែសមុទ្រទឹកជ្រៅតែមួយរបស់ប្រទេសកម្ពុជា ដោយការសាងសង់ចំណតផែពហុបំណង រួមមានចំណតផែទំនិញរាយ និងមូលដ្ឋានផ្គត់ផ្គង់ភស្តុភារ កម្មការរុករករ៉ែប្រេង ព្រមទាំងអភិវឌ្ឍន៍ឋបនីយកណ្តាលផ្សេងទៀត ចូលរួមចំណែកដល់ការអភិវឌ្ឍន៍ ឧស្សាហកម្ម និងកំណើនសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា ។ |
| លទ្ធផលរំពឹងទុក | សម្រាប់ប្រតិបត្តិការលើកដាក់ទំនិញរាយ និងទំនិញទូទៅ ដើម្បីជួយជម្រុញលើកទឹកចិត្តដល់ការនាំចេញផលិតផលកសិកម្មកម្ពុជា ចំណាំងឈើ ចំណិត ជំឡូងមីក្រៀម ជាពិសេសដើម្បីឆ្លើយតបនឹងការពង្រីកយុទ្ធសាស្ត្រនាំអង្ករ ចេញរបស់រាជរដ្ឋាភិបាលកម្ពុជា និងបម្រើសេវាភស្តុភារកម្មសម្រាប់ការរុករក ប្រេងក្នុងដែនសមុទ្រកម្ពុជា ក៏ដូចជាជួយជម្រុញដល់កំណើនសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា |
| ធាតុសំខាន់ៗនៃគម្រោង | សាងសង់ចំណតផែពហុបំណងប្រវែង ៣៣០ម៉ែត្រ និងជម្រៅទឹក ១៣,៥ម៉ែត្រ<br>សាងសង់ចំណតផែមូលដ្ឋានផ្គត់ផ្គង់ការរុករករ៉ែប្រេង និងផលិតកម្មប្រេង ប្រវែង ២០០ម៉ែត្រ និងជម្រៅ ៧,៥ម៉ែត្រ |

| | |
|---|---|
| | ស្តារឃ្លូងនាវាជម្រៅ ១២ម៉ែត្រ ប្រវែង ៣.៩០០ម៉ែត្រ ទទឹង ១៥០ ម៉ែត្រ និងបរិមាណសរុប ១.៨០០.០០០ម៉ែត្រ ត្រីគុណ<br>សាងសង់ទីលានស្តុកទំនិញរាយ ទំហំ ២៨.០០០ម៉ែត្រការេ<br>សាងសង់ទីលានស្តុកធ្យូងថ្មទំហំ ១៣.០០០ម៉ែត្រការ៉េ និងទីលាន ទំនិញទូទៅទំហំ ១៤.០០០ម៉ែត្រការ៉េ ព្រមទាំងបំពាក់បរិក្ខារដោះផ្ទុកសំខាន់ៗមួយចំនួន ។ |
| ទីតាំងគម្រោង | ស្ថិតនៅក្នុងបរិវេណកំពង់ផែស្វយ័តក្រុងព្រះសីហនុ ។ |
| ភ្នាក់ងារអនុវត្តគម្រោង | **កសស** ជាទីភ្នាក់ងារអនុវត្តគម្រោង ហើយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាម្ចាស់គម្រោង (Employer) |
| ប្រភពថវិកា និងចំនួនថវិកា | ប្រាក់កម្ចីពី JICA (លេខៈ CP-P10) តាមរយៈប្រាក់កម្ចីបន្តពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ |
| តម្លៃប៉ាន់ស្មានគម្រោង | JPY7,១៧៦.០០០.០០០ ប្រហាក់ប្រហែលនឹង USD ៧៤.២០០.០០០,០០ |
| ដំណាក់កាលនៃគម្រោង | **ដំណាក់កាលទី ១៖ ការរៀបចំហិរញ្ញវត្ថុ (ឆ្នាំ២០០៨ ដល់ ឆ្នាំ២០០៩)**<br>ដំណាក់កាលនេះ គឺជាដំណាក់កាលនៃការចុះសិក្សា និងវាយតម្លៃគម្រោង និងរកប្រភពថវិកាសម្រាប់ការអនុវត្តគម្រោង។ ការវាយតម្លៃបានចប់សព្វគ្រប់នៅឆ្នាំ២០០៩ ដោយ JICA ហើយ JICA ក៏សម្រេចផ្តល់ប្រាក់កម្ចីសម្រាប់ គម្រោងនេះឱ្យ **កសស** តាមរយៈក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅថ្ងៃទី២១ ខែសីហា ឆ្នាំ២០០៩ ។<br>**ដំណាក់កាលទី ២៖ ការងារជ្រើសរើសទីប្រឹក្សាគម្រោង (ឆ្នាំ២០១០ ដល់ ឆ្នាំ២០១១)**<br>ការងារជ្រើសរើសទីប្រឹក្សានេះ ត្រូវបានអនុវត្តតាមនីតិវិធីនៃការដេញថ្លៃមានលក្ខណៈប្រកួតប្រជែងជាសាធារណៈ (ICB) ។ ក្នុងដំណាក់កាលនីមួយៗត្រូវបានទទួលការឯកភាពជាគោលការណ៍ពីក្រសួងអាណាព្យាបាលទាំងពីរ (MEF & MPWT) និងទីភ្នាក់ងារ JICA ។<br>**ដំណាក់កាលទី ៣៖ ការរៀបចំគំនូសប្លង់វិស្វកម្មលំអិត និងការជ្រើសរើស ក្រុមហ៊ុនផ្គត់ផ្គង់នាវាសណ្តោង និងក្រុមហ៊ុនម៉ៅការសាងសង់ (ឆ្នាំ២០១២ ដល់ ឆ្នាំ២០១៤)**<br>១-ជំហ៊ានទី១ (ឆ្នាំ២០១២ ដល់ ឆ្នាំ២០១៣)៖ ការរៀបចំគំនូសប្លង់វិស្វកម្ម សម្រាប់ ①ការងារផ្គត់ផ្គង់នាវាសណ្តោង និង②ការងារសំណង់ស៊ីវិល ។<br>២-ជំហ៊ានទី២ (ឆ្នាំ២០១៣ ដល់ ឆ្នាំ២០១៤)៖ ការងារលទ្ធកម្មជ្រើសរើស ①ក្រុមហ៊ុនផ្គត់ផ្គង់នាវាសណ្តោង និង②ក្រុមហ៊ុនសាងសង់ ។<br>ក្នុងដំណាក់កាលនីមួយៗ ត្រូវមានការឯកភាពជាគោលការណ៍ពីក្រសួងអាណាព្យាបាលទាំងពីរ (MEF & MPWT) និងទីភ្នាក់ងារ JICA ។<br>**ដំណាក់កាលទី ៤៖ ការងារផ្គត់ផ្គង់នាវាសណ្តោង និងការងារសាងសង់ ចំណតផែ ៣ ហុបំណង (ពីឆ្នាំ២០១៤ ដល់ ឆ្នាំ២០១៨)** |

| | |
|---|---|
| | ១-ជំហ៊ានទី១ (ឆ្នាំ២០១៤ ដល់ ឆ្នាំ២០១៥)៖ ការងារផ្គត់ផ្គង់នាវា សណ្តោង ០១ គ្រឿង សមត្ថភាព ៣.២០0HP ត្រូវបានផ្តល់កិច្ចសន្យាជូន ក្រុមហ៊ុន Asian Marine Services Public Co. Ltd (ប្រទេសថៃ) ។ ការងារនេះ បានចាប់ផ្តើម នៅខែកុម្ភៈ ឆ្នាំ២០១៤ ហើយបញ្ចប់ការងារ (១៨ខែ) និងបានប្រគល់ទទួលនៅខែសីហា ឆ្នាំ២០១៥។<br>២-ជំហ៊ានទី២ (ឆ្នាំ២០១៥ ដល់ ឆ្នាំ២០១៨)៖ ការងារសាងសង់ចំណតផែ ពហុបំណងត្រូវបានផ្តល់កិច្ចសន្យាជូនក្រុមហ៊ុន Toyo-Maeda JV (ប្រទេសជប៉ុន) ។ ការងារនេះបានចាប់ផ្តើម នៅខែមករា ឆ្នាំ២០១៥ ហើយគ្រោងបញ្ចប់ការងារនៅខែកញ្ញា ឆ្នាំ២០១៨ ខាងមុខ (៤៤ខែ) ។ រហូតដល់ដំណាច់ឆ្នាំ២០១៧ នេះ វឌ្ឍនភាពនៃការងារសម្រេចបានលទ្ធផលប្រហែល ៩៤,00% នៃផែនការគ្រោងទុក។<br>**ដំណាក់កាលទី ៥៖ ការត្រួតពិនិត្យជួសជុលថែទាំ (LDP) (ឆ្នាំ២០១៨ ដល់ ឆ្នាំ២០១៩) មិនទាន់បានអនុវត្ត**<br>ដំណាក់កាលជួសជុលថែទាំគម្រោងមានរយៈពេល១ឆ្នាំ ដោយចាប់គិតពីថ្ងៃបញ្ចប់គម្រោង។ ក្នុងដំណាក់កាលនេះក្រុមហ៊ុនសាងសង់ជាអ្នកទទួលខុសត្រូវលើការងារជួសជុលចំពោះឋបនីយភណ្ឌគម្រោងដែលខូចខាត ហើយការចុះត្រួតពិនិត្យបញ្ចប់គម្រោងនឹងប្រព្រឹត្តទៅបន្ទាប់ពីគម្រប់ពេលមួយឆ្នាំគត់ ។ |
| | |

រូបភាពស្តីពីវឌ្ឍនភាពនៃការងារសាងសង់ចំណតផែពហុបំណងកំពង់ផែស្វយ័តក្រុងព្រះសីហនុ
គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧



❖ គម្រោងបំពាក់គ្រឿងចក្រលើកដាក់កុងតឺន័រធុនធ្ងន់:

ចាប់ពីឆ្នាំ២០១៧ ដល់ ឆ្នាំ២០១៩ **កសស** គ្រោងនឹងបំពាក់គ្រឿងចក្រលើកដាក់កុងតឺន័រធុនធ្ងន់ប្រភេទរថស្ទូចចល័តលើគែមផែ (QC) ចំនួន ០៣ គ្រឿង និងរថស្ទូចចល័តនៅទីលាន (RTG) ចំនួន ០៩ គ្រឿងបន្ថែម ។ រហូតដល់ដំណាច់ឆ្នាំ២០១៧ នេះ **កសស** បានបំពាក់គ្រឿងចក្រលើកដាក់កុងតឺន័រធុនធ្ងន់ប្រភេទ QC ចំនួន ០២គ្រឿង និង RTG ចំនួន ០៩គ្រឿង រួចហើយដែលធ្វើឱ្យសមត្ថភាពលើកដាក់កុងតឺន័ររបស់ **កសស** មានរហូតដល់ ៦៥០.០០០ TEUs ក្នុង១ឆ្នាំ ចាប់ពីឆ្នាំ២០១៧ នេះ ។

| **សេចក្តីសង្ខេបគម្រោង** | |
|---|---|
| រយៈពេលនៃគម្រោង | ឆ្នាំ២០១៧ ដល់ ឆ្នាំ២០១៩ |
| គោលបំណងនៃគម្រោង | បង្កើនសមត្ថភាពលើកដាក់កុងតឺន័ររបស់ទីលាន **កសស** |
| លទ្ធផលរំពឹងទុក | បង្កើនសមត្ថភាពលើកដាក់កុងតឺន័រ រហូតដល់ ៦៥០.០០០ TEUs ក្នុង ១ឆ្នាំ ចាប់ពីឆ្នាំ២០១៧ នេះ |
| ធាតុសំខាន់ៗ នៃគម្រោង | បំពាក់ QC ០២ គ្រឿង និង RTG ០៩ គ្រឿង នៅឆ្នាំ ២០១៧ ដើម្បី បង្កើនសមត្ថភាពលើកដាក់ឱ្យបានដល់ ៦៥០.០០០ TEUs ក្នុង ១ឆ្នាំ (បានអនុវត្តបញ្ចប់)<br>បំពាក់ QC ០១ គ្រឿង និងបបនីយភណ្ឌផែបន្ថែម នៅឆ្នាំ ២០១៩ ដើម្បីបង្កើនសមត្ថភាពឱ្យបានដល់ ៦៩០.០០០ TEUs ក្នុង ១ឆ្នាំ |
| ទីភ្នាក់ងារអនុវត្តគម្រោង | **កសស** ជាអ្នកអនុវត្ត |
| ប្រភពថវិកា | ថវិកា **កសស** ផ្ទាល់ និងថវិកាពីការបោះផ្សាយមូលបត្ររបស់ **កសស** |
| តម្លៃប៉ាន់ស្មានគម្រោង | USD ៣៣.៥០០.០០០,០០ |

❖ គម្រោងសាងសង់ចំណតផែកុងតឺន័រថ្មី (ជំហានទី ១) ប្រវែង ៣៥០ម៉ែត្រ ជម្រៅ ១៤,៥ម៉ែត្រ

ចាប់ពីឆ្នាំ២០១៧ ដល់ ឆ្នាំ២០២៣ គឺជាគម្រោងអភិវឌ្ឍន៍ផែកុងតឺន័រថ្មី (ជំហានទី១) ប្រវែង ៣៥០ ម៉ែត្រ និងមានជម្រៅទឹក ១៤,៥ម៉ែត្រ និងបំពាក់គ្រឿងចក្រលើកដាក់កុងតឺន័រធុនធ្ងន់មួយចំនួន។ គម្រោងនេះ ទទួលបានហិរញ្ញប្បទានសម្បទានពីទីភ្នាក់ងារ JICA ដែលគ្រោងនឹងចាប់ផ្តើមការងារសាងសង់នៅ ឆ្នាំ២០២០ ហើយបញ្ចប់ការងារសាងសង់នៅ ឆ្នាំ២០២៣ ។

| **សេចក្តីសង្ខេបគម្រោង** | |
|---|---|
| រយៈពេល នៃគម្រោង | ឆ្នាំ២០១៧ ដល់ ឆ្នាំ២០២៣ |
| គោលបំណងនៃគម្រោង | បង្កើនសមត្ថភាពលើកដាក់កុងតឺន័រនៅកំពង់ផែក្រុងព្រះសីហនុ ដែលជាកំពង់ផែសមុទ្រទឹកជ្រៅតែមួយរបស់ប្រទេសកម្ពុជា និងប្រសិទ្ធិភាពផ្នែកភស្តុភារកម្មប្រទេសកម្ពុជា ដោយការសាងសង់ចំណតផែកុងតឺន័រថ្មី ប្រវែង ៣៥០ម៉ែត្រ ជម្រៅទឹក ១៤,៥ម៉ែត្រ ព្រមទាំងអភិវឌ្ឍន៍បបនីយភណ្ឌផ្សេងទៀត ដើម្បីលុបបំបាត់ឧបសគ្គនៃការចូលចតរបស់នាវាកុងតឺន័រខ្នាតធំ និងចូលរួមចំណែកដល់ការជួយសម្រួលផ្នែកពាណិជ្ជកម្ម និងការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមកម្ពុជា ។ |

| | |
|---|---|
| លទ្ធផលរំពឹងទុក | សមត្ថភាពលើកដាក់កុងតឺន័រដល់ ១.២៩០.០០០ TEUs ក្នុង ១ឆ្នាំ នៅពេលដែលចំណតផែកុងតឺន័រនេះដាក់ឱ្យប្រតិបត្តិការនៅ ឆ្នាំ២០២៣ ខាងមុខ។ |
| ធាតុសំខាន់ៗនៃគម្រោង | សាងសង់ចំណតផែកុងតឺន័រថ្មី ប្រវែង ៣៥០ម៉ែត្រ ជម្រៅទឹក ១៤,៥ម៉ែត្រ ទីលានកុងតឺន័រ និងបរិក្ខារផែ ព្រមទាំងការងារបូមស្តារអាងនាវា និងឃ្លងនាវា ប្រវែង ៤គីឡូម៉ែត និង ជម្រៅ ១៤ ម៉ែត្រ ។ ល។<br>បំពាក់បរិក្ខារផែដែលមាន QC ០៣ គ្រឿង RTG ០៩ គ្រឿង រថលើក (Reach Stacker) ចំនួន ០២ គ្រឿង និងក្បាលសណ្តោងកុងតឺន័រចំនួន ១៦ គ្រឿង។ ល។ |
| ទីតាំងគម្រោង | ស្ថិតនៅភាគខាងកើតនៃចំណតផែកុងតឺន័រមានស្រាប់ ស្ថិតលើផ្ទៃទឹកសមុទ្រក្បែរទំនប់រលកចំងាយប្រមាណ ៣០០ម៉ែត្រ ពីច្រាំងសមុទ្រ និងមានស្ពានភ្ជាប់ពី ដីគោកទៅកាន់ទីលានផែកុងតឺន័រ ។ ផ្ទៃដីសរុប ទំហំ ១៧,៥ ហិកតា ។ |
| ទីភ្នាក់ងារអនុវត្តគម្រោង | **កសស** ជាទីភ្នាក់ងារអនុវត្តគម្រោង ហើយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជា ម្ចាស់គម្រោង (Employer) |
| ប្រភពថវិកា និងចំនួនថវិកា | ប្រាក់កម្ចីពី JICA (លេខ: CP-P21) តាមរយៈប្រាក់កម្ចីបន្តពី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ |
| តម្លៃប៉ាន់ស្មានគម្រោង | JPY ២៣.៥០២.០០០.០០០ ប្រហាក់ប្រហែលនឹង USD ២០៣.០០០.០០០,០០ |
| ដំណាក់កាល នៃការអនុវត្តន៍គម្រោង | **ដំណាក់កាលទី ១ ៖ ការសិក្សាបុរេសមិទ្ធិលទ្ធភាព និងការរៀបចំហិរញ្ញវត្ថុ (ឆ្នាំ២០១៦ ដល់ ឆ្នាំ២០១៧)**<br>-ជំហ៊ានទី១ (ឆ្នាំ២០១៦ ដល់ឆ្នាំ២០១៧)៖ ក្រុមសិក្សា JICA បានចុះមកសិក្សា និងរៀបចំរបាយការណ៍ស្តីពីការសិក្សាបុរេសមិទ្ធិលទ្ធភាព នៃគម្រោងអភិវឌ្ឍន៍ចំណតផែកុងតឺន័រថ្មីកំពង់ផែក្រុងព្រះសីហនុ ។<br>-ជំហ៊ានទី២ (ឆ្នាំ២០១៦ ដល់ឆ្នាំ២០១៧)៖ ទីភ្នាក់ងារ JICA បានចុះមកសិក្សា និងវាយតម្លៃផ្នែកហិរញ្ញវត្ថុ លើគម្រោងអភិវឌ្ឍន៍ចំណតផែកុងតឺន័រថ្មី កំពង់ផែស្វយ័តក្រុងព្រះសីហនុដោយសម្រេចចុះកិច្ចព្រមព្រៀងហិរញ្ញប្បទាន សម្បទានលេខ: CP-P21 នៅថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៧ ។<br>**ដំណាក់កាលទី ២៖ ការងារជ្រើសរើសទីប្រឹក្សាគម្រោង (ឆ្នាំ២០១៧ ដល់ ឆ្នាំ២០១៨) កំពុងដំណើរការ**<br>ការងារជ្រើសរើសទីប្រឹក្សានេះ ត្រូវបានអនុវត្តតាមនីតិវិធី នៃការដេញថ្លៃមាន លក្ខណៈប្រកួតប្រជែងជាសាធារណៈ (ICB)។ ក្នុងដំណាក់កាលនីមួយៗត្រូវមានការឯកភាពជាគោលការណ៍ពីក្រសួងអាណាព្យាបាលទាំងពីរ (MEF & MPWT) និងទីភ្នាក់ងារ JICA ។ សេវាទីប្រឹក្សានេះរួមមាន ការងារសិក្សាគំនូសផ្នែកវិស្វកម្មសំណង់ស៊ីវិល និងការងារផ្គត់ផ្គង់គ្រឿងចក្រលើកដាក់កុងតឺន័រធុនធ្ងន់ព្រមទាំងការងារត្រួតពិនិត្យក្នុងអំឡុងពេលសាងសង់ជាដើម ។ |

| | |
|---|---|
| | **ដំណាក់កាលទី ៣៖ ការរៀបចំគំនូសប្លង់វិស្វកម្ម និងជំនួយការផ្នែកដេញថ្លៃ ជ្រើសរើសក្រុមហ៊ុនម៉ៅការសាងសង់ និងក្រុមហ៊ុនផ្គត់ផ្គង់គ្រឿងចក្រលើកដាក់ កុងតឺន័រធុនធ្ងន់ (ឆ្នាំ២០១៨ ដល់ ឆ្នាំ២០២១)**<br>-ដំហ៊ានទី១ (ឆ្នាំ២០១៨ ដល់ឆ្នាំ២០១៩)៖ ការរៀបចំគំនូសប្លង់វិស្វកម្មសម្រាប់ ①ការងារសំណង់ស៊ីវិល (Packag-1) និង②ការងារផ្គត់ផ្គង់គ្រឿងចក្រលើកដាក់កុងតឺន័រធុនធ្ងន់ (Packag-2) ។<br>-ដំហ៊ានទី២ (ឆ្នាំ២០១៩ ដល់ ឆ្នាំ២០២១)៖ ①ការជ្រើសរើសក្រុមហ៊ុនសាងសង់ចំណតផែកុងតឺន័រថ្មី (Packag-1) (ឆ្នាំ២០១៩ ដល់ ឆ្នាំ២០២០) និង②ការជ្រើសរើសក្រុមហ៊ុនផ្គត់ផ្គង់គ្រឿងចក្រលើកដាក់កុងតឺន័រធុនធ្ងន់ (Packag-2) (ឆ្នាំ ២០២០ ដល់ ឆ្នាំ២០២១) ។ ចំពោះនីតិវិធីជ្រើសរើសក្រុមហ៊ុនសាងសង់ និងក្រុមហ៊ុនផ្គត់ផ្គង់ ត្រូវអនុវត្តតាមនីតិវិធីនៃការដេញថ្លៃមានលក្ខណៈប្រកួតប្រជែងជាសាធារណៈ (ICB) ហើយត្រូវមានការឯកភាពជាគោលការណ៍ពី ក្រសួងអាណាព្យាបាលទាំងពីរ (MEF & MPWT) និងទីភ្នាក់ងារ JICA ។<br>**ដំណាក់កាលទី ៤៖ ដំណាក់កាលសាងសង់ចំណតផែកុងតឺន័រថ្មី និងផ្គត់ផ្គង់ គ្រឿងចក្រលើកដាក់កុងតឺន័រធុនធ្ងន់ (ឆ្នាំ២០២១ ដល់ ឆ្នាំ២០២៣)**<br>-ដំហ៊ានទី១ (ឆ្នាំ២០២០ ដល់ ឆ្នាំ២០២៣)៖ ការងារសាងសង់ចំណតផែកុងតឺន័រថ្មីគ្រោងនឹងចាប់ផ្តើមនៅ ឆ្នាំ២០២០ ហើយគ្រោងបញ្ចប់ការងារនៅ ឆ្នាំ២០២៣ (៣៦ខែ) ។<br>-ដំហ៊ានទី២ (ឆ្នាំ២០២១ ដល់ឆ្នាំ២០២៣)៖ ការងារផ្គត់ផ្គង់គ្រឿងចក្រលើកដាក់កុងតឺន័រធុនធ្ងន់គ្រោងនឹងចាប់ផ្តើមនៅ ឆ្នាំ២០២១ ហើយគ្រោងបញ្ចប់ការងារនៅ ឆ្នាំ២០១៣ (២៨ខែ) ។<br>**ដំណាក់កាលទី ៥៖ រយៈពេលធានាជួសជុលថែទាំ (LDP) (ឆ្នាំ២០២៣ ដល់ ឆ្នាំ ២០២៤)**<br>រយៈពេលធានាជួសជុលថែទាំគម្រោង មានរយៈពេល១ឆ្នាំ ដូចខាងក្រោមៈ<br>-ការងារសាងសង់ចំណតផែកុងតឺន័រថ្មី (ឆ្នាំ២០២៣ ដល់ ឆ្នាំ២០២៤)<br>-ការងារផ្គត់ផ្គង់គ្រឿងចក្រលើកដាក់កុងតឺន័រធុនធ្ងន់ (ឆ្នាំ២០២៣ ដល់ឆ្នាំ២០២៤។ |
| វឌ្ឍនភាពគម្រោង | កិច្ចព្រមព្រៀងប្រាក់កម្ចី បានចុះហត្ថលេខានៅថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៧។ |

## គំនូសប្លង់ទូរទៅគម្រោងអភិវឌ្ឍន៍ចំណតផែកុងតឺន័រថ្មីកំពង់ផែក្រុងព្រះសីហនុ




❖ គម្រោងសាងសង់ចំណតផែកុងតឺន័រថ្មី (ជំហានទី ២) ប្រវែង ៣០០ម៉ែត្រ ជម្រៅទឹក ១៤,៥ម៉ែត្រ

ចាប់ពីឆ្នាំ២០២៤ ដល់ ឆ្នាំ២០៣០ **កសស** មានផែនការសាងសង់ចំណតផែកុងតឺន័រថ្មី (ជំហានទី២) ប្រវែង ៣០០ម៉ែត្រ និងមានជម្រៅទឹក ១៤,៥ម៉ែត្រ និងបំពាក់គ្រឿងចក្រលើកដាក់កុងតឺន័រធុនធ្ងន់បន្ថែមទៀត ។

| សេចក្តីសង្ខេបគម្រោង | |
|---|---|
| រយៈពេលនៃគម្រោង | ឆ្នាំ២០២៤ ដល់ ឆ្នាំ២០៣០ |
| គោលបំណងនៃគម្រោង | បង្កើនសមត្ថភាពលើកដាក់កុងតឺន័រនៅកំពង់ផែក្រុងព្រះសីហនុ ដែលជាកំពង់ផែសមុទ្រទឹកជ្រៅតែមួយគត់របស់ប្រទេសកម្ពុជា និងប្រសិទ្ធិភាពផ្នែកភស្តុភារកម្មប្រទេសកម្ពុជា ដោយការសាងសង់ចំណតផែកុងតឺន័រថ្មី ប្រវែង ៣០០ម៉ែត្រ ជម្រៅទឹក ១៤,៥ម៉ែត្រ ព្រមទាំងអភិវឌ្ឍន៍ឋបនីយកណ្ឌផ្សេងទៀតដើម្បីចូលរួមចំណែកដល់ការជួយសម្រួលផ្នែកពាណិជ្ជកម្ម និងការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមកម្ពុជា។ |
| លទ្ធផលរំពឹងទុក | សមត្ថភាពលើកដាក់កុងតឺន័រដល់ ២.០០០.០០០ TEUs ក្នុង ១ឆ្នាំ នៅពេលដែលចំណតផែកុងតឺន័រនេះដាក់ឱ្យប្រតិបត្តិការនៅ ឆ្នាំ២០៣០ ខាងមុខ។ |
| ធាតុសំខាន់ៗនៃគម្រោង | សាងសង់ចំណតផែកុងតឺន័រថ្មី ប្រវែង ៣០០ម៉ែត្រ ជម្រៅទឹក ១៤,៥ម៉ែត្រ ទីលានកុងតឺន័រ និងឋបនីយភ័ណ្ឌផែមួយចំនួន ។ |

| | |
|---|---|
| | បំពាក់បបនីយភណ្ឌដែលមាន QC ០៣ គ្រឿង RTG ០៩ គ្រឿង រថលើក (Reach Stacker) ចំនួន ០២គ្រឿង និងក្បាលសណ្តោងកុងតឺន័រចំនួន ១៦ គ្រឿងបន្ថែម ។ល។ |
| ទីតាំងគម្រោង | បន្តពីចំណតផែកុងតឺន័រប្រវែង ៣៥០ម៉ែត ស្ថិតលើផ្ទៃទឹកសមុទ្រក្បែរទំនប់រលក ចំងាយប្រមាណ ៦៥០ ម៉ែត្រពីច្រាំងសមុទ្រ និងមានស្ពានភ្ជាប់ពីដីគោកទៅទីលានផែកុងតឺន័រ ។ ផ្ទៃដីសរុប ទំហំ ១៥ ហិកតា ។ |
| ភ្នាក់ងារអនុវត្តគម្រោង | **កសស** ជាទីភ្នាក់ងារអនុវត្តគម្រោង ហើយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាម្ចាស់គម្រោង (Employer) |
| ប្រភពថវិកា | ពីដៃគូរអភិវឌ្ឍន៍គម្រោង |
| តម្លៃប៉ាន់ស្មានគម្រោង | ប្រមាណ USD ១៥០.០០០.០០០,០០ |
| ដំណាក់កាលនៃគម្រោង | **ដំណាក់កាលទី ១៖ ការសិក្សាបុរេសមិទ្ធិលទ្ធភាព និងការរៀបចំហិរញ្ញវត្ថុ (ឆ្នាំ២០២៤ ដល់ ឆ្នាំ២០២៥)**<br>-ជំហ៊ានទី១ (ឆ្នាំ២០២៤ ដល់ ឆ្នាំ២០២៥)៖ ក្រុមសិក្សាដៃគូរអភិវឌ្ឍន៍នឹងចុះ សិក្សា និងរៀបចំរបាយការណ៍ស្តីពីការសិក្សាបុរេសមិទ្ធិលទ្ធភាពនៃគម្រោងអភិវឌ្ឍន៍ចំណតផែកុងតឺន័រថ្មីកំពង់ផែក្រុងព្រះសីហនុ (ជំហ៊ានទី២) ។<br>-ជំហ៊ានទី២ (ឆ្នាំ២០២៥ ដល់ ឆ្នាំ២០២៦)៖ ក្រុមសិក្សាដៃគូរអភិវឌ្ឍន៍នឹងចុះមកសិក្សា និងវាយតម្លៃផ្នែកហិរញ្ញវត្ថុលើគម្រោងអភិវឌ្ឍន៍ចំណតផែកុងតឺន័រថ្មីនេះ ដើម្បីផ្តល់ប្រាក់កម្ចី ។<br>**ដំណាក់កាលទី ២៖ ការងារជ្រើសរើសទីប្រឹក្សាគម្រោង (ឆ្នាំ២០២៦ ដល់ ឆ្នាំ២០២៧)**<br>ការងារជ្រើសរើសទីប្រឹក្សានេះ ត្រូវបានអនុវត្តតាមនីតិវិធី នៃការដេញថ្លៃមានលក្ខណៈប្រកួតប្រជែងជាសាធារណៈ (ICB) ។ សេវាទីប្រឹក្សានេះរួមមាន ការងារសិក្សាគំនូសផ្នែកវិស្វកម្មសំណង់ស៊ីវិល និងការងារផ្គត់ផ្គង់គ្រឿងចក្រលើកដាក់កុងតឺន័រធុនធ្ងន់ ព្រមទាំងការងារត្រួតពិនិត្យក្នុងអំឡុងពេលសាងសង់ជាដើម ។<br>**ដំណាក់កាលទី ៣៖ ការរៀបចំគំនូសប្លង់វិស្វកម្ម និងជំនួយការផ្នែកដេញថ្លៃជ្រើសរើសក្រុមហ៊ុនម៉ៅការសាងសង់ និងក្រុមហ៊ុនផ្គត់ផ្គង់គ្រឿងចក្រលើកដាក់កុងតឺន័រធុនធ្ងន់ (ឆ្នាំ២០២៧ ដល់ ឆ្នាំ២០២៨)**<br>-ជំហ៊ានទី១ (ឆ្នាំ២០២៧ ដល់ ឆ្នាំ២០២៩)៖ ការរៀបចំគំនូសប្លង់វិស្វកម្មសម្រាប់ ①ការងារសំណង់ស៊ីវិល (Packag-1) និង②ការងារផ្គត់ផ្គង់គ្រឿងចក្រលើកដាក់កុងតឺន័រធុនធ្ងន់ (Packag-2) ។<br>-ជំហ៊ានទី២ (ឆ្នាំ២០២៨ ដល់ឆ្នាំ២០២៩)៖ ①ការជ្រើសរើសក្រុមហ៊ុនសាងសង់ចំណតផែកុងតឺន័រថ្មី (Packag-1) និង②ការជ្រើសរើសក្រុមហ៊ុនផ្គត់ផ្គង់គ្រឿងចក្រលើកដាក់កុងតឺន័រធុនធ្ងន់ (Packag-2) ។ |

| | |
|---|---|
| | ចំពោះនីតិវិធីជ្រើសរើសក្រុមហ៊ុនសាងសង់ និងក្រុមហ៊ុនផ្គត់ផ្គង់ត្រូវអនុវត្តតាមនីតិវិធីនៃការដេញថ្លៃមានលក្ខណៈប្រកួតប្រជែងជាសាធារណៈ (ICB) ។<br>**ដំណាក់កាលទី ៤៖ ដំណាក់កាលសាងសង់ចំណតផែកុងតឺន័រថ្មី-ជំហ៊ានទី២ និងផ្គត់ផ្គង់គ្រឿងចក្រលើកដាក់កុងតឺន័រធុនធ្ងន់ (ឆ្នាំ២០២៩ ដល់ ឆ្នាំ២០៣១)**<br>-ជំហ៊ានទី១ (ឆ្នាំ២០២៩ ដល់ ឆ្នាំ២០៣១) (៣៦ខែ)៖ ការងារសាងសង់ចំណតផែកុងតឺន័រថ្មីប្រវែង ៣០០ម៉ែត្រ គ្រោងនឹងចាប់ផ្តើមនៅឆ្នាំ២០២៩ ហើយគ្រោង បញ្ចប់ការងារនៅ ឆ្នាំ២០៣១ ។<br>-ជំហ៊ានទី២ (ឆ្នាំ២០២៩ ដល់ ឆ្នាំ២០៣១)៖ ការងារផ្គត់ផ្គង់គ្រឿងចក្រលើកដាក់កុងតឺន័រធុនធ្ងន់គ្រោងនឹងចាប់ផ្តើមនៅ ឆ្នាំ២០២៩ ហើយគ្រោងបញ្ចប់ការងារនៅ ឆ្នាំ២០៣១ (២៨ខែ) ។<br>**ដំណាក់កាលទី ៥៖ រយៈពេលធានាជួសជុលថែទាំ (LDP) (ឆ្នាំ២០៣១ ដល់ ឆ្នាំ២០៣២)**<br>រយៈពេលធានាជួសជុលថែទាំគម្រោង មានរយៈពេល១ឆ្នាំ ។ |
| វឌ្ឍនភាពគម្រោង | ដំណាក់កាលរៀបចំផែនការរយៈពេលវែង ។ |

គំនូសប្លង់: គម្រោងអភិវឌ្ឍន៍ចំណតផែកុងតឺន័រថ្មី-ជំហ៊ានទី២ (២០២៤-២០៣០)



# ផ្នែកទី ២

## ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច

## ១- លទ្ធផលប្រតិបត្តិការធុរកិច្ច ដោយរួមបញ្ចូលព័ត៌មានធុរកិច្ចតាមផ្នែក

| បរិយាយ | ឯកត្តា | ផែនការ ២០១៧ | ឆ្នាំ២០១៧ | ឆ្នាំ២០១៦ | ប្រៀបធៀប | |
|---|---|---|---|---|---|---|
| | | ១ | ២ | ៣ | ២/១. | ២/៣. |
| **បរិមាណទំនិញឆ្លងកាត់** | តោន | ៤.២៤៤.០០០ | ៤.៣៦៤.៦៣៩ | ៤.០៤០.១៥៥ | ២,៨៤% | ៨,០៣% |
| ជាកុងតឺន័រ | _ | | ២.៨៨២.៣១៦ | ២.៥០២.០៨៦ | | ១៥,២០% |
| ទំនិញរាយ | _ | | ២០៨.៦៧៥ | ៣៧៩.២៩២ | | -៤៤,៩៨% |
| ជាប្រេង | _ | | ១.២៧៣.៦៤៨ | ១.១៥៨.៧៧៧ | | ៩,៩១% |
| **បរិមាណទំនិញនាំចូល** | _ | ៣.១២៦.០០០ | ៣.១៨៦.៨៩២ | ២.៩៨១.៨៦០ | ១,៩៥% | ៦,៨៨% |
| ជាកុងតឺន័រ | _ | | ១.៧១២.៥៧៩ | ១.៤៧១.៩៥៩ | | ១៦,៣៥% |
| ទំនិញរាយ | _ | | ១.៤៧៤.៣១៣ | ១.៥០៩.៩០១ | | -២,៣៦% |
| **បរិមាណទំនិញនាំចេញ** | _ | ១.១១៨.០០០ | ១.១៧៧.៧៤៧ | ១.០៥៨.២៩៥ | ៥,៣៤% | ១១,២៩% |
| ជាកុងតឺន័រ | _ | | ១.១៦៩.៧៣៧ | ១.០៣០.១២៧ | | ១៣,៥៥% |
| ទំនិញរាយ | _ | | ៨.០១០ | ២៨.១៦៨ | | -៧១,៥៧% |
| **បរិមាណទំនិញលើករៀប** | _ | ៥.៦៨៤.០០០ | ៥.៩៩២.៣៤៥ | ៥.៤១៥.២៨៣ | ៥,៤២% | ១០,៦៦% |
| ប្រគល់ផ្ទាល់ | _ | ៣៤១.០០០ | ១៩៧.១១៥ | ៣៤៧.៤៧៤ | -៤២,២០% | -៤៣,២៧% |
| ឆ្លងកាត់ឃ្លាំងនិងទីលាន | _ | ៥.៣៤៣.០០០ | ៥.៧៩៥.២៣០ | ៥.០៦៧.៨០៩ | ៨,៤៦% | ១៤,៣៥% |
| **បរិមាណកុងតឺន័រឆ្លងកាត់** | TEUs | ៤២១.០០០ | ៤៥៩.៨៣៩ | ៤០០.១៨៧ | ៩,២៣% | ១៤,៩១% |
| **នាំចូល** | _ | ២០៩.០០០ | ២៣៣.៦២៣ | ១៩៨.៥០៩ | ១១,៧៨% | ១៧,៦៩% |
| មានទំនិញ | _ | | ២០៦.៧៣៤ | ១៧៤.៦៣៧ | | ១៨,៣៨% |
| គ្មានទំនិញ | _ | | ២៦.៨៨៩ | ២៣.៨៧២ | | ១២,៦៤% |
| **នាំចេញ** | _ | ២១២.០០០ | ២២៦.២១៦ | ២០១.៦៧៨ | ៦,៧១% | ១២,១៧% |

| | | | | | | |
|---|---|---|---|---|---|---|
| មានទំនិញ | _ | | ១៤៨.០៩៦ | ១២៩.៨២០ | | ១៤,០៨% |
| គ្មានទំនិញ | _ | | ៧៨.១២០ | ៧១.៨៥៨ | | ៨,៧១% |
| **ចំនួននាវាចូលចត** | **គ្រឿង** | **១.៣៦៩** | **១.៣០៥** | **១.៣២២** | **-៤,៦៧%** | **-១,២៩%** |
| **ចំណុះផ្ទុកនាវា** | **តោន** | **១៧.៥៣១.០០០** | **១៣.៥៩០.២៨២** | **១៤.៨៥៣.៥៥៦** | **-២២,៤៨%** | **-៨,៥០%** |
| នាវាដឹកកុងតឺន័រ | គ្រឿង | | ៥៣១ | ៦៦៧ | | -២០,៣៩% |
| ចំណុះនាវាដឹកកុងតឺន័រ | តោន | | ៧.៧៨១.៣៧៤ | ៩.០៨៧.១២០ | | -១៤,៣៧% |
| នាវាដឹកប្រេង | គ្រឿង | | ៤៦១ | ៣៣៧ | | ៣៦,៨០% |
| ចំណុះនាវាដឹកប្រេង | តោន | | ១.៦៧០.២៧៥ | ១.៤៣១.៧២៩ | | ១៦,៦៦% |
| នាវាដឹកទំនិញទូទៅ | គ្រឿង | | ២៨៣ | ២៨៣ | | ០,០០% |
| ចំណុះនាវាដឹកទំនិញទូទៅ | តោន | | ២.២៩២.៥១២ | ២.០៥២.៦១០ | | ១១,៦៩% |
| នាវាទេសចរណ៍ | គ្រឿង | | ៣០ | ៣៥ | | -១៤,២៩% |
| នាវាទេសចរណ៍ | តោន | | ១.៨៤៦.១២១ | ២.២៨២.០៩៧ | | -១៩,១០% |
| ចំនួនទេសចរ | នាក់ | | ២៥.៥៣៨ | ៥០.៣១៤ | | -៤៩,២៤% |

## ចំណុះផ្ទុកនាវាឆ្លងកាត់ (តោន)




## បរិមាណកុងតឺន័រឆ្លងកាត់ (TEUs)



## ២- ការប្រែប្រួលសំខាន់ៗពាក់ព័ន្ធនឹងប្រតិបត្តិការធុរកិច្ច

នៅក្នុងឆ្នាំ២០១៧ នេះពុំមានបំរែបំរួលសំខាន់ៗពាក់ព័ន្ធនឹងប្រតិបត្តិការធុរកិច្ចនោះទេ ។

## ៣- រចនាសម្ព័ន្ធចំណូល

| បរិយាយ | សម្រាប់ការិយបរិច្ឆេទឆ្នាំ ២០១៧ | | សម្រាប់ការិយបរិច្ឆេទឆ្នាំ ២០១៦ | |
|---|---|---|---|---|
| | ពាន់រៀល | ភាគរយធៀបនឹងចំណូលសរុប | ពាន់រៀល | ភាគរយធៀបនឹងចំណូលសរុប |
| ចំណូលលើកដាក់ (Stevedoring and LOLO) | ១៦៨.៥០៤.៩៤១ | ៧៤,១០% | ១៤៨.៦៧៥.៩២៤ | ៧១,១៤% |
| ចំណូលពីសេវាកម្មផែ | ៤៩.៦៤៤.០៤៩ | ២១,៨៣% | ៥៤.៤១១.៧៥៥ | ២៦,០៤% |
| ចំណូលស្តុក ឃ្លាំង និងទីលាន | ៤.៤០៦.៦១៥ | ១,៩៤% | ១.៩៥៨.៦៩០ | ០,៩៤% |
| ចំណូលដឹកជញ្ជូន | ៧៥៤.២៥៤ | ០,៣៣% | ១៥៤.៧៣៥ | ០,០៧% |
| ចំណូលនាវាទេសចរណ៍ | ៣៨១.៥០១ | ០,១៧% | ៥៦០.៩១០ | ០,២៧% |
| ចំណូលពីតំបន់ សេដ្ឋកិច្ចពិសេស | ២.៨៤៨.១៨០ | ១,២៥% | ២.៣០១.៥៥១ | ១,១០% |
| ចំណូលជួលទីតាំង | ៥៨៨.០៤២ | ០,២៦% | ៦៧០.៥៨៤ | ០,៣២% |
| ចំណូលផ្សេងៗទៀត | ២៧០.២៥២ | ០,១២% | ២៤៧.១០០ | ០,១២% |
| **ចំណូលសរុប** | **២២៧.៣៩៧.៨៣៥** | **១០០,០០%** | **២០៨.៩៨១.២៤៩** | **១០០,០០%** |

# ផ្នែកទី ៣

## អភិបាលកិច្ចសាជីវកម្ម

## ១- ភាគហ៊ុនិក

### ក-ការការពារសិទ្ធិភាគហ៊ុនិក

សិទ្ធិរបស់ភាគហ៊ុនិក ត្រូវបានធានាដោយមហាសន្និបាតភាគហ៊ុនិក ដោយក្រុមប្រឹក្សាភិបាល និងដោយអគ្គនាយក ដូចដែលមានចែងនៅក្នុងលក្ខន្តិកៈរបស់ **កសស**។

ភាគហ៊ុនិកប្រភេទ "ក"

**ក.សិទ្ធិបោះឆ្នោត៖** ភាគហ៊ុនិកប្រភេទ "ក" ជាទូទៅមិនមានសិទ្ធិបោះឆ្នោតឡើយ លើកលែងតែក្នុងករណីដែលមានកិច្ចប្រជុំសម្រេចលើបញ្ហាណាមួយដែលអាចកាត់បន្ថយ ឬរឹតត្បិតនូវសិទ្ធិ និងផលប្រយោជន៍នៃភាគហ៊ុនិកប្រភេទនេះ (ក្នុងករណីនេះភាគហ៊ុនិកប្រភេទ "ក" មានសិទ្ធិបោះឆ្នោត ១ ភាគហ៊ុនស្មើនឹង ១ សម្លេង) ដូចក្នុងករណីខាងក្រោម៖

- ការកាត់បន្ថយ ឬរឹតត្បិតចំនួន និងសិទ្ធិនៃភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនប្រភេទ "ក"
- ការស្នើរួមបញ្ចូល ឬបំបែក **កសស**
- ការសម្រេចឱ្យជម្រះបញ្ជី ឬរំលាយ **កសស**

**ខ.សិទ្ធិទទួលបានទ្រព្យដែលនៅសល់ពីការជម្រះបញ្ជី ឬការរំលាយ៖** ភាគហ៊ុនិកដែលកាន់កាប់ ភាគហ៊ុនប្រភេទ "ក" មានសិទ្ធិបុរិមាក្នុងការទទួលទ្រព្យសម្បត្តិរបស់ **កសស** ដែលនៅសល់បន្ទាប់ពីការជម្រះ បញ្ជី ឬរំលាយមុនភាគហ៊ុនិកប្រភេទ "ខ" និង "គ" ។

ភាគហ៊ុនិកប្រភេទ "ខ"

**ក.សិទ្ធិបោះឆ្នោត៖** ភាគហ៊ុនិកប្រភេទ "ខ" មានសិទ្ធិបោះឆ្នោតពេញលេញ ដោយមួយសម្លេង ស្មើនឹង ១ ភាគហ៊ុន។

**ខ.សិទ្ធិទទួលបានភាគលាភ៖** ភាគលាភរបស់ **កសស** ដែលត្រូវបានប្រកាសដោយក្រុមប្រឹក្សាភិបាល ក្នុងឆ្នាំសារពើពន្ធណាមួយ នឹងត្រូវបែងចែកក្នុងចំណោមភាគហ៊ុនិក ប្រភេទ "ខ" និង "គ" ។ ភាគហ៊ុនិកប្រភេទ "ខ" មិនមានសិទ្ធិទទួលបានភាគលាភអប្បបរមាដែលត្រូវបានធានាចំពោះភាគហ៊ុនិក ប្រភេទ "គ" ឡើយ ក្នុងកំឡុងពេលធានាភាគលាភអប្បបរមានេះ ប៉ុន្តែអាចទទួលបានភាគលាភដែលត្រូវបានចែងចែកឱ្យលើសពីចំនួនអប្បបរមានេះ ប្រសិនបើមានការបែងចែកភាគលាភឱ្យភាគហ៊ុនិកប្រភេទ "ខ" ។

**គ. សិទ្ធិទទួលបានទ្រព្យដែលនៅសល់ពីការជម្រះបញ្ជី ឬការរំលាយ៖** ភាគហ៊ុនិកប្រភេទ "ខ" មានសិទ្ធិទទួលបានទ្រព្យរបស់ **កសស** បន្ទាប់ពីការធ្វើការជម្រះបញ្ជី ឬរំលាយ ប៉ុន្តែត្រូវគោរពតាមសិទ្ធិបុរិមារបស់ភាគហ៊ុនិកប្រភេទ "ក" ជាមុនសិន ។

**ឃ. សិទ្ធិបរិវត្តន៍៖** ភាគហ៊ុនិកប្រភេទ "ខ" មានសិទ្ធិបរិវត្តន៍ក្នុងការបំលែងភាគហ៊ុនទាំងអស់របស់ខ្លួនទៅ ជាភាគហ៊ុនប្រភេទ "គ" តាមអនុបាត ១ ភាគហ៊ុន ប្រភេទ ខ ស្មើនឹង ១ ភាគហ៊ុនប្រភេទ "គ" ដោយមានលក្ខខណ្ឌដូចខាងក្រោម។

- បន្ទាប់ពីផុតរយៈពេល ៣ ឆ្នាំ នៃការប្រកាស និងបែងចែកភាគលាភដែលបានធានា ភាគលាភអប្បបរមា
- **កសស** មិនមានភាគលាភអប្បបរមាដែលមានការធានា មិនទាន់ត្រូវបានបែងចែករួចអស់

សិទ្ធិបរិវត្តន៍នឹងត្រូវអនុវត្តចំពោះភាគហ៊ុនិកប្រភេទ "ខ" ទាំងអស់

ការធ្វើបរិវត្តន៍នៃភាគហ៊ុនប្រភេទ "ខ" នឹងមានអានុភាពនៅពេលលក្ខន្តិកៈនេះត្រូវបានកែប្រែ និង ចុះបញ្ជីត្រឹមត្រូវនៅស្ថាប័នមានសមត្ថកិច្ច ។

### ភាគហ៊ុនិកប្រភេទ "គ"

**ក. សិទ្ធិបោះឆ្នោត** ភាគហ៊ុនិកប្រភេទ "គ" មានសិទ្ធិបោះឆ្នោតពេញលេញ ដោយមួយសម្លេងស្មើនឹងមួយភាគហ៊ុន។

**ខ.សិទ្ធិទទួលភាគលាភ** ភាគលាភដែលប្រកាសដោយក្រុមប្រឹក្សាភិបាលក្នុងឆ្នាំសារពើពន្ធនឹងត្រូវបែងចែករវាងភាគហ៊ុនិកប្រភេទ "ខ" និង "គ"។ ភាគហ៊ុនិកប្រភេទ "គ" ទទួលបានការធានាទិន្នផល ភាគលាភអប្បបរមា ៥% ក្នុងមួយឆ្នាំ សម្រាប់រយៈពេល ៣ ឆ្នាំ បន្ទាប់ពីការបោះផ្សាយលក់មូលបត្រ កម្មសិទ្ធិមានសិទ្ធិបោះឆ្នោតជាសាធារណៈនេះ។ ការបែងចែកភាគលាភនេះអាចធ្វើឡើងក្នុងទំរង់ជាភាគហ៊ុន ដោយផ្អែកលើថ្លៃបិទនៃថ្ងៃជួញដូរមុនថ្ងៃ អិចឌីវីឌិនដ៍ (Ex-Divident Day) ឬជាសាច់ប្រាក់តាមការកំណត់របស់ក្រុមប្រឹក្សាភិបាល ។ ក្នុងករណីភាគលាភអប្បបរមា ដែលបានធានាមិនត្រូវបានបែងចែកពេញលេញនៅក្នុងឆ្នាំសារពើពន្ធណាមួយនោះ ចំណែកភាគលាភ ដែលមិនត្រូវបែងចែកនឹងត្រូវបង្គរទុកទៅឆ្នាំបន្ទាប់រហូតដល់ការបែងចែកអាចធ្វើទៅបាន។

**គ.សិទ្ធិទទួលបានទ្រព្យដែលនៅសល់ពីការជម្រះបញ្ជី ឬការរំលាយ** ភាគហ៊ុនិកប្រភេទ "គ" មានសិទ្ធិ ទទួលបានទ្រព្យដែលនៅសល់បន្ទាប់ពីការជម្រះបញ្ជី និងការរំលាយ ប៉ុន្តែត្រូវគោរពសិទ្ធិបុរិមារបស់ភាគហ៊ុនិកប្រភេទ "ក" និង "ខ" ជាមុនសិន ។

ក្រៅពីសិទ្ធិទាំងអស់ខាងលើ ភាគហ៊ុនិកប្រភេទ "ក" "ខ" និង "គ" មានសិទ្ធិដូចៗគ្នា លើសិទ្ធិខាងក្រោម៖

**សិទ្ធិបុព្វក្រយ** (Pre-emptive Right)៖ ភាគហ៊ុនិកនីមួយៗ មានសិទ្ធិបុព្វក្រយក្នុងការជាវបានមុននូវភាគហ៊ុនថ្មី ដែលបោះចេញដោយ **កសស** ស្របទៅតាមអនុបាតនៃការកាន់កាប់ភាគហ៊ុនរបស់ខ្លួន ហើយដែលភាគហ៊ុនថ្មីទាំងនោះ ស្ថិតក្នុងប្រភេទតែមួយជាមួយនឹងមូលបត្រកម្មសិទ្ធិដែលខ្លួនកំពុងកាន់កាប់។

**ការផ្ទេរភាគហ៊ុន៖** ភាគហ៊ុនរបស់ **កសស** អាចធ្វើការផ្ទេរបានលើកលែងតែមានច្បាប់ និងលក្ខន្តិកៈចែងផ្សេងពីនេះ ។ ការផ្ទេរហ៊ុនអាចធ្វើឡើង តាមរយៈការប្រគល់វិញ្ញាបនបត្រភាគហ៊ុន ឬតាមទម្រង់លិខិតជូនដំណឹងផ្សេងទៀតដែលទទួលស្គាល់ដោយច្បាប់ ។ ក្នុងករណីដែលភាគហ៊ុនត្រូវបានតម្កល់ទុកនៅប្រតិបត្តិកររក្សាទុកមូលបត្រការផ្ទេរកម្មសិទ្ធិភាគហ៊ុន និងមានសុពលភាពនៅពេលដែលសៀវភៅចុះបញ្ជីការផ្ទេរហ៊ុន ត្រូវបានធ្វើឡើងក្នុងសៀវភៅគណនីមូលបត្ររបស់សមាជិក និងអ្នកចូលរួមដោយអនុលោមតាមប្រកាសលេខ ០០២/១១ គ.ម.ក/ប្រក ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១១ ។ ក្នុងករណីបុគ្គលដែលមានឈ្មោះក្នុងសៀវភៅគណនីមូលបត្រខាងលើ ជាក្រុមហ៊ុនមូលបត្រដូចមានកំណត់ក្នុងប្រកាសលេខ ០០២/១១ គ.ម.ក/ប្រក ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១១ ការផ្ទេរភាគហ៊ុននឹងមានសុពលភាពនៅពេលការផ្ទេរភាគហ៊ុន រឿងគណនីត្រូវបានកត់ត្រាទុកនៅក្នុងសៀវភៅបញ្ជីឈ្មោះភាគហ៊ុនិករបស់ **កសស** ។

## ខ-ការបែងចែកប្រភេទភាគហ៊ុនិក

(គិតត្រឹមថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៧)

| បរិយាយ | សញ្ជាតិ | ប្រភេទ ភាគហ៊ុនិក | ចំនួន ភាគហ៊ុនិក | ចំនួនមូលបត្រ | ភាគរយ |
|---|---|---|---|---|---|
| តិចជាង ០៥ % | សញ្ជាតិខ្មែរ | រូបវន្តបុគ្គល | ៣៦១ | ៤.២៥០.៧២៤ | ៤,៩៦% |
| | | នីតិបុគ្គល | ៦ | ៣.៣០១.៥៩២ | ៣,៨៥% |
| | មិនមាន សញ្ជាតិខ្មែរ | រូបវន្តបុគ្គល | ៥១ | ២៥០.០៧៨ | ០,២៩% |
| | | នីតិបុគ្គល | ៥ | ២.០៦១.៣៨២ | ២,៤០% |
| ចាប់ពី០៥%ដល់ តិចជាង ៣០% | សញ្ជាតិខ្មែរ | រូបវន្តបុគ្គល | គ្មាន | គ្មាន | គ្មាន |
| | | នីតិបុគ្គល | គ្មាន | គ្មាន | គ្មាន |
| | មិនមាន សញ្ជាតិខ្មែរ | រូបវន្តបុគ្គល | គ្មាន | គ្មាន | គ្មាន |
| | | នីតិបុគ្គល | ១ | ១១.៥៧៩.២១៦ | ១៣,៥០% |
| ចាប់ពី ៣០ % ឡើងទៅ | សញ្ជាតិខ្មែរ | រូបវន្តបុគ្គល | គ្មាន | គ្មាន | គ្មាន |
| | | នីតិបុគ្គល | ១ | ៦៤.៣២៨.៩៧៥ | ៧៥,០០% |
| | មិនមាន សញ្ជាតិខ្មែរ | រូបវន្តបុគ្គល | គ្មាន | គ្មាន | គ្មាន |
| | | នីតិបុគ្គល | គ្មាន | គ្មាន | គ្មាន |

## គ-អភិបាល បុគ្គលិកជាន់ខ្ពស់ និងនិយោជិតដែលកាន់កាប់មូលបត្រកម្មសិទ្ធិរបស់បុគ្គលបោះផ្សាយ

| ភាគហ៊ុនិក | ចំនួនភាគហ៊ុនិក | ចំនួនមូលបត្រ | ភាគរយ |
|---|---|---|---|
| អភិបាល | ៧ | ៤០៥.៩៩៩ | ១៨,៩៣% |
| បុគ្គលិកជាន់ខ្ពស់[១] | ១៥ | ៤០៩.០០០ | ១៩,០៧% |
| និយោជិត | ១៩៧ | ១.៣២៩.៣០០ | ៦១,៩៩% |
| សរុប | ២១៩ | ២.១៤៤.២៩៩ | ១០០% |

**(១) រួមបញ្ចូលទាំងមន្ត្រីត្រួតពិនិត្យរដ្ឋ**

## ឃ-ការផ្លាស់ប្តូរភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើន និងភាគហ៊ុនិកកាន់កាប់ភាគ ហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់ ដោយបញ្ជាក់អំពីអត្តសញ្ញាណ

សម្រាប់ឆ្នាំ២០១៧ ពុំមានការផ្លាស់ប្តូរភាគហ៊ុនិកកាន់កាប់មានសិទ្ធិបោះឆ្នោតចំនួនច្រើន និង ភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់ទេ ។

## ង-អត្តសញ្ញាណភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនចាប់ពី ០៥ (ប្រាំ) ភាគរយឡើងទៅ ស្ថិតក្នុងស្ថានភាពអសាធនភាព

សម្រាប់ឆ្នាំ២០១៧ ពុំមានភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនចាប់ពី ៥% ឡើងទៅ ស្ថិតក្នុង ស្ថានភាពអសាធភាពនោះទេ ។

## ច-កិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិក

សម្រាប់ឆ្នាំ២០១៧ **កសស** ពុំទាន់មានរៀបចំកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកនៅឡើយទេ។

## ឆ-គោលនយោបាយភាគលាភ

### ឆ-១-គោលនយោបាយភាគលាភរបស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ

នៅក្នុងការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិមានសិទ្ធិបោះឆ្នោតលើកដំបូងនេះ ក្រុមប្រឹក្សាភិបាលបានកំណត់គោលនយោបាយភាគលាភ ដោយមានការធានាទិន្នផលភាគលាភអប្បបរមាប្រចាំឆ្នាំចំនួន ៥% នៃទំហំវិនិយោគិនដោយគិតតាមថ្លៃបោះផ្សាយលក់មូលបត្រសម្រាប់រយៈពេល ៣ឆ្នាំ ដំបូងដើម្បីជាការលើកទឹកចិត្តដល់វិនិយោគិន ។ ការធានាទិន្នផលអប្បបរមានេះផ្តល់ជូនតែចំពោះមូលបត្រកម្មសិទ្ធិមានសិទ្ធិបោះឆ្នោតប្រភេទ "គ" តែប៉ុណ្ណោះ។ រាជរដ្ឋាភិបាលកម្ពុជា ដែលជាភាគហ៊ុនិកកាន់កាប់មូលបត្រកម្មសិទ្ធិមានសិទ្ធិបោះឆ្នោតប្រភេទ "ខ" និងមូលបត្រកម្មសិទ្ធិគ្មានសិទ្ធិបោះឆ្នោតប្រភេទ "ក" មិនទទួលបានការធានាភាគលាភនេះទេ ។

ក្នុងករណីភាគលាភជាសាច់ប្រាក់បានប្រកាស មានទំហំតិចជាងភាគលាភអប្បបរមាដែលបានធានា **កសស** អាចបែងចែកភាគលាភជាភាគហ៊ុនប្រភេទ "គ" ថ្មីជូនភាគហ៊ុនិកប្រភេទ "គ" ដោយគណនាចំនួនភាគហ៊ុនដែលត្រូវផ្តល់ ស្មើនឹងទំហំភាគលាភអប្បបរមាដែលនៅសល់ ចែកនឹងថ្លៃបិទផ្សារនៅថ្ងៃជួញដូរ ១ថ្ងៃមុនថ្ងៃ **អិចឌីវីឌិន** (Ex-Dividend Date)។ ប្រសិនបើភាគលាភអប្បបរមាដែលបានធានាចំពោះម្ចាស់ ភាគហ៊ុនិកប្រភេទ "គ" មិនត្រូវបានបង់ពេញនៅក្នុងឆ្នាំសារពើពន្ធមួយ ដោយសារតែទំហំភាគលាភសរុបប្រចាំ ឆ្នាំអាចធ្វើការបែងចែកត្រឹមតែស្មើនឹងទំហំប្រាក់ចំណេញដែលមានសម្រាប់ការបែងចែកភាគលាភ នោះភាគលាភ ដែលមិនបានបង់នឹងត្រូវបង្គរទៅឆ្នាំសារពើពន្ធបន្តបន្ទាប់ទៀត។ មានន័យថាភាគលាភអប្បបរមាដែលត្រូវបានធានាសម្រាប់ឆ្នាំបន្តបន្ទាប់នឹងត្រូវកើនឡើងដោយចំនួនភាគលាភមិនទាន់បានបង់នាឆ្នាំមុន។

ការបែងចែកភាគលាភសម្រាប់មូលបត្រកម្មសិទ្ធិមានសិទ្ធិបោះឆ្នោតប្រភេទ "គ" ត្រូវធ្វើឡើងដោយស្របតាម ប្រការទី ៣៥៖ ការបែងចែកប្រាក់ចំណេញ នៅក្នុងលក្ខន្តិកៈរបស់ **កសស**។

ប្រការ ៣៥៖ ការបែងចែកប្រាក់ចំណេញនៃលក្ខន្តិកៈរបស់ **កសស** ក្រោយពីបានអនុម័តលើគណនីប្រចាំឆ្នាំ បើពិនិត្យឃើញថាមានប្រាក់ចំណេញក្រុមប្រឹក្សាភិបាលរបស់ **កសស** អាចសម្រេចផ្ទេរប្រាក់ទាំងនោះដើម្បី៖

ការទូទាត់នូវការខាតបង់នៃការិយបរិច្ឆេទមុន

ក្រោយពីបានការទូទាត់ការខាតបង់នៃការិយបរិច្ឆេទមុនរួចហើយ ប្រសិនបើនៅមានប្រាក់ចំណេញនោះក្រុមប្រឹក្សាភិបាលអាចប្រើប្រាស់ប្រាក់ចំណេញនេះសម្រាប់៖

**ក.** ថ្លៃងសរសើរដល់ថ្នាក់ដឹកនាំ និងនិយោជិតតាមលក្ខខណ្ឌ៖

- ករណីប្រាក់ចំណេញនៅសល់ចន្លោះ ៥% ដល់ ១០% នៃចំណាយសហគ្រាសប្រចាំឆ្នាំ នោះប្រាក់ថ្លៃងសរសើររបស់ **កសស** ត្រូវស្មើនឹងប្រាក់បៀវត្សរ៍ មួយខែ

- ករណីប្រាក់ចំណេញនៅសល់ចន្លោះ ១០% ដល់ ២០% នៃចំណាយសហគ្រាស ប្រចាំឆ្នាំ នោះប្រាក់ថ្លៃងសរសើររបស់ **កសស** ត្រូវស្មើនឹងប្រាក់បៀវត្សរ៍ ពីរខែ
- ករណីប្រាក់ចំណេញលើសពី ២០% នៃចំណាយសហគ្រាសប្រចាំឆ្នាំ នោះប្រាក់ថ្លៃងសរសើររបស់ **កសស** ត្រូវស្មើនឹងប្រាក់បៀវត្សរ៍ បីខែ

**ខ.** បង្កើតមូលនិធិបម្រុងតាមច្បាប់ ៥%

**គ.** បង្កើតមូលនិធិបម្រុងសេរី ៥%

**ឃ.** បង្កើតមូលនិធិសង្គម ៧% ដែលនឹងត្រូវកត់ត្រាជាចំណាយប្រចាំឆ្នាំ

**ង.** បែងចែកភាគលាភតាមការសម្រេចរបស់ក្រុមប្រឹក្សាភិបាល ជូនភាគហ៊ុនិកប្រភេទ "ក" នឹង "ខ"

**ច.** ប្រាក់ដែលនៅសល់ត្រូវបង្កើតមូនិធិអភិវឌ្ឍសហគ្រាស

## ឆ-២- ព័ត៌មានប្រវត្តិសាស្ត្រអំពីការបែងចែកភាគលាភក្នុងរយៈពេល ០៣ (បី) ត្រីមាសចុងក្រោយ

សម្រាប់ឆ្នាំ២០១៧ នេះ **កសស** ពុំទាន់មានការបែងចែកភាគលាភជូនភាគហ៊ុនិករបស់ខ្លួននៅឡើយទេ។

## ២-អង្គការលេខ

## រចនាសម្ព័ន្ធរបស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ

## សម្រាប់ឆ្នាំ២០១៧



## ៣-ក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការនានា

### ក-សមាសភាពក្រុមប្រឹក្សាភិបាល

| ល.រ | ឈ្មោះអភិបាល | តំណែង | កាលបរិច្ឆេទក្លាយជាអភិបាល | កាលបរិច្ឆេទបញ្ចប់អាណត្តិបច្ចុប្បន្ន |
|---|---|---|---|---|
| ១ | ឯ.ឧ. លូ គឹមឈន់ | ប្រធាន | ១០ មិថុនា ២០១៦ | ០៩ មិថុនា ២០១៩ |
| ២ | ឯ.ឧ.តឹករ៉េតសម្រេច | សមាជិក | ១០ មិថុនា ២០១៦ | ០៩ មិថុនា ២០១៩ |
| ៣ | ឯ.ឧ. ផាន់ ផល្លា | សមាជិក | ១០ មិថុនា ២០១៦ | ០៩ មិថុនា ២០១៩ |
| ៤ | ឯ.ឧ. យន្ត មីន | សមាជិក | ១០ មិថុនា ២០១៦ | ០៩ មិថុនា ២០១៩ |
| ៥ | ឯ.ឧ. សុខ សុភ័ក្រ្ត | សមាជិក | ១០ មិថុនា ២០១៦ | ០៩ មិថុនា ២០១៩ |
| ៦ | ឯ.ឧ. ស៊ុយ សាន | សមាជិក | ១០ មិថុនា ២០១៦ | ០៩ មិថុនា ២០១៩ |
| ៧ | លោក លូ លីខេង | សមាជិក | ០៦ ធ្នូ ២០១៣ | ០៥ ធ្នូ ២០១៦ |

ឈ្មោះលេខាធិការរបស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ: **លោក ពិត ប្រាកដ**

### ខ-ប្រសិនបើអភិបាលណាម្នាក់ ជាអភិបាល ជាភាគហ៊ុនិក ជាកម្មសិទ្ធិករ ឬសហកម្មសិទ្ធិករ របស់ក្រុម ហ៊ុន ឬរបស់សហគ្រាសផ្សេងទៀតត្រូវបង្ហាញឈ្មោះក្រុមហ៊ុនពាក់ព័ន្ធទាំងនោះ ដូចមានក្នុង តារាងខាងក្រោម ៖

**កសស** ពុំមានអភិបាលណាម្នាក់ ជាភាគហ៊ុនិក ឬសហកម្មសិទ្ធរបស់ក្រុមហ៊ុនពាក់ព័ន្ធទេ

### គ-តួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាល

យោងតាមប្រការ ២២ នៃលក្ខន្តិកៈរបស់ **កសស** ចុះថ្ងៃទី ២៣ មករា ឆ្នាំ ២០១៧ ក្រុមប្រឹក្សាភិបាល មានបេសកកម្មដឹកនាំតម្រង់ទិស និងត្រួតពិនិត្យ **កសស** ។

ក្រុមប្រឹក្សាភិបាលមានសិទ្ធិពេញលេញដើម្បីសម្រេចក្នុងនាម **កសស** ក្នុងការរៀបចំលិខិតស្នាម និង រាល់ឯកសារផ្សេងៗដែលទាក់ទងនឹងកម្មវត្ថុរបស់សហគ្រាសស្របតាមច្បាប់ជាធរមាន ដោយពុំប៉ះពាល់ដល់ ការអនុវត្តបទប្បញ្ញត្តិស្តីពីអាណាព្យាបាលភាពរដ្ឋឡើយ ។

ក្នុងក្របខណ្ឌនៃបេសកកម្មនេះក្រុមប្រឹក្សាភិបាលត្រូវ ៖

- ពិនិត្យ និងអនុម័តផែនការអាជីវកម្ម ផែនការអភិវឌ្ឍន៍ និងវិនិយោគរបស់ **កសស**
- សម្រេចលើផែនការអភិវឌ្ឍន៍ក្នុងក្របខណ្ឌនៃការតម្រង់ទិសរបស់ **កសស**
- ពិនិត្យ និងអនុម័តគម្រោងថវិកាប្រចាំឆ្នាំ និងត្រួតពិនិត្យអនុម័តតុល្យការ
- កំណត់ការចាត់ចែង និងភារកិច្ចទូទៅរបស់ **កសស**
- ពិនិត្យ និងអនុម័តគម្រោងបែងចែកប្រាក់ចំណេញ ឬគម្រោងបំពេញឱនភាព **កសស**

- ពិនិត្យផែនការ និងលើកសំណូមពរក្នុងការបង្កើន ឬបន្ថយដើមទុនបញ្ញើរបស់ **កសស**
- របាយការណ៍ពីសកម្មភាពការងារ និងគណនីហិរញ្ញវត្ថុប្រចាំឆ្នាំ
- កំណត់ការងារចាត់ចែង និងភារកិច្ចទូទៅរបស់ **កសស**
- កំណត់របបផែនការជ្រើសរើសការតម្លើងឋានៈ និងការផ្តល់លាភការដល់និយោជិត
- សម្រេចចំនួនក្របខណ្ឌនិយោជិត ដែលអនុញ្ញាតសំរាប់ **កសស**
- ជ្រើសរើសកំណត់លាភការសម្រាប់ផ្តល់ឱ្យស្នងការគណនី
- ធ្វើសំណើកែសម្រួលលក្ខន្តិកៈ
- សម្រេចតាមសំណើរបស់អគ្គនាយកនូវរចនាសម្ព័ន្ធ និងបទបញ្ជាផ្ទៃក្នុងរបស់ **កសស** ព្រមទាំងលក្ខន្តិកៈ និងប្រាក់បៀវត្សរ៍ ប្រាក់រង្វាន់ ប្រាក់ឧបត្ថម្ភផ្សេងៗ និងលាភការសម្រាប់បុគ្គលិក ដោយអនុលោមតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តទាំងឡាយជាធរមាន
- ចាត់ចែងធ្វើឱ្យដំណើរការនូវគណៈកម្មាធិការ និងគណៈកម្មាការដែលបានកំណត់ដោយអនុក្រឹត្យស្តីពីការបង្កើត **កសស** ឬដោយលក្ខន្តិកៈរបស់ **កសស**
- អនុម័តលើរបាយការណ៍សកម្មភាពការងារ និងរបាយការណ៍គណនេយ្យហិរញ្ញវត្ថុប្រចាំឆ្នាំ
- វាយតម្លៃក្នុងចន្លោះពេលទៀងទាត់នូវកម្រិតនៃការធ្វើឱ្យសម្រេចគោលដៅ ដែលកំណត់ដោយ **កសស** ហើយនឹងដាក់ចេញនូវវិធានការសម្រាប់កែលម្អចាំបាច់
- កំណត់តម្លៃឈ្នួលពាក់ព័ន្ធនឹងការធ្វើអាជីវកម្ម និងសេវាកម្មរបស់កំពង់ផែ
- អនុម័តលើលទ្ធកម្មនានា យោងតាមច្បាប់ និងបទដ្ឋានគតិយុត្តជាធរមាន
- សម្រេចលើការបើក និងបិទគ្រប់ការិយាល័យ សេវាដ្ឋាន សាខា ទីភ្នាក់ងារ ឬតំណាងទាំងអស់ ដែលចាំបាច់សម្រាប់អនុវត្តឱ្យសម្រេចគោលដៅ និងភារកិច្ចរបស់ **កសស**
- អនុម័តរាល់កិច្ចសន្យាទាំងឡាយណាដែលមិនអាចអនុវត្តតាមតារាងថ្លៃឈ្នួល និងតាមនីតិវិធីលទ្ធកម្មសាធារណៈដែលត្រូវឆ្លងយោបល់របស់ក្រុមប្រឹក្សាភិបាល។

# ក្រុមប្រឹក្សាភិបាល




**ឯកឧត្តម លូ គីមឈន់**

ប្រធានក្រុមប្រឹក្សាភិបាល

ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាប្រធាន អគ្គនាយកកំពង់ផែស្វយ័តក្រុងព្រះសីហនុ

**ជនជាតិ** : ខ្មែរ

**សញ្ជាតិ** : ខ្មែរ

**ថ្ងៃខែឆ្នាំកំណើត** : ថ្ងៃទី ១១ ខែ មីនា ឆ្នាំ ១៩៥៦

**ប្រវត្តិនៃការសិក្សា**

១. ថ្នាក់បណ្ឌិត ឆ្នាំ២០០៦-ឆ្នាំ២០០៨

- មុខជំនាញ : វិទ្យាសាស្ត្រសេដ្ឋកិច្ច
- ឈ្មោះសាលារៀន : សាកលវិទ្យាល័យចំរើនពហុបច្ចេកវិទ្យា ប្រទេសកម្ពុជា

២. ថ្នាក់អនុបណ្ឌិត ឆ្នាំ២០០៤-ឆ្នាំ២០០៦

- មុខជំនាញ : ពាណិជ្ជសាស្ត្រ
- ឈ្មោះសាលារៀន : សាកលវិទ្យាល័យជាតិគ្រប់គ្រងប្រទេសកម្ពុជា

៣. ថ្នាក់អនុបណ្ឌិត ឆ្នាំ១៩៨១-ឆ្នាំ១៩៨៦

- មុខជំនាញ : សំណង់ក្នុងទឹក និងកំពង់ផែ
- សិក្សា : នៅប្រទេសរុស្សី

**បទពិសោធន៍ការងារ**

- ឆ្នាំ២០០៨ ដល់បច្ចុប្បន្ន : ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាប្រធានអគ្គនាយកកំពង់ផែស្វយ័តក្រុងព្រះសីហនុ
- ឆ្នាំ១៩៩៩ - ២០០៨ : ប្រធានអគ្គនាយកកំពង់ផែក្រុងព្រះសីហនុ
- ឆ្នាំ១៩៩២ - ១៩៩៩ : ប្រធានកំពង់ផែក្រុងព្រះសីហនុ
- ឆ្នាំ១៩៩០ - ១៩៩២ : អនុប្រធានកំពង់ផែក្រុងព្រះសីហនុ
- ឆ្នាំ១៩៨៦ - ឆ្នាំ១៩៩០ : វិស្វករសំណង់នៃនាយកដ្ឋានបច្ចេកទេសសំភារៈសំណង់




**ឯកឧត្តម តឹករ៉េត សំរេច**

សមាជិកក្រុមប្រឹក្សាភិបាល

តំណាងទីស្តីការគណៈរដ្ឋមន្ត្រី

**ជនជាតិ** : ខ្មែរ

**សញ្ជាតិ** : ខ្មែរ

**ថ្ងៃខែឆ្នាំកំណើត** : ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៦៨

**ប្រវត្តិនៃការសិក្សា**

១. ថ្នាក់បណ្ឌិត ឆ្នាំ២០០៣

- មុខជំនាញ : គ្រប់គ្រងយុទ្ធសាស្ត្រជំនួញ
- ឈ្មោះសាលារៀន : សាកលវិទ្យាល័យ Hitotsubashi ប្រទេសជប៉ុន

២. ថ្នាក់អនុបណ្ឌិត ឆ្នាំ១៩៩៦

- មុខជំនាញ : វិទ្យាសាស្ត្រនយោបាយ
- ឈ្មោះសាលារៀន : សាកលវិទ្យាល័យ Saitama ប្រទេសជប៉ុន

៣. ថ្នាក់បរិញ្ញាប័ត្រ ឆ្នាំ១៩៩២

- មុខជំនាញ : វិទ្យាសាស្ត្រសេដ្ឋកិច្ច
- ឈ្មោះសាលារៀន : វិទ្យាស្ថានសេដ្ឋកិច្ចភ្នំពេញ ប្រទេសកម្ពុជា

**បទពិសោធន៍ការងារ**

- ឆ្នាំ២០០៨ ដល់បច្ចុប្បន្ន : រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី
- ឆ្នាំ២០០៣ - ២០០៧ : ទីប្រឹក្សាឯកឧត្តមឧបនាយករដ្ឋមន្ត្រី សុខ អាន រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី
- ឆ្នាំ១៩៩៧ - ២០០៣ : អនុប្រធាននាយកដ្ឋានទទួលបន្ទុកផ្នែកគោលនយោបាយពាណិជ្ជកម្ម នាយកដ្ឋានពាណិជ្ជកម្មអន្តរជាតិ ក្រសួងពាណិជ្ជកម្ម
- ឆ្នាំ១៩៩២ - ១៩៩៧ : មន្ត្រីនាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេសនៃក្រសួងពាណិជ្ជកម្ម




**ឯកឧត្តម ផាន់ ផល្លា**

សមាជិកក្រុមប្រឹក្សាភិបាល

តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**ជនជាតិ** : ខ្មែរ

**សញ្ជាតិ** : ខ្មែរ

**ថ្ងៃខែឆ្នាំកំណើត** : ថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ១៩៧៣

**ប្រវត្តិនៃការសិក្សា**

១. ថ្នាក់បណ្ឌិត ឆ្នាំ២០០៣

- មុខជំនាញ : សេដ្ឋកិច្ច
- ឈ្មោះសាលារៀន : សាកលវិទ្យាល័យ Wollonggong ប្រទេសអូស្ត្រាលី

២. ថ្នាក់អនុបណ្ឌិត ឆ្នាំ ១៩៩៩

- មុខជំនាញ : ពាណិជ្ជកម្ម
- ឈ្មោះសាលារៀន : សាកលវិទ្យាល័យ New South Wales ប្រទេសអូស្ត្រាលី

៣. ថ្នាក់បរិញ្ញាប័ត្រ ឆ្នាំ១៩៩៤-ឆ្នាំ១៩៩៦

- មុខជំនាញ : រដ្ឋបាលពាណិជ្ជកម្ម
- ឈ្មោះសាលារៀន : សាកលវិទ្យាល័យ Hawaii Pacific សហរដ្ឋអាមេរិក

**បទពិសោធន៍ការងារ**

- ឆ្នាំ២០១៦ ដល់បច្ចុប្បន្ន : អនុរដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ឆ្នាំ២០១៣ - ២០១៦ : អគ្គនាយក នៃអគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>សាធារណៈ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ឆ្នាំ២០០៨ - ២០១៣ : ប្រធាននាយកដ្ឋានព័ត៌មានវិទ្យានៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ




**ឯកឧត្តម យន្ត មីន**

សមាជិកក្រុមប្រឹក្សាភិបាល

តំណាងអាជ្ញាធរខេត្តព្រះសីហនុ

**ជនជាតិ** : ខ្មែរ

**សញ្ជាតិ** : ខ្មែរ

**ថ្ងៃខែឆ្នាំកំណើត** : ថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ១៩៦២

**ប្រវត្តិនៃការសិក្សា**

១. ថ្នាក់អនុបណ្ឌិត ឆ្នាំ២០០៥ - ឆ្នាំ២០០៧

- ឈ្មោះសាលារៀន : សាកលវិទ្យាល័យចំរើនពហុបច្ចេកវិទ្យាប្រទេសកម្ពុជា

២. ថ្នាក់វិញ្ញាបនប័ត្រ ឆ្នាំ២០១៥ - ឆ្នាំ២០១៦

- មុខជំនាញ : វគ្គវិក្រឹត្យការជាន់ខ្ពស់

**បទពិសោធន៍ការងារ**

- ឆ្នាំ២០១៥ ដល់បច្ចុប្បន្ន : អភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុ
- ឆ្នាំ២០១៤ - ២០១៥ : ទីប្រឹក្សាក្រសួងមហាផ្ទៃ




## ឯកឧត្តម សុខ សុភ័ក្ត្រ

សមាជិកក្រុមប្រឹក្សាភិបាល
តំណាងក្រសួងពាណិជ្ជកម្ម

**ជនជាតិ** : ខ្មែរ

**សញ្ជាតិ** : ខ្មែរ

**ថ្ងៃខែឆ្នាំកំណើត** : ថ្ងៃទី ០៩ ខែ មករា ឆ្នាំ ១៩៥៨

**ប្រវត្តិនៃការសិក្សា**

១. ថ្នាក់អនុបណ្ឌិត ឆ្នាំ២០០០
- មុខជំនាញ : នយោបាយសេដ្ឋកិច្ច
- ឈ្មោះសាលារៀន : សាកលវិទ្យាល័យ Saitama ប្រទេសជប៉ុន

២. ថ្នាក់អនុបណ្ឌិត ឆ្នាំ១៩៩៧
- មុខជំនាញ : សេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ឈ្មោះសាលារៀន : សាកលវិទ្យាល័យ London ប្រទេសអង់គ្លេស

៣. ថ្នាក់បរិញ្ញាបត្រ ឆ្នាំ១៩៩២
- មុខជំនាញ : សេដ្ឋកិច្ច
- ឈ្មោះសាលារៀន : វិទ្យាស្ថានវិទ្យាសាស្ត្រសេដ្ឋកិច្ច ប្រទេសកម្ពុជា

៤. ថ្នាក់បរិញ្ញាបត្ររង ឆ្នាំ១៩៨៦
- មុខជំនាញ : បច្ចេកទេសអគ្គិសនី
- ឈ្មោះសាលារៀន : វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា ប្រទេសកម្ពុជា

**បទពិសោធន៍ការងារ**
- ឆ្នាំ២០១៦ ដល់បច្ចុប្បន្ន : អនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម
- ឆ្នាំ២០១៤ - ២០១៦ : អគ្គនាយក នៃអគ្គនាយកដ្ឋានសេវាពាណិជ្ជកម្ម ក្រសួងពាណិជ្ជកម្ម
- ឆ្នាំ២០០៧ - ២០១៣ : អគ្គនាយក នៃអគ្គនាយកដ្ឋានពាណិជ្ជកម្មអន្តរជាតិ ក្រសួងពាណិជកម្ម
- ឆ្នាំ២០០៤ - ២០០៧ : អគ្គនាយករងនៃអគ្គនាយកដ្ឋានបច្ចេកទេស ក្រសួងពាណិជកម្ម




**ឯកឧត្តម ស៊ុយ សាន**

សមាជិកក្រុមប្រឹក្សាភិបាល

តំណាងក្រសួងសាធារណការ និងដឹកជញ្ជូន

**ជនជាតិ** : ខ្មែរ

**សញ្ជាតិ** : ខ្មែរ

**ថ្ងៃខែឆ្នាំកំណើត** : ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ១៩៥៨

**ប្រវត្តិនៃការសិក្សា**

១. ថ្នាក់បណ្ឌិត ឆ្នាំ ១៩៩៤

- មុខជំនាញ : វិទ្យាសាស្ត្រសេដ្ឋកិច្ច

**បទពិសោធន៍ការងារ**

- ឆ្នាំ២០១៦ ដល់បច្ចុប្បន្ន : អនុរដ្ឋលេខាធិការនិងជានាយកខុទ្ទកាល័យក្រសួងសាធារណការ និងដឹកជញ្ជូន
- ឆ្នាំ២០១៣ - ២០១៦ : នាយកខុទ្ទកាល័យក្រសួងពាណិជ្ជកម្ម
- ឆ្នាំ២០០៨ - ២០១៣ : ជំនួយការទេសរដ្ឋមន្ត្រី
- ឆ្នាំ២០០៣ - ២០០៨ : នាយកខុទ្ទកាល័យក្រសួងពាណិជ្ជកម្ម




**លោក លូ លីខេង**

សមាជិកក្រុមប្រឹក្សាភិបាល

តំណាងនិយោជិត **កសស**

| | | |
|---|---|---|
| **ជនជាតិ** | : | ខ្មែរ |
| **សញ្ជាតិ** | : | ខ្មែរ |
| **ថ្ងៃខែឆ្នាំកំណើត** | : | ថ្ងៃទី ១១ ខែ មេសា ឆ្នាំ ១៩៧៤ |
| **ប្រវត្តិនៃការសិក្សា** | | |
| ១. ថ្នាក់អនុបណ្ឌិត ឆ្នាំ២០០៦ | | |
| - មុខជំនាញ | : | ពាណិជ្ជសាស្ត្រ |
| ២. ថ្នាក់បរិញ្ញាប័ត្រ ឆ្នាំ ១៩៩៦ | | |
| - មុខជំនាញ | : | គីមីចំណីអាហារ |
| **បទពិសោធន៍ការងារ** | | |
| - ឆ្នាំ២០១៥ ដល់បច្ចុប្បន្ន | : | នាយកទទួលបន្ទុកចាត់ចែងត្រួតពិនិត្យភារកិច្ចទូទៅនៃនាយកដ្ឋានប្រតិបត្តិការទំនិញទូទៅ |

## ឃ-សេចក្តីសម្រេច និងលទ្ធផលការងាររបស់ក្រុមប្រឹក្សាភិបាល

នៅក្នុងឆ្នាំ២០១៧ នេះ ក្រុមប្រឹក្សាភិបាលបានជួបប្រជុំចំនួន ០២ ដង និងបានសម្រេច របៀបវារៈដូចខាងក្រោម៖

*សម័យប្រជុំក្រុមប្រឹក្សាភិបាល អាណត្តិទី ៦ លើក ទី ៤ នា ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០១៧*

កិច្ចប្រជុំបានពិនិត្យនឹងសម្រេចលើចំនុចដូចខាងក្រោម៖

របាយការណ៍បូកសរុបលទ្ធផលការងារអាជីវកម្មរបស់ **កសស** សម្រាប់ឆមាសទី១ ឆ្នាំ២០១៧

របាយការណ៍ស្តីពីវឌ្ឍនភាព នៃការងារអនុវត្តគម្រោងអភិវឌ្ឍចំណតផែពហុបំណង ក្រោមឥណទានសម្បទានជប៉ុន JICA លេខ CP.P10

របាយការណ៍ស្តីពីវឌ្ឍនភាព ក្រោយពេលដែល **កសស** បានបោះផ្សាយលក់មូលបត្រជា សាធារណៈលើកដំបូងនៅផ្សារមូលបត្រកម្ពុជា និងសកម្មភាពការងារបន្ត។ អង្គប្រជុំក៏បានសម្រេចប្រគល់ភារកិច្ចជូន ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាប្រធានអគ្គនាយក អនុវត្តនូវសកម្មភាពការងារបន្ត ដើម្បីបំពេញបាននូវលក្ខខណ្ឌអភិបាលកិច្ចសាជីវកម្ម បន្ទាប់ពី **កសស** បានចុះបញ្ជីលក់មូលបត្រនៅផ្សារមូលបត្រកម្ពុជារួចមក។ អង្គប្រជុំក៏បានសម្រេចប្រគល់ជូន ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាប្រធានអគ្គនាយក ឱ្យធ្វើលិខិតស្នើសុំការសម្រេចពី ឯកឧត្តមបណ្ឌិតសភាចារ្យ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

របាយការណ៍ស្តីពីវឌ្ឍនភាពនៃការវិនិយោគនៅតំបន់សេដ្ឋកិច្ចពិសេសកំពង់ផែក្រុងព្រះសីហនុ

ពិនិត្យ និងអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុសម្រាប់ការិយបរិច្ឆេទឆ្នាំ ២០១៦ និងសំណូមពរបែងចែកប្រាក់ចំណេញ

ពិនិត្យ និងអនុម័តទិញដីសម្រាប់ធ្វើជា Inland Container Depot (ICD)

*សម័យប្រជុំក្រុមប្រឹក្សាភិបាល អាណត្តិទី ៦ លើក ទី ៥ នា ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៧*

កិច្ចប្រជុំបានពិនិត្យនឹងសម្រេចលើចំនុចដូចខាងក្រោម៖

របាយការណ៍បូកសរុបលទ្ធផលការងារអាជីវកម្មរបស់ **កសស** ១០ខែ ឆ្នាំ២០១៧

របាយការណ៍ស្តីពីវឌ្ឍនភាព នៃការងារអនុវត្តគម្រោងអភិវឌ្ឍចំណតផែពហុបំណង ក្រោមឥណទានសម្បទានជប៉ុន JICA លេខ CP.P10

របាយការណ៍ស្តីពីវឌ្ឍនភាព ក្រោយពេលដែល **កសស** បានបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូងនៅផ្សារមូលបត្រកម្ពុជា និងសកម្មភាពការងារបន្ត។ អង្គប្រជុំក៏បានសម្រេចប្រគល់ភារកិច្ចជូន ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាប្រធានអគ្គនាយក អនុវត្តនូវសកម្មភាពការងារបន្ត ដើម្បីបំពេញបាននូវលក្ខខណ្ឌអភិបាលកិច្ចសាជីវកម្ម បន្ទាប់ពី **កសស** បានចុះបញ្ជីលក់មូលបត្រនៅផ្សារមូលបត្រកម្ពុជារួចមក។ អង្គប្រជុំក៏បានសម្រេចប្រគល់ជូន ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាប្រធានអគ្គនាយក ឱ្យធ្វើ លិខិតស្នើសុំការសម្រេចពី ឯកឧត្តមបណ្ឌិតសភាចារ្យ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

របាយការណ៍ស្ដីពីវឌ្ឍនភាពនៃការវិនិយោគនៅតំបន់សេដ្ឋកិច្ចពិសេសកំពង់ផែក្រុងព្រះសីហនុ
ពិនិត្យ និងអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុសម្រាប់ការិយបរិច្ឆេទឆ្នាំ ២០១៦ និងសំណូមពរបែងចែកប្រាក់ចំណេញ
ពិនិត្យ និងអនុម័តទិញដីសម្រាប់ធ្វើជា Inland Container Depot (ICD)

ក្រុមប្រឹក្សាភិបាលក៏បានអបអរសាទរចំពោះ ឯកឧត្តម **ផាន់ ផល្លា** ដែលត្រូវបានតែងតាំងជា អណត្តិគាហកៈតំណាងភាគកម្មសាធារណៈនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុរបស់ **កសស**

## ង-ការបណ្ដុះបណ្ដាលអភិបាល

នៅក្នុងឆ្នាំ២០១៧ នេះ **កសស** ពុំមានការបណ្ដុះបណ្ដាលក្រុមប្រឹក្សាភិបាលទេ។

## ច-គណៈកម្មាធិការនានារបស់ក្រុមប្រឹក្សាភិបាល

### ច-១-គណៈកម្មាធិការសវនកម្ម

#### ច-១-១-សមាសភាព

នៅក្នុងឆ្នាំ២០១៧ នេះ **កសស** ពុំទាន់បានបង្កើតគណៈកម្មាធិការសវនកម្មទេ។

#### ច-១-២-សកម្មភាពការងារ

នៅក្នុងឆ្នាំ២០១៧ នេះ គណកម្មាធិការសវនកម្ម ពុំទាន់មានសកម្មភាពការងារនោះទេ។

#### ច-១-៣-បញ្ហាប្រឈម

នៅក្នុងឆ្នាំ២០១៧ នេះ គណកម្មាធិការសវនកម្ម ពុំមានបញ្ហាប្រឈមនោះទេ។

### ច-២-គណៈកម្មាធិការគ្រប់គ្រងហានិភ័យ

#### ច-២-១-សមាសភាព

នៅក្នុងឆ្នាំ២០១៧ នេះ **កសស** ពុំទាន់បានបង្កើតគណៈកម្មាធិការហានិភ័យទេ។

#### ច-២-២-សកម្មភាពការងារ

នៅក្នុងឆ្នាំ២០១៧ នេះ គណៈកម្មាធិការហានិភ័យ ពុំទាន់មានសកម្មភាពការងារនោះទេ។

#### ច-២-៣-បញ្ហាប្រឈម

នៅក្នុងឆ្នាំ២០១៧ នេះ គណៈកម្មាធិការហានិភ័យ ពុំមានបញ្ហាប្រឈមនោះទេ។

### ច-៣-គណៈកម្មាធិការតែងតាំង

#### ច-៣-១-សមាសភាព

នៅក្នុងឆ្នាំ២០១៧ នេះ **កសស** ពុំទាន់បានបង្កើតគណៈកម្មាធិការតែងតាំងទេ។

### ច-៣-២-សកម្មភាពការងារ

នៅក្នុងឆ្នាំ២០១៧ នេះ គណៈកម្មាធិការតែងតាំង ពុំមានសកម្មភាពការងារនោះទេ។

### ច-៣-៣-បញ្ហាប្រឈម

នៅក្នុងឆ្នាំ២០១៧ នេះ គណៈកម្មាធិការតែងតាំង ពុំមានបញ្ហាប្រឈមនោះទេ។

## ច-៤-គណៈកម្មាធិការផ្សេងទៀត

### ច-៤-១-សមាសភាព

នៅក្នុងឆ្នាំ២០១៧ នេះ **កសស** ពុំទាន់បានបង្កើតគណៈកម្មាធិការផ្សេងទៀតនៅឡើយទេ។

### ច-៤-២-សកម្មភាពការងារ

នៅក្នុងឆ្នាំ២០១៧ នេះ គណៈកម្មាធិការផ្សេងទៀត ពុំទាន់មានសកម្មភាពការងារនោះទេ។

### ច-៤-៣-បញ្ហាប្រឈម

នៅក្នុងឆ្នាំ២០១៧ នេះ គណៈកម្មាធិការផ្សេងទៀត ពុំមានបញ្ហាប្រឈមនោះទេ។

# ៤-បុគ្គលិកជាន់ខ្ពស់

## ក-សមាសភាពបុគ្គលិកជាន់ខ្ពស់



**ឯកឧត្តម លូ គឹមឈន់**

ប្រធានក្រុមប្រឹក្សាភិបាល

ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាប្រធាន អគ្គនាយកកំពង់ផែស្វយ័តក្រុងព្រះសីហនុ

**ជនជាតិ** : ខ្មែរ

**សញ្ជាតិ** : ខ្មែរ

**ថ្ងៃខែឆ្នាំកំណើត** : ថ្ងៃទី ១១ ខែ មីនា ឆ្នាំ ១៩៥៦

**ប្រវត្តិនៃការសិក្សា**

១. ថ្នាក់បណ្ឌិត ឆ្នាំ២០០៦-ឆ្នាំ២០០៨

- មុខជំនាញ : វិទ្យាសាស្ត្រសេដ្ឋកិច្ច
- ឈ្មោះសាលារៀន : សាកលវិទ្យាល័យចំរើនពហុបច្ចេកវិទ្យា ប្រទេសកម្ពុជា

២. ថ្នាក់អនុបណ្ឌិត ឆ្នាំ២០០៤-ឆ្នាំ២០០៦

- មុខជំនាញ : ពាណិជ្ជសាស្ត្រ
- ឈ្មោះសាលារៀន : សាកលវិទ្យាល័យជាតិគ្រប់គ្រង ប្រទេសកម្ពុជា

៣. ថ្នាក់អនុបណ្ឌិត ឆ្នាំ១៩៨១-ឆ្នាំ១៩៨៦

- មុខជំនាញ : សំណង់ក្នុងទឹក និងកំពង់ផែ
- សិក្សា : នៅប្រទេសរុស្ស៊ី

**បទពិសោធន៍ការងារ**

- ឆ្នាំ២០០៨ ដល់បច្ចុប្បន្ន : ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាប្រធានអគ្គនាយកកំពង់ផែស្វយ័តក្រុងព្រះសីហនុ
- ឆ្នាំ១៩៩៩ - ២០០៨ : ប្រធានអគ្គនាយកកំពង់ផែក្រុងព្រះសីហនុ
- ឆ្នាំ១៩៩២ - ១៩៩៩ : ប្រធានកំពង់ផែក្រុងព្រះសីហនុ
- ឆ្នាំ១៩៩០ - ១៩៩២ : អនុប្រធានកំពង់ផែក្រុងព្រះសីហនុ
- ឆ្នាំ១៩៨៦ - ឆ្នាំ១៩៩០ : វិស្វករសំណង់នៃនាយកដ្ឋានបច្ចេកទេសសំភារៈសំណង់



## លោក ព្រុំ សេខ

មន្ត្រីត្រួតពិនិត្យរដ្ឋអមកំពង់ផែស្វយ័តក្រុងព្រះសីហនុ

**ជនជាតិ** : ខ្មែរ

**សញ្ជាតិ** : ខ្មែរ

**ថ្ងៃខែឆ្នាំកំណើត** : ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ១៩៦០

### ប្រវត្តិនៃការសិក្សា

១. ថ្នាក់អនុបណ្ឌិត ឆ្នាំ ២០០២ - ២០០៤

- មុខជំនាញ : ហិរញ្ញវត្ថុ-ធនាគារ
- ឈ្មោះសាលារៀន : សាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា ប្រទេសកម្ពុជា

២. ថ្នាក់បរិញ្ញាប័ត្រ ឆ្នាំ១៩៨៥ - ១៩៨៩

- មុខជំនាញ : ហិរញ្ញវត្ថុ-ធនាគារ
- ឈ្មោះសាលារៀន : មហាវិទ្យាល័យហិរញ្ញវត្ថុ-គណនេយ្យទីក្រុងហូជីមិញ ប្រទេសវៀតណាម

៣. ថ្នាក់វិទ្យាល័យ ឆ្នាំ ១៩៨៣

- ឈ្មោះសាលារៀន : វិទ្យាល័យបឹងត្របែក

៤. ការសិក្សា និងសញ្ញាប័ត្រផ្សេងៗ

- ឆ្នាំ ២០០៩ : វគ្គបណ្តុះបណ្តាលស្តីពីពន្ធដារកម្ពុជា
- ឆ្នាំ ២០១០ : វគ្គបណ្តុះបណ្តាលស្តីពីស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ
- ឆ្នាំ ២០១៤ : វគ្គបណ្តុះបណ្តាលស្តីពីគណនេយ្យអន្តរជាតិវិស័យសាធារណៈ
- ឆ្នាំ ២០១៥ : វគ្គបំពាក់បំប៉នស្តីពីជំនាញលទ្ធកម្មសាធារណៈ

### បទពិសោធន៍ការងារ

- ឆ្នាំ១៩៩៩ ដល់បច្ចុប្បន្ន : សាស្ត្រាចារ្យផ្នែកគណនេយ្យ នៅសាកលវិទ្យាល័យ ន័រតុន / បៀលប្រាយ
- ឆ្នាំ២០០១ ដល់បច្ចុប្បន្ន : មន្ត្រីត្រួតពិនិត្យរដ្ឋអមកំពង់ផែស្វយ័តក្រុងព្រះសីហនុ
- ឆ្នាំ២០០៦ - ២០០៩ : សវនកម្មផ្ទៃក្នុង (អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា)



**លោក ថៃ ឫទ្ធី**

អគ្គនាយករងអាជីវកម្ម

**ជនជាតិ** : ខ្មែរ

**សញ្ជាតិ** : ខ្មែរ

**ថ្ងៃខែឆ្នាំកំណើត** : ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ១៩៧១

**ប្រវត្តិនៃការសិក្សា**

១. ថ្នាក់អនុបណ្ឌិត ឆ្នាំ២០០៥ - ២០០៧

- មុខជំនាញ : គ្រប់គ្រងធុរកិច្ច
- ឈ្មោះសាលារៀន : សាកលវិទ្យាល័យជាតិគ្រប់គ្រង ប្រទេសកម្ពុជា

២. ថ្នាក់បរិញ្ញាប័ត្រ ឆ្នាំ១៩៩០ - ១៩៩៥

- មុខជំនាញ : វិស្វករគីមីចំណីអាហារ
- ឈ្មោះសាលារៀន : វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា ប្រទេសកម្ពុជា

៣. ថ្នាក់វិទ្យាល័យ ឆ្នាំ១៩៨៦ - ១៩៨៩

- ឈ្មោះសាលារៀន : វិទ្យាល័យព្រះសីហនុ ខេត្តកំពង់ចាម ប្រទេសកម្ពុជា

៤. ការសិក្សា និងសញ្ញាប័ត្រផ្សេងៗ

- ឆ្នាំ ១៩៩៨ : វិញ្ញាបនប័ត្រ ការគ្រប់គ្រងស្ថានីយ៍កុងតឺន័រ ប្រទេសជប៉ុន
- ឆ្នាំ ២០០៤ : វិញ្ញាបនប័ត្រ Train for Trade and Development
- ឆ្នាំ ២០០៩ : វិញ្ញាបនប័ត្រ Port Management ប្រទេសសិង្ហបុរី

**បទពិសោធន៍ការងារ**

- ឆ្នាំ២០១៥ ដល់បច្ចុប្បន្ន : អគ្គនាយករង ទទួលបន្ទុកផ្នែកអាជីវកម្ម គ្រប់គ្រងអាជីវកម្ម និង ប្រតិបត្តិការ
- ឆ្នាំ២០០០ - ២០១៥ : នាយករងទទួលបន្ទុករួមនាយកដ្ឋានអាជីវកម្មគ្រប់គ្រងកិច្ចការ Billing
- ឆ្នាំ១៩៩៨ - ២០០០ : ប្រធានការិយាល័យគ្រប់គ្រងស្ថិតិ គ្រប់គ្រងស្ថិតិ សន្និធិឃ្លាំងទីលាន



**លោក ឈុន ហុង**

អគ្គនាយករងគ្រប់គ្រងរដ្ឋបាល

**ជនជាតិ** : ខ្មែរ

**សញ្ញាតិ** : ខ្មែរ

**ថ្ងៃខែឆ្នាំកំណើត** : ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ១៩៥៥

**ប្រវត្តិនៃការសិក្សា**

១. ថ្នាក់បណ្ឌិត ឆ្នាំ២០០៧ - ២០១០

- មុខជំនាញ : វិទ្យាសាស្ត្រសេដ្ឋកិច្ច
- ឈ្មោះសាលារៀន : សាកលវិទ្យាល័យចំរើនពហុបច្ចេកវិទ្យា ប្រទេសកម្ពុជា

២. ថ្នាក់អនុបណ្ឌិត ឆ្នាំ២០០៣-ឆ្នាំ២០០៥

- មុខជំនាញ : វិទ្យាសាស្ត្រនយោបាយ
- ឈ្មោះសាលារៀន : សាកលវិទ្យាល័យចំរើនពហុបច្ចេកវិទ្យា ប្រទេសកម្ពុជា

**បទពិសោធន៍ការងារ**

- ឆ្នាំ២០០៨ ដល់បច្ចុប្បន្ន : អគ្គនាយករងកំពង់ផែទទួលបន្ទុកគ្រប់គ្រងរដ្ឋបាល គ្រប់គ្រង និងត្រួត ពិនិត្យប្រតិបត្តិការរដ្ឋបាល
- មុនឆ្នាំ ២០០៨ : ប្រធាននាយកដ្ឋាន ប្រតិបត្តិការទំនិញទូទៅ គ្រប់គ្រងប្រតិបត្តិការលើក ដាក់ទំនិញ ដឹកជញ្ជូនទំនិញ ស្តុកទុក



## លោក ជា យុទ្ធឌីកា

អគ្គនាយករងបច្ចេកទេស

**ជនជាតិ** : ខ្មែរ

**សញ្ជាតិ** : ខ្មែរ

**ថ្ងៃខែឆ្នាំកំណើត** : ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ១៩៥៦

**ប្រវត្តិនៃការសិក្សា**

១. ថ្នាក់អនុបណ្ឌិត ឆ្នាំ២០០៧

- មុខជំនាញ : វិទ្យាសាស្ត្រនយោបាយ

២. ថ្នាក់បរិញ្ញាប័ត្រ ឆ្នាំ២០០៦

- មុខជំនាញ : គ្រប់គ្រងសេដ្ឋកិច្ច

**បទពិសោធន៍ការងារ**

- ឆ្នាំ២០១៥ ដល់បច្ចុប្បន្ន : អគ្គនាយករងបច្ចេកទេស ត្រួតពិនិត្យ និងគ្រប់គ្រងចាត់ចែងពីលក្ខណៈ បច្ចេកទេសគ្រឿងចក្រឧបករណ៍ ប្រើប្រាស់ បរិក្ខារ និងលក្ខណៈ បច្ចេកទេសសំណង់ ដែលចាំបាច់សម្រាប់ តម្រូវការរបស់កំពង់ផែ
- ឆ្នាំ២០០៣ - ២០១៥ : នាយកបច្ចេកទេសសំភារៈ និងសំណង់ គ្រប់គ្រងពីលក្ខណៈ បច្ចេកទេស គ្រឿងចក្រ ឧបករណ៍ប្រើប្រាស់ បរិក្ខារ និងលក្ខណៈ បច្ចេកទេសសំណង់ ដែលចាំបាច់សម្រាប់តម្រូវការរបស់កំពង់ផែ
- ឆ្នាំ១៩៩៥ - ២០០៣ : ប្រធានការិយាល័យបច្ចេកទេសសំភារៈ និងសំណង់ ទទួលខុសត្រូវក្នុង ការគ្រប់គ្រង ថែរក្សា និង ផ្គត់ផ្គង់សំភារៈបន្លាស់ និងបរិក្ខារផ្សេងៗ ទៅ តាមបទដ្ឋានបច្ចេកទេស



## លោក រ័ត្ន សិលា

ប្រធាននាយកដ្ឋាន រដ្ឋបាល-ធនធានមនុស្ស

**ជនជាតិ** : ខ្មែរ

**សញ្ជាតិ** : ខ្មែរ

**ថ្ងៃខែឆ្នាំកំណើត** : ថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៦៩

**ប្រវត្តិនៃការសិក្សា**

១. ថ្នាក់អនុបណ្ឌិត ឆ្នាំ២០០៤-ឆ្នាំ២០០៧

- មុខជំនាញ : នីតិសាស្ត្រ
- ឈ្មោះសាលារៀន : សាកលវិទ្យាល័យភូមិន្ទ នីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ប្រទេសកម្ពុជា

២. ថ្នាក់បរិញ្ញាប័ត្រ ឆ្នាំ២០០០-ឆ្នាំ២០០៤

- មុខជំនាញ : គ្រប់គ្រងពាណិជ្ជកម្ម
- ឈ្មោះសាលារៀន : សាកលវិទ្យាល័យបៀល-ប្រាយ ប្រទេសកម្ពុជា

៣. ថ្នាក់វិទ្យាល័យ បញ្ចប់ឆ្នាំ១៩៨៧

- ឈ្មោះសាលារៀន : វិទ្យាល័យកំពត ប្រទេសកម្ពុជា

៤. ការសិក្សា និងសញ្ញាប័ត្រផ្សេងៗ

- DBA Candidate, Western University

**បទពិសោធន៍ការងារ**

- ឆ្នាំ២០១៦ ដល់បច្ចុប្បន្ន : នាយករដ្ឋបាល ធនធានមនុស្សគ្រប់គ្រង ចាត់ចែង និងសម្រប សម្រួល សកម្មភាពរដ្ឋបាលគ្រប់ផ្នែក



**លោក ប៉ាត សិត**

ប្រធាននាយកដ្ឋាន គណនេយ្យហិរញ្ញវត្ថុ

**ជនជាតិ** : ខ្មែរ

**សញ្ជាតិ** : ខ្មែរ

**ថ្ងៃខែឆ្នាំកំណើត** : ថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ១៩៥៨

**ប្រវត្តិនៃការសិក្សា**

១. ថ្នាក់អនុបណ្ឌិត ឆ្នាំ២០០៥-ឆ្នាំ២០០៧

- មុខជំនាញ : រដ្ឋបាលសាធារណៈ
- ឈ្មោះសាលារៀន : សាកលវិទ្យាល័យចំរើនពហុបច្ចេកវិទ្យាប្រទេសកម្ពុជា

២. ថ្នាក់វិទ្យាល័យ ឆ្នាំ១៩៦៥-ឆ្នាំ១៩៧៥

- ឈ្មោះសាលារៀន : នៅស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល

**បទពិសោធន៍ការងារ**

- ឆ្នាំ២០១៦ ដល់បច្ចុប្បន្ន : នាយកគណនេយ្យ-ហិរញ្ញវត្ថុ រៀបចំ និងគ្រប់គ្រងអនុវត្តការងារគណនេយ្យ ហិរញ្ញវត្ថុឱ្យបានត្រឹមត្រូវសមស្របទៅតាម គោលការណ៍ ស្តង់ដារគណនេយ្យ



**លោក សូ សៀង**

ប្រធាននាយកដ្ឋាន ផែនការ លទ្ធកម្ម និងស្ថិតិ

| | | |
|---|---|---|
| **ជនជាតិ** | : | ខ្មែរ |
| **សញ្ជាតិ** | : | ខ្មែរ |
| **ថ្ងៃខែឆ្នាំកំណើត** | : | ថ្ងៃទី ១៥ ខែ មេសា ឆ្នាំ ១៩៧៥ |

**ប្រវត្តិនៃការសិក្សា**

១. ថ្នាក់អនុបណ្ឌិត ឆ្នាំ២០០៥-ឆ្នាំ២០០៨

- មុខជំនាញ : នីតិសាស្ត្រ និងវិទ្យាសាស្ត្រនយោបាយ
- ឈ្មោះសាលារៀន : សាកលវិទ្យាល័យបៀល-ប្រាយ ប្រទេសកម្ពុជា

២. ថ្នាក់បរិញ្ញាប័ត្រ ឆ្នាំ១៩៩៧ -ឆ្នាំ២០០១

- មុខជំនាញ : នីតិសាស្ត្រ/នីតិសាធារណៈ
- ឈ្មោះសាលារៀន : សាកលវិទ្យាល័យន័រតុន ប្រទេសកម្ពុជា
- មុខជំនាញ : សង្គមសាស្ត្រ និង មនុស្សសាស្ត្រ
- ឈ្មោះសាលារៀន : សាកលវិទ្យាល័យភូមិន្ទភ្នំពេញ ប្រទេសកម្ពុជា

៣. ថ្នាក់វិទ្យាល័យ ឆ្នាំ១៩៨០ -ឆ្នាំ១៩៩២

- ឈ្មោះសាលារៀន : វិទ្យាល័យស្រីសន្ធរ

**បទពិសោធន៍ការងារ**

- ឆ្នាំ២០១៦ ដល់បច្ចុប្បន្ន : នាយកផែនការ លទ្ធកម្ម និងស្ថិតិ ភារកិច្ចៈ កសាងផែនការអាជីវកម្ម (សេវាកម្ម) ហិរញ្ញវត្ថុប្រចាំឆ្នាំ និង រៀបចំរបាយការណ៍លទ្ធផល អាជីវកម្ម ប្រចាំខែ ត្រីមាស ឆមាស និង ឆ្នាំជូន **កសស** ។ កសាង ផែនការលទ្ធកម្មប្រចាំឆ្នាំ (ទំនិញ សំណង់ និងសេវាកម្ម) និងរៀបចំ របាយការណ៍អនុវត្តលទ្ធកម្ម ប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ ជូន **កសស** ។



**លោក ឌី សាត្ថុណា**

ប្រធាននាយកដ្ឋាន បច្ចេកទេសសំភារៈ-សំណង់

**ជនជាតិ** : ខ្មែរ

**សញ្ជាតិ** : ខ្មែរ

**ថ្ងៃខែឆ្នាំកំណើត** : ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ១៩៦០

**ប្រវត្តិនៃការសិក្សា**

១. ថ្នាក់អនុបណ្ឌិត ឆ្នាំ២០០៦

- មុខជំនាញ : ពាណិជ្ជសាស្ត្រ
- ឈ្មោះសាលារៀន : សាកលវិទ្យាល័យជាតិគ្រប់គ្រង ប្រទេសកម្ពុជា

២. ថ្នាក់បរិញ្ញាប័ត្រ ឆ្នាំ១៩៨២ -ឆ្នាំ១៩៨៨

- មុខជំនាញ : វិស្វករសំណង់ផ្លូវទឹក និងកំពង់ផែ
- ឈ្មោះសាលារៀន : សាកលវិទ្យាល័យ បច្ចេកទេស ទីក្រុង DRESDEN ប្រទេសអាល្លឺម៉ង់

៣. ថ្នាក់វិទ្យាល័យ ឆ្នាំ១៩៧២ -ឆ្នាំ១៩៨២

- ឈ្មោះសាលារៀន : នៅទីក្រុងភ្នំពេញប្រទេសកម្ពុជា

**បទពិសោធន៍ការងារ**

- ឆ្នាំ២០១៥ ដល់បច្ចុប្បន្ន : នាយក នាយកដ្ឋាន បច្ចេកទេស និងសំភារៈសំណង់
  ភារកិច្ចៈ គ្រប់គ្រង និងទទួលខុសត្រូវខាងផ្នែកលក្ខណៈ បច្ចេកទេសទូទៅ
- ឆ្នាំ២០១១ - ២០១៥ : នាយករង នាយកដ្ឋានបច្ចេកទេស សំភារៈសំណង់
  ភារកិច្ចៈ ទទួលខុសត្រូវ ខាងផ្នែកបច្ចេកទេសទូទៅ



**លោកស្រី ជ័យ សុគន្ធា**

ប្រធាននាយកដ្ឋាន ទីផ្សារ

| | | |
|---|---|---|
| **ជនជាតិ** | : | ខ្មែរ |
| **សញ្ជាតិ** | : | ខ្មែរ |
| **ថ្ងៃខែឆ្នាំកំណើត** | : | ថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ១៩៧៥ |

**ប្រវត្តិនៃការសិក្សា**

១. ថ្នាក់អនុបណ្ឌិត ឆ្នាំ២០០៥-ឆ្នាំ២០០៧

- មុខជំនាញ : គ្រប់គ្រងពាណិជ្ជកម្ម
- ឈ្មោះសាលារៀន : សាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ច ប្រទេសកម្ពុជា

២. ថ្នាក់បរិញ្ញាប័ត្រ ឆ្នាំ២០០១-ឆ្នាំ២០០៤

- មុខជំនាញ : គ្រប់គ្រងពាណិជ្ជកម្ម
- ឈ្មោះសាលារៀន : សាកលវិទ្យាល័យវេនលេន នៅខេត្តព្រះសីហនុ ប្រទេសកម្ពុជា

៣. ថ្នាក់វិទ្យាល័យ ឆ្នាំ១៩៨៦-ឆ្នាំ១៩៩១

- ឈ្មោះសាលារៀន : នៅខេត្តព្រះសីហនុ ប្រទេសកម្ពុជា

៤. ការសិក្សា និងសញ្ញាប័ត្រផ្សេងៗ

- Modern Port Management, UNCTAD, Ireland, 2016-2017
- Women in Port management, France, 2015

**បទពិសោធន៍ការងារ**

- ឆ្នាំ២០១៥ ដល់បច្ចុប្បន្ន : នាយិកានាយកដ្ឋានទីផ្សារ ភារកិច្ច ៖ ផ្សព្វផ្សាយ និងជម្រុញការលើក កម្ពស់គុណភាព សេវាកម្ម របស់ **កសស** ។ តាមដានព័ត៌មាន និងបម្រែបម្រួលនិន្នាការទីផ្សារ ដៃគូរប្រកួតប្រជែង។ ទទួលជួបពិភាក្សាជាមួយអតិថិជន ឬដៃគូវិនិយោគសក្តានុពលសិក្សា និងអភិវឌ្ឍគោលដៅយុទ្ធសាស្ត្រសម្រាប់សកម្មភាពទីផ្សារ។
- ឆ្នាំ២០១៤ - ២០១៥ នាយិការងនាយកដ្ឋានទីផ្សារ
  ភារកិច្ច៖ ផ្សព្វផ្សាយ និងជម្រុញការលើក កម្ពស់គុណភាព សេវាកម្ម របស់ **កសស** និងជួបប្រជុំសំខាន់ផ្សេងៗ ។



**លោក ជីវ ច័ន្ទសុផល**

ប្រធាននាយកដ្ឋាន តំបន់សេដ្ឋកិច្ចពិសេស

**ជនជាតិ** : ខ្មែរ

**សញ្ជាតិ** : ខ្មែរ

**ថ្ងៃខែឆ្នាំកំណើត** : ថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ១៩៧៦

**ប្រវត្តិនៃការសិក្សា**

១. ថ្នាក់បរិញ្ញាប័ត្រ ឆ្នាំ១៩៩៣-ឆ្នាំ២០០០

- មុខជំនាញ : ស្ថាបត្យកម្ម និង នគរូបនីយកម្ម
- ឈ្មោះសាលារៀន : នៅរាជធានីភ្នំពេញប្រទេសកម្ពុជាប្រទេសកម្ពុជា

២. ថ្នាក់វិទ្យាល័យ ឆ្នាំ១៩៨៩-ឆ្នាំ១៩៩២

- ឈ្មោះសាលារៀន : នៅខេត្តព្រះសីហនុប្រទេសកម្ពុជា

៣. សញ្ញាប័ត្រផ្សេងៗ

- ២០០៩ : Certificate on Sustainable Port Development and Planning, Yokohama ប្រទេសជប៉ុន
- ឆ្នាំ ២០១៣ : Certificate on Strategic Port Administration and Management, Yokohama ប្រទេសជប៉ុន
- ឆ្នាំ ២០១១ - ២០១៣ : មធ្យមសិក្សា ផ្នែកហិរញ្ញវត្ថុ និងវិនិយោគ នៅរាជធានីភ្នំពេញ ប្រទេសកម្ពុជា

**បទពិសោធន៍ការងារ**

- ឆ្នាំ២០១៦ ដល់បច្ចុប្បន្ន : នាយកតំបន់សេដ្ឋកិច្ចពិសេស កំពង់ផែស្វយ័តក្រុងព្រះសីហនុ ភារកិច្ច៖ ដោះស្រាយបញ្ហាក្នុងតំបន់ និងទំនាក់ទំនងវិនិយោគិនដើម្បីវិនិយោគក្នុងតំបន់សេដ្ឋកិច្ចពិសេសរបស់កំពង់ផែ
- ឆ្នាំ២០១៤ - ២០១៥ : នាយករងទទួលបន្ទុករួមនៃនាយកដ្ឋានតំបន់សេដ្ឋកិច្ចពិសេស ភារកិច្ច៖ សម្របសម្រួលការងារក្នុងតំបន់ និងពង្រីកសក្តានុពលវិនិយោគ
- ឆ្នាំ២០១០ - ឆ្នាំ២០១៤ : នាយករងសវនកម្មផ្ទៃក្នុង ភារកិច្ច៖ ត្រួតពិនិត្យលើប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុង និងលើប្រតិបត្តិការរបស់កំពង់ផែ



**លោក ពិត ច្រាកដ**

ប្រធាននាយកដ្ឋាន អាជីវកម្ម

**ជនជាតិ** : ខ្មែរ

**សញ្ជាតិ** : ខ្មែរ

**ថ្ងៃខែឆ្នាំកំណើត** : ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ១៩៧៤

**ប្រវត្តិនៃការសិក្សា**

១. ថ្នាក់អនុបណ្ឌិត ឆ្នាំ២០០៤-ឆ្នាំ២០០៧

- មុខជំនាញ : គ្រប់គ្រងពាណិជ្ជកម្ម
- ឈ្មោះសាលារៀន : សាកលវិទ្យាល័យ បៀល- ប្រាយ ប្រទេសកម្ពុជាប្រទេសកម្ពុជា

២. ថ្នាក់បរិញ្ញាប័ត្រ ឆ្នាំ១៩៩៩-ឆ្នាំ២០០៣

- មុខជំនាញ : វិទ្យាសាស្ត្រសេដ្ឋកិច្ច
- ឈ្មោះសាលារៀន : សាកលវិទ្យាល័យ ន័រតុនប្រទេសកម្ពុជា

៣. ថ្នាក់វិទ្យាល័យ ឆ្នាំ១៩៨៤-ឆ្នាំ១៩៩០

- ឈ្មោះសាលារៀន : សាលាមធ្យមសិក្សាទួលទំពូង ប្រទេសកម្ពុជា

៤. ការសិក្សា និងសញ្ញាប័ត្រផ្សេងៗ

- DBA Candidate, Western University

**បទពិសោធន៍ការងារ**

- ឆ្នាំ២០១៦ ដល់បច្ចុប្បន្ន : នាយកផ្នែកអាជីវកម្ម ភារកិច្ចៈ រៀបចំ និងគិតគូរលើតម្លៃឈ្នួលគ្រប់ប្រភេទនៃការងារ សេវាកម្ម អាជីវកម្ម ដោយអនុវត្តទៅតាមបទដ្ឋានសេចក្តីសម្រេច និងកំណត់របស់កំពង់ផែ ។



## លោក ស្រី ឈារិន្ទ

ប្រធាននាយកដ្ឋាន ប្រតិបត្តិការទីលានកុងតឺន័រ

**ជនជាតិ** : ខ្មែរ

**សញ្ជាតិ** : ខ្មែរ

**ថ្ងៃខែឆ្នាំកំណើត** : ថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ១៩៥៦

**ប្រវត្តិនៃការសិក្សា**

១. បរិញ្ញាប័ត្រ ឆ្នាំ២០០៣-ឆ្នាំ២០០៥

- មុខជំនាញ : នយោបាយសេដ្ឋកិច្ច ប្រទេសកម្ពុជា

២. ថ្នាក់វិទ្យាល័យ ឆ្នាំ១៩៧០-ឆ្នាំ១៩៧៥

- ឈ្មោះសាលារៀន : នៅខេត្តកំពង់ធំ ប្រទេសកម្ពុជា

៣. សញ្ញាប័ត្រផ្សេងៗ

- សញ្ញាប័ត្រគ្រប់គ្រងទីលានកុងតឺន័រ ប្រទេសសិង្ហបុរី

**បទពិសោធន៍ការងារ**

- ឆ្នាំ១៩៨៩ ដល់បច្ចុប្បន្ន : នាយក នាយកដ្ឋានប្រតិបត្តិ-ការទីលានកុងតឺន័រ ភារកិច្ចៈ គ្រប់គ្រង និងដឹកនាំការងារក្នុងនាយកដ្ឋានប្រតិបត្តិការ ទីលានកុងតឺន័រ និងធ្វើ អោយផលិតភាពមានការកើនឡើងជាបន្តបន្ទាប់
- ឆ្នាំ១៩៨៧ - ១៩៨៩ : ប្រធានការិយាល័យឃ្លាំងទំនិញកំពង់ផែ ភារកិច្ចៈ គ្រប់គ្រង និងអនុវត្ត អោយបានល្អ ក្នុងការថែរក្សាទំនិញក្នុងឃ្លាំង
- ឆ្នាំ១៩៨០ - ១៩៨៧ : បុគ្គលិកការិយាល័យគណនេយ្យកំពង់ផែភារកិច្ចៈ កាន់ស្តុកឃ្លាំង ទំនិញ



**លោក លូ លីខេង**

ប្រធាននាយកដ្ឋាន ប្រតិបត្តិការទំនិញទូទៅ

| | | |
|---|---|---|
| **ជនជាតិ** | : | ខ្មែរ |
| **សញ្ជាតិ** | : | ខ្មែរ |
| **ថ្ងៃខែឆ្នាំកំណើត** | : | ថ្ងៃទី ១១ ខែ មេសា ឆ្នាំ ១៩៧៤ |

**ប្រវត្តិនៃការសិក្សា**

១. ថ្នាក់អនុបណ្ឌិត ឆ្នាំ២០០៦

- មុខជំនាញ : ពាណិជ្ជសាស្ត្រ

២. ថ្នាក់បរិញ្ញាប័ត្រ ឆ្នាំ ១៩៩៦

- មុខជំនាញ : គីមីចំណីអាហារ

**បទពិសោធន៍ការងារ**

- ឆ្នាំ២០១៥ ដល់បច្ចុប្បន្ន : នាយកទទួលបន្ទុកចាត់ចែងត្រួតពិនិត្យភារកិច្ចទូទៅនៃនាយកដ្ឋានប្រតិបត្តិការទំនិញទូទៅ



**លោក ថោង ទីរ៉ូ**

ប្រធាននាយកដ្ឋាន នាវាចរ-កណ្ណធារ

**ជនជាតិ** : ខ្មែរ

**សញ្ជាតិ** : ខ្មែរ

**ថ្ងៃខែឆ្នាំកំណើត** : ថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ១៩៦៨

**ប្រវត្តិនៃការសិក្សា**

១. ថ្នាក់អនុបណ្ឌិត ឆ្នាំ២០០៤-ឆ្នាំ២០០៥

- ឈ្មោះសាលារៀន : នៅប្រទេសថៃ

២. ថ្នាក់បរិញ្ញាប័ត្រ ឆ្នាំ១៩៨២-ឆ្នាំ១៩៨៨

- មុខជំនាញ : អ្នកបើកនាវា ប្រទេសរុស្សី

៣. ថ្នាក់វិទ្យាល័យ ឆ្នាំ១៩៧៩-ឆ្នាំ១៩៨២

- ឈ្មោះសាលារៀន : នៅទីក្រុងភ្នំពេញ ប្រទេសកម្ពុជា

**បទពិសោធន៍ការងារ**

- ឆ្នាំ២០១៦ ដល់បច្ចុប្បន្ន : នាយក នាយកដ្ឋាននាវា ចរកណ្ណធារ
ភារកិច្ច៖ គ្រប់គ្រងការងារសន្តិសុខ និង បែបបទការងារនាវាចរ ក្នុងកំពង់ផែ



**លោក នាក់ សុហ៊ីយ៉ាន**

ប្រធាននាយកដ្ឋាន គ្រឿងចក្រ

**ជនជាតិ** : ខ្មែរ

**សញ្ជាតិ** : ខ្មែរ

**ថ្ងៃខែឆ្នាំកំណើត** : ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ១៩៥៨

**ប្រវត្តិនៃការសិក្សា**

១. ថ្នាក់បណ្ឌិត ឆ្នាំ១៩៨៥-ឆ្នាំ១៩៨៧

- មុខជំនាញ : គ្រប់គ្រងរដ្ឋបាលសាធារណៈ
- ឈ្មោះសាលារៀន : សាកលវិទ្យាល័យ Troy State, Alabama សហរដ្ឋអាមេរិក

២. ថ្នាក់បរិញ្ញាប័ត្រ ឆ្នាំ១៩៧៩-ឆ្នាំ១៩៨២

- មុខជំនាញ : គ្រប់គ្រងពាណិជ្ជកម្ម
- ឈ្មោះសាលារៀន : សាកលវិទ្យាល័យ OLLU, Texas សហរដ្ឋអាមេរិក

៣. ថ្នាក់វិទ្យាល័យ ឆ្នាំ១៩៦៧-ឆ្នាំ១៩៧៣

- ឈ្មោះសាលារៀន : វិទ្យាល័យបឹងត្របែកប្រទេសកម្ពុជា

**បទពិសោធន៍ការងារ**

- ឆ្នាំ២០០៨ ដល់បច្ចុប្បន្ន : ប្រធាននាយកដ្ឋានគ្រឿងចក្រ **កសស**
ភារកិច្ចៈ គ្រប់គ្រងចាត់ចែង លើភារកិច្ចលើកដាក់ ដឹកជញ្ជូនទំនិញគ្រប់ប្រភេទតាមលក្ខណៈបច្ចេកទេស និងគ្រប់គ្រងលើការថែទាំ និងជួសជុលបណ្តាគ្រឿងចក្រគ្រប់ប្រភេទ ។



**លោក ម៉ែន ចាន់**

ប្រធាននាយកដ្ឋាន សវនកម្មផ្ទៃក្នុង

**ជនជាតិ** : ខ្មែរ

**សញ្ជាតិ** : ខ្មែរ

**ថ្ងៃខែឆ្នាំកំណើត** : ថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ១៩៦៨

**ប្រវត្តិនៃការសិក្សា**

១. ថ្នាក់អនុបណ្ឌិត ឆ្នាំ២០០៥-ឆ្នាំ២០០៨

- មុខជំនាញ : គ្រប់គ្រងពាណិជ្ជកម្ម

២. ថ្នាក់បរិញ្ញាប័ត្រ ឆ្នាំ២០០២-ឆ្នាំ២០០៥

- មុខជំនាញ : គ្រប់គ្រងពាណិជ្ជកម្ម
- ឈ្មោះសាលារៀន : សាកលវិទ្យាល័យបៀល-ប្រាយ ខេត្តព្រះសីហនុប្រទេសកម្ពុជា

៣. ថ្នាក់វិទ្យាល័យ ឆ្នាំ១៩៨២-ឆ្នាំ១៩៨៨

- ឈ្មោះសាលារៀន : វិទ្យាល័យសន្ធរម៉ុក ភ្នំពេញ ប្រទេសកម្ពុជា

៤. ការសិក្សា និងសញ្ញាប័ត្រផ្សេងៗ

- Certificate - Port Administration & Management, Japan

  Certificate - Port Facility Security, Japan

  Certificate UNCTAD Port Training Program

**បទពិសោធន៍ការងារ**

- ឆ្នាំ២០១៥ ដល់បច្ចុប្បន្ន : នាយកទទួលបន្ទុករួមសវនកម្មផ្ទៃក្នុង និង ជាជំនួយការផ្ទាល់ ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាប្រធានអគ្គនាយក

## ខ-តួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់បុគ្គលិកជាន់ខ្ពស់

តួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់បុគ្គលិកជាន់ខ្ពស់របស់ **កសស** មានដូចខាងក្រោម៖

### ខ.១. ឯកឧត្តម លូ គឹមឈន់ ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាប្រធានអគ្គនាយក៖

ឯកឧត្តម **លូ គឹមឈន់** ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាប្រធានអគ្គនាយកមានតួនាទី និងភារកិច្ច ទទួលបន្ទុកដឹកនាំការងាររួមដឹកនាំត្រួតពិនិត្យនិងតាមដានជំរុញការអនុវត្តការងារលើគ្រប់វិស័យ របស់កំពង់ផែរួមមានការងារ អាជីវកម្ម សេវាកម្មការងារសាងសង់ពង្រីកមូលដ្ឋានតាមផែនការអភិវឌ្ឍន៍កំពង់ផែ និងជាពិសេសការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល លើរាល់ចំណុច ដែលពាក់ព័ន្ធនឹងវិស័យកំពង់ផែ។

*ចំពោះនាយកដ្ឋាននឹងអង្គភាពដែលស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់ ឯកឧត្តមប្រធានអគ្គនាយករួមមាន៖*

- នាយកដ្ឋាន ផែនការ លទ្ធកម្ម និងស្ថិតិ
- នាយកដ្ឋាន គណនេយ្យ-ហិរញ្ញវត្ថុ
- នាយកដ្ឋាន ទីផ្សារ
- នាយកដ្ឋាន សវនកម្មផ្ទៃក្នុង
- លេខាធិការដ្ឋាន

### ខ.២. លោក ថៃ ឫទ្ធី អគ្គនាយករងអាជីវកម្ម៖

លោក **ថៃ ឫទ្ធី** អគ្គនាយករងអាជីវកម្ម មានតួនាទី និងភារកិច្ចជាជំនួយការអោយឯកឧត្តមប្រធាន អគ្គនាយក និងទទួលបន្ទុកការងារអាជីវកម្ម និងជួយឯកឧត្តមប្រធានអគ្គនាយកក្នុងការតាមដាននឹងត្រួត ពិនិត្យការអនុវត្តទិសដៅរបស់រាជរដ្ឋាភិបាលដែលមានពាក់ព័ន្ធនឹងការអនុវត្តផែនការរបស់ **កសស** ជាពិសេស ការងារអាជីវកម្ម ។

ចំពោះនាយកដ្ឋាន ដែលស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់ លោកអគ្គនាយករងអាជីវកម្ម រួមមាន៖

- នាយកដ្ឋាន អាជីវកម្ម
- នាយកដ្ឋាន ប្រតិបត្តិការទីលានកុងតឺន័រ
- នាយកដ្ឋាន ប្រតិបត្តិការទំនិញទូទៅ

### ខ.៣. លោក ឈុន ហុង អគ្គនាយករងរដ្ឋបាល-គ្រប់គ្រង៖

លោក **ឈុន ហុង** អគ្គនាយករងរដ្ឋបាល-គ្រប់គ្រងមានតួនាទី និងភារកិច្ចជាជំនួយការអោយ ឯកឧត្តមប្រធានអគ្គនាយក ទទួលបន្ទុកការងាររដ្ឋបាល-គ្រប់គ្រង និងនាវាចរ-កណ្ណធារ និងជួយឯកឧត្តម ប្រធានអគ្គនាយកក្នុងការតាមដាន និងត្រួតពិនិត្យការអនុវត្តទិសដៅរបស់រាជរដ្ឋាភិបាលដែលមានពាក់ព័ន្ធ នឹងការអនុវត្តផែនការរបស់ **កសស** ជាពិសេសការងាររដ្ឋបាល-គ្រប់គ្រង ។

ចំពោះនាយកដ្ឋានដែលស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់លោកអគ្គនាយករង រដ្ឋបាល-គ្រប់គ្រង រួមមាន៖

- នាយកដ្ឋាន រដ្ឋបាល-ធនធានមនុស្ស
- នាយកដ្ឋាន នាវាចរ-កណ្ណធារ

## ខ.៤. លោក ជា យុទ្ធឌីកា អគ្គនាយករង បច្ចេកទេស៖

លោក **ជា យុទ្ធឌីកា** អគ្គនាយករង បច្ចេកទេសមានតួនាទី និងភារកិច្ចជាជាជំនួយការអោយ ឯកឧត្តមប្រធានអគ្គនាយកទទួលបន្ទុកការងារបច្ចេកទេសសាងសង់ និងជួយប្រធានអគ្គនាយកក្នុងការតាមដាន និងត្រួតពិនិត្យការអនុវត្តទិសដៅរបស់រាជរដ្ឋាភិបាល ដែលមានពាក់ព័ន្ធនឹងការអនុវត្តផែនការរបស់ **កសស** ជាពិសេសការងារបច្ចេកទេស និងសំណង់ ។

ចំពោះនាយកដ្ឋានដែលស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់លោកអគ្គនាយករងបច្ចេកទេសរួមមាន៖

- នាយកដ្ឋាន បច្ចេកទេស សម្ភារៈ-សំណង់
- នាយកដ្ឋាន គ្រឿងចក្រ

## ខ.៥. លោក វ័ត្ន សិលា នាយក រដ្ឋបាល-ធនធានមនុស្ស ៖

លោក **វ័ត្ន សិលា** នាយក រដ្ឋបាល-ធនធានមនុស្ស មានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- គ្រប់គ្រង និងសម្របសម្រួលនូវរាល់សកម្មភាពពាក់ព័ន្ធនឹងការងាររដ្ឋបាល និងធនធានមនុស្ស
- រៀបចំប្រាក់បៀវត្ស ប្រាក់ឧបត្ថម្ភ ប្រាក់សោធននិវត្តន៍ ជូនមន្ត្រី និយោជិត កម្មករ
- គ្រប់គ្រង និងរៀបចំ ឯកសាររដ្ឋបាល លិខិតអនុញ្ញាតច្បាប់ លិខិតបង្គាប់ការ លិខិតបញ្ជាបេសកកម្ម និងត្រា របស់អង្គភាព
- ទទួលរៀបចំបដិសណ្ឋារកិច្ចភ្ញៀវជាតិ និងអន្តរជាតិ
- គ្រប់គ្រងរាល់ការងារពាក់ព័ន្ធនឹងធនធានមនុស្ស ការបណ្តុះបណ្តាលក្នុង-ក្រៅប្រទេស និងការងារ APA
- គ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យា ប្រព័ន្ធទូរស័ព្ទ អ៊ីនធើណេត និងអ៊ីម៉ែល
- គ្រប់គ្រង ជួសជុល និងផ្គត់ផ្គង់ប្រេងឥន្ធនៈ ដល់មធ្យោបាយដឹកជញ្ជូន ដែលបម្រើឱ្យការងាររដ្ឋបាល និងរថយន្តបង្ការអគ្គីភ័យ
- គ្រប់គ្រងជួសជុល កែលម្អអគារ ទីស្នាក់ការ បណ្តាអង្គភាព និងនាយកដ្ឋាននានា
- គ្រប់គ្រងផ្គត់ផ្គង់ សម្ភារៈ និងឧបករណ៍ ការិយាល័យ រដ្ឋបាល អេឡិចត្រូនិច និងទូរស័ព្ទ
- រៀបចំតួនាទីភារកិច្ច និងកែសម្រួលរចនាសម្ព័ន្ធតាមស្ថានភាពជាក់ស្តែង
- គ្រប់គ្រងការងារសង្គម របស់មន្ត្រី និយោជិត កម្មករ
- រៀបចំបែបបទទាក់ទងនឹងធានារ៉ាប់រងសង្គមចំពោះមន្ត្រីចូលមរណភាព និងការឧបត្ថម្ភកូនកំព្រា
- គ្រប់គ្រង ការងារ ថែទាំសុខភាព ព្យាបាល និងផ្គត់ផ្គង់ឱសថជូនដល់ មន្ត្រី និយោជិត កម្មករ
- គ្រប់គ្រងការងារសំអាត អនាម័យ និងបរិស្ថានកំពង់ផែ
- កសាងគម្រោងចំណាយរដ្ឋបាលរយៈពេលខ្លី វែង ជូនថ្នាក់ដឹកនាំ
- បំពេញភារកិច្ចផ្សេងទៀត ដែលថ្នាក់ដឹកនាំប្រគល់ជូន

## ខ.៦. លោក ប៉ាត សិត នាយកគណនេយ្យ-ហិរញ្ញវត្ថុ៖

លោក **ប៉ាត សិត** នាយកគណនេយ្យ-ហិរញ្ញវត្ថុ មានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- រៀបចំ និងគ្រប់គ្រងអនុវត្តការងារគណនេយ្យ-ហិរញ្ញវត្ថុ ឱ្យត្រឹមត្រូវសមស្របតាមគោលការណ៍ គណនេយ្យកម្ពុជា ដែលដាក់ឱ្យប្រើដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- គ្រប់គ្រង និងកត់ត្រាជាប្រចាំនូវសាលាកប័ត្រ និងបញ្ជីការគណនេយ្យ ស្របទៅតាមច្បាប់គណនេយ្យ-ហិរញ្ញវត្ថុ របស់ព្រះរាជាណាចក្រកម្ពុជា
- តាមដាន គ្រប់គ្រង និងធ្វើរបាយការណ៍ខាងគណនេយ្យ-ហិរញ្ញវត្ថុ
- គ្រប់គ្រងសាច់ប្រាក់ក្នុងបេឡា និងធនាគារ
- ផ្ទៀងផ្ទាត់ និងប្រមូលចំណូលឱ្យទាន់ពេលវេលា សមស្របតាមនីតិវិធីហិរញ្ញវត្ថុ
- គ្រប់គ្រងចំណូល និងចំណាយដោយអនុវត្តតាមផែនការកំណត់ជាមូលដ្ឋាន
- ណែនាំ និងត្រួតពិនិត្យបញ្ជីការបណ្ដានាយកដ្ឋានរបស់ **កសស** ដែលទាក់ទងដល់មុខសញ្ញាចំណូល ចំណាយ ដើម្បីអនុវត្តឱ្យបានត្រឹមត្រូវតាមលិខិតបទដ្ឋាន និងគោលការណ៍
- ចូលរួមក្នុងការកសាងផែនការហិរញ្ញវត្ថុប្រចាំឆ្នាំ
- ចូលរួមក្នុងការងារលទ្ធកម្ម ដោយអនុវត្តតាមផែនការលទ្ធកម្មប្រចាំឆ្នាំ
- ចូលរួមក្នុងការជម្រះបញ្ជីអចលនទ្រព្យ ដោយអនុវត្តតាមច្បាប់ស្ដីពីការគ្រប់គ្រងសម្បត្តិរដ្ឋ
- គ្រប់គ្រងបញ្ជីសារពើភ័ណ្ឌ
- អនុវត្តកាតព្វកិច្ចបង់ពន្ធអាករគ្រប់ប្រភេទចូលថវិការដ្ឋ
- ចូលរួមក្នុងការធ្វើសវនកម្មផ្ទៃក្នុង **កសស**
- តាមដាន និងគ្រប់គ្រងនូវរាល់បណ្ដាប្រាក់ជំនួយឧបត្ថម្ភធន និងប្រាក់កម្ចី
- តាមដានបំណុល និងបំណុលពុំរ៉ៃ និងរៀបចំរបាយការណ៍ជម្រះបញ្ជីជូន **ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាប្រធានអគ្គនាយក កសស** ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលសម្រេច
- បំពេញភារកិច្ចផ្សេងទៀត ដែលថ្នាក់ដឹកនាំប្រគល់ជូន

## ខ.៧. លោក សូ សៀង នាយកផែនការ លទ្ធកម្ម និងស្ថិតិ៖

លោក **សូ សៀង** នាយកផែនការ លទ្ធកម្ម និងស្ថិតិ មានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- រៀបចំផែនការអាជីកម្ម (សេវាកម្ម) ហិរញ្ញវត្ថុ និងផែនការជួសជុលសាងសង់សំណង់មូលដ្ឋាន ការប្រើប្រាស់មធ្យោបាយ គ្រឿងចក្រ ប្រេងឥន្ធនៈ ធនធានមនុស្សប្រចាំឆ្នាំជូន **កសស**
- រៀបចំផែនការអភិវឌ្ឍន៍រយៈពេលខ្លី មធ្យម វែង និងវិនិយោគសាធារណៈ
- ធ្វើរបាយការណ៍បូកសរុបលទ្ធផលការងារ អាជីវកម្ម សេវាកម្ម ប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ
- កសាងកិច្ចសន្យាអាជីវកម្ម (សេវាកម្ម) កិច្ចសន្យាអភិវឌ្ឍន៍ និងវិនិយោគសាធារណៈ រយៈពេលមធ្យម និងវែង (លើសពី ០១ឆ្នាំ)
- រៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំ និងផែនការលទ្ធកម្មកែតម្រូវក្នុងករណីចាំបាច់
- គ្រប់គ្រង និងសម្របសម្រួល ក្នុងការអនុវត្តនីតិវិធីលទ្ធកម្មរបស់ **កសស**

- កសាងតារាងតម្លៃអាជីវកម្ម (សេវាកម្ម) និងគម្រោងផែនការ តម្លៃសេវាកម្មអនាគត
- រៀបចំកិច្ចប្រជុំជារៀងរាល់ខែ ត្រីមាស ឆមាស និងឆ្នាំ
- បំពេញភារកិច្ចផ្សេងទៀត ដែលថ្នាក់ដឹកនាំប្រគល់ជូន

## ខ.៨. លោក ទី សាគុណ នាយកបច្ចេកទេស សម្ភារៈ-សំណង់៖

លោក **ទី សាគុណ** នាយកបច្ចេកទេស សម្ភារៈ-សំណង់ មានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- ពិនិត្យណែនាំបង្ហាញតាមដានអំពីការអនុវត្តបទដ្ឋានបច្ចេកទេសក្នុងការប្រើប្រាស់ថែទាំ ជួសជុលគ្រប់បណ្តាមធ្យោបាយគ្រឿងចក្រ សម្ភារៈ ប្រេងឥន្ធនៈ បរិក្ខាអគ្គីសនី និងសំណង់ របស់ **កសស**
- សិក្សាពីលក្ខណៈបច្ចេកទេសគ្រឿងចក្រ ឧបករណ៍ប្រើប្រាស់បរិក្ខាអគ្គិសនី ប្រេងឥន្ធនៈ និងលក្ខណៈបច្ចេកទេសសំណង់
- លើកគម្រោងជួសជុលធំ ជួសជុលអចិន្ត្រៃយ៍រាល់មធ្យោបាយគ្រឿងចក្រ
- ទទួលខុសត្រូវក្នុងការងារគ្រប់គ្រងថែរក្សា និងផ្គត់ផ្គង់សម្ភារៈ បន្លាស់សម្ភារៈសំណង់ បរិក្ខាអគ្គិសនី ប្រេងឥន្ធនៈ អ៊ូនាវា-ពោងសញ្ញា យានដ្ឋាន និងសំណង់ផ្សេងៗទៅតាមបទដ្ឋានបច្ចេកទេស
- សិក្សារៀបចំគម្រោង និងអនុវត្តការងារសាងសង់ជួសជុលសង់សំណង់មូលដ្ឋាន
- ចូលរួមស្រាវជ្រាវកសាងនូវរបកគំហើញថ្មីក្នុងគោលដៅអភិវឌ្ឍន៍ **កសស**
- បំពេញភារកិច្ចផ្សេងទៀត ដែលថ្នាក់ដឹកនាំប្រគល់ជូន

## ខ.៩. លោកស្រី ជ័យ សុគន្ធា នាយិកាទីផ្សារ៖

លោកស្រី **ជ័យ សុគន្ធា** នាយិកាទីផ្សារមានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- ផ្តើមគំនិតក្នុងការលើកស្ទួយគុណភាពទីផ្សារ សេវាកម្មរបស់ **កសស** អោយមានកម្រិត សមស្របទៅនឹងដំណើរនៃសកលភាវូបនីយកម្មក្នុងតំបន់ ក៏ដូចតម្រូវការរបស់អតិថិជន
- សិក្សា និងតាមដានអំពីស្ថានភាព តម្លៃ និងគុណភាពសេវាកម្ម របស់គូប្រកួតប្រជែង ដើម្បី ផ្តល់យោបល់ជូនថ្នាក់ដឹកនាំ
- សិក្សាស្វែងយល់ទីផ្សារអំពីតម្រូវការ ទំនោរនិន្នាការ និងព័ត៌មានត្រលប់របស់អតិថិជន
- ប្រមូលទិន្នន័យព័ត៌មានដើម្បីចងក្រង និងរៀបចំដាក់ចេញនូវយុទ្ធសាស្ត្រទីផ្សារ
- ផ្តើមគំនិតផលិតឯកសារផ្សព្វផ្សាយព័ត៌មានដូចជាព្រឹត្តប័ត្រប្រចាំឆ្នាំ ប្រតិទិន និងប្រភេទនៃសម្ភារៈផ្សព្វផ្សាយផ្សេងៗ
- រួមចំណែកលើកកម្ពស់គុណភាពសេវាកម្មរបស់ **កសស** នៅក្នុងទីផ្សារជាតិ និងអន្តរជាតិ ដើម្បីឆ្លើយតបនឹងសំណូមពរអតិថិជន
- ធ្វើបច្ចុប្បន្នភាពគេហទំព័រ និងបណ្តាញសង្គមរបស់ **កសស**
- បំពេញភារកិច្ចផ្សេងទៀត ដែលថ្នាក់ដឹកនាំប្រគល់ជូន

## ខ.១០. លោក ជីវ ច័ន្ទសុផល នាយកតំបន់សេដ្ឋកិច្ចពិសេស៖

លោក **ជីវ ច័ន្ទសុផល** នាយក តំបន់សេដ្ឋកិច្ចពិសេស មានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- ទំនាក់ទំនង និងពិភាក្សាជាមួយអតិថិជនដើម្បីរៀបចំកិច្ចព្រមព្រៀង
- ផ្តល់សេវាកម្ម និងព័ត៌មានអំពីការវិនិយោគទាក់ទងនឹង **តសព** ជូនអតិថិជនប្រកបដោយគុណភាព និងប្រសិទ្ធិភាព
- សហការ និងសម្របសម្រួល ជាមួយអាជ្ញាធរមានសមត្ថកិច្ចប្រចាំនៅរដ្ឋបាល **តសព** និងវិនិយោគិនក្នុងតំបន់ ដើម្បីធ្វើអោយប្រតិបត្តិការមានភាពរលូន
- បង្កើតគំនិតផ្នែប្រឌិតទីផ្សារថ្មីៗ ដើម្បីអោយ **តសព** មានឧត្តមភាពប្រកួតប្រជែងក្នុងតំបន់ និងសាកល
- ចូលរួមលើកគម្រោងផែនការសម្រាប់រយៈពេលវែង ខ្លី ដែលពាក់ព័ន្ធនឹង **តសព**
- ស្វែងយល់អំពីស្ថានភាព និងកម្រិត **តសព** ក្នុងប្រទេសជិតខាងក្នុងតំបន់
- សហការជាមួយនាយកដ្ឋានពាក់ព័ន្ធដើម្បីបម្រើ ឬផ្តល់សេវាជូនអតិថិជនក្នុង **តសព** ឬសេវាដទៃទៀតដែលពាក់ព័ន្ធដើម្បីជាប្រយោជន៍ដល់ **កសស**
- ទទួលខុសត្រូវលើកិច្ចការចេញវិក្កយបត្រ គិតថ្លៃឈ្នួល និងសេវាគ្រប់ប្រភេទជូនដល់អតិថិជន
- គ្រប់គ្រងសុវត្ថិភាព សន្តិសុខ សណ្តាប់ធ្នាប់ល្អក្នុង **តសព**
- ធ្វើរបាយការណ៍អំពីស្ថានភាពវិនិយោគនៅ **តសព** និងលទ្ធផលនៃប្រតិបត្តិការ
- បំពេញភារកិច្ចផ្សេងទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន

## ខ.១១. លោក ពិត ប្រាកដ នាយកអាជីវកម្ម៖

លោក **ពិត ប្រាកដ** នាយកអាជីវកម្ម មានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- ទទួលខុសត្រូវអនុវត្តតម្លៃឈ្នួលគ្រប់ប្រភេទលើការងារសេវាកម្ម អាជីវកម្ម ដោយអនុវត្តទៅតាមបទដ្ឋាន សេចក្តីសម្រេច សេចក្តីកំណត់របស់ **កសស**
- ពិនិត្យ និងតាមដានការងារអាជីវកម្ម ការប្រើប្រាស់សេវាកម្មផ្សេងៗរបស់ **កសស**
- ចូលរួមលើកគម្រោងជាមួយបណ្តានាយកដ្ឋាននានា ក្នុងការរៀបចំកសាងកិច្ចសន្យាអាជីវកម្ម (សេវាកម្ម) កិច្ចសន្យាអភិវឌ្ឍន៍ និងវិនិយោគ និងកសាងតម្លៃឈ្នួលផ្សេងៗ សម្រាប់បម្រើ អោយការងារអាជីវកម្មរបស់ **កសស**
- បូកសរុបបញ្ជីការប្រចាំ សប្តាហ៍ ខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ ជូននាយកដ្ឋានពាក់ព័ន្ធដើម្បីផ្ទៀងផ្ទាត់ជាមួយនាយកដ្ឋានគណនេយ្យ-ហិរញ្ញវត្ថុ
- រៀបចំ និងកសាងកិច្ចសន្យាស្តីពីការប្រើប្រាស់សេវាកម្ម (លើកដាក់ ដឹកជញ្ជូន) របស់ **កសស** និងការជួលផ្សេងៗរយៈពេលខ្លីក្រោម ០១ឆ្នាំ
- សិក្សាអំពីតម្លៃឈ្នួលនៅតាមបណ្តាកំពង់ផែនានា នៅក្នុងតំបន់ និងក្នុងស្រុកព្រមទាំងបណ្តាច្រកព្រំដែន ដើម្បីមានមូលដ្ឋានក្នុងការកសាង និងកែលម្អតម្លៃផ្សេងៗរបស់ **កសស**
- សហការណ៍ជាមួយនាយកដ្ឋានពាក់ព័ន្ធ ក្នុងការក្រើនរំលឹកដល់អតិថិជនទាំងឡាយដែលជាប់បំណុលដើម្បីទូទាត់ឱ្យទាន់ពេលវេលា

- ទទួលខុសត្រូវគ្រប់គ្រង ប្រើប្រាស់ និងថែរក្សាប្រព័ន្ធ CTMS និង SWSS អោយដំណើរការបានរលូនល្អ និងមានប្រសិទ្ធិភាព
- ចូលរួមសហការណ៍ជាមួយសមត្ថកិច្ចពាក់ព័ន្ធនានា ដើម្បីអនុវត្តការងារច្រក ចេញ-ចូល តែមួយឱ្យមានប្រសិទ្ធិភាព និងទទួលបាននូវជោគជ័យ
- បំពេញភារកិច្ចផ្សេងទៀត ដែលថ្នាក់ដឹកនាំប្រគល់ជូន

## ខ.១២. លោក ស្រី ណារិទ្ធ នាយកប្រតិបត្តិការទីលានកុងតឺន័រ៖

លោក **ស្រី ណារិទ្ធ** នាយកប្រតិបត្តិការទីលានកុងតឺន័រ មានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- ចូលរួមអនុវត្តកិច្ចព្រមព្រៀងរវាង **កសស** និងក្រុមហ៊ុននាវា
- ចូលរួមសហការណ៍ជាមួយនាយកដ្ឋានពាក់ព័ន្ធ លើការងារនាំនាវា ចូល-ចេញ និងការងារផ្ទេរ-ផ្ទុក កុងតឺន័រជាមួយនាវា
- ទទួលព័ត៌មាននាវា ស្តីពីពេលវេលានៃការចូលចត និងបរិមាណកុងតឺន័រដែលត្រូវ ផ្ទេរ-ផ្ទុក និងបញ្ចូលទៅក្នុងប្រព័ន្ធ CTMS
- ធ្វើផែនការនាវា ផែនការទីលាន ផែនការមធ្យោបាយ ផ្ទេរ-ផ្ទុក លើកដាក់ និងកម្លាំង ប្រតិបត្តិការ
- ទទួលកុងតឺន័រនាំចូលពីនាវា និងពីគ្រប់មធ្យោបាយដឹកជញ្ជូនមកទីលាន
- ប្រគល់កុងតឺន័រនាំចូល ពីនាវាទៅម្ចាស់ទំនិញ និងកុងតឺន័រនាំចេញទៅនាវា
- ផ្ទៀងផ្ទាត់វិក្កយប័ត្រ នៃការលើកដាក់នៅទីលានជាមួយម្ចាស់ទំនិញ
- ធ្វើរបាយការណ៍ ស្តីពីប្រតិបត្តិការកុងតឺន័រ ជូននាយកដ្ឋានពាក់ព័ន្ធ
- រៀបចំសណ្តាប់ធ្នាប់ ប្រព័ន្ធចរាចរណ៍ក្នុងតំបន់ប្រតិបត្តិការ និងទីលាន
- គ្រប់គ្រង ទុកដាក់ ថែរក្សា កុងតឺន័រនៅទីលានអោយមានសុវត្ថិភាព
- គ្រប់គ្រងជញ្ជីងថ្លឹងកុងតេន័រ
- កត់ត្រាចំនួនកុងតឺន័រដែល ផ្ទេរ-ផ្ទុក ជាមួយនាវា
- គ្រប់គ្រងការប្រើប្រាស់មធ្យោបាយលើកដាក់ និងអ្នកបើកបរ ទៅតាមមុខសញ្ញាការងារអោយមានប្រសិទ្ធិភាព
- គ្រប់គ្រងការប្រើប្រាស់ប្រព័ន្ធ CTMS ទាំងអស់ដែលពាក់ព័ន្ធជាមួយប្រតិបត្តិការកុងតឺន័រ
- បំពេញភារកិច្ចផ្សេងទៀត ដែលថ្នាក់ដឹកនាំប្រគល់ជូន

## ខ.១៣. លោក លូ លីខេង នាយកប្រតិបត្តិការទំនិញទូទៅ៖

លោក **លូ លីខេង** នាយក ប្រតិបត្តិការទំនិញទូទៅ មានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- ទទួលព័ត៌មាននាវា ដែលផ្ទុកទំនិញរាយ
- ធ្វើផែនការ ផ្ទេរ-ផ្ទុក ទំនិញ ទៅតាមប្រភេទប្រតិបត្តិការ
- ទទួលព័ត៌មាន និងដោះស្រាយរាល់បាតុភាពផ្សេងៗតាមការដ្ឋាន
- ទទួល ប្រគល់ និងថែរក្សាទំនិញឱ្យបានត្រឹមត្រូវតាមបទដ្ឋាន

- ស្រាវជ្រាវបទដ្ឋាន និងនីតិវិធីថ្មីៗ ដើម្បីហ្វឹកហ្វឺនដល់ប្រតិបត្តិករ
- ក្រើនរំលឹកដល់ប្រតិបត្តិករ អំពីការប្រើប្រាស់ ការថែទាំគ្រឿងចក្រទៅតាមបទដ្ឋាន និងយកចិត្តទុកដាក់លើសុខភាព សុវត្ថិភាព ពលកម្ម ក្នុងពេលប្រតិបត្តិការគ្រប់ការដ្ឋាន
- លើកគម្រោងស្នើសុំសម្ភារៈប្រើប្រាស់ផ្សេងៗ ឧបករណ៍ និងមធ្យោបាយលើកដាក់ដឹកជញ្ជូន
- ធ្វើរបាយការណ៍អំពីលទ្ធផលការងារប្រចាំវេន ថ្ងៃ ខែ និងឆ្នាំ ដើម្បីផ្តល់ជូនភាគី និងនាយកដ្ឋានពាក់ព័ន្ធ
- បំពេញភារកិច្ចផ្សេងទៀត ដែលថ្នាក់ដឹកនាំប្រគល់ជូន

## ខ.១៤. លោក ចោង រី្ស នាយកនាវាចរ-កណ្តធារ៖

លោក **ចោង រី្ស** នាយកនាវាចរ-កណ្តធារ មានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- កណ្តធារកិច្ច
- រៀបចំផែនការស្តីពីកណ្តធារកិច្ច
- ដឹកនាំគណៈកម្មការ ដើម្បីបំពេញបែបបទនាំនាវាចូល-ចេញពីកំពង់ផែ
- គ្រប់គ្រង និងទំនាក់ទំនងប្រព័ន្ធប្រតិបត្តិការចលនានាវា
- គ្រប់គ្រង ប្រើប្រាស់ និងថែទាំ មធ្យោបាយជើងទឹក (នាវាសណ្តោង)
- គ្រប់គ្រងឯកសារ និងធ្វើរបាយការណ៍រាល់សកម្មភាពនាវា ចេញ-ចូល **កសស**
- ទទួលគ្រប់គ្រងចំណតផែ ពោង ភ្លើងសញ្ញា ជម្រៅទឹក ដើម្បីសុវត្ថិភាពនាវា
- ទំនាក់ទំនងក្នុងការប្រមូលកាកសំណល់ រឹង-រាវ ពីនាវា និងផ្គត់ផ្គង់ទឹកស្អាត
- រុករក និងសង្គ្រោះ រាល់ហេតុការណ៍ដែលអាចកើតមានឡើងក្នុងតំបន់ទឹក **កសស**
- លើកគម្រោងអភិវឌ្ឍន៍ចំណតផែ និងជម្រៅទឹក នៅថ្ងៃអនាគតសម្រាប់ **កសស**
- សិក្សា និងស្រាវជ្រាវឯកសារច្បាប់ជាតិ និងអន្តរជាតិ ដែលពាក់ព័ន្ធនឹងនាវាចរ
- គ្រប់គ្រងសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ និងទំនាក់ទំនងការងារសន្តិសុខថ្នាក់ជាតិ និងអន្តរជាតិ ព្រមទាំង ISPS Code
- បំពេញភារកិច្ចផ្សេងទៀត ដែលថ្នាក់ដឹកនាំប្រគល់ជូន

## ខ.១៥. លោក នាក់ សូហ្វីយ៉ាន នាយកគ្រឿងចក្រ៖

លោក **នាក់ សូហ្វីយ៉ាន** នាយកគ្រឿងចក្រ មានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- ចូលរួមពិនិត្យការគ្រប់គ្រងថែទាំនូវបណ្តាគ្រឿងចក្រគ្រប់ប្រភេទ
- ស្រាវជ្រាវបទដ្ឋានបច្ចេកទេស ដើម្បីជាមូលដ្ឋានក្នុងការ ថែទាំ-ជួសជុល នូវមធ្យោបាយ លើកដាក់ និងដឹកជញ្ជូន ក្នុងការធានាគុណភាពប្រកបដោយប្រសិទ្ធិភាពខ្ពស់
- ត្រួតពិនិត្យជាប្រចាំ ដើម្បីក្តាប់ឱ្យបាននូវស្ថានភាពមធ្យោបាយគ្រឿងចក្រ និងឧបករណ៍
- រៀបចំហ្វឹកហ្វឺន លើជំនាញបើកបរ និងថែទាំគ្រឿងចក្រ
- សហការណ៍ត្រួតពិនិត្យ ការជួសជុលមធ្យោបាយនានា ដើម្បីស្វែងយល់អំពីលទ្ធផលនៃការជួសជុល និងការប្រើប្រាស់មធ្យោបាយទាំងនោះ

- ចូលរួមកសាងគម្រោងមធ្យោបាយលើកដាក់ ដឹកជញ្ជូនទំនិញទៅតាមសភាពការណ៍អភិវឌ្ឍន៍ របស់ **កសស**
- បំពេញភារកិច្ចផ្សេងទៀត ដែលថ្នាក់ដឹកនាំប្រគល់ជូន

ខ.១៦. លោក ម៉ែន ចាន់ នាយកសវនកម្មផ្ទៃក្នុង ៖

លោក **ម៉ែន ចាន់** នាយកសវនកម្មផ្ទៃក្នុង មានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- ធ្វើសវនកម្មលើការអនុវត្តច្បាប់ បទបញ្ញានានា វិន័យ ថវិកា និងអភិបាលកិច្ចល្អនៅក្នុងប្រតិបត្តិការហិរញ្ញវត្ថុ ពិសេសការគៀងគរ និងគ្រប់គ្រងចំណូល ចំណាយ ថវិកា ហិរញ្ញប្បទានបំណុល និងទ្រព្យសម្បត្តិរដ្ឋ
- ធ្វើសវនកម្មលើពាក្យបណ្តឹងបរិហារទាំងឡាយ
- ធ្វើសវនកម្មលើនីតិវិធី និងការអនុវត្តគោលការណ៍ ដើម្បីធានាថាវិធានការដែលបានដាក់ពិតជាត្រឹមត្រូវ
- ទទួលអនុវត្តការងារសវនកម្មផ្សេងៗទៀត ស្របតាមវិជ្ជាជីវៈសវនកម្ម និងសេចក្តីប្រកាសណែនាំទាក់ទងនឹងការងារសវនកម្មផ្ទៃក្នុង
- ធ្វើសវនកម្មលើគម្រោងអភិវឌ្ឍន៍នានា
- បំពេញភារកិច្ចផ្សេងទៀត ដែលថ្នាក់ដឹកនាំប្រគល់ជូន

### គ-លទ្ធផលការងាររបស់បុគ្គលិកជាន់ខ្ពស់

នៅក្នុងឆ្នាំ២០១៧ នេះ បុគ្គលិកជាន់ខ្ពស់បានប្រជុំបូកសរុបការងារ និងពិនិត្យលទ្ធផលដែល បានអនុវត្តកន្លងមក និងដាក់ផែនការទិសដៅដែលត្រូវអនុវត្តបន្ត។

### ឃ-ការបណ្តុះបណ្តាលបន្តសម្រាប់បុគ្គលិកជាន់ខ្ពស់

នៅក្នុងឆ្នាំ២០១៧ នេះបុគ្គលិកជាន់ខ្ពស់របស់ **កសស** បានចូលរួមវគ្គបណ្តុះបណ្តាលស្តី អំពីការបង្ហាញព័ត៌មានសាជីវកម្ម និងការអនុវត្តអភិបាលកិច្ចសាជីវកម្មក្រោយពេលបោះផ្សាយលក់មូលបត្រជា សាធារណៈដែលរៀបចំឡើងនៅ **កសស** ក្រោមការបណ្តុះបណ្តាលពីមន្ត្រីរបស់ **គ.ម.ក** ។

## ៥-ការជាប់ពាក់ព័ន្ធរបស់អភិបាល និងបុគ្គលិកជាន់ខ្ពស់ក្នុងដំណើរការផ្លូវច្បាប់

នៅក្នុងឆ្នាំ២០១៧ នេះ មិនមានការជាប់ពាក់ព័ន្ធរបស់អភិបាល និងបុគ្គលិកជាន់ខ្ពស់ក្នុងដំណើរការផ្លូវច្បាប់ទេ ។

## ៦-លាភការ ឬប្រាក់បំណាច់របស់អភិបាល និងបុគ្គលិកជាន់ខ្ពស់

### ក-ឈ្មោះ តំណែងអភិបាល និងបុគ្គលិកជាន់ខ្ពស់ និងប្រាក់បំណាច់ ឬលាភការដែលទទួលបាន

| ល.រ | អភិបាល | មុខតំណែង | ប្រាក់បៀវត្សរ៍ និងលាភការមធ្យមប្រចាំខែសម្រាប់ | ប្រាក់បៀវត្សរ៍ និងលាភការសរុបសម្រាប់ |
|---|---|---|---|---|
| | | | ឆ្នាំ២០១៧ | |
| ១ | ឯកឧត្តមលូ គឹមឈន់ | ប្រធានក្រុមប្រឹក្សាភិបាល | ១៥.៦០០.០០០ | ១.៨៧២.០០០.០០០ |
| ២ | ឯកឧត្តម តឹករ៉េតសំរេច | អភិបាល | ១៤.៤០០.០០០ | ១៧២.៨០០.០០០ |
| ៣ | ឯកឧត្តម ផាន់ផល្លា | អភិបាល | ១៤.៤០០.០០០ | ១៧២.៨០០.០០០ |
| ៤ | ឯកឧត្តម យន្តមីន | អភិបាល | ១៤.៤០០.០០០ | ១៧២.៨០០.០០០ |
| ៥ | ឯកឧត្តម សុខសុភ័ក្ត្រ | អភិបាល | ១៤.៤០០.០០០ | ១៧២.៨០០.០០០ |
| ៦ | ឯកឧត្តម ស៊ុយសាន | អភិបាល | ១៤.៤០០.០០០ | ១៧២.៨០០.០០០ |
| ៧ | លោក លូ លីខេង | អភិបាល | ១៤.៤០០.០០០ | ១៧២.៨០០.០០០ |
| ៨ | លោក ព្រំ សេង | មន្ត្រីត្រួតពិនិត្យរដ្ឋ | ១៤.៤០០.០០០ | ១៧២.៨០០.០០០ |

| ល.រ | បុគ្គលិកជាន់ខ្ពស់ | មុខតំណែង | ប្រាក់បៀវត្សរ៍ និងលាភការ មធ្យម ប្រចាំខែ សម្រាប់ | ប្រាក់បៀវត្សរ៍ និងលាភការ សរុបសម្រាប់ |
|---|---|---|---|---|
| | | | ឆ្នាំ២០១៧ | |
| ១ | ឯកឧត្តមលូ គឹមឈន់ | ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាប្រធានអគ្គនាយក | ១៣.១៣២.៣៧៥ | ១៥៧.៥៨៨.៤៩៧ |
| ២ | លោក ថៃ ឫទ្ធី | អគ្គនាយករងអាជីវកម្ម | ១០.៧២.៧០៤ | ១២៨.៦៩៦.៤៤៩ |
| ៣ | លោក ឈុនហុង | អគ្គនាយករងរដ្ឋបាល-គ្រប់គ្រង | ១១.៣០៩.៨១៥ | ១៣៥.៧១៧.៧៨០ |
| ៤ | លោក ជាយុទ្ធឌីកា | អគ្គនាយករងបច្ចេកទេស | ១១.០៤៤.៧៦៧ | ១៣២.៥៣៧.២០៧ |
| ៥ | លោក វ័ត្ន សិលា | នាយករដ្ឋបាល-ធនធានមនុស្ស | ៨.៧៩៣.៦០២ | ១០៥.៥២៣.២២៩ |
| ៦ | លោក ប៉ាត សិត | នាយកគណនេយ្យ-ហិរញ្ញវត្ថុ | ៨.៣០៦.៦៥៦ | ៩៩.៦៧៩.៨៧៦ |
| ៧ | លោក សូ សៀង | នាយកផែនការ លទ្ធកម្ម និងស្ថិតិ | ៨.១០២.៩៣៥ | ៩៧.២៣៥.២២៤ |
| ៨ | លោក ទី សាគុណ | នាយកបច្ចេកទេស សម្ភារៈ-សំណង់ | ៧.៤៦៣.៨២០ | ៨៩.៥៦៥.៨៤៤ |
| ៩ | លោកស្រី ជ័យសុគន្ធា | នាយិកា ទីផ្សារ | ៨.១៦១.១៣៧ | ៩៧.៩៣៣.៦៤៩ |

| | | | | |
|---|---|---|---|---|
| ១០ | លោក ជីវច័ន្ទសុផល | នាយកតំបន់សេដ្ឋកិច្ចពិសេស | ៧.៩៤០.៤០៩ | ៩៥.២៨៤.៩០៦ |
| ១១ | លោក ពិត ប្រាកដ | នាយកអាជីវកម្ម | ៩.០១០.៩៥០ | ១០៨.១៣១.៤០១ |
| ១២ | លោក ស្រីណារិទ្ធ | នាយកប្រតិបត្តិការទីលានកុងតឺន័រ | ៩.៦៦៦.៤១៧ | ១១៥.៩៩៦.៩៩៨ |
| ១៣ | លោក លូ លីខេង | នាយកប្រតិបត្តិការទំនិញទូទៅ | ៧.១៩៩.៩៤៨ | ៨៦.៣៩៩.៣៧៧ |
| ១៤ | លោក ថោង វី | នាយកនាវាចរ-កណ្ណធារ | ១២.១២៧.១៣៨ | ១៤៥.៥២៥.៦៦០ |
| ១៥ | លោក នាក់សូហ្វីយ៉ាន | នាយកគ្រឿងចក្រ | ៧.០៣១.៧៥៩ | ៨៤.៣៨១.១០៧ |
| ១៦ | លោក ម៉ែន ចាន់ | នាយកសវនកម្មផ្ទៃក្នុង | ៨.៥៤០.៩១៦ | ១០២.៤៩០.៩៨៧ |

## ខ-ចំនួនប្រាក់បំណាច់ ឬលាភការសរុបដែលបើកឱ្យអភិបាលមិនប្រតិបត្តិ

**កសស** មានអភិបាលមិនប្រតិបត្តិចំនួន ០៥រូប ដែលជាសមាជិកក្រុមប្រឹក្សាភិបាលតំណាងស្ថាប័នក្រសួង ដែលមិនប្រតិបត្តិការងារប្រចាំថ្ងៃនៅក្នុង **កសស** និងតែងតាំងដោយអនុក្រឹត្យ។

ដែលចំនួនប្រាក់បំណាច់ ឬលាភការសរុបមានចំនួន ៨៦៤.០០០.០០០ រៀល

## គ-ចំនួនប្រាក់បំណាច់ ឬលាភការជាកញ្ចប់ដែលបានបើកឱ្យអភិបាល និងបុគ្គលិកជាន់ខ្ពស់

**កសស** មានអភិបាលសរុបចំនួន ០៧រូប និងបុគ្គលិកជាន់ខ្ពស់ចំនួន ១៧រូប រួមទាំងមន្ត្រីត្រួតពិនិត្យរដ្ឋ។ ខាងក្រោមនេះគឺចំនួនសរុប (ប្រាក់បៀវត្សរ៍ និងប្រាក់បំណាច់មិនបូកបញ្ចូលប្រាក់សោធននិវត្តន៍)៖

- អភិបាលទាំងអស់ ២.៩០៨.៨០០.០០០ រៀល
- បុគ្គលិកជាន់ខ្ពស់ទាំងអស់ ១.៩៥៥.៤៨៨.១៩១ រៀល

## ឃ-ចំនួនប្រាក់បំណាច់ ឬលាភការសរុបសម្រាប់រយៈពេលមួយឆ្នាំខាងមុខ ដែលត្រូវផ្តល់ជូនអភិបាល ឬបុគ្គលិកជាន់ខ្ពស់

ប្រាក់បំណាច់ ឬលាភការសរុបសម្រាប់រយៈពេលមួយឆ្នាំខាងមុខ ដែលត្រូវផ្តល់ជូនអភិបាល ឬបុគ្គលិកជាន់ខ្ពស់

- អភិបាលទាំងអស់ ២.៩០៨.៨០០.០០០ រៀល
- បុគ្គលិកជាន់ខ្ពស់ទាំងអស់ ១.៩៥៥.៤៨៨.១៩១ រៀល

## ង-ការបង្កើនប្រាក់បំណាច់ ឬលាភការសរុបក្នុងចំនួនច្រើនដល់អភិបាល ឬបុគ្គលិកជាន់ខ្ពស់របស់ក្រុមហ៊ុននៅក្នុងឆ្នាំសារពើពន្ធ ឬអនាគត

**កសស** ពុំមានផែនការបង្កើនប្រាក់បំណាច់ ឬលាភការដល់អភិបាល ឬបុគ្គលិកជាន់ខ្ពស់ទេ។

## ៧-ក្រមសីលធម៌សម្រាប់អភិបាល និងបុគ្គលិកជាន់ខ្ពស់

### ក-គោលការណ៍នៃក្រមសីលធម៌

### ប្រការ ១. សេចក្តីផ្តើម

ដោយយោងតាមច្បាប់ និងបទប្បញ្ញត្តិជាធរមានរួមទាំងប្រកាសស្តីពីអភិបាលកិច្ចសាជីវកម្មសម្រាប់សហគ្រាសសាធារណៈបោះផ្សាយលក់មូលបត្រជាសាធារណៈ និងជាការប្តេជ្ញាជម្រុញឱ្យមានការអនុវត្តន៍ការងារប្រកបដោយវិជ្ជាជីវៈ និងក្រមសីលធម៌ល្អ ក្រុមប្រឹក្សាភិបាលនៃកំពង់ផែស្វយ័តក្រុងព្រះសីហនុ **កសស** បានអនុម័តក្រមសីលធម៌សម្រាប់អភិបាល និងបុគ្គលិកជាន់ខ្ពស់ក្នុងគោលបំណងដូចខាងក្រោម៖

- លើកទឹកចិត្តឱ្យមានភាពស្មោះត្រង់ និងឥរិយាបថប្រកបដោយសីលធម៌ក្នុងការធ្វើអាជីវកម្ម ដើម្បីធានាឱ្យបាននូវសមភាព និងជៀសវាងអំពីទំនាស់ផលប្រយោជន៍ ។
- លើកទឹកចិត្តក្នុងការផ្តល់ព័ត៌មានចាំបាច់នានាដែលតម្រូវដោយច្បាប់ និងបទប្បញ្ញត្តិជាធរមានឱ្យបានពេញលេញ ច្បាស់លាស់ ត្រូវត្រឹម និងទាន់ពេល ។
- លើកទឹកចិត្តដល់ការអនុវត្តន៍ច្បាប់ និងបទប្បញ្ញត្តិជាធរមាន ។
- ធានាការពារផលប្រយោជន៍អាជីវកម្មស្របច្បាប់របស់ក្រុមហ៊ុន រួមបញ្ចូលទាំងកាលានុវត្តភាពអាជីវកម្ម ទ្រព្យសកម្ម និងទ្រព្យអរូបិយ និងព័ត៌មានសម្ងាត់របស់ក្រុមហ៊ុន ។
- បញ្ចៀសនូវអាកប្បកិរិយាមិនត្រឹមត្រូវ ឬទង្វើឆ្នាំឆ្លងទាំងឡាយ ។

អាជីវកម្មរបស់ **កសស** ត្រូវស្ថិតក្រោមការគ្រប់គ្រង និងដឹកនាំទូទៅដោយក្រុមប្រឹក្សាភិបាល ។ អភិបាល និងបុគ្គលិកជាន់ខ្ពស់មានការទទួលខុសត្រូវជាចម្បង ក្នុងការសម្រេចចិត្តអាជីវកម្មដែលខ្លួនជឿជាក់ថាផ្តល់ប្រយោគន៍ល្អដល់ **កសស** និងសម្រាប់ភាគហ៊ុនិកទាំងអស់របស់ **កសស** ។

អភិបាល និងបុគ្គលិកជាន់ខ្ពស់ទាំងអស់ត្រូវយល់ច្បាស់ពីក្រមសីលធម៌ ហើយត្រូវប្រកាន់ខ្ជាប់នូវគោលការណ៍ និងវិធានដែលមានចែងនៅក្នុងក្រមសីលធម៌នេះ ។

### ប្រការ ២. និយមន័យ

នៅក្នុងបរិបថនៃក្រមសីលធម៌ ពាក្យខាងក្រោមត្រូវបានឱ្យនិយមន័យដូចតទៅ៖

- **ច្បាប់ និងបទប្បញ្ញត្តិជាធរមាន ៖** សំដៅដល់រាល់ច្បាប់ និងបទប្បញ្ញត្តិ នៃព្រះរាជាណាចក្រកម្ពុជា រួមមានជាអាទិ៍ ច្បាប់ អនុក្រឹត្យ ប្រកាស វិធាន និងគោលការណ៍ណែនាំរបស់អាជ្ញាធរមានសមត្ថកិច្ចដូចជា **គ.ម.ក** និងក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ហៅកាត់ថា **ផ.ម.ក** ដែលច្បាប់ និងបទប្បញ្ញត្តិ ទាំងនោះត្រូវអនុវត្តន៍ ទៅលើ **កសស** អភិបាល និងបុគ្គលិកជាន់ខ្ពស់របស់ **កសស** ។
- **អភិបាល ៖** សំដៅដល់សមាជិកក្រុមប្រឹក្សាភិបាលរបស់ **កសស** រួមបញ្ចូលទាំងអភិបាលប្រតិបត្តិ អភិបាលមិនប្រតិបត្តិ និងអភិបាលឯករាជ្យ ។
- **បុគ្គលិកជាន់ខ្ពស់ ៖** សំដៅដល់បុគ្គលទាំងឡាយណាដែលមានមុខតំណែងចាប់ពីប្រធាននាយក រហូតដល់អគ្គនាយក រួមទាំងប្រធានលេខាធិការ និងអ្នកដែលមានមុខតំណែងសំខាន់ៗផ្សេងទៀតក្នុង **កសស** ដែលកំណត់ដោយក្រុមប្រឹក្សាភិបាល **កសស** ។

## ប្រការ ៣. ការអនុវត្តច្បាប់ និងបទប្បញ្ញត្តិ

ក្នុងពេលបំពេញតួនាទី និងការទទួលខុសត្រូវរបស់ខ្លួនអភិបាល និងបុគ្គលិកជាន់ខ្ពស់ទាំងអស់ត្រូវអនុវត្ត និងព្យាយាមធ្វើឱ្យ **កសស** អនុវត្តតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន ។ ប្រសិនបើអភិបាល ឬបុគ្គលិកជាន់ខ្ពស់ណាមួយបានដឹងពីព័ត៌មានដែលខ្លួនជឿជាក់ថា អភិបាល ឬបុគ្គលិកជាន់ខ្ពស់ ឬនិយោជិតណាមួយបានបំពានច្បាប់ និងបទប្បញ្ញត្តិជាធរមាន អភិបាល ឬបុគ្គលិកជាន់ខ្ពស់ដែលបានដឹងត្រូវផ្តល់ព័ត៌មានជូនប្រធានក្រុមប្រឹក្សាភិបាល អគ្គនាយក ប្រធានគណៈកម្មាធិការសវនកម្ម ឬសវនកម្មផ្ទៃក្នុង ។

## ប្រការ ៤. អំពីទំនាស់ផលប្រយោជន៍

បន្ថែមលើបទប្បបញ្ញត្តិទាំងឡាយនៃមាត្រា ១៣៤ ១៤៥ ១៣៦ និងមាត្រា ១៣៨ នៃច្បាប់ស្តីពី សហគ្រាសពាណិជ្ជកម្ម អភិបាល និងបុគ្គលិកជាន់ខ្ពស់ត្រូវជៀសវាងនូវរាល់អំពើទំនាស់ផលប្រយោជន៍ដែល អាចកើតមានជាមួយ **កសស** ។

ជាទូទៅ ទំនាស់ផលប្រយោជន៍កើតឡើងនៅពេលដែលផលប្រយោជន៍ផ្ទាល់ខ្លួនរបស់ អភិបាល ឬបុគ្គលិកជាន់ខ្ពស់ ឬអាចនឹងជះឥទ្ធិពលធ្ងន់ធ្ងរដល់ ៖

**ក.** ផលប្រយោជន៍ទូទៅ ឬអាជីវកម្មរបស់ **កសស** ។

**ខ.** លទ្ធភាពរបស់អភិបាល ឬបុគ្គលិកជាន់ខ្ពស់ផ្សេងទៀតក្នុងការអនុវត្តតួនាទី និងការទទួលខុសត្រូវរបស់ខ្លួន ។

អភិបាល និងបុគ្គលិកជាន់ខ្ពស់ត្រូវផ្តល់ព័ត៌មានទៅក្រុមប្រឹក្សាភិបាលរបស់ **កសស** ហើយត្រូវធ្វើសេចក្តីប្រកាសជាសាធារណៈពីប្រតិបត្តិការ ឬទំនាក់ទំនងណាមួយដែលខ្លួនគិតថានឹងនាំឱ្យកើតមានទំនាស់ផលប្រយោជន៍ជាមួយ **កសស** តាមការកំណត់របស់ **គ.ម.ក** ឬ **ផ.ម.ក** ។

អភិបាល ឬបុគ្គលិកជាន់ខ្ពស់របស់ **កសស** ត្រូវបង្ហាញនូវផលប្រយោជន៍របស់ខ្លួនជាលាយលក្ខណ៍អក្សរទៅ **កសស** ស្នើរឱ្យមានសេចក្តីប្រកាសដែលបានដាក់ចូលទៅក្នុងកំណត់ហេតុនៃកិច្ចប្រជុំក្រុមប្រឹក្សា ភិបាលក្នុងករណីដែល ៖

**ក.** អភិបាល ឬបុគ្គលិកជាន់ខ្ពស់នោះជាភាគីនៃកិច្ចសន្យា ឬជាអ្នកស្នើធ្វើជាមួយនឹង **កសស**

**ខ.** អភិបាល ឬបុគ្គលិកជាន់ខ្ពស់នោះមានផលប្រយោជន៍សំខាន់ជាមួយនឹងបុគ្គល ឬនីតិបុគ្គលដែលជាភាគីក្នុងកិច្ចសន្យា ឬភាគីដែលស្នើធ្វើកិច្ចសន្យាជាមួយ **កសស** ដោយយោងតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន រួមទាំងប្រកាសស្តីពីអភិបាលកិច្ចសាជីវកម្មសម្រាប់សហគ្រាសសាធារណៈបោះផ្សាយលក់មូលបត្រជាសាធារណៈអភិបាលឯករាជមិនត្រូវមានផលប្រយោជន៍ណាមួយនៅក្នុង **កសស** ដែលធ្វើឱ្យប៉ះពាល់ឯករាជរបស់ខ្លួន និងមិនត្រូវកាន់កាប់ភាគហ៊ុនលើសពី ១% (មួយភាគរយ) នៃភាគហ៊ុនរបស់ **កសស** ឡើយ ។

## ប្រការ ៥. កាលានុវត្តភាពអាជីវកម្ម

នៅក្នុងការអនុវត្តតួនាទី និងការទទួលខុសត្រូវរបស់ខ្លួន អភិបាល និងបុគ្គលិកជាន់ខ្ពស់ត្រូវយកចិត្តទុកដាក់ជាអទិភាពដល់ផលប្រយោជន៍ស្របច្បាប់របស់ **កសស** នៅពេលសមស្រប ។

អភិបាល និងបុគ្គលិកជាន់ខ្ពស់ត្រូវជៀសវាង ៖

**ក.** ឆ្លៀតឱកាសធ្វើកិច្ចការដើម្បីផលប្រយោគន៍ផ្ទាល់ខ្លួនដែលខ្លួនបានដឹងក្នុងពេលអនុវត្តតួនាទី និងការទទួលខុសត្រូវរបស់ខ្លួននៅក្នុង **កសស** ។

**ខ.** ប្រើប្រាស់ទ្រព្យសម្បត្តិ ឬព័ត៌មានរបស់ **កសស** ឬឋានៈ និងមុខតំណែងរបស់ខ្លួនដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួន ។

**គ.** ប្រកួតប្រជែងជាមួយ **កសស** ។

ក្រុមប្រឹក្សាភិបាល និងកំណត់ពីទង្វើដែលផ្ទុយពីខ្លឹមសារនៃប្រការនេះដោយពិចារណាលើអង្គហេតុ និងស្ថានការណ៍ដែលពាក់ព័ន្ធទាំងឡាយនៃទង្វើនោះ ។

## ប្រការ ៦. ទំនាក់ទំនងដោយស្មើភាព

នៅក្នុងការបំពេញតួនាទី និងការទទួលខុសត្រូវរបស់ខ្លួន អភិបាល និងបុគ្គលិកជាន់ខ្ពស់ត្រូវធ្វើឱ្យមានភាពស្មើគ្នាក្នុងការទំនាក់ទំនងរវាងគ្នា និងជាមួយអតិថិជន អ្នកផ្គត់ផ្គង់ គូប្រជែង អ្នកម៉ៅការ និងនិយោជិតរបស់ **កសស** ។

អភិបាល និងបុគ្គលិកជាន់ខ្ពស់មិនត្រូវទាញយកប្រយោជន៍ពីបុគ្គលណាម្នាក់ដោយមិនស្មោះត្រង់ ដោយប្រើប្រាស់ឧបាយកល ការលាក់បាំង ការបំភ័ន្ត ព័ត៌មានសំខាន់ៗ ការបង្ហាញហេតុការណ៍ដែលខុសពី ការពិត ឬដោយអំពើមិនស្មោះត្រង់ផ្សេងទៀតក្នុងអាជីវកម្ម ។

ការប្រើប្រាស់សិទ្ធអំពីព័ត៌មានសម្ងាត់នៃអាជីវកម្មរបស់ **កសស** ឬការបញ្ចុះបញ្ចូលអភិបាល បុគ្គលិកជាន់ខ្ពស់ និងនិយោជិតរបស់ **កសស** ទាំងអតិត និងបច្ចុប្បន្នឱ្យទម្លាយនូវព័ត៌មានទាំងនោះត្រូវបាន ហាមឃាត់ជាដាច់ខាត ។

អភិបាល និងបុគ្គលិកជាន់ខ្ពស់ត្រូវអនុវត្តតួនាទី និងការទទួលខុសត្រូវរបស់ខ្លួនដោយសុច្ចរិត និងដើម្បីផលប្រយោជន៍របស់ **កសស** និងភាគហ៊ុនិកទាំងអស់របស់ **កសស** ។ អភិបាល និងបុគ្គលិកជាន់ខ្ពស់ មិនត្រូវទាញយកផលប្រយោជន៍ពីមុខតំណែងរបស់ខ្លួនជាអភិបាល ឬជាបុគ្គលិកជាន់ខ្ពស់ និងមិនត្រូវទទួលអំណោយណាមួយពីតតិយជនដោយសារមុខតំណែងជាអភិបាល ឬបុគ្គលិកជាន់ខ្ពស់ ។

## ប្រការ ៧. ការការពារ និងការប្រើប្រាស់ទ្រព្យសម្បត្តិរបស់ កសស

នៅក្នុងការអនុវត្តតួនាទី និងការទទួលខុសត្រូវរបស់ខ្លួន អភិបាល និងបុគ្គលិកជាន់ខ្ពស់ត្រូវជំរុញឱ្យមានការត្រួតពិនិត្យ និងការប្រើប្រាស់ឱ្យបានត្រឹមត្រូវដោយមានការទទួលខុសត្រូវនូវទ្រព្យសម្បត្តិរបស់ **កសស** រួមទាំងទ្រព្យរូបិយ និងទ្រព្យអរូបិយ ។

ទ្រព្យសម្បត្តិរបស់ **កសស** មានដូចជា ព័ត៌មាន សម្ភារៈ គ្រឿងបរិក្ខារ កម្មសិទ្ធបញ្ញា ឧបករណ៍ ប្រភពធនធាន ប្រព័ន្ធព័ត៌មានវិទ្យា និងទ្រព្យដទៃទៀតដែលជាកម្មសិទ្ធរបស់ **កសស** ឬទ្រព្យដែល **កសស** ជួលពីគេ ឬទ្រព្យដែលស្ថិតក្រោមការកាន់កាប់របស់ **កសស** ត្រូវបានប្រើប្រាស់សម្រាប់តែគោលដៅអាជីវកម្ម ស្របច្បាប់របស់ **កសស** តែប៉ុណ្ណោះ ។

## ប្រការ ៨. បណ្តឹងពាក់ព័ន្ធនឹងគណនេយ្យ

គណៈកម្មាធិការសវនកម្ម (ប្រសិនបើមាន) ឬសវនករផ្ទៃក្នុងរបស់ **កសស** ត្រូវទទួលខុសត្រូវក្នុងការការរៀបចំនីតិវិធីសមស្របមួយសម្រាប់ទទួលពាក្យបណ្តឹង និងរក្សាទុកនូវពាក្យបណ្តឹង និងពិនិត្យមើលពាក្យ

បណ្ដឹងទាក់ទងនឹងគណនេយ្យ ការត្រួតពិនិត្យគណនេយ្យផ្ទៃក្នុង ឬបញ្ហាផ្សេងៗទៀតដែលទាក់ទងទៅនឹងសវនកម្ម ។

អភិបាល ឬបុគ្គលិកជាន់ខ្ពស់អាចដាក់ពាក្យបណ្ដឹងពីបញ្ហាខាងលើ ទៅគណៈកម្មាធិការសវនកម្ម ឬសវនករផ្ទៃក្នុងរបស់ **កសស** ។ ការស្នើសុំឱ្យពិនិត្យបណ្ដឹងជាសម្ងាត់អាចធ្វើឡើងតាមច្បាប់ និងបទប្បញ្ញត្តិ ជាធរមាន ។

## ប្រការ ៩. ការលើកទឹកចិត្តឱ្យរាយការណ៍ពីទង្វើខុសច្បាប់ ឬអសីលធម៌

អភិបាល និងបុគ្គលិកជាន់ខ្ពស់ត្រូវខិតខំជម្រុញឱ្យ **កសស** ប្រកាន់ខ្ជាប់នូវក្រមសីលធម៌ទៅនាយក ឬបុគ្គលដែលមានសមត្ថកិច្ចនៅក្នុង **កសស** នៅពេលដែលទង្វើខុសច្បាប់ ឬអសីលធម៌ណាមួយអាចនឹងធ្វើឱ្យប៉ះពាល់ជាអវិជ្ជមានធ្ងន់ធ្ងរដល់អាជីវកម្ម និងកេរ្តិ៍ឈ្មោះរបស់ **កសស** ឬវាអាចនឹងនាំឱ្យមានការទទួលខុសត្រូវធ្ងន់ធ្ងរតាមផ្លូវច្បាប់ ។

## ប្រការ ១០. ការជួញដូរផ្ទៃក្នុង

អភិបាល និងបុគ្គលិកជាន់ខ្ពស់ត្រូវអនុវត្ត និងប្រកាន់ឱ្យបានខ្ជាប់ខ្ជួននូវច្បាប់ និងបទប្បញ្ញត្តិជាធរមាន បទបញ្ជាផ្ទៃក្នុង និងគោលនយោបាយ **កសស** ពាក់ព័ន្ធនឹងការលក់-ទិញភាគហ៊ុនរបស់ **កសស** ។

## ប្រការ ១១. ការរក្សាការសម្ងាត់

អភិបាល និងបុគ្គលិកជាន់ខ្ពស់ត្រូវរក្សាការសម្ងាត់នៃព័ត៌មានសម្ងាត់របស់ **កសស** ដែលខ្លួនបានដឹង លើកលែងតែក្នុងករណីដែល **កសស** អនុញ្ញាតឱ្យផ្ដល់ព័ត៌មាន ឬការផ្ដល់ព័ត៌មាននេះត្រូវបានតម្រូវដោយច្បាប់ និងបទប្បញ្ញត្តិជាធរមាន ឬមានការតម្រូវពីអាជ្ញាធរមានសមត្ថកិច្ច ឬតុលាការនៃព្រះរាជាណាចក្រកម្ពុជា ។

ពាក្យថា "ព័ត៌មានសម្ងាត់" រួមមានជាអាទិ៍ ព័ត៌មានមិនមែនសាធារណៈដែលអាចត្រូវបានប្រើដោយគូប្រកួតប្រជែងរបស់ **កសស** ឬព័ត៌មានមិនមែនសាធារណៈដែលធ្វើឱ្យប៉ះពាល់ដល់ **កសស** ឬអតិថិជនរបស់ **កសស** ប្រសិនបើព័ត៌មាននោះត្រូវបានបង្ហាញ ។

អភិបាល ឬបុគ្គលិកជាន់ខ្ពស់ត្រូវពិភាក្សាជាមុនជាមួយនឹងអគ្គនាយក ឬប្រធានក្រុមប្រឹក្សាភិបាលប្រសិនបើអភិបាល ឬបុគ្គលិកជាន់ខ្ពស់នោះគិតថាខ្លួនមានកាតព្វកិច្ចតាមច្បាប់ក្នុងការបង្ហាញព័ត៌មានសម្ងាត់នោះ ។

## ប្រការ ១២. ការផ្ដល់ព័ត៌មាន

អភិបាល និងបុគ្គលិកជាន់តម្រូវឱ្យយល់ច្បាស់ពីនីតិវិធី និងការត្រួតពិនិត្យការផ្ដល់ព័ត៌មានរបស់ **កសស** ដើម្បីឱ្យចេញសេចក្ដីប្រកាសជាសាធារណៈ របាយការណ៍ និងឯកសារផ្ដល់ព័ត៌មានដែលត្រូវចុះបញ្ជីជាមួយអាជ្ញាធររដ្ឋរួមបញ្ចូលទាំង **គ.ម.ក** អាចរៀបចំធ្វើឡើងដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមានរួមទាំងគោលការណ៍ណែនាំរបស់ **គ.ម.ក** និង **ផ.ម.ក** ។

ម៉្យាងវិញទៀតក្នុងទំហំនៃតួនាទី និងការទទួលខុសត្រូវរបស់អភិបាល និងបុគ្គលិកជាន់ខ្ពស់ដែលមានអំណាចដឹកនាំ ឬគ្រប់គ្រងការចុះបញ្ជីឯកសារជាមួយ **គ.ម.ក** និង / ឬ **ផ.ម.ក** ឬការជូនដំណឹងជាសាធារណៈផ្សេងៗទៀតរបស់ **កសស** ពាក់ព័ន្ធអាជីវកម្មទូទៅ លទ្ធផល លក្ខខណ្ឌ និងលទ្ធភាពហិរញ្ញវត្ថុត្រូវពិភាក្សាជាមួយនឹងអភិបាល បុគ្គលិកជាន់ខ្ពស់ផ្សេងទៀត និងជាមួយនិយោជិតពាក់ព័ន្ធហើយចាត់វិធានការសមស្រប

សម្រាប់នីតិវិធី និងការត្រួតពិនិត្យការផ្តល់ព័ត៌មានដើម្បីឱ្យការផ្តល់ព័ត៌មានធ្វើបានពេញលេញ ច្បាស់លាស់ ត្រឹមត្រូវទាន់ពេល និងអាចយល់បាន ។

ក្នុងទំហំដែលពាក់ព័ន្ធទៅនឹងនីតិវិធី និងការត្រួតពិនិត្យ ការផ្តល់ព័ត៌មានរបស់ **កសស** អភិបាល និង បុគ្គលិកជាន់ខ្ពស់ម្នាក់ៗ ៖

- ត្រូវយល់ច្បាស់អំពីលក្ខខណ្ឌតម្រូវនៃការផ្តល់ ព័ត៌មានរបស់ **កសស** ក៏ដូចជាប្រតិបត្តិការអាជីវកម្ម និងហិរញ្ញវត្ថុរបស់ **កសស** ។
- មិនត្រូវធ្វើសេចក្តីថ្លែងខុសពីការពិត ឬធ្វើឱ្យអ្នកដទៃថ្លែងខុសពីការពិតទាក់ទងអំពីព័ត៌មានរបស់ **កសស** ប្រាប់អ្នកដទៃ ទោះបីជាអ្នកនោះនៅក្នុង ឬក្រៅ **កសស** រួមទាំងសវនករឯករាជ្យ និយ័តករ របស់រាជរដ្ឋាភិបាល និងស្ថាប័នផ្សេងទៀត ។

## ប្រការ ១៣. វិសោធនកម្ម និងការលើកលែង

ក្រុមសីលធម៌នេះអាចត្រូវបានធ្វើវិសោធនកម្ម ឬលើកលែងមិនអនុវត្តដោយក្រុមប្រឹក្សាភិបាលរបស់ **កសស** ដោយគោរពតាមលក្ខខណ្ឌតម្រូវក្នុងការផ្តល់ព័ត៌មាន ច្បាប់ និងបទប្បញ្ញត្តិជាធរមាន។ ជាវិធានទូទៅ ក្រុមប្រឹក្សាភិបាលនឹងមិនផ្តល់ការលើកលែងមិនអនុវត្តប្រការណាមួយនៃក្រុមសីលធម៌នេះឡើយ ប្រសិនបើ គ្មានមូលហេតុសមស្រប និងចាំបាច់នោះទេ ។

អភិបាល និងបុគ្គលិកជាន់ខ្ពស់ត្រូវអនុវត្តឱ្យបានខ្ជាប់ខ្ជួនតាមស្មារតី និងខ្លឹមសារនៃក្រុមសីលធម៌នេះ។ អភិបាល និងបុគ្គលិកជាន់ខ្ពស់មានកាតព្វកិច្ចយល់ដឹងពីក្រុមសីលធម៌ និងស្វែងរកការពន្យល់ និងការផ្តល់ប្រឹក្សាបន្ថែមទាក់ទងនឹងការបកស្រាយខ្លឹមសារបន្ថែម និងលក្ខខណ្ឌតម្រូវនៃក្រុមសីលធម៌ជាពិសេសនៅពេល មានហេតុការណ៍ណាមួយដែលអាចមានទំទាស់ជាមួយនឹងក្រុមសីលធម៌ ។

ក្រុមប្រឹក្សាត្រូវចាត់វិធានការសមស្រប ក្នុងករណីដែលមានការបំពានក្រុមសីលធម៌នេះ ។

អភិបាល និងបុគ្គលិកជាន់ខ្ពស់អាចសាកសួរដោយផ្ទាល់ទៅអគ្គនាយកទាក់ទងនិងការអនុវត្ត ឬការ បកស្រាយក្រុមសីលធម៌នេះ ។

### ខ-ការអនុវត្តក្រុមសីលធម៌

ក្រុមសីលធម៌នេះត្រូវបានអនុម័តដោយក្រុមប្រឹក្សាភិបាលរបស់ **កសស** នៅថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១៧ និងមានអានុភាពអនុវត្តចាប់ពី **កសស** ទទួលបានការយល់ព្រមឱ្យធ្វើការបោះផ្សាយលក់មូលបត្រ កម្ម សិទ្ធជាសាធារណៈដោយ **គ.ម.ក** និងត្រូវបានចុះបញ្ជីលក់មូលបត្រនៅ **ផ.ម.ក** ។

# ផ្នែកទី ៤

## ព័ត៌មានអំពីការជួញដូរមូលបត្ររបស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ

## ១-ព័ត៌មានអំពីមូលបត្រកម្មសិទ្ធិ

ឈ្មោះមូលបត្រកម្មសិទ្ធិ: **មូលបត្រកម្មសិទ្ធិមានសិទ្ធិបោះឆ្នោតប្រភេទ “គ”**

អក្សរកូដមូលបត្រកម្មសិទ្ធិ: **KH1000060009**

ចំណាត់ថ្នាក់នៃមូលបត្រកម្មសិទ្ធិ: **មូលបត្រកម្មសិទ្ធិមានសិទ្ធិបោះឆ្នោតប្រភេទ “គ”**

តម្លៃចារឹកក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ: **១.០០០ រៀល**

ថ្លៃលក់ក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ: **៥.០៤០ រៀល (១,២៥៩ ដុល្លារអាមេរិក)**

បរិមាណមូលបត្រកម្មសិទ្ធិសរុបទាំងអស់ដែលកំពុងធ្វើចរាចរលើទីផ្សារ: **២១.៤៤២.៩៩២ មូលបត្រ**

មូលធនូបនីយកម្មទីផ្សារ: **១០៨.០៧២.៦៧៩.៦៨០ រៀល (២៦.៩៩១.១៧៩ ដុល្លារអាមេរិក)**

ឈ្មោះទីផ្សារមូលបត្រប្រតិស្រុត: **ផ្សារមូលបត្រកម្ពុជា**

កាលបរិច្ឆេទនៃការចុះបញ្ជីលក់មូលបត្រ: **ថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០១៧**

## ២-ថ្លៃ និងបរិមាណជួញដូរ

| មូលបត្រកម្មសិទ្ធិ | | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|
| ថ្លៃជួញដូរ (រៀល) | អតិបរមា | ៥.១២០ | ៥.០៨០ | ៥.០៦០ | ៥.០៤០ | ៥.០៤០ | ៥.០០០ | ៥.១០០ |
| | អប្បបរមា | ៥.០៤០ | ៥.០២០ | ៥.០២០ | ៥.០០០ | ៥.០០០ | ៤.៩០០ | ៤.៦២០ |
| | មធ្យម | ៥.០៨០ | ៥.០៤០ | ៥.០៥០ | ៥.០៣០ | ៥.០៣០ | ៤.៩៤០ | ៤.៨៧០ |
| បរិមាណជួញដូរ (ភាគហ៊ុន) | អតិបរមា | ១៣.៧៩៨ | ២១.៩៨៤ | ១០.៨៤៨ | ១០.០០០ | ៨.០៧៧ | ៨.១០៤ | ២.៣០០ |
| | អប្បបរមា | ០ | ០ | ០ | ០ | ០ | ០ | ០ |
| | មធ្យម | ២.៣៧៣ | ១.៤០២ | ៨៩២ | ១.៤២៤ | ៦២៣ | ៨៩៦ | ៣២៩ |

# ផ្នែកទី ៥

## របាយការណ៍សវនកម្មរបស់សវនករផ្ទៃក្នុង
## លើការត្រួតពិនិត្យផ្ទៃក្នុង

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**កំពង់ផែស្វយ័តក្រុងព្រះសីហនុ**
**នាយកដ្ឋានសវនកម្មផ្ទៃក្នុង**
លេខ.០០៥..សផក -កសស

**របាយការណ៍សវនកម្ម**
**ស្តីពីការអនុវត្ត ការត្រួតពិនិត្យផ្ទៃក្នុង**
**ប្រចាំឆ្នាំ ២០១៧**

## ផ្នែក ក: ខ្លឹមសារសង្ខេប

### ១. សាវតារ

ដំណើរការសវនកម្មផ្ទៃក្នុងនៅ នាយកដ្ឋានរដ្ឋបាល -ធនធានមនុស្ស នាយកដ្ឋានផែនការ -លទ្ធកម្មនិងស្ថិតិ និងនាយកដ្ឋានបច្ចេកទេសសម្ភារនិងសំណង់ សម្រាប់ការិយបរិច្ឆេទ ២០១៧ ដែលជាផ្នែកមួយនៃផែនការសវន កម្មប្រចាំឆ្នាំរបស់នាយកដ្ឋានសវនកម្មផ្ទៃក្នុង បានទទួលការយល់ព្រមពី **ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាប្រធានអគ្គនាយក កសស** ចុះថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ ២០១៧ ។ ការធ្វើសវនកម្មក្នុងការិយបរិច្ឆេទ ២០១៧ រួមមានលទ្ធផលការងារសវនកម្មស្តីពីការអនុវត្ត ការត្រួតពិនិត្យផ្ទៃក្នុងសម្រាប់ត្រីមាស ទី ៣ ឆ្នាំ ២០១៧ លេខ:០០៣.សផក.កសស ចុះថ្ងៃទី ២៩ ខែកញ្ញា ឆ្នាំ ២០១៧ និងត្រីមាសទី៤ លេខ ០០៤. សផក.កសស ចុះ ថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ ២០១៧ និងសំណូមពរក៏ដូចជាវិធានការ និងការឯកភាពរបស់ថ្នាក់គ្រប់គ្រងសវនដ្ឋាន ។

### ២. ហានិភ័យគន្លឹះ

ជាទូទៅហានិភ័យអាចរាប់បញ្ចូលនូវ៖

ហានិភ័យប្រតិបត្តិការ: ជាហានិភ័យលើការបាត់បង់ ដែលជាលទ្ធផលបរាជ័យនៃដំណើរការមនុស្ស និងប្រព័ន្ធ ឬ ពីហេតុការណ៍ខាងក្រៅ ។

ហានិភ័យអនុលោមភាព: ជាលទ្ធភាពដែលសកម្មភាពអនុវត្ត មិនអនុលោមតាមច្បាប់និងបទប្បញ្ញត្តិ។

ដោយឡែក ក្នុងកិច្ចដំណើរការសវនកម្ម នៅនាយកដ្ឋានសវនដ្ឋានខាងលើ សវនករបានកំណត់ហានិភ័យ គន្លឹះមួយចំនួនដូចខាងក្រោម:

#### ២.១ ការកំណត់ហានិភ័យគន្លឹះ

- ការអនុវត្តការងារស្របតាមនីតិវិធីរដ្ឋបាលសាធារណៈ បទដ្ឋានគតិយុត្តិ និងការិយបរិច្ឆេទដែលបានកំណត់ ។
- នីតិវិធីនៃការអនុវត្តការងារ លើផែនការប្រចាំឆ្នាំដែលបានគ្រោងទុក ។

## ៣. វិសាលភាពសវនកម្ម

សវនកម្មនេះ គ្របដណ្តប់លើសកម្មភាពគ្រប់គ្រង និងប្រតិបត្តិការដែលបានដំណើរការដោយនាយកដ្ឋានរដ្ឋបាល-ធនធានមនុស្ស នាយកដ្ឋានផែនការ-លទ្ធកម្មនិងស្ថិតិ និងនាយកដ្ឋានបច្ចេកទេសសម្ភារៈ និងសំណង់ សម្រាប់ការិយបរិច្ឆេទឆ្នាំ២០១៧ និងឆ្នាំពាក់ព័ន្ធ ។ ការប្រមូលព័ត៌មានសវនកម្ម និងការធ្វើតេស្តសវនកម្មត្រូវបានប្រព្រឹត្តទៅនៅនាយកដ្ឋានសវនកម្មផ្ទៃក្នុង **កសស** ។ ការធ្វើសវនកម្មនេះ ជៀសមិនផុតពីហានិភ័យសវនកម្មឡើយ ។ ក្រុមការងារសវនកម្មនឹងរាយការណ៍តែអំពីចំណុចខ្វះខាត និងចំណុចដែលត្រូវផ្តល់សំណូមពរកែលំអប៉ុណ្ណោះ ។

## ៤. គោលបំណងសវនកម្ម

គោលបំណងរួមនៃសវនកម្ម ផ្តោតសំខាន់លើការវាយតម្លៃ និងការធ្វើឱ្យល្អប្រសើរឡើងនូវប្រសិទ្ធភាពនៃដំណើរការគ្រប់គ្រងហានិភ័យ ដំណើរការត្រួតពិនិត្យនិងដំណើរការអភិបាលកិច្ច ក្នុងសវនដ្ឋានដែលស្ថិតក្នុងវិសាលភាពសវនកម្ម ។

ជាទូទៅការងារសវនកម្ម ផ្តោតសំខាន់លើប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុង ដើម្បីផ្តល់ការធានាសមស្របមួយសំដៅសម្រេចឱ្យបាននូវគោលបំណងដូចខាងក្រោមៈ

- **គោលបំណងប្រតិបត្តិការៈ** សម្រេចគោលបំណងធុរកិច្ចដោយប្រសិទ្ធភាព ។
- គោលបំណងអនុលោមភាពៈ ធានាអនុលោមភាពតាមផ្លូវច្បាប់ បទប្បញ្ញត្តិគោលការណ៍ នីតិវិធី និងបទដ្ឋាននានាជាធរមាន ។

ដោយឡែក នៅក្នុងកិច្ចដំណើរការសវនកម្មនេះ សវនករបានកំណត់គោលបំណងសំខាន់ៗមួយចំនួនដើម្បីគ្រប់គ្រងហានិភ័យរួមមានដូចខាងក្រោម៖

- ប្រសិទ្ធភាពនៃការគ្រប់គ្រងធនធានមនុស្សនៅក្នុងក្របខ័ណ្ឌ **កសស**
- ការសម្រេចតាមគោលបំណង និងគោលដៅប្រតិបត្តិការ
- ការធានាអនុលោមភាពតាមគោលនយោបាយផែនការនីតិវិធីច្បាប់បទប្បញ្ញត្តិ និងបទដ្ឋានផ្សេងៗ
- ការប្រើប្រាស់ធនធានប្រកបដោយលក្ខណៈសន្សំសំចៃ និងមានប្រសិទ្ធភាពខ្ពស់ ។

## ៥. អភិក្រមសវនកម្ម

អភិក្រមសវនកម្ម ផ្តោតសំខាន់លើដំណើរការមានហានិភ័យ ដែលត្រូវបានប្រើប្រាស់នៅក្នុងការងារសវនកម្មនេះ ។ អភិក្រមសវនកម្មរួមមាន៖

- កំណត់ត្រាប្រព័ន្ធគ្រប់គ្រង (កុងត្រូល) ផ្ទៃក្នុងតាមរយៈការត្រួតពិនិត្យឯកសារ និងការសម្ភាសន៍មន្ត្រីពាក់ព័ន្ធ
- ការកំណត់កុងត្រូលគន្លឹះ ដោយធ្វើការប្រៀបធៀបជាមួយកុងត្រូលដែលបានរំពឹងទុក
- ការធ្វើតេស្តសវនកម្មអំពីប្រសិទ្ធភាពប្រតិបត្តិការនៃកុងត្រូល ។

តាមរយៈការងារសវនកម្មនេះ ក្រុមការងារសវនកម្មផ្ទៃក្នុង បានសហការកំណត់ការរំពឹងទុករួមជាមួយ ថ្នាក់ដឹកនាំសវនដ្ឋាន ។

## ៦. សង្ខេបលទ្ធផលគន្លឹះ

ក្រុមការងារសវនកម្មផ្ទៃក្នុង បានកត់សម្គាល់ឃើញចំណុចខ្វះខាតមួយចំនួនដូចខាងក្រោម៖

- ការិយាល័យអប់រំសុខភាព **កសស**
- វគ្គបណ្តុះបណ្តាលស្តីពីបច្ចេកទេសបើកបរគ្រឿងចក្រ QC (ZPMC)
- ការពិនិត្យផែនការពលកម្ម ឆ្នាំ២០១៧
- ការពិនិត្យនីតិវិធីនៃការអនុវត្តកិច្ចលទ្ធកម្មរបស់ **កសស**
- តារាងវត្តមានការងារប្រចាំថ្ងៃរបស់ការិយាល័យសំណង់
- តារាងវត្តមានការងារប្រចាំថ្ងៃរបស់ផ្នែកយានដ្ឋាន
- ការត្រួតពិនិត្យលក្ខណៈបច្ចេកទេស និងការគ្រប់គ្រងម៉ាស៊ីនភ្លើង ។ល។

## ៧. សេចក្តីសន្និដ្ឋាន

ផ្អែកតាមលទ្ធផលសវនកម្មជាក់ស្តែង នៅនាយកដ្ឋានរដ្ឋបាល -ធនធានមនុស្ស នាយកដ្ឋានផែនការលទ្ធកម្មនិងស្ថិតិ និងនាយកដ្ឋានបច្ចេកទេសសម្ភារនិងសំណង់ សម្រាប់ការិយបរិច្ឆេទឆ្នាំ២០១៧ លើប្រព័ន្ធគ្រប់គ្រង និងយន្តការនៃដំណើរការក្នុងវិសាលភាព និងគោលបំណងខាងលើ ក្រុមការងារសវនកម្មផ្ទៃក្នុងអាចធ្វើការសន្និដ្ឋានបានថាសវនដ្ឋាននៅមានបញ្ហា/ចំណុចខ្វះខាតមួយចំនួនតូច លើផ្នែកអនុលោមភាពតាមច្បាប់ បទដ្ឋាននានានិង ប្រសិទ្ធភាពប្រតិបត្តិការ ។

## ៨. វិធានការកែលម្អ

សំណូមពរដែលបានផ្តល់ជូន ក្នុងគោលបំណងដើម្បីធ្វើឱ្យល្អប្រសើរឡើង នូវការអនុវត្តដំណើរការធុរកិច្ច និងការគ្រប់គ្រងផ្ទៃក្នុងរបស់សវនដ្ឋាន ត្រូវបានដាក់បញ្ចូលក្នុងលទ្ធផលលម្អិត (ផ្នែក ខ) ។ សំណូមពរនិងរបកគំហើញមួយចំនួន ត្រូវបានឯកភាពជាមួយថ្នាក់ដឹកនាំជាលាយលក្ខណ៍អក្សរ ។ លទ្ធផលលម្អិត (ផ្នែក ខ) ក៏បាន រំលេចអំពីការឆ្លើយតបរបស់ថ្នាក់ដឹកនាំសវនដ្ឋាន ចំពោះសំណូមពរសវនករនិងការរកឃើញផងដែរ ។

វិធានការរបស់ថ្នាក់ដឹកនាំ ត្រូវបានរំលេចនៅក្នុងផែនការកែលម្អ ដូចមានចែងនៅក្នុង ឧបសម្ព័ន្ធ ២ ដែលបានភ្ជាប់ជូនមកជាមួយនេះ ។ ផែនការសកម្មភាពកែលម្អត្រូវបានបញ្ចូលក្នុងសកម្មភាពដែលសវនដ្ឋានបានឯកភាពទទួលយក ដើម្បីអនុវត្តតាមសំណូមពរដែលត្រូវបានផ្តល់ជូន ។ សំណូមពរនីមួយៗត្រូវបានរៀបចំតាមចំណាត់ថ្នាក់ដើម្បីបង្ហាញអំពីកម្រិតហានិភ័យដល់ថ្នាក់ដឹកនាំ ប្រសិនបើសំណូមពរទាំងនោះមិនត្រូវបានអនុវត្ត ។

## ៩. ការថ្លែងអំណរគុណ

ការងារសវនកម្មត្រូវបានដឹកនាំដោយលោក **ម៉ែន ចាន់** ជាប្រធានត្រួតពិនិត្យនិងគ្រប់គ្រងរួមនិងជានាយកនាយកដ្ឋានសវនកម្មផ្ទៃក្នុង ព្រមទាំងសមាជិកក្រុមការងារក្នុងការធ្វើសវនកម្មនេះ ។

ក្រុមការងារសវនកម្ម ដែលដឹកនាំដោយលោកនាយកនាយកដ្ឋានសវនកម្មផ្ទៃក្នុង សូមថ្លែងអំណរគុណដល់មន្ត្រីពាក់ព័ន្ធទាំងអស់ ដែលបានរួមចំណែកក្នុងការងារសវនកម្មនេះ ជាពិសេសសូមថ្លែងអំណរគុណចំពោះលោក **រត្ន័ សិលា** នាយកនាយកដ្ឋានរដ្ឋបាល-ធនធានមនុស្ស លោក **សូ សៀង** នាយកនាយកដ្ឋានផែនការលទ្ធកម្ម និងស្ថិតិ និងលោក **ទី សាគុណ** នាយកនាយកដ្ឋានបច្ចេកទេសសម្ភារៈ និងសំណង់ ព្រមទាំងមន្ត្រី និងបុគ្គលិកដទៃទៀតដែលបានសហការផ្តល់ព័ត៌មាន និងមតិយោបល់ដ៏មានតម្លៃ ដើម្បីឱ្យកិច្ចដំណើរការសវនកម្មនេះអាចប្រព្រឹត្តទៅបានតាមការគ្រោងទុក ។

## ផ្នែក ខ: លទ្ធផលសវនកម្មលម្អិត

### ១. ធនធានសវនកម្ម និងគោលសំខាន់ៗ

#### ១.១ ក្រុមការងារសវនកម្ម

ក្នុងការងារសវនកម្មនេះ ក្រុមការងារសវនកម្ម រួមមានសមាសភាពដូចខាងក្រោម៖

- លោក ម៉ែន ចាន់ ប្រធានត្រួតពិនិត្យសវនកម្ម និងគ្រប់គ្រងរួម
- លោក ជីវ ច័ន្ទសុភាព សមាជិក
- លោក ហោ សុធី សមាជិក
- លោកស្រី ទូច វណ្ណា សមាជិក
- លោក ជីវ ច័ន្ទសុធា សមាជិក

#### ១.២ ខណៈគោលសំខាន់ៗ

ខាងក្រោមនេះគឺជាខណៈគោលសំខាន់ៗ នៅក្នុងដំណើរការសវនកម្ម៖

- ការធ្វើសវនកម្មបានបញ្ចប់ ថ្ងៃទី ១៥ ខែ មករា ឆ្នាំ២០១៨
- សេចក្តីព្រាងលើកទី ១ បានបញ្ចប់ ថ្ងៃទី ២២ ខែ មករា ឆ្នាំ២០១៨
- ការឆ្លើយតបចុងក្រោយពីថ្នាក់ដឹកនាំសវនដ្ឋាន ថ្ងៃទី ២៣ ខែ មីនា ឆ្នាំ២០១៨
- របាយការណ៍ស្ថាពរ ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ២០១៨

### ២. ទិដ្ឋភាពរួមសវនកម្មផ្ទៃក្នុង

គោលបំណងរួមនៃសវនកម្មផ្ទៃក្នុងគឺដើម្បីជួយថ្នាក់ដឹកនាំ ធ្វើឱ្យកាន់តែល្អប្រសើរឡើងនូវដំណើរការគ្រប់គ្រងហានិភ័យ ការត្រួតពិនិត្យផ្ទៃក្នុង និងអភិបាលកិច្ច ។ ការត្រួតពិនិត្យផ្ទៃក្នុងត្រូវបានអនុវត្តដោយថ្នាក់ដឹកនាំ និងមន្ត្រីដទៃទៀតដើម្បីធានាឱ្យសម្រេចបាននូវគោលបំណងដូចខាងក្រោម៖

- ប្រតិបត្តិការប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល
- អនុលោមភាពតាមច្បាប់ និងបទដ្ឋាននានា ។

របាយការណ៍នេះរួមមានការពិនិត្យលើប្រតិបត្តិការនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដោយសវនករនៃនាយកដ្ឋានសវនកម្មផ្ទៃក្នុង ដែលទទួលបានការឯកភាពពីថ្នាក់ដឹកនាំ និងបានរួមសហការជាមួយសវនដ្ឋាន។

### ៣. ទិដ្ឋភាពទូទៅ

កំពង់ផែស្វយ័តក្រុងព្រះសីហនុ "**កសស**" គឺជាកំពង់ផែអន្តរជាតិសមុទ្រទឹកជ្រៅតែមួយគត់នៃព្រះរាជាណាចក្រកម្ពុជា។ កំពង់ផែនេះត្រូវបានបង្កើតឡើងជាសហគ្រាសសាធារណៈដែលគ្រប់គ្រងដោយរដ្ឋមានឈ្មោះថា៖ កំពង់ផែស្វយ័តក្រុងព្រះសីហនុ សរសេរកាត់ "**កសស**" ស្ថិតក្រោមបទប្បញ្ញត្តិនៃអនុក្រឹត្យលេខ ៥០ អនក្រ.បក ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ១៩៩៨ ។ **កសស** គឺជាកំពង់ផែដែលមានជម្រៅទឹកជ្រៅជាងគេនៃព្រះរាជាណាចក្រកម្ពុជាដែលអាចផ្តល់សេវាកម្មលើកដាក់ ផ្ទេរ -ផ្ទុក ស្តុកទំនិញ នាំនាវាចូល -ចេញ និងសេវាកម្មសំខាន់ៗជាច្រើនផ្សេងទៀតជូនអតិថិជនបានយ៉ាងឆាប់រហ័ស។ ដោយមានកិច្ចខិតខំប្រឹងប្រែង និងការកំណត់ចក្ខុវិស័យច្បាស់លាស់របស់ថ្នាក់ដឹកនាំព្រមទាំងការចូលរួមចំណែកយ៉ាងសកម្មពីមន្ត្រីគ្រប់ជាន់ថ្នាក់ធ្វើអោយ **កសស** បាន

ចូលជាទីផ្សារមូលបត្រកម្មសិទ្ធិសាធារណៈលើកដំបូងមួយ ក្នុងចំណោមទីផ្សារមូលបត្រកម្មសិទ្ធិសារធារណៈលើកដំបូងទាំង ៥ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ក្រោមទិសដៅអភិវឌ្ឍរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រមុខរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ក្នុងកិច្ចសហប្រតិបត្តិការជាមួយរដ្ឋាភិបាលជប៉ុន និងដើម្បីឆ្លើយតបនឹងបរិមាណទំនិញឆ្លងកាត់ ដែលបន្តកើនឡើងជារៀងរាល់ឆ្នាំ កំពង់ផែស្វយ័តក្រុងព្រះសីហនុ "**កសស**" បានគ្រោងសាងសង់ចំណតផែកុងតឺន័រថ្មីមួយផ្សេងទៀតដែលមានប្រវែង ៣៥០ម ជម្រៅទឹក ១៤.៥០ម រួមទាំងការបំពាក់សម្ភារលើកដាក់ទំនិញធុនធ្ងន់នៅឆ្នាំ ២០២០ និងគ្រោងបញ្ចប់នៅឆ្នាំ ២០២៣ ។

**កសស** ត្រូវបានដឹកនាំដោយក្រុមប្រឹក្សាភិបាល ដែលមានសមាជិក ចំនួន ០៧ រូប អមដោយមន្ត្រីត្រួតពិនិត្យរដ្ឋ ០១ រូប ដោយមានមន្ត្រី និយោជិត កម្មករចំនួន ៨៩៣ នាក់ (គិតត្រឹមថ្ងៃទី ២៩/១២/២០១៧) ។ បច្ចុប្បន្ន **កសស** មានទីស្នាក់ការស្ថិតនៅ ភូមិ ៣ សង្កាត់ ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ។

ការងារត្រួតពិនិត្យផ្ទៃក្នុង គឺជាកត្តាចម្បងដែលមានសារៈសំខាន់បំផុតដើម្បីជម្រុញអោយ **កសស** អនុវត្តប្រតិបត្តិការអាជីវកម្មប្រចាំថ្ងៃរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព និងទទួលបានសេចក្តីទុកចិត្តពីអតិថិជន អ្នកប្រើប្រាស់ផែ ភាពទន់ភ្លន់នៃតម្លៃនឹងផ្តល់សេវាកម្មជូនអតិថិជនបានឆាប់រហ័ស និងសមស្របតាមតម្រូវការទីផ្សារប្រកបដោយគណនេយ្យភាព ។

## ៤. ការពិនិត្យលើការគ្រប់គ្រងផ្ទៃក្នុង

សវនករបានវាយតម្លៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដោយផ្អែកលើការពិនិត្យសមត្ថភាពនៃដំណើរការគ្រប់គ្រងនីមួយៗ ដើម្បីសម្រេចបាននូវគោលបំណងគ្រប់គ្រងចំនួនប្រាំពីររួមមាន: (១) ការផ្តល់សិទ្ធិ (២) ភាពពេញលេញ (៣) ភាពត្រឹមត្រូវ (៤) សុពលភាព (៥) សុវត្ថិភាពរូបវន្ត (៦) ការដោះស្រាយកំហុសឆ្គង និង (៧) ការបែងចែកតួនាទី ។

## ៥. ព័ត៌មានអំពីសវនដ្ឋាន

នាយកដ្ឋានរដ្ឋបាល-ធនធានមនុស្ស នាយកដ្ឋានផែនការ-លទ្ធកម្មនិងស្ថិតិ និងនាយកដ្ឋានបច្ចេកទេស-សម្ភារៈ និងសំណង់ ស្ថិតក្រោមការគ្រប់គ្រងរបស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ ដោយអនុលោមតាមអនុក្រឹត្យលេខ ៥០ អនក្រ.បក ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៩៨ ស្តីពីការបង្កើតកំពង់ផែស្វយ័តក្រុងព្រះសីហនុ និងដំណើរការតាមសេចក្តីកំណត់ស្តីពីរចនាសម្ព័ន្ធ និងភារកិច្ចសម្រាប់នាយកដ្ឋាននីមួយៗរបស់ **កសស** ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៦ ។

### ៥.១ រចនាសម្ព័ន្ធគ្រប់គ្រងរបស់នាយកដ្ឋានរដ្ឋបាល-ធនធានមនុស្ស

មានរចនាសម្ព័ន្ធគ្រប់គ្រងរួមមួយ ដោយចែកចេញជា ០៩ ការិយាល័យ៖

(១) ការិយាល័យរដ្ឋបាល

(២) ការិយាល័យព័ត៌មានវិទ្យា

(៣) ការិយាល័យធនធានមនុស្ស

(៤) ការិយាល័យគ្រប់គ្រងមធ្យោបាយ បង្ការ និងពន្លត់អគ្គិភ័យ

(៥) ការិយាល័យ ធានារ៉ាប់រងសង្គម

(៦) ការិយាល័យពិធីការ

(៧) ការិយាល័យរបៀប និងឯកសារ

(៨) ការិយាល័យថែទាំសុខភាព

(៩) ការិយាល័យបរិស្ថាននិងអនាម័យ និងមានបុគ្គលិកកម្មករសរុប ចំនួន ១៣៦ នាក់ ប្រុស ៩៦ នាក់ ស្រី ៤០ នាក់ ស្ថិតក្រោមការដឹកនាំដោយលោកនាយក ០១ រូប ។

### ៥.២ រចនាសម្ព័ន្ធគ្រប់គ្រងរបស់នាយកដ្ឋានផែនការ-លទ្ធកម្មនិងស្ថិតិ

មានរចនាសម្ព័ន្ធគ្រប់គ្រងរួមមួយដោយចែកចេញជា ០៤ ការិយាល័យ៖

(១) ការិយាល័យស្ថិតិ

(២) ការិយាល័យគ្រប់គ្រងគម្រោង

(៣) ការិយាល័យផែនការ-វិនិយោគ

(៤) ការិយាល័យលទ្ធកម្មសាធារណៈ

ក្នុងក្របខ័ណ្ឌនាយកដ្ឋានផែនការ-លទ្ធកម្ម និងស្ថិតិ មានមន្ត្រី បុគ្គលិកសរុបចំនួន ១១ នាក់ ប្រុស ០៨ នាក់ ស្រី ០៣ នាក់ ស្ថិតក្រោមការដឹកនាំដោយលោកនាយក ០១ រូប នាយករង ០១ រូប និងប្រធានការិយាល័យ ០២ រូប ។

### ៥.៣ រចនាសម្ព័ន្ធគ្រប់គ្រងរបស់នាយកដ្ឋានបច្ចេកទេសសម្ភារ និងសំណង់

មានរចនាសម្ព័ន្ធគ្រប់គ្រងរួមមួយដោយចែកជា ០៦ ការិយាល័យ៖

(១) ការិយាល័យសំណង់

(២) ការិយាល័យស្ថាបត្យកម្ម

(៣) ការិយាល័យវាស់ស្ទង់

(៤) ការិយាល័យសិក្សាគម្រោង

(៥) ការិយាល័យគ្រឿងចក្រសំណង់

(៦) ការិយាល័យសម្ភារគ្រឿងបន្លាស់

ក្នុងក្របខ័ណ្ឌនាយកដ្ឋានបច្ចេកទេស-សម្ភារ និងសំណង់ មានមន្ត្រី បុគ្គលិកសរុបចំនួន ១៨៨ នាក់ ប្រុស ១៨៦ នាក់ ស្រី ០២ នាក់ ស្ថិតក្រោមការដឹកនាំដោយលោកនាយក ០១ រូប នាយករង ០១ រូប និងប្រធានការិយាល័យ ០២ រូប ។

### ៥.៤ ការទទួលខុសត្រូវ

**ក. ការទទួលខុសត្រូវរបស់សវនដ្ឋាន**

នាយកដ្ឋានរដ្ឋបាល-ធនធានមនុស្ស នាយកដ្ឋានផែនការ-លទ្ធកម្មនិងស្ថិតិ និងនាយកដ្ឋាន បច្ចេកទេស-សម្ភារៈ និងសំណង់ ត្រូវទទួលខុសត្រូវចំពោះការគ្រប់គ្រងប្រព័ន្ធផ្ទៃក្នុងរបស់ខ្លួន ព្រមទាំងប្រសិទ្ធភាពប្រតិបត្តិការ និងអនុលោមភាពនៅក្នុងនាយកដ្ឋាន ក៏ដូចជាក្នុងក្របខ័ណ្ឌរួមរបស់ **កសស** ។

**ខ. ការទទួលខុសត្រូវរបស់ក្រុមការងារសវនកម្មផ្ទៃក្នុង**

ក្រុមការងារសវនកម្មផ្ទៃក្នុងទទួលខុសត្រូវ តែលើរបាយការណ៍សវនកម្មនេះប៉ុណ្ណោះ ។

## ៦. លទ្ធផលសវនកម្ម

### ៦.១ ផ្នែកប្រសិទ្ធភាពប្រតិបត្តិការ

### ៦.១.១ នាយកដ្ឋានរដ្ឋបាល-ធនធានមនុស្ស

គោលបំណងនៃការត្រួតពិនិត្យនេះ គឺដើម្បីអះអាងអំពីប្រសិទ្ធភាពប្រតិបត្តិការ ពាក់ព័ន្ធនឹងការរៀបចំរបាយការណ៍ សំណុំបែបបទឯកសារ និងសេចក្ដីកំណត់ស្ដីពីរចនាសម្ព័ន្ធនិងភារកិច្ចសម្រាប់បណ្ដានាយកដ្ឋាននៃ **កសស** ឱ្យបានសមស្របតាមតម្រូវការរបស់អង្គភាព នីតិវិធីរដ្ឋបាលសាធារណៈ និងលក្ខន្តិកៈ បុគ្គលិក **កសស** ព្រមទាំងច្បាប់ និងបទប្បញ្ញត្តិនានាជាធរមាន ។

សវនករពិនិត្យឃើញថា នាយកដ្ឋានរដ្ឋបាល-ធនធានមនុស្ស បានយកចិត្តទុកដាក់ខ្ពស់និងខិតខំប្រឹងប្រែងអនុវត្តការងារដោយឈរលើមូលដ្ឋានច្បាប់ និងបទប្បញ្ញត្តិនានាជាធរមាន ។

**ក. ការិយាល័យអប់រំសុខភាព កសស**

- ការិយាល័យអប់រំសុខភាព គួរធ្វើរបាយការណ៍អំពីស្ថានភាពអ្នកជម្ងឺ ដែលមានលក្ខណៈធ្ងន់ធ្ងរ ឬ ដែលត្រូវបញ្ជូនបន្តទៅព្យាបាលនៅមន្ទីរពេទ្យបង្អែកខេត្តព្រះសីហនុ ក៏ដូចជាមន្ទីរពេទ្យ នៅរាជធានីភ្នំពេញ ឬ ប្រទេសជិតខាងជាទៀងទាត់ ក្នុងករណីមានអ្នកជម្ងឺប្រភេទនេះ ។
- យោងរបាយការណ៍អ្នកជម្ងឺដែលចូលមកពិនិត្យ ផ្នែកជម្ងឺក្រៅទូទៅក្នុងត្រីមាសទី ៣ ឆ្នាំ ២០១៧ សវនករសង្កេតឃើញមានអ្នកជម្ងឺផ្លូវដង្ហើម ជាច្រើនករណីកំពុងកើនឡើងពីមួយខែទៅមួយខែដោយពុំមានការថយចុះ ហេតុដូច្នេះការិយាល័យអប់រំសុខភាពគួរធ្វើរបាយការណ៍អំពីស្ថានភាពជម្ងឺរបស់ពួកគាត់ ដោយផ្ដល់ការណែនាំលំអិតអំពីការការពារ និងថែទាំសុខភាព ដើម្បីជៀសវាងការចម្លងមេរោគ ឬ គ្រោះថ្នាក់ក្នុងស្ថានភាពធ្ងន់ធ្ងរ ឬ មិនអាចព្យាបាលបាន ។
- ក្នុងរបាយការណ៍ ស្ដីពីការចំណាយឱសថប្រចាំខែ ការិយាល័យអប់រំសុខភាពគួរបន្ថែមជួរបញ្ឈរពីរជួរទៀត ដើម្បីដាក់ឈ្មោះប្រទេសផលិត និងរយៈពេលផុតសុពលភាពប្រើប្រាស់នៃឱសថគ្រប់ប្រភេទ ដែលបានបញ្ជាទិញមកប្រើប្រាស់ក្នុងក្របខ័ណ្ឌ **កសស** ។

**ខ. វគ្គបណ្ដុះបណ្ដាលស្ដីពីក្រមសន្តិសុខនាវាអន្តរជាតិ និងបបនីយកណ្ឌផែ** (ISPS Code)

- សវនករយល់ឃើញថា បន្ទាប់ពីវគ្គបណ្ដុះបណ្ដាលនីមួយៗ សវនដ្ឋាន/ការិយាល័យសន្តិសុខ ឬ ផ្នែកបណ្ដុះបណ្ដាលគួរធ្វើរបាយការណ៍សង្ខេប និងវាយតម្លៃអំពីសមត្ថភាពយល់ដឹងរបស់សិក្ខាកាមដែលបានចូលរួមក្នុងវគ្គបណ្ដុះបណ្ដាល ដើម្បីត្រួតពិនិត្យនិងជ្រើសរើសអ្នកមានសមត្ថភាពចូលរួមធ្វើជាអ្នកបណ្ដុះបណ្ដាលបន្ត សម្រាប់វគ្គក្រោយៗទៀត ។
- ក្នុងប្រយោគដែលសរសេរជាអក្សរកាត់ថា ISPS Code (International Ship and Port Facility Security Code) សវនករយល់ឃើញថាប្រយោគ ឬ ឃ្លានេះមិនមែនសំដៅលើច្បាប់នោះទេ ដូច្នេះសវនដ្ឋាន/ការិយាល័យសន្តិសុខ គួរសរសេរថាក្រុមសន្តិសុខនាវាអន្តរជាតិ និងបបនីយកណ្ឌផែវិញ ។

**គ. វគ្គបណ្ដុះបណ្ដាលស្ដីពីបច្ចេកទេសបើកបរគ្រឿងចក្រ** QC (ZPMC)

- សវនករយល់ឃើញថា ក្នុងបញ្ជីវត្តមាននៃវគ្គបណ្តុះបណ្តាល ស្តីពីបច្ចេកទេសបើកបរគ្រឿង ចក្រ QC (ZPMC) ចុះថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ ២០១៧ សវនដ្ឋានគួរបន្ថែមជួរបញ្ឈរមួយ ជួរទៀតដើម្បីអោយសិក្ខាកាមចុះថ្ងៃខែឆ្នាំកំណើត ។
- សវនករយល់ឃើញថា បន្ទាប់ពីវគ្គបណ្តុះបណ្តាលនីមួយៗ សវនដ្ឋាន/ផ្នែកបណ្តុះបណ្តាល គួរធ្វើរបាយការណ៍សង្ខេប និងវាយតម្លៃអំពីសមត្ថភាពយល់ដឹង របស់សិក្ខាកាមដែលបានចូលរួមក្នុងវគ្គបណ្តុះបណ្តាលដើម្បីត្រួតពិនិត្យ និងជ្រើសរើសអ្នកមានសមត្ថភាពចូលរួមធ្វើជាអ្នកបណ្តុះបណ្តាលបន្តសម្រាប់វគ្គក្រោយៗទៀត ។

## ៦.១.២ នាយកដ្ឋានផែនការ-លទ្ធកម្ម និងស្ថិតិ

### ក. ការពិនិត្យផែនការពលកម្មឆ្នាំ ២០១៧ របស់ កសស

- យោងផែនការពលកម្មឆ្នាំ ២០១៧ សវនករបានសង្កេតឃើញ ថ្នាក់នាយករងនៅតាមនាយកដ្ឋានមួយចំនួន ត្រូវបានតែងតាំងស្របតាមសេចក្តីកំណត់ដែលមានចែងនៅក្នុងផែនការពលកម្មឆ្នាំ ២០១៧ និងសេចក្តីកំណត់ស្តីពីរចនាសម្ព័ន្ធចាត់តាំង និងតួនាទីភារកិច្ចរបស់នាយកដ្ឋានសាមី ។
- ដោយឡែក ថ្នាក់នាយករង និងប្រធានការិយាល័យសម្រាប់នាយកដ្ឋានផ្សេងៗទៀត ដែលបានកំណត់នៅក្នុងផែនការពលកម្មឆ្នាំ ២០១៧ ដូចគ្នា សវនករសង្កេតឃើញថានៅមិនទាន់មានការសម្រេចតែងតាំងនៅឡើយ ក្នុងនេះមាននាយកដ្ឋានមួយចំនួនតូចសូម្បីតែប្រធានការិយាល័យក៏គ្មានដែរ ។

## ៦.១.៣ នាយកដ្ឋានបច្ចេកទេស សម្ភារ និងសំណង់

### ក. តារាងវត្តមានការងារប្រចាំថ្ងៃរបស់ការិយាល័យសំណង់

- យោងតារាងវត្តមានការងារប្រចាំថ្ងៃ របស់ការិយាល័យសំណង់ និងគ្រប់ផ្នែកពាក់ព័ន្ធដែល ស្ថិតក្រោមការគ្រប់គ្រង របស់នាយកដ្ឋានបច្ចេកទេសសម្ភារនិងសំណង់ សម្រាប់រយៈពេល បីខែចុងក្រោយក្នុងការិយបរិច្ឆេទ ២០១៧ សរសេរថា "**បានឃើញនិងពិនិត្យដោយលោក នាយកបច្ចេកទេសសម្ភារនិងសំណង់ និងលោកនាយករដ្ឋបាល-ធនធានមនុស្ស**" ករណីនេះ សវនករយល់ឃើញថា គួរមានហត្ថលេខាបញ្ជាក់ដោយលោកនាយកទាំងពីររូបជាមុនសិន ទើបអាចយកមកប្រើប្រាស់ ឬ រក្សាទុកជាឯកសារស្របច្បាប់បាន ។
- ក្នុងតារាងវត្តមានការងារប្រចាំថ្ងៃរបស់ការិយាល័យសំណង់ សម្រាប់រយៈពេលបីខែចុងក្រោយ ក្នុងការិយបរិច្ឆេទឆ្នាំ២០១៧ នេះដែរ សវនករបានសង្កេតឃើញមានបុគ្គលិកមួយចំនួនអវត្តមានឥតច្បាប់ក្នុងចន្លោះពី ០២ (ពីរ) ទៅ ១៥ (ដប់ប្រាំ) ដងក្នុងមួយខែៗ ក្នុងនេះមានមួយចំនួនតូចត្រូវបានសរសេរជាអក្សរជំនួសហត្ថលេខា "ឈឺ" ក្នុងរយៈពេលយូរដោយគ្មានការបញ្ជាក់អំពីស្ថានភាពជម្ងឺច្បាស់លាស់ ។

### ខ. តារាងវត្តមានការងារប្រចាំថ្ងៃរបស់ផ្នែកយានដ្ឋាន

- យោងតារាងវត្តមានការងារប្រចាំថ្ងៃរបស់ផ្នែកយានដ្ឋាន សម្រាប់រយៈពេលបីខែចុងក្រោយក្នុងការិយបរិច្ឆេទឆ្នាំ២០១៧ សវនករបានសង្កេតឃើញមានបុគ្គលិកមួយចំនួន

អវត្តមានឥតច្បាប់ក្នុងចន្លោះពី ០២ (ពីរ) ទៅ ១៩ (ដប់ប្រាំបួន) ដងក្នុងមួយខែៗ ហើយមួយចំនួនតូច ក៏ត្រូវបានឃើញសរសេរជាអក្សរជំនួសហត្ថលេខា "ឈឺ" ក្នុងរយៈពេលយូរដោយគ្មានការ បញ្ជាក់អំពីស្ថានភាពជម្ងឺច្បាស់លាស់ដែរ ។

**គ. ការត្រួតពិនិត្យលក្ខណៈបច្ចេកទេស និងការគ្រប់គ្រងម៉ាស៊ីនភ្លើង**

- ពាក់ព័ន្ធនឹងរោង/បន្ទប់ម៉ាស៊ីនភ្លើងរបស់ **កសស** ទាំងបួនស្ថានីយ៍ សវនករយល់ឃើញថា សវនដ្ឋាន/ផ្នែកអគ្គិសនី គួរបិទស្លាកឈ្មោះនិង/ឬ ស្លាកសញ្ញាគ្រោះថ្នាក់នៅតាមរោង/បន្ទប់ម៉ាស៊ីននីមួយៗ ជាពិសេសនៅរោងម៉ាស៊ីនធំ/ស្ថានីយ៍អគ្គិសនីទី III ដើម្បីបង្ការគ្រោះថ្នាក់ផ្សេងៗ និងដើម្បីអនុវត្តអោយបានសមស្របតាមគោលការណ៍ណែនាំ នៃប្រព័ន្ធគ្រប់គ្រងសុវត្ថិភាព សុខភាព និងបរិស្ថានរបស់ **កសស** ។ ក្រៅពីនេះ សវនដ្ឋាន/ផ្នែកអគ្គិសនីគួរស្នើសុំជួសជុលរបាំងសំណាញ់ដែកការពារនៅស្ថានីយ៍ទី II ដែលមានស្នាមដាច់ជាចំណែក ធំៗនោះឡើងវិញ ហើយក្នុងករណីមិនចាំបាច់គួរយកកំណាត់ឈើក្តារ ជាច្រើនកំណាត់ដែល ស្ថិតនៅជាប់នឹងម៉ាស៊ីនភ្លើងធំ "ស្ថានីយ៍ទី III" ចេញដើម្បីបង្ការគ្រោះអគ្គិភ័យ ឬ គ្រោះថ្នាក់ ផ្សេងៗដែលអាចកើតមានឡើងជាយថាហេតុ ។ (សូមយោងរូបភាពភ្ជាប់ជូនមកជាមួយ) ។

## ៦.២ ផ្នែកអនុលោមភាព

### ៦.២.១ នាយកដ្ឋានផែនការ-លទ្ធកម្ម និងស្ថិតិ

**ក. ការពិនិត្យនីតិវិធីនៃការអនុវត្តកិច្ចលទ្ធកម្មរបស់ កសស**

- សវនករសង្កេតឃើញគោលការណ៍ដោះស្រាយវិវាទ ដែលបានចែងនៅក្នុងប្រការ ១៥ នៃកិច្ចសន្យាស្តីពីការងារជួសជុលផែចាស់ចន្លោះទី ៤ Beam4 Bay3 Beam3 Bay5 លេខ 013/01 កសស.អល.ពថ ប្រការ ១៧ នៃកិច្ចសន្យាស្តីពីការផ្គត់ផ្គង់ប្រេងឥន្ធនៈលេខ 010/3 កសស.អល.ដបស និងប្រការ ១៤ នៃកិច្ចសន្យាស្តីពីការផ្គត់ផ្គង់សម្ភារបន្លាស់ លេខ 098/6 កសស.អល.ពថ មានអត្ថន័យត្រួតគ្នានឹងគោលការណ៍ច្បាប់ ស្តីពីការគ្រប់គ្រងដោយ នៅក្នុងប្រយោគទីមួយនៃប្រការ ១៥ ប្រការ ១៧ និងប្រការ ១៤ នៃកិច្ចសន្យាទាំងបីនេះបាន ចែងថាកិច្ចសន្យានេះត្រូវគ្រប់គ្រង និងបកស្រាយតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។ ហេតុដូច្នេះ នៅក្នុងប្រការ ១៥ ប្រការ ១៧ និងប្រការ ១៤ សវនដ្ឋានគួរចែងថា "**ច្បាប់គ្រប់គ្រង**" ជំនួសវិញ រីឯគោលការណ៍ "**ដោះស្រាយវិវាទ**" គួរចែងនៅក្នុងប្រការដាច់ដោយឡែកមួយ ផ្សេងទៀត ។

### ៦.២.២ នាយកដ្ឋានបច្ចេកទេស-សម្ភារ និងសំណង់

**ក. របាយការណ៍ចំណូលចំណាយប្រេងឥន្ធនៈ សម្រាប់ម៉ាស៊ីនភ្លើងរបស់ កសស**

- ចំពោះការប្រើប្រាស់ប្រេងឥន្ធនៈ សវនករពិនិត្យឃើញមានឯកសារស្តីពីការធ្វើតេស្តបទដ្ឋានប្រេងឥន្ធនៈសម្រាប់ម៉ាស៊ីនភ្លើង ដែលមានកម្លាំងសេះចាប់ពី 255 KVA, 350 KVA, 500 KVA និង 1000 KVA ដោយមានហត្ថលេខាបញ្ជាក់របស់គណៈកម្មការរៀបចំ

បទដ្ឋានប្រើប្រាស់ប្រេងឥន្ធនៈ សម្រាប់ម៉ាស៊ីនភ្លើងរបស់ **កសស** ចុះថ្ងៃទី ០៩ ខែកញ្ញា ឆ្នាំ ២០០៩ ថ្ងៃទី ១០ ខែកញ្ញា ឆ្នាំ ២០០៩ និងថ្ងៃទី ២៩ ខែសីហា ឆ្នាំ ២០០៩ ។

- ទោះជាយ៉ាងនេះក្តី ម៉ាស៊ីនភ្លើងថ្មីម៉ាក HIMOINSA ផលិតនៅប្រទេសជប៉ុន 03 (បី) គ្រឿង ដែលមានសមត្ថភាពផ្គត់ផ្គង់ថាមពលអគ្គិសនីសរុប 800 KVA សវនដ្ឋាន/ផ្នែកអគ្គិសនី នៅមិនទាន់មានឯកសារ ស្តីពីការធ្វើតេស្តបទដ្ឋានប្រេងឥន្ធនៈនៅឡើយទេ ប៉ុន្តែដោយម៉ាស៊ីន ភ្លើងទាំងនេះត្រូវបានបម្រុងទុកសម្រាប់ប្រើប្រាស់ ដើម្បីផ្គត់ផ្គង់តម្រូវការថាមពលផ្នែករដ្ឋបាល របស់នាយកដ្ឋានតំបន់សេដ្ឋកិច្ចពិសេស **កសស** ក្នុងករណីភ្លើងរដ្ឋដាច់ផ្នែកអគ្គិសនីបាន ទទួលការអនុញ្ញាតអោយប្រើប្រាស់ប្រេងឥន្ធនៈតាម Engine Specifications ពីថ្នាក់ដឹកនាំ សវនដ្ឋានផ្ទាល់ ។

## ៧. សំណូមពរ

ដើម្បីលើកកំពស់គុណភាពផលិតកម្ម និងកែលម្អប្រសិទ្ធភាពប្រតិបត្តិការរបស់ **កសស** អោយកាន់តែល្អប្រសើរឡើងជាលំដាប់ និងទទួលបានសេចក្តីទុកចិត្តពីអតិថិជននិងអ្នកប្រើប្រាស់ផែ និងផ្តល់សេវាកម្មជូនអតិថិជនបានឆាប់រហ័ស និងសមស្របតាមតម្រូវការទីផ្សារ សវនដ្ឋានគួរបន្តយកចិត្តទុកដាក់លើសុខុមាលភាព ការបណ្តុះបណ្តាលធនធានមនុស្ស រួមទាំងសន្តិសុខ និងសុវត្ថិភាពការងាររបស់អង្គភាព និងរៀបចំកសាងផែនការពលកម្មសម្រាប់ឆ្នាំនីមួយៗ ដោយធ្វើការសិក្សាអំពីសន្ទស្សន៍បរិមាណទំនិញឆ្លងកាត់ និងតម្រូវការចាំបាច់ពាក់ព័ន្ធនឹងកិច្ចប្រតិបត្តិការអាជីវកម្ម និងសេវាកម្មរបស់ **កសស** និងបន្តតាមដានការអនុវត្តសហការសម្របសម្រួលជាមួយនាយកដ្ឋានរដ្ឋបាល-ធនធានមនុស្ស ដើម្បីលើកសំណើផ្តល់ជូននូវតម្រូវការធនធានមនុស្ស ទាំងថ្នាក់ដឹកនាំកណ្តាល និង/ឬ កម្លាំងពលកម្ម ក៏ដូចជាតម្រូវការផ្សេងៗទៀតដែលនាយកដ្ឋានពាក់ព័ន្ធបានស្នើសុំដើម្បីជៀសវាងការអូសបន្លាយពេលវេលា និងការអនុវត្តតួនាទីនិងភារកិច្ចដែល **កសស** បានប្រគល់ជូនដោយគ្មានអនុលោមភាព និងប្រសិទ្ធភាពប្រតិបត្តិការ ។

ពាក់ព័ន្ធនឹងនីតិវិធីនៃការអនុវត្តកិច្ចលទ្ធកម្មរបស់ **កសស** សវនករយល់ឃើញថាសវនដ្ឋានគួរបន្តយកចិត្តទុកដាក់ត្រួតពិនិត្យ ស្រាវជ្រាវរាល់លិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធនឹងនីតិវិធីច្បាប់ និងសារាចរណែនាំស្តីពីការអនុវត្តកិច្ចលទ្ធកម្មសាធារណៈរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក៏ដូចជាច្បាប់និងបទប្បញ្ញត្តិនានាជាធរមាន ដើម្បីជម្រុញការអនុវត្តកិច្ចលទ្ធកម្មរបស់ **កសស** អោយកាន់តែមានសុក្រឹតភាព និងអនុលោមតាមនីតិវិធីច្បាប់ ស្តីពីកិច្ចលទ្ធកម្មរបស់សហគ្រាសសាធារណៈ ។

ជាងនេះទៀត ដើម្បីធ្វើឱ្យអោយកាន់តែល្អប្រសើរឡើងជាលំដាប់ និងទទួលបានសេចក្តីទុកចិត្តពីអតិថិជន និងអ្នកប្រើប្រាស់ផែ ជាពិសេសដើម្បីជាគំរូល្អសម្រាប់ **កសស** ក្នុងការអនុវត្តតាមលិខិតបទដ្ឋានគតិយុត្តិ ក៏ដូចជាច្បាប់ និងបទប្បញ្ញត្តិនានាជាធរមាន សវនករយល់ឃើញថាសវនដ្ឋានគួរពង្រឹង ការគ្រប់គ្រងវត្តមានរបស់មន្ត្រី បុគ្គលិក កម្មករ ជាប្រចាំថ្ងៃទាំងព្រឹកទាំងល្ងាច និងរាយការណ៍ជូនថ្នាក់ដឹកនាំ **កសស** ដើម្បីស្នើសុំការណែនាំអនុវត្តជាប្រយោជន៍ដើម្បីលើកកំពស់វិន័យការងារ មនសិការវិជ្ជាជីវៈ និងធានាបាននូវប្រសិទ្ធភាពប្រតិបត្តិការរបស់អង្គភាពស្របតាមគោលការណ៍ណែនាំ ដែលមានចែងនៅក្នុងជំពូកទី V នៃលក្ខន្តិកៈបុគ្គលិកកំពង់ផែស្វយ័តក្រុងព្រះសីហនុ **កសស** ចុះថ្ងៃទី ០៤ ខែមេសា ឆ្នាំ ២០០៣ ស្តីពីវិន័យ ទណ្ឌកម្ម ការលើកសរសើរ ការដាក់ពិន្ទុ និងក្រុមប្រឹក្សាវិន័យ ។

ម្យ៉ាងវិញទៀត ដើម្បីធានាលទ្ធភាពផលិតថាមពលអគ្គិសនីគ្រប់គ្រាន់ និងបន្តនិរន្តរភាពដំណើរការអាជីវកម្មរបស់ **កសស** បានសមស្របតាមតម្រូវការរបស់អតិថិជន សវនដ្ឋាន/ផ្នែកអគ្គិសនីគួរពិនិត្យលទ្ធភាពលើកសំណើសុំថ្នាក់ដឹកនាំជួសជុលម៉ាស៊ីនភ្លើងផលិតនៅ USA 02 (ពីរ) គ្រឿងនៅស្ថានីយ៍ទី I ដែលខូច-គ្មានការប្រើប្រាស់ ម៉ាស៊ីនភ្លើងផលិតនៅប្រទេសជប៉ុន 02 (ពីរ) គ្រឿងនៅស្ថានីយ៍ទី II ដែលនៅអាចប្រើប្រាស់បានជាបណ្ដោះអាសន្ន និងម៉ាស៊ីនភ្លើងម៉ាក IVECO ផលិតនៅប្រទេសអ៊ីតាលី 01 (មួយ) គ្រឿងនៅស្ថានីយ៍ទី III សមត្ថភាព ផ្គត់ផ្គង់ថាមពលអគ្គិសនី 500 KVA លេខសម្គាល់ 306 ដែលមិនអាច Synchronize ជាមួយម៉ាស៊ីនភ្លើងផ្សេងៗទៀតបានឱ្យដំណើរការជាប្រក្រតីឡើងវិញ ដើម្បីជៀសវាងកង្វះខាតថាមពលអគ្គិសនី និងការរាំងស្ទះដល់ ប្រសិទ្ធភាពប្រតិបត្តិការអាជីវកម្មរបស់ **កសស** ។

## ៨. សេចក្តីសន្និដ្ឋានរួម

នៅក្នុងអំឡុងពេលនៃការធ្វើសវនកម្មនេះ ផ្នែកខ្លះនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង នៅក្នុងសវដ្ឋាននីមួយៗត្រូវបានកត់សម្គាល់ឃើញថាមានការខិតខំប្រឹងប្រែងរៀបចំដំណើរការអនុវត្ត ប្រកបដោយប្រសិទ្ធភាពប្រតិបត្តិការ និងទទួលខុសត្រូវខ្ពស់ ។ ជាមួយគ្នានេះដែរ ក្រុមការងារសវនកម្មផ្ទៃក្នុងសង្កេតឃើញថា ថ្នាក់ដឹកនាំ មន្ត្រី និង បុគ្គលិកគ្រប់សវនដ្ឋានមានឆន្ទៈរួមសហការ និងយកចិត្តទុកដាក់ក្នុងការបំពេញតួនាទី និងភារកិច្ចរបស់ខ្លួនដោយ អនុលោមតាមលក្ខន្តិកៈបុគ្គលិក **កសស** ច្បាប់ បទប្បញ្ញត្តិ និងគោលការណ៍គ្រប់គ្រងធនធានមនុស្ស ។

## ៩. ផែនការសកម្មភាពកែលម្អ

ដើម្បីធានាប្រសិទ្ធភាពអនុវត្ត និងកែលម្អតាមសំណូមពរដែលសវនករបានស្នើឡើង ថ្នាក់ដឹកនាំនាយកដ្ឋានរដ្ឋបាល-ធនធានមនុស្ស នាយកដ្ឋានផែនការ-លទ្ធកកម្ម និងស្ថិតិ និងនាយកដ្ឋានបច្ចេកទេស-សម្ភារៈ និងសំណង់ បានឯកភាពតាមផែនការសកម្មភាពដូចបានកំណត់ក្នុងតារាងនៃ **ឧបសម្ព័ន្ធ ២** ។

ថ្ងៃសុក្រ ៧កើត ខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស ២៥៦១
ធ្វើនៅខេត្តព្រះសីហនុ ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៨

**បានឃើញ និងឯកភាព**
ខេត្តព្រះសីហនុ ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ២០១៨
**ប្រធានក្រុមប្រឹក្សាភិបាល**

PORT AUTONOME DE SIHANOUKVILLE

**លូ_គីមឈន់**

**នាយកសវនកម្មផ្ទៃក្នុង**

**ម៉ែន ចាន់**

# ផ្នែកទី ៦

# របាយការណ៍ហិរញ្ញវត្ថុដែលបានពិនិត្យឡើងវិញ ដោយសវនករឯករាជ្យ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

កំពង់ផែស្វយ័តក្រុងព្រះសីហនុ

## របាយការណ៍ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលរបស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ (ហៅកាត់ថា "ក.ស.ស") មានសេចក្តីសោមនស្ស សូមបង្ហាញរបាយការណ៍របស់ខ្លួន និងរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួចហើយ សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧។

## សកម្មភាពអាជីវកម្មចម្បង

សកម្មភាពអាជីវកម្មចម្បងរបស់ ក.ស.ស គឺពាក់ព័ន្ធនឹងការផ្តល់សេវាកំពង់ផែសមុទ្រ និងសេវាផ្សេងៗទៀតដែលពាក់ព័ន្ធនឹងកំពង់ផែ ព្រមទាំងអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេសសម្រាប់ជួល។

## លទ្ធផលហិរញ្ញវត្ថុ

លទ្ធផលហិរញ្ញវត្ថុសម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ ត្រូវបានបង្ហាញនៅក្នុងចំណេញ-ខាត និងលទ្ធផលលម្អិតផ្សេងៗ នៅលើទំព័រទី ១២។

## ទ្រព្យសកម្ម

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយ ដែលនឹងបណ្តាលឱ្យមានការភាន់ច្រឡំដល់ការកំណត់តម្លៃទ្រព្យសកម្ម នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ ក.ស.ស នោះទេ។

## បំណុលយថាភាព និងបំណុលផ្សេងៗទៀត

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ មិនមាន :

ក) បន្ទុកណាមួយលើទ្រព្យសកម្មរបស់ ក.ស.ស ដែលបានកើតឡើងដោយសារការដាក់បញ្ចាំ សម្រាប់ធានាបំណុលរបស់បុគ្គលណាម្នាក់ឡើយ ចាប់តាំងពីដំណាច់ឆ្នាំមក ឬ

ខ) បំណុលយថាភាពណាមួយ កើតឡើងចំពោះ ក.ស.ស ចាប់តាំងពីដំណាច់ឆ្នាំមក។

តាមយោបល់របស់ក្រុមប្រឹក្សាភិបាល ក.ស.ស ពុំមានបំណុលយថាភាព ឬបំណុលផ្សេងៗទៀត ដែលត្រូវបានទាមទារឱ្យសង ឬអាចត្រូវបានទាមទារឱ្យសង ក្នុងអំឡុងពេល១២ខែបន្ទាប់ពីដំណាច់ឆ្នាំ ដែលនឹងអាចមានផលប៉ះពាល់ធ្ងន់ធ្ងរដល់លទ្ធភាពរបស់ ក.ស.ស ក្នុងការបំពេញកាតព្វកិច្ចសងបំណុលរបស់ខ្លួន នៅថ្ងៃកំណត់សងនោះទេ។

## ការផ្លាស់ប្តូរហេតុការណ៍

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលបានកើតឡើងពាក់ព័ន្ធនឹងរបាយការណ៍នេះ ឬរបាយការណ៍ហិរញ្ញវត្ថុរបស់ ក.ស.ស ដែលធ្វើឱ្យចំនួនទឹកប្រាក់ ដែលបានរាយការណ៍នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុមានកំហុសឆ្គងធ្ងន់ធ្ងរនោះទេ។

## ប្រតិបត្តិការមិនធម្មតា

តាមយោបល់របស់ក្រុមប្រឹក្សាភិបាល លទ្ធផលហិរញ្ញវត្ថុរបស់ ក.ស.ស សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ មិនបានទទួលរងនូវឥទ្ធិពលធ្ងន់ធ្ងរ ដែលកើតចេញពីគណនី ប្រតិបត្តិការ ឬព្រឹត្តិការណ៍ទាំងឡាយ ដែលមានលក្ខណៈជាសារវន្តនិងមិនធម្មតានោះទេ។

## ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលទទួលខុសត្រូវក្នុងការធានាថា របាយការណ៍ហិរញ្ញវត្ថុត្រូវបានរៀបចំឡើងត្រឹមត្រូវនូវគ្រប់ទិដ្ឋភាពជាសារវន្តទាំងអស់នៃស្ថានភាពហិរញ្ញវត្ថុរបស់ ក.ស.ស គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ និងលទ្ធផលហិរញ្ញវត្ថុ ព្រមទាំងលំហូរសាច់ប្រាក់សម្រាប់ដំណាច់ឆ្នាំ។ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ ក្រុមប្រឹក្សាភិបាលត្រូវ៖

១) អនុវត្តគោលការណ៍គណនេយ្យដែលសមស្រប ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (ហៅកាត់ថា "CIFRS") ដែលគាំទ្រដោយការវិនិច្ឆ័យនិងការប៉ាន់ប្រមាណសមហេតុផល ហើយបន្ទាប់មកត្រូវអនុវត្តវាជាប្រចាំ

២) គោរពតាមតម្រូវការរបស់ CIFRS ក្នុងការលាតត្រដាងព័ត៌មាន ហើយប្រសិនបើមានការប្រាសចាកណាមួយពីស្តង់ដារទាំងនេះ ក្នុងការបង្ហាញឱ្យមានត្រឹមត្រូវ ការប្រាសចាកទាំងនោះត្រូវបានលាតត្រដាង ពន្យល់ និងកំណត់ចំនួនទឹកប្រាក់សមស្របនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ

៣) ថែរក្សាបញ្ជីគណនេយ្យឱ្យបានគ្រប់គ្រាន់ ដើម្បីឱ្យ ក.ស.ស អាចរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដែលអនុលោមទៅតាម CIFRS និងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងដែលមានប្រសិទ្ធភាព

៤) រៀបចំរបាយការណ៍ហិរញ្ញវត្ថុដោយផ្អែកលើមូលដ្ឋាននិរន្តរភាព លើកលែងតែមានការសន្មតថា ក.ស.ស មិនមានលក្ខណៈសមស្របក្នុងការបន្តប្រតិបត្តិការនៅពេលអនាគតដែលអាចប៉ាន់ស្មានបាន និង

៥) គ្រប់គ្រង និងដឹកនាំ ក.ស.ស ឱ្យមានប្រសិទ្ធភាពហើយប្រាកដថាការសម្រេចចិត្តលើបញ្ហាសំខាន់ៗទាំងអស់ ដែលអាចប៉ះពាល់ដល់ប្រតិបត្តិការ ហើយការចូលរួមរាល់ការសម្រេចចិត្តទាំងនោះ ត្រូវបានឆ្លុះបញ្ចាំងត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ក្រុមប្រឹក្សាភិបាលធានាអះអាងថា ក.ស.ស បានអនុវត្តតាមរាល់តម្រូវការខាងលើ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ។

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ សមាជិកក្រុមប្រឹក្សាភិបាលរបស់ ក.ស.ស មានសមាសភាគដូចខាងក្រោម៖

| ឈ្មោះ | តំណាង | តួនាទី |
|---|---|---|
| ឯកឧត្តមលូ គឹមឈន់ | ប្រធានអគ្គនាយកកំពង់ផែស្វយ័តក្រុងព្រះសីហនុ | ប្រធានក្រុមប្រឹក្សាភិបាល |
| ឯកឧត្តមតឹកវ៉េត សម្រេច | ទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិកក្រុមប្រឹក្សាភិបាល |
| ឯកឧត្តមផាន់ ផល្លា | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិកក្រុមប្រឹក្សាភិបាល |
| ឯកឧត្តមយន្ត មិន | សាលាក្រុងព្រះសីហនុ | សមាជិកក្រុមប្រឹក្សាភិបាល |
| ឯកឧត្តមស៊ុយ សាន | ក្រសួងសាធារណៈការ និងដឹកជញ្ជូន | សមាជិកក្រុមប្រឹក្សាភិបាល |
| ឯកឧត្តមសុខ សុភ័ក្ត្រ | ក្រសួងពាណិជ្ជកម្ម | សមាជិកក្រុមប្រឹក្សាភិបាល |
| លោក លូ លីខេង | បុគ្គលិកកំពង់ផែស្វយ័តក្រុងព្រះសីហនុ | សមាជិកក្រុមប្រឹក្សាភិបាល |

**ការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ**

យើងខ្ញុំជាក្រុមប្រឹក្សាភិបាល អនុម័តលើរបាយការណ៍ហិរញ្ញវត្ថុដែលភ្ជាប់មកជាមួយ ព្រមទាំងកំណត់សម្គាល់ផ្សេងៗ ដែលបានបង្ហាញត្រឹមត្រូវ នូវគ្រប់ទិដ្ឋភាពជាសារវន្តទាំងអស់នៃស្ថានភាពហិរញ្ញវត្ថុរបស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់សម្រាប់ដំណាច់ឆ្នាំ ដោយស្របតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា។

**តាងនាមក្រុមប្រឹក្សាភិបាល**

**ឯកឧត្តមលូ គីមឈន់**
ប្រធានក្រុមប្រឹក្សាភិបាល និងជាអគ្គនាយក

**លោក ប៉ាត សិត**
នាយកគណនេយ្យ និងហិរញ្ញវត្ថុ

ខេត្តព្រះសីហនុ ព្រះរាជាណាចក្រកម្ពុជា
កាលបរិច្ឆេទៈ ថ្ងៃទី២៦ខែ មីនា ឆ្នាំ២០១៨

**របាយការណ៍សវនករឯករាជ**
**ជូនភាគហ៊ុនិក កំពង់ផែស្វយ័តក្រុងព្រះសីហនុ**

## មតិយោបល់របស់យើងខ្ញុំ

តាមមតិយោបល់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុរបស់ កំពង់ផែស្វយ័តក្រុងព្រះសីហនុ (ហៅកាត់ថា"ក.ស.ស") បង្ហាញត្រឹមត្រូវនូវគ្រប់ទិដ្ឋភាពជាសារវន្តទាំងអស់អំពីស្ថានភាពហិរញ្ញវត្ថុរបស់ ក.ស.ស គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ និងលទ្ធផលហិរញ្ញវត្ថុ ព្រមទាំងលំហូរសាច់ប្រាក់សម្រាប់ដំណាច់ឆ្នាំ ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (ហៅកាត់ថា "CIFRS")។

## របាយការណ៍ដែលយើងខ្ញុំបានធ្វើសវនកម្ម

របាយការណ៍ហិរញ្ញវត្ថុរបស់ ក.ស.ស រួមមាន៖

- តារាងតុល្យការគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧
- របាយការណ៍ចំណេញ-ខាត និងលទ្ធផលលម្អិតផ្សេងៗសម្រាប់ដំណាច់ឆ្នាំ
- របាយការណ៍បម្រែបម្រួលមូលធនសម្រាប់ដំណាច់ឆ្នាំ
- របាយការណ៍លំហូរសាច់ប្រាក់សម្រាប់ដំណាច់ឆ្នាំ និង
- កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ រាប់ទាំងសេចក្តីសង្ខេបគោលការណ៍គណនេយ្យសំខាន់ៗ។

## មូលដ្ឋាននៃមតិយោបល់របស់យើងខ្ញុំ

យើងខ្ញុំបានធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដារអន្តរជាតិ ស្តីពីសវនកម្ម នៃ កម្ពុជា (ហៅកាត់ថា "ស្តង់ដារសវនកម្ម")។ ការទទួលខុសត្រូវរបស់យើងខ្ញុំដែលអនុលោមទៅតាមស្តង់ដារទាំងនោះ ត្រូវបានពណ៌នាបន្ថែមទៀតនៅក្នុងកថាខណ្ឌ *"ការទទួលខុសត្រូវរបស់សវនករក្នុងការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ"* នៅក្នុងរបាយការណ៍សវនកម្មរបស់យើងខ្ញុំ។

យើងខ្ញុំជឿជាក់ថាភស្តុតាងសវនកម្មដែលយើងខ្ញុំបានទទួល មានភាពគ្រប់គ្រាន់ និងសមហេតុផល ដើម្បីធ្វើជាមូលដ្ឋានសម្រាប់ការបញ្ចេញមតិយោបល់របស់យើងខ្ញុំ។

## ឯករាជ្យ

យើងខ្ញុំមានឯករាជ្យពី ក.ស.ស ដែលអនុលោមទៅតាមក្រមសីលធម៌សម្រាប់គណនេយ្យករវិជ្ជាជីវៈ ដែលចេញផ្សាយដោយក្រុមប្រឹក្សាស្តង់ដារក្រមសីលធម៌អន្តរជាតិ (ហៅកាត់ថា "ក្រមសីលធម៌អន្តរជាតិ") និងអនុលោមទៅតាមក្រមសីលធម៌របស់ វិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា (ហៅកាត់ថា "ក្រមសីលធម៌ វគសក")។ យើងខ្ញុំបានបំពេញកាតព្វកិច្ចក្នុងការទទួលខុសត្រូវផ្នែកក្រមសីលធម៌ផ្សេងៗទៀត ដែលកំណត់ដោយក្រមសីលធម៌អន្តរជាតិ និងក្រមសីលធម៌វគសក។

**បញ្ហាសវនកម្មសំខាន់ៗ**

តាមការវិនិច្ឆ័យប្រកបដោយវិជ្ជាជីវៈរបស់យើងខ្ញុំ បញ្ហាសវនកម្មសំខាន់ៗគឺជាបញ្ហាទាំងឡាយណា ដែលមានសារៈសំខាន់បំផុតនៅក្នុងការធ្វើសវនកម្មរបស់យើងខ្ញុំលើរបាយការណ៍ហិរញ្ញវត្ថុ។ បញ្ហាទាំងនេះត្រូវបានលើកឡើងនៅក្នុងបរិបទនៃការធ្វើសវនកម្មរបស់យើងខ្ញុំទៅលើរបាយការណ៍ហិរញ្ញវត្ថុទាំងមូល ដូចនេះក្នុងការបញ្ចេញមតិយោបល់ យើងខ្ញុំពុំបញ្ចេញយោបល់ដោយឡែកទៅលើបញ្ហាទាំងនេះទេ។

| **បញ្ហាសវនកម្មសំខាន់ៗ** | **នីតិវិធីដែលយើងខ្ញុំដោះស្រាយបញ្ហាសវនកម្មសំខាន់ៗ** |
|---|---|
| **កាតព្វកិច្ចអត្ថប្រយោជន៍សោធននិវត្តន៍** | |
| យោងទៅកំណត់សម្គាល់ ២.១៩ – សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ ស្តីពី អត្ថប្រយោជន៍បុគ្គលិក និង កំណត់សម្គាល់ ៤.ខ – ការសន្មត និងការវិនិច្ឆ័យលើកាតព្វកិច្ចអត្ថប្រយោជន៍សោធននិវត្តន៍។<br><br>គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ ក.ស.ស មានសមតុល្យដែលនៅមិនទាន់ទូទាត់ចំនួន ៤១.០០៨ លានរៀល។ ការប៉ាន់ស្មានរបស់គណៈគ្រប់គ្រង គឺគណនាដោយផ្អែកទៅតាមវិធីសាស្ត្រប៉ាន់ស្មានឯកតាឥណទាន (projected unit credit)។<br><br>គណៈគ្រប់គ្រងបានវាយតម្លៃបំណុលកាតព្វកិច្ច អាស្រ័យទៅតាមទិន្នន័យប្រជាសាស្ត្រក្នុងគ្រាកន្លងមក ស្ថានភាពអាជីវកម្មក្នុងពេលបច្ចុប្បន្ន និងគោលការណ៍គណនេយ្យ។ គណៈគ្រប់គ្រងក៏បានជួលអ្នកជំនាញខាងក្រៅ ដើម្បីធ្វើការគណនាលម្អិតអំពីភាពស្មុគស្មាញនេះផងដែរ។<br><br>ការវាយតម្លៃកាតព្វកិច្ចអត្ថប្រយោជន៍សោធននិវត្តន៍ តម្រូវឱ្យមានការវិនិច្ឆ័យជាក់លាក់របស់គណៈគ្រប់គ្រង និងអ្នកជំនាញបច្ចេកទេស ក្នុងការអនុវត្តការសន្មតដែលសមស្រប។ បម្រែបម្រួលការសន្មតសំខាន់ៗ រួមមាន កំណើនប្រាក់បៀវត្សរ៍ អតិផរណា អត្រាអប្បហារ និងអត្រាមរណភាព ដែលអាចនាំឱ្យមានផលប៉ះពាល់ជាសារវន្តលើការគណនាបំណុល។<br><br>យើងខ្ញុំផ្តោតលើផ្នែកទាំងនេះ ដោយសារវាពាក់ព័ន្ធយ៉ាងសំខាន់ទៅលើការវិនិច្ឆ័យ និងការប៉ាន់ស្មានរបស់គណៈគ្រប់គ្រង ដើម្បីធ្វើការវាយតម្លៃយ៉ាងសមស្រប និងត្រឹមត្រូវ។ | នីតិវិធីសវនកម្មរបស់យើងខ្ញុំ ទាក់ទិនទៅនឹងការប៉ាន់ស្មានរបស់គណៈគ្រប់គ្រង លើចំនួនទឹកប្រាក់បំណុលនេះ រួមមាន៖<br><br>វាយតម្លៃអំពីសមត្ថភាព ឯករាជ្យ និងគោលបំណង ព្រមទាំងបញ្ជាក់អំពីលក្ខណៈសម្បត្តិ នៃអ្នកជំនាញរបស់គណៈគ្រប់គ្រង និងពិនិត្យលើវិសាលភាពរបស់ពួកគេផងដែរ។<br><br>ការបង្កើតនូវគោលសន្មតផ្ទៃក្នុង ដើម្បីប្រៀបធៀបទៅនឹងកំណើនប្រាក់បៀវត្សរ៍ អតិផរណា អត្រាអប្បហារ និងអត្រាមរណភាព។<br><br>ពិនិត្យកត្តាសំខាន់ៗនៃទិន្នន័យក្នុងគ្រាកន្លងមក ដូចជាអត្រាអតិផរណា និងអត្រាអប្បហារជាដើម។<br><br>ពិនិត្យ និងគណនាលើតារាង ដែលអ្នកវាយតម្លៃសោធននិវត្តន៍បានធ្វើ និង<br><br>ផ្ទៀងផ្ទាត់ និងគណនាចំនួនទឹកប្រាក់ក្នុងរបាយការណ៍វាយតម្លៃហានិភ័យ ធៀបជាមួយនឹងការកត់ត្រាគណនេយ្យ។<br><br>ជាលទ្ធផលនៃនីតិវិធីរបស់យើងខ្ញុំខាងលើ យើងខ្ញុំបានរកឃើញថាការវិនិច្ឆ័យ និងការប៉ាន់ស្មានជាក់លាក់របស់គណៈគ្រប់គ្រង គឺមានភាពសមស្រប។ យើងខ្ញុំមិនបានរកឃើញនូវករណីខុសឆ្គងជាសារវន្តណាមួយទេ។ |

| **បញ្ហាសវនកម្មសំខាន់ៗ** | **នីតិវិធីដែលយើងខ្ញុំដោះស្រាយបញ្ហាសវនកម្មសំខាន់ៗ** |
|---|---|
| **ការកត់ត្រាគណនេយ្យនៃឥណទានផ្តល់ឱ្យបុគ្គលិក** | |
| យោងទៅកំណត់សម្គាល់ ២.៨.១ – សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ ស្តីពី ការធ្វើចំណាត់ថ្នាក់ទ្រព្យសកម្មហិរញ្ញវត្ថុ និងកំណត់សម្គាល់ ៩ – ឥណទានផ្តល់ឱ្យបុគ្គលិក។<br><br>ក.ស.ស បានផ្តល់ឥណទានឱ្យបុគ្គលិកជាសាច់ប្រាក់ ចំនួន ១០.២៦៧ លានរៀល ដើម្បីទិញភាគហ៊ុនប្រភេទ "គ" នៅថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៧។ ឥណទានទាំងនេះមិនមានការប្រាក់ទេ និងមានរយៈពេល៤ឆ្នាំ។ ឥណទានទាំងនេះត្រូវទូទាត់សងវិញជារៀងរាល់ខែក្នុងរយៈពេល៤៨ខែ ដែលត្រូវកាត់កងពីប្រាក់បៀវត្សរ៍ប្រចាំខែរបស់បុគ្គលិក។<br><br>គណៈគ្រប់គ្រងបានយល់ឃើញថា ឥណទានផ្តល់ឱ្យបុគ្គលិក គឺធ្វើឡើងក្នុងវិសាលភាពនៃឧបករណ៍ហិរញ្ញវត្ថុ (CIAS 39) ជាជាងក្នុងវិសាលភាពនៃការទូទាត់តាមភាគហ៊ុន (CIFRS 2) ដោយសារបុគ្គលិក អាចមានហានិភ័យតម្លៃភាគហ៊ុនធ្លាក់ចុះ ហើយបុគ្គលិកចាំបាច់ត្រូវសងប្រាក់វិញទាំងស្រុង ទោះជាក្នុងកាលៈទេសៈណាក៏ដោយ។ ដូចនេះ ឥណទានទាំងនេះត្រូវបានចាត់ទុកជាទ្រព្យសកម្មហិរញ្ញវត្ថុ ដែលត្រូវបានកត់ត្រាដំបូងតាមតម្លៃសមស្រប ក្នុងទឹកប្រាក់ចំនួន ៦.៩២៤ លានរៀល ហើយបន្ទាប់មកទៀតវាត្រូវបានវាស់វែងតាមថ្លៃដើមដករំលស់។ លម្អៀងរវាងតម្លៃសមស្របនៃទ្រព្យសកម្មហិរញ្ញវត្ថុ និងសាច់ប្រាក់ដែលបុគ្គលិកបានទទួលដើម្បីទិញភាគហ៊ុន ត្រូវបានកត់ត្រាជាចំណាយបែងចែកតាមរយៈពេលឥណទាន។<br><br>យើងខ្ញុំផ្តោតលើផ្នែកទាំងនេះ ដោយសារវាពាក់ព័ន្ធយ៉ាងសំខាន់ទៅលើការវិភាគរបស់គណៈគ្រប់គ្រង ដើម្បីធ្វើការកត់ត្រាគណនេយ្យ និងអនុត្តការសន្មត និងការវិនិច្ឆ័យជាក់លាក់ ទៅលើការកត់ត្រាតម្លៃសមស្រប។ | នីតិវិធីរបស់យើងខ្ញុំ ទាក់ទិនទៅនឹងការប៉ាន់ស្មាន និងការវិនិច្ឆ័យរបស់គណៈគ្រប់គ្រង ទៅលើការកត់ត្រាគណនេយ្យ និងការកំណត់តម្លៃ រួមមាន៖<br><br>ស្វែងយល់ និងវាយតម្លៃលើភាពសមស្របនៃគោលការណ៍ និងនីតិវិធីរបស់គណៈគ្រប់គ្រង ពាក់ព័ន្ធទៅនឹង គម្រោងជម្រើសភាគហ៊ុនរបស់បុគ្គលិក (Employee Stock Option Plan)។<br><br>ចូលរួមពីអ្នកជំនាញបច្ចេកទេស ផ្នែកគណនេយ្យរបស់យើងខ្ញុំ ដើម្បីផ្តល់ជាជំនួយ ក្នុងការវាយតម្លៃភាពសមស្របនៃការកត់ត្រាគណនេយ្យ និងវិធីសាស្ត្រវាយតម្លៃ។<br><br>ពិនិត្យការគណនាតម្លៃសមស្រប និងការសន្មត ដែលគណៈគ្រប់គ្រងបានធ្វើឡើង ដើម្បីឱ្យមានភាពត្រឹមត្រូវ និងគ្រប់គ្រាន់។<br><br>ផ្ទៀងផ្ទាត់ការសងប្រាក់ខ្លះៗ ជាមួយនឹងសន្លឹកបើកប្រាក់បៀវត្សរ៍ដែលបានចុះហត្ថលេខាដោយបុគ្គលិក និង<br><br>តាមដានរបាយការណ៍ស្តីពីការគណនាតម្លៃសមស្រប ជាមួយនឹងការកត់ត្រាគណនេយ្យ ដើម្បីធានានូវភាពត្រឹមត្រូវ។<br><br>ជាលទ្ធផលនៃនីតិវិធីរបស់យើងខ្ញុំខាងលើ យើងខ្ញុំបានរកឃើញថា ការប៉ាន់ស្មាន និងការវិនិច្ឆ័យជាក់លាក់របស់គណៈគ្រប់គ្រង គឺមានភាពសមស្រប។ យើងខ្ញុំមិនបានរកឃើញនូវករណីខុសឆ្គងជាសារវន្តណាមួយទេ។ |

| បញ្ហាសវនកម្មសំខាន់ៗ | នីតិវិធីដែលយើងខ្ញុំដោះស្រាយបញ្ហាសវនកម្មសំខាន់ៗ |
|---|---|
| **ការកត់ត្រាគណនេយ្យនៃភាគលាភធានាអប្បបរមាត្រូវបង់** | |
| យោងទៅកំណត់សម្គាល់ ២.២៤ – សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ ស្តីពី ការបែកចែកភាគលាភ និង កំណត់សម្គាល់ ១៤.ខ – ដើមទុន និងបុព្វលាភភាគហ៊ុន។<br><br>ក.ស.ស បានបោះផ្សាយភាគហ៊ុនប្រភេទ "គ" សម្រាប់លក់ឱ្យអ្នកវិនិយោគ ដោយមានភាគលាភអប្បបរមាធានាត្រូវបង់ ក្នុងអត្រាការប្រាក់៥% ក្នុងមួយឆ្នាំ ក្នុងរយៈពេលបីឆ្នាំ ចាប់ពីកាលបរិច្ឆេទចុះបញ្ជីលក់មូលបត្រសាធារណៈលើកដំបូងនៅថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៧។ ភាគលាភអប្បបរមាធានាត្រូវបង់ មានលក្ខណៈពិសេសជាបំណុលបង្កប់ ដែលបណ្តាលឱ្យភាគហ៊ុនប្រភេទ "គ" ត្រូវបានកត់ត្រាជាឧបករណ៍មូលធន និងបំណុល (compound instrument)។<br><br>ដូចនេះ គណៈគ្រប់គ្រងបានបំបែកសាច់ប្រាក់បានពីការបោះផ្សាយភាគហ៊ុនថ្មី ប្រភេទ "គ" ដាច់ដោយឡែករវាង បំណុល និងមូលធន ក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។ តម្លៃសមស្របរបស់បំណុល ត្រូវបានគណនាលើកដំបូង ដោយមិនមានសមាសភាគមូលធន ហើយបន្ទាប់មក គេកំណត់សមាសភាគមូលធនជា ភាគសំណល់បន្ទាប់ពីកាត់កងពីតម្លៃសមស្របនៃឧបករណ៍ទាំងមូល។<br><br>គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ ក.ស.ស បានកត់ត្រាបំណុលនៃភាគលាភធានាអប្បបរមាត្រូវបង់ ក្នុងទឹកប្រាក់ចំនួន ១៤.១៨០ លានរៀល និងសមាសភាគមូលធន ក្នុងទឹកប្រាក់ចំនួន ៩៣.៨៩២ លានរៀល។<br><br>យើងខ្ញុំផ្តោតលើផ្នែកទាំងនេះ ដោយសារវាពាក់ព័ន្ធនឹងគណៈគ្រប់គ្រងក្នុងការកត់ត្រាគណនេយ្យ និងការកំណត់អត្តសញ្ញាណ។ សមតុល្យភាគលាភធានាអប្បបរមាត្រូវបង់ មានចំនួនជាសារវន្តចំពោះរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។ | នីតិវិធីរបស់យើងខ្ញុំ ទាក់ទិនទៅនឹងការចូលរួមរបស់គណៈគ្រប់គ្រងទៅលើការកំណត់អត្តសញ្ញាណក្នុងការកត់ត្រាគណនេយ្យ រួមមាន៖<br><br>ស្វែងយល់ និងវាយតម្លៃគោលការណ៍ និងនីតិវិធីរបស់គណៈគ្រប់គ្រង ស្តីពីភាគលាភធានាអប្បបរមា។<br><br>ចូលរួមពីអ្នកជំនាញបច្ចេកទេស ផ្នែកគណនេយ្យរបស់យើងខ្ញុំ ដើម្បីធ្វើការវាយតម្លៃការកត់ត្រាគណនេយ្យឧបករណ៍ ដែលមានសមាសភាគមូលធន និងបំណុល ចំពោះភាគហ៊ុនប្រភេទ "គ" ដែលបានបោះផ្សាយ។<br><br>ពិនិត្យការគណនាភាគលាភធានាអប្បបរមាត្រូវបង់ ផ្អែកទៅលើតម្លៃសមស្រប នៃលំហូរសាច់ប្រាក់ចេញប៉ាន់ស្មាននាពេលអនាគត ដែលត្រូវបានកំណត់ដោយកត្តាអប្បហារ ដោយប្រើអត្រាការប្រាក់មានប្រសិទ្ធភាពនាពេលបច្ចុប្បន្ន និង<br><br>វាយតម្លៃអំពីភាពសមស្រប នៃអត្រាការប្រាក់មានប្រសិទ្ធភាពដែលបានប្រើជាកត្តាអប្បហារ ដោយធ្វើការបញ្ជាក់ជាមួយនឹង អត្រាការប្រាក់មធ្យម ដែលយើងខ្ញុំចាត់ទុកថាមានលក្ខខណ្ឌប្រហាក់ប្រហែលគ្នា ក៏ដូចជាមានប្រភេទរូបិយវត្ថុ និងទិន្នផលឥណទានប្រហាក់ប្រហែលគ្នា។<br><br>ផ្អែកទៅតាមនីតិវិធីសវនកម្មដែលយើងខ្ញុំបានបំពេញ យើងខ្ញុំយល់ស្របថា ការកត់ត្រាគណនេយ្យភាគលាភធានាអប្បបរមាត្រូវបង់របស់គណៈគ្រប់គ្រង គឺមានភាពសមស្រប។ |

## ព័ត៌មានផ្សេងៗ

គណៈគ្រប់គ្រងទទួលខុសត្រូវចំពោះព័ត៌មានផ្សេងៗ។ ព័ត៌មានផ្សេងៗរួមមានរបាយការណ៍របស់ក្រុមប្រឹក្សាភិបាល និងព័ត៌មានដែលរួមបញ្ចូលនៅក្នុងរបាយការណ៍ប្រចាំឆ្នាំ ប៉ុន្តែមិនរួមបញ្ចូលនូវរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍សវនកររបស់យើងខ្ញុំទេ។ របាយការណ៍ប្រចាំឆ្នាំត្រូវបានរំពឹងថានឹងផ្តល់ឱ្យយើងខ្ញុំ បន្ទាប់ពីកាលបរិច្ឆេទនៃរបាយការណ៍សវនករនេះ។

មតិយោបល់របស់យើងខ្ញុំចំពោះរបាយការណ៍ហិរញ្ញវត្ថុ ពុំបានគ្របដណ្តប់ទៅលើព័ត៌មានផ្សេងៗនោះទេ ហើយយើងខ្ញុំមិនធ្វើការធានាអះអាងចំពោះព័ត៌មានទាំងនោះទេ។

ទាក់ទងនឹងការធ្វើសវនកម្មរបស់យើងខ្ញុំទៅលើរបាយការណ៍ហិរញ្ញវត្ថុ យើងខ្ញុំទទួលខុសត្រូវក្នុងការអានព័ត៌មានផ្សេងៗដែលបានរៀបរាប់ខាងលើ ដើម្បីពិចារណាថាតើព័ត៌មានផ្សេងៗទាំងនោះមានភាពផ្ទុយគ្នាជាសារវន្តពីរបាយការណ៍ហិរញ្ញវត្ថុ ឬផ្ទុយពីការយល់ដឹងរបស់យើងខ្ញុំ ផ្អែកលើលទ្ធផលនៃការធ្វើសវនកម្ម ឬមានការរាយការណ៍ពីកំហុសឆ្គងជាសារវន្តដែលបានកើតឡើងឬទេ។

ផ្អែកទៅលើការងារដែលយើងខ្ញុំបានបំពេញ ប្រសិនបើយើងខ្ញុំសន្និដ្ឋានថាមានកំហុសឆ្គងជាសារវន្តដែលកើតចេញពីព័ត៌មានផ្សេងៗទាំងនេះ យើងខ្ញុំត្រូវរាយការណ៍ពីអង្គហេតុនៃកំហុសឆ្គងទាំងនោះ។ យើងខ្ញុំមិនមានអ្វីត្រូវរាយការណ៍ចំពោះបញ្ហានេះទេ។

## ការទទួលខុសត្រូវរបស់គណៈគ្រប់គ្រង និងអ្នកដែលទទួលបន្ទុកអភិបាលកិច្ចរបាយការណ៍ហិរញ្ញវត្ថុ

គណៈគ្រប់គ្រងទទួលខុសត្រូវក្នុងការរៀបចំ និងបង្ហាញរបាយការណ៍ហិរញ្ញវត្ថុឱ្យបានត្រឹមត្រូវ ដោយអនុលោមទៅតាម CIFRS និងទទួលខុសត្រូវលើការត្រួតពិនិត្យផ្ទៃក្នុង ដែលគណៈគ្រប់គ្រងកំណត់ថាមានភាពចាំបាច់ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ឱ្យចៀសផុតពីការរាយការណ៍ខុសជាសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំ ឬកំហុសឆ្គងផ្សេងៗ។

ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ គណៈគ្រប់គ្រងទទួលខុសត្រូវក្នុងការវាយតម្លៃអំពីលទ្ធភាពរបស់ ក.ស.ស ក្នុងការបន្តនិរន្តរភាពអាជីវកម្ម ការលាតត្រដាងព័ត៌មានដែលពាក់ព័ន្ធ ក៏ដូចជាបញ្ហាផ្សេងៗដែលទាក់ទិនទៅនឹងនិរន្តរភាពអាជីវកម្ម ដោយប្រើមូលដ្ឋានគណនេយ្យសម្រាប់និរន្តរភាពអាជីវកម្ម លើកលែងតែគណៈគ្រប់គ្រងគ្រោងនឹងបិទអាជីវកម្មរបស់ ក.ស.ស ឬបញ្ឈប់ប្រតិបត្តិការ ដោយមិនមានជម្រើសណាផ្សេងប្រកបដោយភាពប្រាកដប្រជាណាមួយ។

អ្នកដែលទទួលបន្ទុកលើអភិបាលកិច្ច ត្រូវមានការទទួលខុសត្រូវក្នុងការត្រួតពិនិត្យដំណើរការនៃការរាយការណ៍ហិរញ្ញវត្ថុរបស់ ក.ស.ស ។

**ការទទួលខុសត្រូវរបស់សវនករ ក្នុងការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ**

គោលបំណងរបស់យើងខ្ញុំគឺស្វែងរកអំណះអំណាងដែលសមហេតុផល ថារបាយការណ៍ហិរញ្ញវត្ថុទាំងមូលពុំមានការរាយការណ៍ខុសជាសារវន្តដែលបណ្តាលមកពីការក្លែងបន្លំ ឬកំហុសឆ្គងផ្សេងៗ និងចេញរបាយការណ៍សវនកម្មដែលមានមតិយោបល់របស់យើងខ្ញុំ។ ការអះអាងដែលសមហេតុផលគឺជាការអះអាងក្នុងកម្រិតខ្ពស់ ប៉ុន្តែវាមិនមែនជាការធានាថាសវនកម្មដែលបានធ្វើឡើងដោយអនុលោមទៅតាមស្តង់ដារសវនកម្ម តែងតែរកឃើញជានិច្ចនូវការរាយការណ៍ខុសជាសារវន្តដែលបានកើតឡើងនោះទេ។ ការរាយការណ៍ខុសអាចកើតឡើងពីការក្លែងបន្លំ ឬកំហុសឆ្គង ហើយវាត្រូវបានចាត់ទុកថាមានលក្ខណៈជាសារវន្ត ប្រសិនបើការរាយការណ៍ខុសនីមួយៗ ឬការរាយការណ៍ខុសសរុប អាចត្រូវបានរំពឹងថាវាជះឥទ្ធិពលលើមូលដ្ឋាននៃការសម្រេចចិត្តផ្នែកសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុទាំងនេះ។

ផ្នែកមួយនៃការធ្វើសវនកម្មដែលអនុលោមទៅតាមស្តង់ដារសវនកម្ម តម្រូវឱ្យយើងខ្ញុំប្រើប្រាស់ការវិនិច្ឆ័យ និងរក្សាភាពងឿងឆ្ងល់ប្រកបដោយវិជ្ជាជីវៈក្នុងពេលបំពេញការងារសវនកម្មរបស់យើងខ្ញុំ ហើយយើងខ្ញុំៈ

កំណត់ និងវាយតម្លៃហានិភ័យនៃភាពខុសជាសារវន្តនៃរបាយការណ៍ហិរញ្ញវត្ថុ ដែលអាចបណ្តាលមកពីការក្លែងបន្លំ ឬកំហុសឆ្គងផ្សេងៗ ដោយតាក់តែងនីតិវិធីសវនកម្ម និងធ្វើសវនកម្មដើម្បីឆ្លើយតបទៅនឹងហានិភ័យ ទាំងនោះ និងស្វែងរកភស្តុតាងសវនកម្មគ្រប់គ្រាន់និងសមស្រប ដើម្បីធ្វើជាមូលដ្ឋានសម្រាប់ការបញ្ចេញមតិយោបល់របស់យើងខ្ញុំ។ ហានិភ័យដែលបណ្តាលមកពីការរកមិនឃើញកំហុសជាសារវន្តពីការក្លែងបន្លំ វាមានទំហំធំជាងហានិភ័យដែលបណ្តាលមកពីកំហុសឆ្គងអចេតនា។ ការក្លែងបន្លំរួមមាន ការសមគំនិត ការក្លែងបន្លំឯកសារ ការលុបបំបាត់ដោយចេតនា ការបង្ហាញខុស ឬការរំលងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង។

ស្វែងយល់អំពីប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងដែលពាក់ព័ន្ធទៅនឹងសវនកម្ម ដើម្បីតាក់តែងនីតិវិធីសវនកម្មដែលសមស្របទៅតាមកាលៈទេសៈ ប៉ុន្តែមិនបញ្ចេញមតិយោបល់របស់យើងខ្ញុំទៅលើប្រសិទ្ធភាពនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់ ក.ស.ស ទេ។

វាយតម្លៃអំពីភាពសមស្របនៃគោលការណ៍គណនេយ្យដែលបានប្រើប្រាស់ ភាពសមហេតុផលនៃការប៉ាន់ស្មានគណនេយ្យ និងការលាតត្រដាងពាក់ព័ន្ធ ដែលគណៈគ្រប់គ្រងបានធ្វើឡើង។

សន្និដ្ឋានលើភាពសមស្របនៃការប្រើប្រាស់មូលដ្ឋានគណនេយ្យនិរន្តរភាពអាជីវកម្ម របស់គណៈគ្រប់គ្រងអាស្រ័យទៅលើភស្តុតាងសវនកម្មដែលយើងខ្ញុំទទួលបាន ថាតើវាមានភាពមិនច្បាស់លាស់ជាសារវន្តដែលបានកើតឡើងកម្រិតណាពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍ ឬលក្ខខណ្ឌនានា អាចបណ្តាលឱ្យមានការសង្ស័យជាដុំកំភួនទៅលើលទ្ធភាពរបស់ ក.ស.ស ក្នុងការបន្តនិរន្តរភាពអាជីវកម្មរបស់ខ្លួនដែរឬទេ។ ប្រសិនបើយើងខ្ញុំសន្និដ្ឋានថា វាមានភាពមិនច្បាស់លាស់ជាសារវន្តបានកើតឡើង នោះយើងខ្ញុំត្រូវធ្វើការបង្ហាញនៅក្នុងរបាយការណ៍សវនកម្ម ដើម្បីទាញចំណាប់អារម្មណ៍អ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុ ចំពោះការលាតត្រដាងព័ត៌មាននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ឬប្រសិនបើការលាតត្រដាងនោះនៅមិនទាន់គ្រប់គ្រាន់ទៀត យើងខ្ញុំត្រូវធ្វើការកែប្រែមតិយោបល់របស់យើងខ្ញុំ។ សេចក្តីសន្និដ្ឋានសរុបរបស់យើងខ្ញុំ អាស្រ័យទៅលើភស្តុតាងសវនកម្មដែលយើងខ្ញុំទទួលបាន រហូតដល់ថ្ងៃចុះហត្ថលេខាលើរបាយការណ៍សវនកម្មនេះ។ ទោះជាយ៉ាងណាក៏ដោយ ព្រឹត្តិការណ៍ ឬលក្ខខណ្ឌនានាក្នុងពេលអនាគត អាចបណ្តាលឱ្យ ក.ស.ស ឈប់បន្តនិរន្តរភាពអាជីវកម្ម។

វាយតម្លៃការបង្ហាញទូទៅ រចនាសម្ព័ន្ធ និងខ្លឹមសារក្នុងរបាយការណ៍ហិរញ្ញវត្ថុ រួមទាំងការលាតត្រដាងព័ត៌មានផ្សេងៗ និងកំណត់ថារបាយការណ៍ហិរញ្ញវត្ថុបង្ហាញពីប្រតិបត្តិការ និងព្រឹត្តិការណ៍ជាក់ស្តែង ដែលអាចធ្វើឱ្យមានការបង្ហាញត្រឹមត្រូវ។

យើងខ្ញុំបានរាយការណ៍ជូនអ្នកដែលទទួលបន្ទុកអភិបាលកិច្ចនូវបញ្ហាផ្សេងៗដូចជា ទំហំការងារ និងពេលវេលាសវនកម្ម ព្រមទាំងបញ្ហាសវនកម្មសំខាន់ៗ រួមទាំងរាយការណ៍ពីភាពខ្វះខាតជាសារវន្តនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលយើងខ្ញុំបានរកឃើញក្នុងការធ្វើសវនកម្មរបស់យើងខ្ញុំ។

យើងខ្ញុំក៏ផ្តល់ជូនចំពោះអ្នកទទួលបន្ទុកអភិបាលកិច្ច នូវការអះអាងថាយើងខ្ញុំបានអនុត្តតាមតម្រូវការផ្នែកវិជ្ជាជីវៈពាក់ព័ន្ធ ទាក់ទិននឹងឯករាជ្យ ព្រមទាំងជម្រាប់ជូនពួកគេអំពីទំនាក់ទំនងនានាទាំងអស់ និងបញ្ហាផ្សេងៗទៀត ដែលអាចចាត់ទុកថាមានឥទ្ធិពលចំពោះឯករាជ្យរបស់យើងខ្ញុំ និងវិធានការប្រព័ន្ធការពាររបស់យើងខ្ញុំ។

ស្តែងចេញពីបញ្ហានានាដែលយើងខ្ញុំបានជម្រាបជូនអ្នកទទួលបន្ទុកអភិបាលកិច្ច យើងខ្ញុំកំណត់ពីបញ្ហានានា ដែលមានភាពជាសារវន្តក្នុងការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុក្នុងការិយបរិច្ឆេទបច្ចុប្បន្ន ដូចនេះបញ្ហានេះជាបញ្ហាសវនកម្មសំខាន់។ យើងខ្ញុំពណ៌នាបញ្ហាទាំងនេះនៅក្នុងរបាយការណ៍សវនកម្មរបស់យើងខ្ញុំ លើកលែងតែក្នុងករណីដែលច្បាប់ ឬបទប្បញ្ញត្តិហាមប្រាមការបង្ហាញបញ្ហាទាំងនេះជាសាធារណៈ ឬលើកលែងតែក្នុងករណីដ៏កម្របំផុតដែលយើងខ្ញុំកំណត់ថាបញ្ហានេះមិនគួរបញ្ចូលទៅក្នុងរបាយការណ៍របស់យើងខ្ញុំ ដោយមូលហេតុថាវានឹងមានផលអវិជ្ជមាននានា ដែលនាំឱ្យមានផលប៉ះពាល់ដល់ផលប្រយោជន៍សាធារណៈ ចំពោះការរាយការណ៍បែបនេះ។

**ជ. ក្រុមហ៊ុន** PricewaterhouseCoopers (Cambodia) Ltd.

**ឡាង ហ៊ី**
Partner

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
កាលបរិច្ឆេទ៖ ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៨

# កំពង់ផែស្វយ័តក្រុងព្រះសីហនុ

## របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ
## នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧

| | កំណត់សម្គាល់ | ២០១៧ ពាន់រៀល | ២០១៦ ពាន់រៀល |
|---|---|---|---|
| **ទ្រព្យសកម្ម** | | | |
| **ទ្រព្យសកម្មរយៈពេលវែង** | | | |
| ទ្រព្យសម្បត្តិ និងបរិក្ខារ | ៦ | ៨០៨.៨៧០.៣៣៨ | ៧៣៤.៧៤៣.៧៩២ |
| ទ្រព្យសម្បត្តិវិនិយោគ | ៧ | ២៨៣.៦៧២.០៦៩ | ២៥៩.១៣៥.៩៥០ |
| ទ្រព្យសកម្មអរូបី | ៨ | ៨.៥៥៧.៧០២ | ៩.០២០.៥៩២ |
| ឥណទានផ្តល់ឱ្យបុគ្គលិក | ៩ | ៥.៣០៥.១១៣ | - |
| | | ១.១០៦.៤០៥.២២២ | ១.០០២.៩០០.៣៣៤ |
| **ទ្រព្យសកម្មរយៈពេលខ្លី** | | | |
| ឥណទានផ្តល់ឱ្យបុគ្គលិក | ៩ | ១.៦១៨.៤២៥ | - |
| សន្និធិ | ១០ | ៨.៤៤៣.៥៦៦ | ៦.៧៩៥.៩១១ |
| គណនីអតិថិជនពាណិជ្ជកម្ម និងគណនីអតិថិជនផ្សេងៗ | ១១ | ៣៩.៧៦៧.៣៩៥ | ២៥.១០៤.៥៧០ |
| ប្រាក់បញ្ញើរយៈពេលខ្លីនៅធនាគារ | ១២ | ៧៣.១៩៤.២០១ | ១៣.៤៧៩.២២៨ |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូល | ១៣ | ៥១.០៨១.២២៩ | ៣៤.៦៥១.៦០៤ |
| | | ១៧៤.១០៤.៨១៦ | ៨០.០៣១.៣១៣ |
| **ទ្រព្យសកម្មសរុប** | | ១.២៨០.៥១០.០៣៨ | ១.០៨២.៩៣១.៦៤៧ |
| **មូលធន និងបំណុល** | | | |
| **មូលធន** | | | |
| ដើមទុន និងបុព្វលាភភាគហ៊ុន | ១៤ | ៥១៨.០១៨.០៦៣ | ៤២៨.៨៥៩.៨៣៦ |
| ទុនបម្រុងផ្សេងៗ | ១៥ | ១៧.៦៤១.៩១៤ | ១៤.៩៦៩.៨៦៧ |
| ចំណេញរក្សាទុក | | ១១០.៩៥០.៥៧៧ | ៩០.៧៨៣.៣០៨ |
| **មូលធនសរុប** | | ៦៤៦.៦១០.៥៥៤ | ៥៣៤.៦១៣.០១១ |
| **បំណុល** | | | |
| **បំណុលរយៈពេលវែង** | | | |
| ប្រាក់កម្ចី | ១៦ | ៥០៣.៥៣៧.៣០៦ | ៤៦៣.២៣៥.៣៧២ |
| កាតព្វកិច្ចអត្ថប្រយោជន៍សោធននិវត្តន៍ | ១៧ | ៤១.០០៨.២៥៥ | ៤០.៣០១.៤១១ |
| ភាគលាភអប្បបរមាជានាត្រូវបង់ | ១៤(ខ) | ៩.៣៥៦.២៦០ | - |
| បំណុលពន្ធពន្យារ | ២៧ | ៧.៦១៧.២០០ | - |
| ចំណូលពន្យារ | ១៨ | ៥.៧៩៥.១១៤ | ៥.៩២៨.៣៣៥ |
| | | ៥៦៧.៣១៤.១៣៥ | ៥០៩.៤៦៥.១១៨ |
| **បំណុលរយៈពេលខ្លី** | | | |
| ភាគលាភអប្បបរមាជានាត្រូវបង់ | ១៤(ខ) | ៥.៤០៣.៦៣៤ | - |
| បំណុលពន្ធលើប្រាក់ចំណេញ | | ៣.៤៦២.៤១៨ | ៦.៤៦២.៦៧៥ |
| គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម និងគណនីអ្នកផ្គត់ផ្គង់ផ្សេងៗ | ១៩ | ៣៥.៨៨៨.៥០០ | ១៥.៧១៣.៨៨៧ |
| ប្រាក់កម្ចី | ១៦ | ២១.៦៩៧.៥៧៦ | ១៦.៥៨៣.៧៣៥ |
| ចំណូលពន្យារ | ១៨ | ១៣៣.២២១ | ១៣៣.២២១ |
| | | ៦៦.៥៨៥.៣៤៩ | ៣៨.៨៩៣.៥១៨ |
| **បំណុលសរុប** | | ៦៣៣.៨៩៩.៤៨៤ | ៥៤៨.៣១៨.៦៣៦ |
| **មូលធន និងបំណុលសរុប** | | ១.២៨០.៥១០.០៣៨ | ១.០៨២.៩៣១.៦៤៧ |

កំណត់សម្គាល់ដែលបានភ្ជាប់មកជាមួយពីទំព័រទី ១៥ ដល់ ទំព័រទី ៦៣ ជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

## របាយការណ៍ចំណេញ-ខាត និងលទ្ធផលលម្អិតផ្សេងៗ
## សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧

| | កំណត់សម្គាល់ | ២០១៧ ពាន់រៀល | ២០១៦ ពាន់រៀល |
|---|---|---|---|
| **ចំណូល** | | | |
| ចំណូល | ២០ | ២២៧.៣៩៧.៨៣៥ | ២០៨.៩៨១.២៤៩ |
| **ចំណាយ** | | | |
| ចំណាយសម្ភារផ្គត់ផ្គង់ | ២១ | (៥៤.៣៨៩.៦៥៥) | (៤៨.៦០២.០៨១) |
| ចំណាយប្រាក់បៀវត្សរ៍ ប្រាក់ឈ្នួល និងចំណាយពាក់ព័ន្ធ | ២២ | (៦១.៦៣៤.៨៨៦) | (៥៥.៣៧៧.៤៤៤) |
| ចំណាយរំលស់ទ្រព្យសម្បត្តិ និងបរិក្ខារ និងរំលស់ទ្រព្យសកម្មអរូបី | ២៣ | (២៥.២៣៩.៩៣៦) | (២២.១៧៩.៥០៨) |
| ចំណាយជួសជុល និងថែទាំ | | (៥.១៤២.២៩៦) | (៥.៩៤៦.៧២៣) |
| ចំណាយផ្សេងៗ | ២៤ | (២១.៩៥៧.១៤៧) | (២០.៦២១.៧៩៩) |
| ខាតផ្សេងៗ – សុទ្ធ | ២៥ | (៦៨៧.៥៧៥) | (១.៦៣៩.០២៣) |
| | | (១៦៨.៩៩១.៤៩៥) | (១៥៤.៣៦៦.៥៧៨) |
| ចំណេញប្រតិបត្តិការ | | ៥៨.៤០៦.៣៤០ | ៥៤.៦១៤.៦៧១ |
| ចំណូលហិរញ្ញវត្ថុ | | ១.៩៧៥.០៨៤ | ២៩៣.៦៤៨ |
| ចំណាយហិរញ្ញវត្ថុ | | (២២.៥២៦.៧៩២) | (១៩.០៦២.១៤៤) |
| ចំណាយហិរញ្ញវត្ថុ - សុទ្ធ | ២៦ | (២០.៥៥១.៧០៨) | (១៨.៧៦៨.៤៩៦) |
| **ចំណេញមុនបង់ពន្ធលើប្រាក់ចំណេញ** | | ៣៧.៨៥៤.៦៣២ | ៣៥.៨៤៦.១៧៥ |
| ចំណាយពន្ធលើប្រាក់ចំណេញ | ២៧ | (១២.៧១៥.៣១៦) | (៩.១២៥.៧០៣) |
| **ចំណេញក្នុងឆ្នាំ** | | ២៥.១៣៩.៣១៦ | ២៦.៧២០.៤៧២ |
| **ចំណូលលម្អិតផ្សេងៗ** | | | |
| ខ្ទង់ដែលមិនត្រូវបានចាត់ថ្នាក់ឡើងវិញក្នុងចំណេញ – ខាត៖ | | - | - |
| **លទ្ធផលលម្អិតសរុបក្នុងឆ្នាំ** | | - | - |
| **ចំណេញរបស់ភាគហ៊ុនិក** | | ២៥.១៣៩.៣១៦ | ២៦.៧២០.៤៧២ |
| **លទ្ធផលលម្អិតសរុបរបស់ភាគហ៊ុនិក** | | ២៥.១៣៩.៣១៦ | ២៦.៧២០.៤៧២ |

ចំណេញក្នុងមួយភាគហ៊ុន (ជាពាន់រៀល) របស់ភាគហ៊ុនិករបស់ ក.ស.ស សម្រាប់ដំណាច់ឆ្នាំនេះមានដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ចំណេញក្នុងមួយភាគហ៊ុនមូលដ្ឋាន | ២៨ | ៣២៨,៤០ | ៤១៥,៣៧ |
| ចំណេញក្នុងមួយភាគហ៊ុនថយចុះ | ២៨ | ៣២៨,៤០ | ៤១៥,៣៧ |

កំណត់សម្គាល់ដែលបានភ្ជាប់មកជាមួយពីទំព័រទី ១៥ ដល់ ទំព័រទី ៦៣ ជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

# របាយការណ៍បម្រែបម្រួលមូលធន
# សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧

| | ដែលជារបស់ភាគហ៊ុនិក | | | |
|---|---|---|---|---|
| | ដើមទុន និង បុព្វលាភភាគហ៊ុន ពាន់រៀល | ទុនបម្រុងផ្សេងៗ ពាន់រៀល | ចំណេញរក្សាទុក ពាន់រៀល | សរុប ពាន់រៀល |
| សមតុល្យនៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១៦ | ៤២៨.៨៥៩.៨៣៦ | ១២.២៤៥.៤០៥ | ៦៩.០៨៧.២៩៨ | ៥១០.១៩២.៥៣៩ |
| ចំណេញក្នុងឆ្នាំ | - | - | ២៦.៧២០.៤៧២ | ២៦.៧២០.៤៧២ |
| ចំណូលលម្អិតសរុប | - | - | ២៦.៧២០.៤៧២ | ២៦.៧២០.៤៧២ |
| ផ្ទេរទៅទុនបម្រុង (កំណត់សម្គាល់ ១៥) | - | ២.៧២៤.៤៦២ | (២.៧២៤.៤៦២) | - |
| ភាគលាភបានបង់ | - | - | (២.៣០០.០០០) | (២.៣០០.០០០) |
| **សមតុល្យនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦** | ៤២៨.៨៥៩.៨៣៦ | ១៤.៩៦៩.៨៦៧ | ៩០.៧៨៣.៣០៨ | ៥៣៤.៦១៣.០១១ |
| សមតុល្យនៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១៧ | ៤២៨.៨៥៩.៨៣៦ | ១៤.៩៦៩.៨៦៧ | ៩០.៧៨៣.៣០៨ | ៥៣៤.៦១៣.០១១ |
| ចំណេញក្នុងឆ្នាំ | - | - | ២៥.១៣៩.៣១៦ | ២៥.១៣៩.៣១៦ |
| ចំណូលលម្អិតសរុប | - | - | ២៥.១៣៩.៣១៦ | ២៥.១៣៩.៣១៦ |
| សាច់ប្រាក់បានពីការចេញភាគហ៊ុន | ៨៩.១៥៨.២២៧ | - | - | ៨៩.១៥៨.២២៧ |
| ផ្ទេរទៅទុនបម្រុង (កំណត់សម្គាល់ ១៥) | - | ២.៦៧២.០៤៧ | (២.៦៧២.០៤៧) | - |
| ភាគលាភបានបង់ | - | - | (២.៣០០.០០០) | (២.៣០០.០០០) |
| **សមតុល្យនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧** | ៥១៨.០១៨.០៦៣ | ១៧.៦៤១.៩១៤ | ១១០.៩៥០.៥៧៧ | ៦៤៦.៦១០.៥៥៤ |

កំណត់សម្គាល់ដែលបានភ្ជាប់មកជាមួយពីទំព័រទី ១៥ ដល់ ទំព័រទី ៦៣ ជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

**កំពង់ផែស្វយ័តក្រុងព្រះសីហនុ**

## របាយការណ៍លំហូរសាច់ប្រាក់
## សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧

| | កំណត់សម្គាល់ | ២០១៧ ពាន់រៀល | ២០១៦ ពាន់រៀល |
|---|---|---|---|
| **លំហូរសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការ** | | | |
| សាច់ប្រាក់បានពីប្រតិបត្តិការ | ២៩ | ៧៦.៦៥០.៧៦៧ | ៧៨.៥១៥.២៤៣ |
| ពន្ធលើប្រាក់ចំណេញបានបង់ | | (៨.០៩៨.៣៧៣) | (៦.២៣៨.៩៥៦) |
| កាតព្វកិច្ចអត្ថប្រយោជន៍សោធននិវត្តន៍បានបង់ | ១៧ | (៣.៤៤៧.១៥៦) | (៣.២៦០.៣៧៧) |
| សាច់ប្រាក់បានមកពីសកម្មភាពប្រតិបត្តិការ | | ៦៥.១០៥.២៣៨ | ៦៩.០១៥.៩១០ |
| **លំហូរសាច់ប្រាក់ពីសកម្មភាពវិនិយោគ** | | | |
| ការទិញទ្រព្យសម្បត្តិ និងបរិក្ខារ (*) | ៦ | (៧៣.៥៨៩.៧៩៣) | (៨០.០២៣.៥៦៨) |
| ការទិញទ្រព្យសម្បត្តិវិនិយោគ | ៧ | (៣០.៦០៧.៩៩២) | (៥៨១.១៦២) |
| ការទិញទ្រព្យសកម្មអរូបី | ៨ | (៥៩៥.០២៣) | (៧២៩.៣៨៨) |
| ឥណទានផ្តល់ឱ្យបុគ្គលិក | | (១០.២៦៦.៩០៤) | - |
| ប្រាក់ដើមបានទទួលពីឥណទានបុគ្គលិក | ៩ | ១.២៨៣.៣៦៣ | - |
| ការដាក់ប្រាក់បញ្ញើរយៈពេលខ្លីនៅធនាគារ | | (៥៩.៧១៤.៩៧៣) | (២៦៦.៤២៨) |
| ការប្រាក់បានទទួល | | ២៦៨.៦០៦ | ២៩៣.៦៤៧ |
| សាច់ប្រាក់បានប្រើក្នុងសកម្មភាពវិនិយោគ | | (១៧៣.២២២.៧១៦) | (៨១.៣០៦.៨៩៩) |
| **លំហូរសាច់ប្រាក់ពីសកម្មភាពហិរញ្ញប្បទាន** | | | |
| សាច់ប្រាក់បានពីការបោះផ្សាយភាគហ៊ុនលក់ - សុទ្ធ | | ១០៣.៣៣៩.០៦៩ | - |
| ភាគលាភបានបង់ | | (២.៣០០.០០០) | (២.៣០០.០០០) |
| សាច់ប្រាក់បានមកពីប្រាក់កម្ចី | | ៤៨.៩៣៥.៤៨១ | ៣០.០៩១.១៩៤ |
| ការបង់សងប្រាក់កម្ចី | | (១៤.៦៧៨.៩១៥) | (១៤.១៨៣.៩៧៩) |
| ការប្រាក់បានបង់ | | (១០.៧៤៨.៥៣២) | (១១.៨៩៤.៤២៦) |
| សាច់ប្រាក់បានពីសកម្មភាពហិរញ្ញប្បទាន | | ១២៤.៥៤៧.១០៣ | ១.៧១២.៧៨៩ |
| **កំណើន/(ថយចុះ)សាច់ប្រាក់ និងសាច់ប្រាក់សមមូលសុទ្ធ** | | ១៦.៤២៩.៦២៥ | (១០.៥៧៨.២០០) |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូលដើមឆ្នាំ | | ៣៤.៦៥១.៦០៤ | ៤៥.២២៩.៨០៤ |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលចុងឆ្នាំ** | ១៣ | ៥១.០៨១.២២៩ | ៣៤.៦៥១.៦០៤ |

(*) សូមយោងទៅកំណត់សម្គាល់ ៦ ចំពោះប្រតិបត្តិការជាសាច់ប្រាក់ និងប្រតិបត្តិការមិនមែនសាច់ប្រាក់ ដែលទាក់ទងនឹងការទិញទ្រព្យសម្បត្តិ និងបរិក្ខារ ។

កំណត់សម្គាល់ដែលបានភ្ជាប់មកជាមួយពីទំព័រទី ១៥ ដល់ ទំព័រទី ៦៣ ជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

## កំពង់ផែស្វយ័តក្រុងព្រះសីហនុ

## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧

### ១. ព័ត៌មានទូទៅ

កំពង់ផែស្វយ័តក្រុងព្រះសីហនុ (ហៅកាត់ថា "ក.ស.ស") គឺជាគ្រឹះស្ថានស្វយ័តសាធារណៈ ដែលស្ថិតក្រោមការគ្រប់គ្រងផ្នែកបច្ចេកទេសរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន និងស្ថិតក្រោមការគ្រប់គ្រងផ្នែកហិរញ្ញវត្ថុ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ហើយមានការិយាល័យកណ្តាលនៅក្រុងព្រះសីហនុ ព្រះរាជាណាចក្រកម្ពុជា។

ក.ស.ស គឺជានីតិអង្គភាពដែលមានលក្ខណៈស្វយ័តទាំងផ្នែករដ្ឋបាល និងហិរញ្ញវត្ថុ និងត្រូវបានបង្កើតឡើងដោយអនុលោមទៅតាមអនុក្រឹតលេខ ៥០ អនក្រ.បក ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៩៨ ដែលបានផ្តល់ស្ថានភាពឱ្យក្រុមហ៊ុនជាសហគ្រាសសាធារណៈ។

ក.ស.ស បានចុះបញ្ជីពាណិជ្ជកម្មនៅក្រសួងពាណិជ្ជកម្ម ក្រោមវិញ្ញាបនបត្រចុះបញ្ជីលេខ Co.៤៧៨៤ET/២០១៧ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៧ ហើយភាគហ៊ុនប្រភេទ "គ" របស់ ក.ស.ស ត្រូវបានចុះបញ្ជីនៅផ្សារមូលបត្រកម្ពុជា (ហៅកាត់ថា "ផ.ម.ក") នៅថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៧។

បច្ចុប្បន្ននេះ ក.ស.ស គឺជាកំពង់ផែសមុទ្រអន្តរជាតិ និងជាកំពង់ផែពាណិជ្ជកម្មតែមួយគត់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ អនុលោមទៅតាមអនុក្រឹតស្តីពីការបង្កើតកំពង់ផែស្វយ័តក្រុងព្រះសីហនុ បេសកកម្មរបស់ ក.ស.ស គឺផ្តល់សេវាកំពង់ផែសមុទ្រ និងសកម្មភាពផ្សេងៗដែលពាក់ព័ន្ធនឹងសេវាកំពង់ផែសមុទ្រ ដូចខាងក្រោម៖

- កណ្តុណធារកិច្ចនាំនាវាចេញ-ចូល និងផ្តល់ភស្តុភាដល់នាវា
- លើកដាក់ ផ្ទេរផ្ទុក និងដឹកជញ្ជូនទំនិញ
- ការងារថែរក្សា ស្តុកទំនិញ ឃ្លាំង-ទីលាន
- ការងារអភិវឌ្ឍន៍ ស្តារ និងពង្រីកហេដ្ឋារចនាសម្ព័ន្ធ ក.ស.ស ដែលមានស្រាប់
- ទទួលខុសត្រូវ និងចាត់ចែងលើការងារការពារសុវត្ថិភាព សន្តិសុខ សណ្តាប់ធ្នាប់ក្នុងតំបន់គ្រប់គ្រង
- ប្រកាន់គោលការណ៍ និងរបៀបកិច្ចការដូចនឹងការប្រកបអាជីវកម្ម
- គ្រប់គ្រងដឹកនាំ និងចាត់ចែងសកម្មភាពឱ្យមានប្រសិទ្ធភាពនិងមានការរីកចម្រើន
- ជួលតំបន់សេដ្ឋកិច្ចពិសេសរបស់ខ្លួន

ក្នុងឋានៈជាស្ថាប័នសាធារណៈ ក.ស.ស ទទួលពីរដ្ឋនូវអំណាច និងកាតព្វកិច្ចទាំងឡាយ ដើម្បីបំពេញបេសកកម្មស្របតាមកម្មវត្ថុរបស់ខ្លួន ។

ការិយាល័យចុះបញ្ជីរបស់ ក.ស.ស មានទីតាំងស្ថិតនៅតិវិថី សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ព្រះរាជាណាចក្រកម្ពុជា។

របាយការណ៍ហិរញ្ញវត្ថុត្រូវបានក្រុមប្រឹក្សាភិបាលអនុម័តឱ្យចេញផ្សាយនៅថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៨។

**កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ**
**សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧**

## ២. សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ

### ២.១ មូលដ្ឋានក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ

គោលការណ៍គណនេយ្យសំខាន់ៗដែលបានអនុវត្តក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុត្រូវបានបង្ហាញដូចខាងក្រោម។ គោលការណ៍ទាំងនេះត្រូវបានអនុវត្តស៊ីសង្វាក់គ្នាគ្រប់ឆ្នាំទាំងអស់ដែលបានបង្ហាញ លើកលែងតែមានការបញ្ជាក់ផ្សេងពីនេះ។

របាយការណ៍ហិរញ្ញវត្ថុរបស់ ក.ស.ស ត្រូវបានបង្ហាញជាប្រាក់រៀល ។

របាយការណ៍ហិរញ្ញវត្ថុត្រូវបានរៀបចំឡើងតាមវិធីសាស្ត្រថ្លៃដើម។

ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុដែលស្របទៅតាម CIFRS តម្រូវឱ្យប្រើប្រាស់ការប៉ាន់ស្មានគណនេយ្យជាក់លាក់សំខាន់ៗមួយចំនួន ហើយក៏តម្រូវឱ្យគណៈគ្រប់គ្រងធ្វើការវិនិច្ឆ័យនៅក្នុងអនុវត្តគោលការណ៍គណនេយ្យនេះដែរ។ ផ្នែកដែលទាក់ទងទៅនឹងការវិនិច្ឆ័យឬភាពស្មុគស្មាញក្នុងកម្រិតខ្ពស់ ឬផ្នែកដែលការសន្មត និងការប៉ាន់ស្មានមានលក្ខណៈជាសារវន្តចំពោះរបាយការណ៍ហិរញ្ញវត្ថុ ត្រូវបានលាតត្រដាងនៅក្នុងកំណត់សម្គាល់ ៤។

### ២.២ ស្តង់ដារគណនេយ្យថ្មី ស្តង់ដារគណនេយ្យដែលបានធ្វើវិសោធនកម្ម និងបំណកស្រាយផ្សេងៗ

### (i) ស្តង់ដារគណនេយ្យថ្មី ស្តង់ដារគណនេយ្យដែលបានធ្វើវិសោធនកម្ម និងបំណកស្រាយផ្សេងៗដែល ក.ស.ស បានអនុវត្ត

ក.ស.ស បានអនុវត្តស្តង់ដារដែលបានធ្វើវិសោធនកម្ម សម្រាប់ការិយបរិច្ឆេទគណនេយ្យចាប់ផ្តើមនៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១៧៖

CIAS 7 (វិសោធន*កម្ម*) ស្តីពី "ការផ្តួចផ្តើមការលាតត្រដាង"

ការអនុវត្តវិសោធនកម្មស្តង់ដារ CIAS 7 បានធ្វើឱ្យមានការលាតត្រដាងព័ត៌មានបន្ថែមទៀត ចំពោះការផ្ទៀងផ្ទាត់បំណុលដែលកើតពីសកម្មភាពហិរញ្ញប្បទាន ក្នុងកំណត់សម្គាល់ ២៩។

## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧

## ២. សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ (ត)

### ២.២ ស្តង់ដារគណនេយ្យថ្មី ស្តង់ដារគណនេយ្យដែលបានធ្វើវិសោធនកម្ម និងបំណកស្រាយផ្សេងៗ(ត)

### (ii) ស្តង់ដារគណនេយ្យថ្មី ស្តង់ដារគណនេយ្យដែលបានធ្វើវិសោធនកម្ម និងបំណកស្រាយផ្សេងៗ ដែលមិនទាន់បានអនុវត្ត

មានស្តង់ដារគណនេយ្យថ្មី និងបំណកស្រាយមួយចំនួន ដែលត្រូវបានចេញផ្សាយរួច ប៉ុន្តែមិនទាន់ចូលជាធរមានសម្រាប់ការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ ទេ។ ក.ស.ស មិនទាន់បានអនុវត្តស្តង់ដារគណនេយ្យថ្មី និង វិសោធនកម្មដែលបានចេញផ្សាយរួច ប៉ុន្តែមិនទាន់ចូលជាធរមាន ដូចខាងក្រោមនេះ មុនកាលកំណត់ទេ ៖

| CIFRS 9 ស្តីពី "ឧបករណ៍ហិរញ្ញវត្ថុ" | |
|---|---|
| ចរិតនៃការផ្លាស់ប្តូរ | CIFRS 9 បង្ហាញពីការធ្វើចំណាត់ថ្នាក់ ការវាស់វែង និងការឈប់កត់ត្រាទ្រព្យសកម្មហិរញ្ញវត្ថុ និង បំណុលហិរញ្ញវត្ថុ និងណែនាំអំពីក្បួនច្បាប់ថ្មីសម្រាប់គណនេយ្យការពារហានិភ័យ ក៏ដូចជាណែនាំអំពីគំរូថ្មីសម្រាប់ការថយចុះតម្លៃនៃទ្រព្យសកម្មហិរញ្ញវត្ថុ។ |
| ផលប៉ះពាល់ | ក.ស.ស បានពិនិត្យទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុរបស់ខ្លួនឡើងវិញ ហើយ ក.ស.ស រំពឹងថាមិនមានផលប៉ះពាល់ពីការអនុវត្តស្តង់ដារថ្មីនេះ នៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨ ទេ។<br><br>ស្តង់ដារនេះនឹងមិនបណ្តាលឱ្យមានផលប៉ះពាល់ដល់ការកត់ត្រាគណនេយ្យ ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុរបស់ ក.ស.ស ទេ ដោយសារ ក.ស.ស មានទ្រព្យសកម្មហិរញ្ញវត្ថុតែមួយប្រភេទប៉ុណ្ណោះ ដែលត្រូវបានចាត់ថ្នាក់តាមថ្លៃដើមដករំលស់ តាមការធ្វើចំណាត់ថ្នាក់ និងការវាស់វែងថ្មីនេះ។ មិនមានផលប៉ះពាល់ដទៃទៀតចំពោះបំណុលហិរញ្ញវត្ថុរបស់ ក.ស.ស ទេ ដោយសារតម្រូវការថ្មីនេះមានផលប៉ះពាល់តែចំពោះការកត់ត្រាគណនេយ្យបំណុលហិរញ្ញវត្ថុ ដែលត្រូវបានកំណត់តម្លៃតាមតម្លៃសមស្រប តាមរយៈចំណេញ-ខាត ប៉ុណ្ណោះ ហើយ ក.ស.ស មិនមានបំណុលប្រភេទនោះទេ។ ក្រុមហ៊ុនមិនមានគណនេយ្យសម្រាប់ការការពារហានិភ័យទេ។ គំរូថ្មីសម្រាប់ការថយចុះតម្លៃ តម្រូវឱ្យមានការកត់ត្រាសំវិធានធនសម្រាប់ការថយចុះតម្លៃ អាស្រ័យទៅតាមការខាតឥណទានរំពឹងទុក ជាជាងកត់ត្រាតែតាមការខាតឥណទានដែលបានកើតឡើង ដូចបានចែងក្នុង CIAS 39។ ស្តង់ដារនេះត្រូវអនុវត្តចំពោះទ្រព្យសកម្មហិរញ្ញវត្ថុ ដែលបានចាត់ថ្នាក់តាមថ្លៃដើមដករំលស់។ គណៈគ្រប់គ្រងកំពុងធ្វើការវាយតម្លៃ អំពីផលប៉ះពាល់នៃការអនុវត្តគំរូសម្រាប់ការថយចុះតម្លៃថ្មីនេះ ទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់ ក.ស.ស។<br><br>ស្តង់ដារថ្មីនេះ ក៏ណែនាំអំពីតម្រូវការក្នុងការលាតត្រដាងព័ត៌មានបន្ថែមទៀត និងណែនាំអំពីការផ្លាស់ប្តូរក្នុងការដាក់បង្ហាញព័ត៌មាន ដែលរំពឹងថានឹងមានការផ្លាស់ប្តូរចរិតលក្ខណៈ និងវិសាលភាព នៃការលាតត្រដាងព័ត៌មានរបស់ ក.ស.ស អំពីឧបករណ៍ហិរញ្ញវត្ថុរបស់ខ្លួន ជាពិសេសនៅក្នុងឆ្នាំនៃការអនុវត្តស្តង់ដារថ្មីនេះ។ |
| កាលបរិច្ឆេទដែលក្រុមហ៊ុនត្រូវអនុវត្ត | ស្តង់ដារនេះត្រូវអនុវត្តសម្រាប់ឆ្នាំហិរញ្ញវត្ថុដែលចាប់ផ្តើមនៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨ ឬការិយបរិច្ឆេទបន្ទាប់ពីនេះ។ ក.ស.ស នឹងអនុវត្តស្តង់ដារថ្មីនេះត្រលប់ថយក្រោយវិញ ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨ ជាមួយនឹងការអនុវត្តជាក់ស្តែងដែលបានអនុញ្ញាតតាមស្តង់ដារនេះ។ តួលេខប្រៀបធៀបសម្រាប់ឆ្នាំ ២០១៧ នឹងមិនត្រូវបានរាយការណ៍ឡើងវិញទេ។ |

២. សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ (ត)
២.២ ស្តង់ដារគណនេយ្យថ្មី ស្តង់ដារគណនេយ្យដែលបានធ្វើវិសោធនកម្ម និងបំណកស្រាយផ្សេងៗ(ត)
(ii) ស្តង់ដារគណនេយ្យថ្មី ស្តង់ដារគណនេយ្យដែលបានធ្វើវិសោធនកម្ម និងបំណកស្រាយផ្សេងៗ ដែលមិនទាន់បានអនុវត្ត (ត)

| CIFRS 15 ស្តីពី "ប្រាក់ចំណូលបានពីកិច្ចសន្យាជាមួយអតិថិជន" | |
|---|---|
| ចរិតនៃការផ្លាស់ប្តូរ | IASB បានចេញផ្សាយស្តង់ដារថ្មីមួយសម្រាប់ការកត់ត្រាប្រាក់ចំណូល។ ស្តង់ដារនេះនឹងជំនួសស្តង់ដារ CIAS 18 លើកិច្ចសន្យាសម្រាប់ទំនិញ និងសេវាផ្សេងៗ និងជំនួសស្តង់ដារ CIAS 11 លើកិច្ចសន្យាសាងសង់។ ស្តង់ដារថ្មីនេះ គឺផ្អែកទៅតាមគោលការណ៍ដែលប្រាក់ចំណូលត្រូវបានកត់ត្រា នៅពេលការគ្រប់គ្រងទំនិញ និងសេវាត្រូវបានផ្ទេរជូនអតិថិជនរួចរាល់។<br>ស្តង់ដារនេះអនុញ្ញាតឱ្យអនុវត្តវិធីសាស្ត្រត្រលប់ថយក្រោយទាំងស្រុង ឬ អនុវត្តត្រលប់ថយក្រោយខ្លះក៏បាន។ |
| ផលប៉ះពាល់ | គណៈគ្រប់គ្រងកំពុងធ្វើការវាយតម្លៃអំពីផលប៉ះពាល់នៃការអនុវត្តស្តង់ដារថ្មីនេះ ទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់ ក.ស.ស។ |
| កាលបរិច្ឆេទដែលក្រុមហ៊ុនត្រូវអនុវត្ត | ស្តង់ដារនេះត្រូវអនុវត្តសម្រាប់ឆ្នាំហិរញ្ញវត្ថុដែលចាប់ផ្តើមនៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨ ឬការិយបរិច្ឆេទបន្ទាប់ពីនេះ។ ក.ស.ស គ្រោងនឹងអនុវត្តស្តង់ដារនេះ ដោយប្រើវិធីសាស្ត្រត្រលប់ថយក្រោយវិញខ្លះ ដែលមានន័យថាផលប៉ះពាល់បង្គរពីការអនុវត្តនេះ នឹងត្រូវបានកត់ត្រាក្នុងខ្ទង់ចំណេញរក្សាទុក គិតត្រឹមថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨ ហើយតួលេខប្រៀបធៀបនឹងមិនត្រូវបានរាយការណ៍ឡើងវិញទេ។ |
| CIFRS 16 ស្តីពី "ភតិសន្យា" | |
| ចរិតនៃការផ្លាស់ប្តូរ | CIFRS 16 ត្រូវបានចេញផ្សាយក្នុងខែមករា ឆ្នាំ២០១៦។ ស្តង់ដារនេះកំណត់ថាស្ទើរតែរាល់ភតិសន្យាទាំងអស់ ត្រូវបានកត់ត្រានៅក្នុងតារាងតុល្យការ ដោយសារតែភាពខុសគ្នារវាងភតិសន្យាប្រតិបត្តិ និងភតិសន្យាហិរញ្ញវត្ថុ ត្រូវបានលុបចោល។ តាមស្តង់ដារថ្មីនេះ ទ្រព្យសកម្មហិរញ្ញវត្ថុ (សិទ្ធិប្រើប្រាស់ទ្រព្យជួល) និងបំណុលហិរញ្ញវត្ថុ ចំពោះការបង់ថ្លៃឈ្នួលត្រូវបានកត់ត្រា ដោយមានករណីលើកលែងតែមួយគត់ គឺភតិសន្យាដែលមានរយៈពេលខ្លី និងភតិសន្យាដែលមានថ្លៃឈ្នួលទាប។<br>ការកត់ត្រាគណនេយ្យសម្រាប់ភាគីម្ចាស់ទ្រព្យជួល មិនមានការប្រែប្រួលជាសារវន្តទេ។ |
| ផលប៉ះពាល់ | ស្តង់ដារនេះនឹងប៉ះពាល់ជាចម្បង ទៅលើការកត់ត្រាគណនេយ្យសម្រាប់ភតិសន្យាប្រតិបត្តិរបស់ ក.ស.ស។ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ ក.ស.ស មិនមានកិច្ចសន្យាភតិសន្យាប្រតិបត្តិជាសារវន្តទេ។<br>ក.ស.ស មិនទាន់បានធ្វើការវាយតម្លៃអំពីនិយ័តកម្មផ្សេងៗ ប្រសិនបើមាន ដែលចាំបាច់សម្រាប់ធ្វើជាឧទាហរណ៍នោះទេ ដោយសារការផ្លាស់ប្តូរនិយមន័យនៃលក្ខខណ្ឌភតិសន្យា និងការកត់ត្រាខុសៗគ្នាចំពោះការបង់ថ្លៃឈ្នួលដែលមានតម្លៃអថេរ និងជម្រើសនៃការបន្ត និងការលុបចោលកិច្ចសន្យា។ ដូចនេះ ក.ស.ស នៅមិនទាន់អាចធ្វើការប៉ាន់ស្មានចំនួនទឹកប្រាក់ទ្រព្យសកម្មនៃសិទ្ធិក្នុងការប្រើប្រាស់ និងបំណុលភតិសន្យាដែលនឹងត្រូវកត់ត្រាចំពោះការអនុវត្តស្តង់ដារថ្មីនេះ ក៏ដូចជាមិនទាន់អាចសិក្សាអំពីផលប៉ះពាល់លើចំណេញ-ខាតរបស់ ក.ស.ស និងការធ្វើចំណាត់ថ្នាក់លំហូរសាច់ប្រាក់នាពេលអនាគតបាននៅឡើយទេ។ |

## ២. សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ (ត)

## ២.២ ស្តង់ដារគណនេយ្យថ្មី ស្តង់ដារគណនេយ្យដែលបានធ្វើវិសោធនកម្ម និងបំណកស្រាយផ្សេងៗ(ត)

### (ii) ស្តង់ដារគណនេយ្យថ្មី ស្តង់ដារគណនេយ្យដែលបានធ្វើវិសោធនកម្ម និងបំណកស្រាយផ្សេងៗ ដែលមិនទាន់បានអនុវត្ត (ត)

| CIFRS 16 ស្តីពី "ភតិសន្យា" (ត) | |
|---|---|
| កាលបរិច្ឆេទដែលក្រុមហ៊ុនត្រូវអនុវត្ត | ស្តង់ដារនេះត្រូវអនុវត្តសម្រាប់ឆ្នាំហិរញ្ញវត្ថុដែលចាប់ផ្តើមនៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១៩ ឬការិយបរិច្ឆេទបន្ទាប់ពីនេះ។ នាដំណាក់កាលនេះ ក.ស.ស មិនមានគម្រោងអនុវត្តស្តង់ដារនេះមុនកាលបរិច្ឆេទចូលជាធរមាននោះទេ។ ក.ស.ស គ្រោងនឹងអនុវត្តតាមវិធីសាស្រ្តដែលមានលក្ខណៈសាមញ្ញ ហើយនឹងមិនរាយការណ៍ចំនួនតួលេខប្រៀបធៀបសម្រាប់ឆ្នាំមុនការអនុវត្តលើកដំបូងនេះ ឡើងវិញនោះទេ។ |

ក.ស.ស កំពុងស្ថិតក្នុងដំណើរការនៃការវាយតម្លៃអំពីផលប៉ះពាល់នៃស្តង់ដារគណនេយ្យថ្មីទាំងនេះ និងបំណកស្រាយរបស់វា ទៅលើរបាយការណ៍របស់ ក.ស.ស ក្នុងការអនុវត្តលើកដំបូងនេះ។

## ២.៣ ការប្តូររូបិយប័ណ្ណ

(i) រូបិយប័ណ្ណគោល និងរូបិយប័ណ្ណសម្រាប់បង្ហាញ

គណនីទាំងអស់ដែលមាននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុត្រូវបានវាស់វែងដោយប្រើប្រាស់រូបិយប័ណ្ណនៃបរិយាកាសសេដ្ឋកិច្ចចម្បងដែល ក.ស.ស ធ្វើប្រតិបត្តិការ (ហៅកាត់ថា "រូបិយប័ណ្ណគោល")។ ក.ស.ស រក្សាកំណត់ត្រាបញ្ជីគណនេយ្យ និងរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួនជាប្រាក់រៀល ដែលជារូបិយប័ណ្ណគោល និងជារូបិយប័ណ្ណសម្រាប់បង្ហាញ។

(ii) ប្រតិបត្តិការ និងសមតុល្យ

ប្រតិបត្តិការជារូបិយប័ណ្ណផ្សេងៗក្រៅពីប្រាក់រៀល ត្រូវបានប្តូរទៅជារូបិយប័ណ្ណគោល តាមអត្រាប្តូរប្រាក់នាកាលបរិច្ឆេទនៃប្រតិបត្តិការនោះ។ ចំណេញ និងខាតដែលបណ្តាលមកពីការទូទាត់ប្រតិបត្តិការបែបនេះ និងពីការប្តូរទ្រព្យសកម្ម និងបំណុលរូបិយវត្ថុនានាដែលជារូបិយប័ណ្ណផ្សេងៗក្រៅពីប្រាក់រៀល តាមអត្រានាដំណាច់ឆ្នាំ ត្រូវបានកត់ត្រាក្នុងចំណេញ-ខាត និងលទ្ធផលលម្អិតផ្សេងៗ។ ចំណេញនិងខាតពីការប្តូររូបិយប័ណ្ណដែលពាក់ព័ន្ធនឹងប្រាក់កម្ចី ត្រូវបានបង្ហាញនៅក្នុងចំណេញ-ខាត និងលទ្ធផលលម្អិតផ្សេងៗ ក្រោមខ្ទង់ "ចំណូលហិរញ្ញវត្ថុ និងចំណាយហិរញ្ញវត្ថុ"។

## ២.៤ ទ្រព្យសម្បត្តិ និងបរិក្ខារ

ទ្រព្យសម្បត្តិ និងបរិក្ខារ ត្រូវបានរាយការណ៍តាមថ្លៃដើម ដករំលស់បង្គរ។ ថ្លៃដើមរួមមានចំណាយផ្ទាល់ផ្សេងៗក្នុងការទិញទ្រព្យសម្បត្តិទាំងអស់នោះ។

ចំណាយបន្តបន្ទាប់មកទៀតត្រូវបានកត់ត្រាបញ្ចូលទៅក្នុងតម្លៃយោងនៃទ្រព្យសកម្ម ឬត្រូវបានទទួលស្គាល់ជាទ្រព្យសកម្មដាច់ដោយឡែកតាមការសមស្រប តែនៅពេលដែលមានភាពប្រាកដថាផលប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគតដែលពាក់ព័ន្ធនឹងទ្រព្យសកម្មនោះ នឹងហូរចូលមកក្នុង ក.ស.ស ហើយចំណាយទាំងនោះអាចត្រូវបានវាស់វែងគួរឱ្យជឿជាក់ប៉ុណ្ណោះ។ តម្លៃយោងនៃផ្នែកដែលត្រូវបានជំនួសឡើងវិញ ត្រូវបានឈប់កត់ត្រា។ ចំណាយទៅលើរាល់ការជួសជុល និងថែទាំផ្សេងៗ ត្រូវបានកត់ត្រានៅក្នុងចំណេញ-ខាត ក្នុងឆ្នាំដែលប្រតិបត្តិការនោះបានកើតឡើង។

## ២. សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ (ត)

### ២.៤ ទ្រព្យសម្បត្តិ និងបរិក្ខារ (ត)

ដីធ្លីមិនត្រូវបានគេធ្វើរំលស់ទេ។ រំលស់លើទ្រព្យសកម្មផ្សេងៗ ត្រូវបានគណនាតាមវិធីសាស្ត្ររំលស់ថេរ ដើម្បីជម្រុះចោលថ្លៃដើមនៃទ្រព្យសកម្ម ឱ្យនៅត្រឹមតម្លៃសំណល់របស់វា លើអាយុកាលប្រើប្រាស់ប៉ាន់ស្មាន ដូចខាងក្រោម៖

| | ចំនួនឆ្នាំ |
|---|---|
| ការកែលម្អដីធ្លី | ៧,៣០,៥០ |
| អគារ | ៧,២០,២៥,៣០,៣៥,៥០ |
| ឋបនីយភ័ណ្ឌកំពង់ផែ | ៥០ |
| បរិក្ខារបច្ចេកទេស | ៥-៣០ |
| បរិក្ខារផ្សេងៗ | ៥-១៥ |
| សង្ហារិម និងបរិក្ខារបំពាក់ | ៣-១០ |
| កុំព្យូទ័រ និងបរិក្ខារការិយាល័យ | ៣-៥ |
| បរិក្ខារដឹកជញ្ជូន | |
| - យានយន្ត | ៥ |
| - ផ្សេងៗ (គ្រឿងម៉ាស៊ីន រថយន្តដឹកកុងតឺន័រ អេឡេវ៉ាទ័រ) | ១០-១៥ |
| បរិក្ខារកំពង់ផែសមុទ្រ | ២០-៣០ |
| ប៉ាឡែត (Palettes) | ១០ |

តម្លៃសំណល់ និងអាយុកាលប្រើប្រាស់របស់ទ្រព្យសកម្ម ត្រូវបានត្រួតពិនិត្យនិងកែតម្រូវតាមការសមស្រប នៅរៀងរាល់កាលបរិច្ឆេទរាយការណ៍នីមួយៗ។

ចំណេញនិងខាតពីការលក់ទ្រព្យសម្បត្តិ និងបរិក្ខារ ត្រូវបានកំណត់ដោយធ្វើការប្រៀបធៀបសាច់ប្រាក់លក់បានជាមួយនឹងតម្លៃយោង ហើយត្រូវបានកត់ត្រានៅក្នុងចំណេញ-ខាត។

### ២.៥ ទ្រព្យសកម្មអរូបី

ទ្រព្យសកម្មអរូបីរួមមានកម្មវិធីគណនេយ្យ និងប្រព័ន្ធប្រតិបត្តិការកំពង់ផែ ត្រូវបានកត់ត្រាតាមថ្លៃដើម ដករំលស់បង្គរ និងការថយចុះតម្លៃ ប្រសិនបើមាន។ ទ្រព្យសកម្មអរូបីទាំងនេះត្រូវបានធ្វើមូលធនកម្មតាមមូលដ្ឋានថ្លៃដើមដែលបានកើតឡើងក្នុងការទិញ និងយកកម្មវិធីនោះមកប្រើប្រាស់។ សេចក្តីលម្អិតអំពីការផ្លាស់ប្តូរអាយុកាលប្រើប្រាស់ មានដូចខាងក្រោម៖

| | **ចំនួនឆ្នាំ** |
|---|---|
| កម្មវិធីគណនេយ្យ | ១០ |
| ប្រព័ន្ធប្រតិបត្តិការកំពង់ផែ | ១០ |

**កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ**
**សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧**

## ២. សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ (ត)

## ២.៦ ទ្រព្យសម្បត្តិវិនិយោគ

ទ្រព្យសម្បត្តិដែលត្រូវបានកាន់កាប់សម្រាប់ការជួលរយៈពេលវែង ឬសម្រាប់រំលស់ដើមទុន ឬសម្រាប់ទាំងពីរយ៉ាង ហើយដែលមិនត្រូវបានកាន់កាប់ដោយ ក.ស.ស ត្រូវបានចាត់ថ្នាក់ជាទ្រព្យសម្បត្តិវិនិយោគ។ ទ្រព្យសម្បត្តិវិនិយោគ ក៏រួមបញ្ចូលនូវទ្រព្យសម្បត្តិដែលកំពុងសាងសង់សម្រាប់អភិវឌ្ឍឱ្យក្លាយជាទ្រព្យសម្បត្តិវិនិយោគនាពេលអនាគត។ ទ្រព្យសម្បត្តិវិនិយោគត្រូវបានកត់ត្រាជាបឋមតាមថ្លៃដើម ដករំលស់បង្គរនិងការថយចុះតម្លៃ។ ក.ស.ស ប្រើប្រាស់គំរូថ្លៃដើម និងគណនីសម្រាប់ទ្រព្យសម្បត្តិវិនិយោគ ដោយអនុលោមទៅតាម CIAS 16 (ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ)។

ទ្រព្យសម្បត្តិវិនិយោគត្រូវបានផ្ទេរទៅជាសន្និធិ តែនៅពេលដែលមានការផ្លាស់ប្តូរក្នុងការប្រើប្រាស់ ដោយមានភស្តុតាងបង្ហាញពីការចាប់ផ្តើមការអភិវឌ្ឍ ក្នុងទស្សនវិស័យសម្រាប់ការលក់។ នៅពេលដែល ក.ស.ស សម្រេចលក់ទ្រព្យសម្បត្តិវិនិយោគណាមួយចេញ ដោយមិនមានការអភិវឌ្ឍ ក្រុមហ៊ុនបន្តចាត់ទុកទ្រព្យសម្បត្តិនោះ ជាទ្រព្យសម្បត្តិវិនិយោគរហូតដល់ពេលឈប់កត់ត្រា និងលុបវាចេញពីរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ ហើយមិនចាត់ទុកវាជាសន្និធិទេ។ ប្រសិនបើទ្រព្យសម្បត្តិវិនិយោគត្រូវបានគេអភិវឌ្ឍឡើងវិញដើម្បីប្រើប្រាស់បន្តទៅទៀតជាទ្រព្យសម្បត្តិវិនិយោគ នោះទ្រព្យសម្បត្តិនោះនៅរក្សាទុកជាទ្រព្យសម្បត្តិវិនិយោគដដែល ហើយមិនត្រូវបានចាត់ថ្នាក់ឡើងវិញជាទ្រព្យសម្បត្តិដែលកាន់កាន់ដោយម្ចាស់ (owner-occupied property) ក្នុងអំឡុងពេលការអភិវឌ្ឍឡើងវិញទេ។

នៅពេលលក់ទ្រព្យសម្បត្តិវិនិយោគណាមួយ ឬនៅពេលដែលទ្រព្យសម្បត្តិវិនិយោគណាមួយត្រូវបានដកចេញពីការប្រើប្រាស់ជាអចិន្ត្រៃយ៍ និងមិនមានការរំពឹងថានឹងមានអត្ថប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគតពីការលក់ចេញទៀត នោះវានឹងត្រូវបានគេឈប់កត់ត្រា (លុបចេញពីតារាងតុល្យការ)។ ចំនួនលម្អៀងរវាងសាច់ប្រាក់សុទ្ធដែលបានពីការលក់ និងតម្លៃយោងត្រូវបានកត់ត្រាក្នុងចំណេញខាត ក្នុងការិយបរិច្ឆេទឈប់ប្រើ ឬការិយបរិច្ឆេទលក់ចេញ។

ដីមិនត្រូវបានធ្វើរំលស់ទេ ចំណែកអគារត្រូវបានត្រូវបានធ្វើរំលស់ ដោយប្រើវិធីសាស្ត្ររំលស់ថេរលើអាយុកាលប្រើប្រាស់ប៉ាន់ស្មានរបស់វាក្នុងរយៈពេល៥០ឆ្នាំ។

## ២.៧ ការថយចុះតម្លៃនៃទ្រព្យសកម្ម

ទ្រព្យសកម្មដែលត្រូវធ្វើរំលស់ ត្រូវបានត្រួតពិនិត្យលើការថយចុះតម្លៃ នៅពេលដែលមានព្រឹត្តិការណ៍ ឬការផ្លាស់ប្តូរកាលៈទេសៈនានា ចង្អុលបង្ហាញថាតម្លៃយោងនឹងមិនអាចស្រង់មកវិញបាន។ ការខាតដែលបណ្តាលមកពីការថយចុះតម្លៃ ត្រូវបានកត់ត្រាតាមតម្លៃយោងរបស់ទ្រព្យសកម្ម ដែលលើសពីតម្លៃដែលអាចស្រង់មកវិញបាន។ តម្លៃដែលអាចស្រង់មកវិញបាន គឺជាតម្លៃដែលខ្ពស់ជាងគេរវាងតម្លៃសមស្របនៃទ្រព្យសកម្ម ដកចំណាយលើការលក់ និងតម្លៃនៅអាចប្រើប្រាស់បានរបស់វា។ ក្នុងការប៉ាន់ស្មានរកការថយចុះតម្លៃ ទ្រព្យសកម្មត្រូវបានបែងចែកជាក្រុមតូចៗបំផុត សម្រាប់ទ្រព្យសកម្មដែលមានលក្ខណៈជាលំហូរសាច់ប្រាក់ដាច់ដោយឡែកធំៗ (ឯកតាបង្កើតសាច់ប្រាក់)។

## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧

### ២. សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ (ត)
### ២.៨ ទ្រព្យសកម្មហិរញ្ញវត្ថុ
### ២.៨.១ ការធ្វើចំណាត់ថ្នាក់ទ្រព្យសកម្មហិរញ្ញវត្ថុ

ក.ស.ស បានធ្វើចំណាត់ថ្នាក់ទ្រព្យសកម្មហិរញ្ញវត្ថុរបស់ខ្លួនជាឥណទាននិងគណនីអតិថិជន។ ការធ្វើចំណាត់ថ្នាក់នេះ គឺអាស្រ័យទៅតាមគោលបំណងដែលបានទិញទ្រព្យសកម្មហិរញ្ញវត្ថុ។ ក.ស.ស កំណត់ការធ្វើចំណាត់ថ្នាក់នៃទ្រព្យសកម្មហិរញ្ញវត្ថុរបស់ខ្លួនទៅតាមការកត់ត្រាបឋម។

*ឥណទាន និងគណនីអតិថិជន*

ឥណទាន និងគណនីអតិថិជន គឺជាទ្រព្យសកម្មហិរញ្ញវត្ថុមិននិស្សន្ទ ដែលមានការសងប្រាក់ថេរ ឬអាចកំណត់បាន ហើយមិនបានដាក់លក់លើទីផ្សារសកម្ម។ ទ្រព្យសកម្មហិរញ្ញវត្ថុទាំងនេះ ត្រូវបានរួមបញ្ចូលទៅក្នុងទ្រព្យសកម្មរយៈពេលខ្លី លើកលែងតែទ្រព្យសកម្មហិរញ្ញវត្ថុទាំងឡាយណា ដែលមានកាលផុតកំណត់លើសពី១២ខែ បន្ទាប់ពីដំណាច់កាលបរិច្ឆេទរាយការណ៍ ក្នុងករណីនេះ វាត្រូវបានចាត់ទុកជាទ្រព្យសកម្មហិរញ្ញវត្ថុរយៈពេលវែង។ ទ្រព្យសកម្មហិរញ្ញវត្ថុរបស់ ក.ស.ស "គណនីអតិថិជនពាណិជ្ជកម្ម និង គណនីអតិថិជនផ្សេងៗ (មិនរួមបញ្ចូល ឥណទានពន្ធកាត់ទុក និងចំណាយបង់មុន)" "ឥណទានផ្តល់ឱ្យបុគ្គលិក" "ប្រាក់បញ្ញើនៅធនាគាររយៈពេលខ្លី" "គណនីសាច់ប្រាក់និង សាច់ប្រាក់សមមូល" នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។

### ២.៨.២ ការទទួលស្គាល់ និងការវាស់វែងទ្រព្យសកម្មហិរញ្ញវត្ថុ

ឥណទាននិងគណនីអតិថិជន ត្រូវបានកត់ត្រាជាបឋមតាមតម្លៃសមស្រប បូកបញ្ចូលថ្លៃដើមប្រតិបត្តិការ ហើយបន្ទាប់មកទៀតវាត្រូវបានកត់ត្រាតាមថ្លៃដើមដករំលស់ ដោយប្រើវិធីសាស្រ្តអត្រាការប្រាក់មានប្រសិទ្ធភាព (effective interest rate method)។ នៅរៀងរាល់កាលបរិច្ឆេទរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុនីមួយៗ ក.ស.ស បានវាយតម្លៃរកមើលថាតើមានភស្តុតាងជាក់ស្តែងចង្អុលបង្ហាញថាទ្រព្យសកម្មហិរញ្ញវត្ថុទោល ឬក្រុមទ្រព្យសកម្មហិរញ្ញវត្ថុជាក្រុម មានការថយចុះតម្លៃដែរឬទេ។

### ២.៩ ការថយចុះតម្លៃនៃទ្រព្យសកម្មហិរញ្ញវត្ថុ
### (ក) ទ្រព្យសកម្មដែលកត់ត្រាតាមថ្លៃដើមដករំលស់

ក.ស.ស វាយតម្លៃនៅរៀងរាល់កាលបរិច្ឆេទរាយការណ៍នីមួយៗ ដើម្បីរកមើលថាតើមានភស្តុតាងជាក់ស្តែងបង្ហាញថាទ្រព្យសកម្មហិរញ្ញវត្ថុទោល ឬទ្រព្យសកម្មហិរញ្ញវត្ថុជាក្រុម មានការថយចុះតម្លៃដែរឬទេ។ ទ្រព្យសកម្មហិរញ្ញវត្ថុទោល ឬទ្រព្យសកម្មហិរញ្ញវត្ថុជាក្រុមមានការថយចុះតម្លៃ ហើយការខាតដែលបណ្តាលមកពីការថយចុះតម្លៃត្រូវបានកើតឡើង តែក្នុងករណីដែលមានភស្តុតាងជាក់ស្តែងអំពីការថយចុះតម្លៃ ដែលជាលទ្ធផលនៃព្រឹត្តិការណ៍មួយឬច្រើនបានកើតឡើងបន្ទាប់ពីការកត់ត្រាទ្រព្យសកម្មដំបូង ("ព្រឹត្តិការណ៍ខាតបង់") ហើយព្រឹត្តិការណ៍ខាតបង់នោះ (ឬព្រឹត្តិការណ៍ច្រើន) មានផលប៉ះពាល់លើលំហូរសាច់ប្រាក់ប៉ាន់ស្មាននាពេលអនាគតនៃទ្រព្យសកម្មហិរញ្ញវត្ថុទោល ឬទ្រព្យសកម្មហិរញ្ញវត្ថុជាក្រុម ដែលអាចប៉ាន់ស្មានគួរឱ្យជឿជាក់បានតែប៉ុណ្ណោះ។

ភស្តុតាងនៃការថយចុះតម្លៃរួមមានសញ្ញាណផ្សេងៗដែលកូនបំណុល ឬក្រុមកូនបំណុលជួបប្រទះនូវផលវិបាកផ្នែកហិរញ្ញវត្ថុជាសារវន្ត ការសងប្រាក់ដើមឬការប្រាក់យឺតយ៉ាវ ឬខកខានមិនបានសង ប្រូបាប (probability) ដែលពួកគេនឹងក្ស័យធន ឬពួកគេមានការរៀបចំរចនាសម្ព័ន្ធហិរញ្ញវត្ថុឡើងវិញ និងនៅពេលដែលមានទិន្នន័យដែលអាចអង្កេតបានចង្អុលបង្ហាញថាមានតំហយដែលអាចវាស់វែងបានក្នុងលំហូរសាច់ប្រាក់ប៉ាន់ស្មាននាពេលអនាគត ដូចជាបម្រែបម្រួលក្នុងការសងប្រាក់ ឬលក្ខខណ្ឌសេដ្ឋកិច្ចដែលទាក់ទិននឹងការសងប្រាក់យឺតយ៉ាវជាដើម។

## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧

### ២. សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ (ត)
### ២.៩ ការថយចុះតម្លៃនៃទ្រព្យសកម្មហិរញ្ញវត្ថុ (ត)
### (ក) ទ្រព្យសកម្មដែលកត់ត្រាតាមថ្លៃដើមដករំលស់ (ត)

ប្រសិនបើនៅពេលក្រោយមកទៀតចំនួននៃការខាតបង់ដែលបណ្តាលមកពីការថយចុះតម្លៃមានការថយចុះ ហើយការថយចុះនោះ អាចពាក់ព័ន្ធយ៉ាងជាក់ស្តែងទៅនឹងព្រឹត្តិការណ៍ដែលកើតឡើង បន្ទាប់ពីកត់ត្រាការថយចុះតម្លៃរួចហើយ (ដូចជាការកែលម្អអត្រាឥណទានរបស់កូនបំណុល) ការកត់ត្រាត្រលប់មកវិញនៃការខាតដែលបណ្តាលមកពីការថយចុះតម្លៃដែលបានទទួលស្គាល់រួចហើយ ត្រូវបានកត់ត្រានៅក្នុងចំណេញ-ខាត។

### ២.១០ ការកាត់កងឧបករណ៍ហិរញ្ញវត្ថុ

ទ្រព្យសកម្មនិងបំណុលហិរញ្ញវត្ថុត្រូវបានកាត់កងជាមួយគ្នា ហើយចំនួនសុទ្ធបន្ទាប់ពីកាត់កងត្រូវបានរាយការណ៍ក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ នៅពេលដែលក្រុមហ៊ុនមានសិទ្ធិស្របច្បាប់ក្នុងការកាត់កងចំនួនដែលបានកត់ត្រា និងនៅពេលដែលក្រុមហ៊ុនមានបំណងទូទាត់វាតាមមូលដ្ឋានសុទ្ធបន្ទាប់ពីកាត់កង ឬមានបំណងកត់ត្រាទ្រព្យសកម្ម និងទូទាត់បំណុលក្នុងពេលដំណាលគ្នា។

### ២.១១ សន្និធិ

សន្និធិត្រូវបានកត់ត្រាតាមតម្លៃមួយណាដែលទាបជាងគេ (ថ្លៃដើមក្នុងការទិញ និងថ្លៃដើមផ្សេងៗទៀតក្នុងការនាំយកសន្និធិនោះមកកាន់ទីតាំង និងលក្ខខណ្ឌបច្ចុប្បន្នរបស់វា) ធៀបនឹងតម្លៃសុទ្ធដែលអាចលក់បាន។ តម្លៃសុទ្ធដែលអាចលក់បាន គឺជាតម្លៃលក់ប៉ាន់ស្មាននៅក្នុងដំណើរការអាជីវកម្មធម្មតា ដកចំណាយក្នុងការលក់ផ្សេងៗ។

សន្និធិរួមមាន វត្ថុប្រើប្រាស់ គ្រឿងបន្លាស់ និងសន្និធិផ្សេងៗដែលពាក់ព័ន្ធនឹងការផ្គត់ផ្គង់ ត្រូវបានវាយតម្លៃតាមថ្លៃដើមជាក់ស្តែង ក្នុងការយកសន្និធិនោះមកប្រើប្រាស់ទៅតាមគោលបំណងដែលបានគ្រោងទុក ដកសំវិធានធនសម្រាប់សន្និធិខូចខាត សន្និធិប្រើប្រាស់លែងបាន និងសន្និធិដែលមានចលនាយឺតយ៉ាវ ដោយប្រើមូលដ្ឋានចូលមុន-ចេញមុន។

### ២.១២ គណនីអតិថិជនពាណិជ្ជកម្ម

គណនីអតិថិជនពាណិជ្ជកម្មជាទឹកប្រាក់ដែលទទួលបានពីការផ្តល់សេវាកម្មផ្សេងៗដល់អតិថិជន ក្នុងដំណើរការអាជីវកម្មធម្មតា។ គណនីអតិថិជនពាណិជ្ជកម្មត្រូវបានចាត់ថ្នាក់ជាបំណុលរយៈពេលខ្លី ប្រសិនបើការប្រមូលប្រាក់ត្រូវផុតកំណត់ក្នុងរយៈពេល១ឆ្នាំ ឬតិចជាង (ឬនៅក្នុងអំឡុងពេលប្រតិបត្តិការអាជីវកម្មធម្មតា)។ ប្រសិនបើលើសពី១ឆ្នាំ វាត្រូវបានចាត់ទុកជាបំណុលរយៈពេលវែង។

គណនីអតិថិជនពាណិជ្ជកម្ម ត្រូវបានកត់ត្រាជាបឋមតាមតម្លៃសមស្រប ហើយបន្ទាប់មកទៀតវាត្រូវបានវាស់វែងតាមថ្លៃដើមដករំលស់ ដោយប្រើវិធីសាស្ត្រអត្រាការប្រាក់ដែលមានប្រសិទ្ធភាព ដកសំវិធានធនសម្រាប់ការថយចុះតម្លៃ។

### ២.១៣ សាច់ប្រាក់ និងសាច់ប្រាក់សមមូល

សាច់ប្រាក់ និងសាច់ប្រាក់សមមូល រួមមាន សាច់ប្រាក់ក្នុងដៃ សមតុល្យនៅធនាគារ និងការវិនិយោគរយៈពេលខ្លីដែលអាចបម្លែងទៅជាសាច់ប្រាក់បានភ្លាមៗ និងមានអាយុកាលបីខែ ឬក៏តិចជាងបីខែ។

**កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ**
**សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧**

## ២. សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ (ត)

### ២.១៤ ដើមទុន និងបុព្វលាភភាគហ៊ុន

ដើមទុន និងបុព្វលាភភាគហ៊ុន ត្រូវបានចាត់ថ្នាក់ជាមូលធន។ ចំណាយផ្ទាល់បន្ថែមក្នុងដំណើរការបោះភាគហ៊ុនថ្មី ត្រូវបង្ហាញក្នុងមូលធន ដោយដកចេញពីមូលធនបន្ទាប់ពីកាត់ពន្ធរួច។

### ២.១៥ គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម និងគណនីអ្នកផ្គត់ផ្គង់ផ្សេងៗ

គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម និងគណនីអ្នកផ្គត់ផ្គង់ផ្សេងៗ ជាកាតព្វកិច្ចបង់ប្រាក់សម្រាប់ការទិញទំនិញ ឬសេវាផ្សេងៗពីអ្នកផ្គត់ផ្គង់ ក្នុងដំណើរការអាជីវកម្មធម្មតា។ គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្មត្រូវបានចាត់ថ្នាក់ជាបំណុលរយៈពេលខ្លី ប្រសិនបើការសងប្រាក់ត្រូវផុតកំណត់ក្នុងរយៈពេល១ឆ្នាំ ឬតិចជាង (ឬនៅក្នុងអំឡុងពេលប្រតិបត្តិការអាជីវកម្មធម្មតា)។ ប្រសិនបើលើសពី១ឆ្នាំ វាត្រូវបានចាត់ទុកជាបំណុលរយៈពេលវែង។

គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម និងគណនីអ្នកផ្គត់ផ្គង់ផ្សេងៗ ត្រូវបានកត់ត្រាជាបឋមតាមតម្លៃសមស្រប ហើយបន្ទាប់មកទៀតវាត្រូវបានវាស់វែងតាមថ្លៃដើមដករំលស់ ដោយប្រើវិធីសាស្ត្រអត្រាការប្រាក់មានប្រសិទ្ធភាព។

### ២.១៦ ប្រាក់កម្ចី

ប្រាក់កម្ចីត្រូវបានកត់ត្រាជាបឋមតាមតម្លៃសមស្រប ដកចំណាយប្រតិបត្តិការដែលបានកើតឡើង ហើយបន្ទាប់មកវាត្រូវបានរាយការណ៍តាមថ្លៃដើមដករំលស់។ ភាពលម្អៀងរវាងសាច់ប្រាក់ (ដកចំណាយប្រតិបត្តិការ) និងតម្លៃដែលត្រូវបង្វិលសងវិញ ត្រូវបានកត់ត្រានៅក្នុងរបាយការណ៍ចំណេញ-ខាត លើរយៈពេលនៃប្រាក់កម្ចី ដោយប្រើវិធីសាស្ត្រការប្រាក់មានប្រសិទ្ធភាព។

កម្រៃបានបង់លើដំណើរការឥណទាន ត្រូវបានកត់ត្រាជាចំណាយប្រតិបត្តិការប្រាក់កម្ចី ទៅតាមចំនួនឥណទានមួយចំនួន ឬឥណទានទាំងអស់ដែលត្រូវដក។ ក្នុងករណីនេះ កម្រៃបានបង់លើដំណើរការឥណទានត្រូវបានពន្យារ រហូតដល់ពេលដកសាច់ប្រាក់ជាក់ស្តែង។ នៅពេលមិនមានភស្តុតាងបញ្ជាក់ថា មានការដកឥណទានមួយចំនួន ឬឥណទានទាំងអស់ នោះកម្រៃបានបង់លើដំណើរការឥណទានត្រូវបានចាត់ថ្នាក់ជាចំណាយបង់មុនសម្រាប់សេវាសាច់ប្រាក់ និងត្រូវបានធ្វើរំលស់លើរយៈពេលឥណទានដែលពាក់ព័ន្ធ។

### ២.១៧ បន្ទុកប្រាក់កម្ចី

បន្ទុកប្រាក់កម្ចីជាក់លាក់និងទូទៅដែលបានចំណាយផ្ទាល់ក្នុងការទិញ ការសាងសង់ ហើយជាទ្រព្យសកម្មដែលត្រូវចំណាយពេលវេលាចាំបាច់សម្រាប់បញ្ចប់ ដើម្បីអាចប្រើប្រាស់តាមការគ្រោងទុករបស់គេ ឬសម្រាប់លក់ ត្រូវបានកត់ត្រាបន្ថែមទៅក្នុងថ្លៃដើមនៃទ្រព្យសកម្មទាំងនោះ រហូតដល់ពេលទ្រព្យសកម្មនោះមានភាពរួចរាល់សម្រាប់ការប្រើប្រាស់ ឬសម្រាប់លក់បាន។

ចំណូលលើការវិនិយោគដែលរកបានពីការវិនិយោគបណ្តោះអាសន្ននៃប្រាក់កម្ចីជាក់លាក់ ដែលមិនទាន់ជាចំណាយរបស់ទ្រព្យសម្បត្តិដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ត្រូវបានដកចេញពីបន្ទុកប្រាក់កម្ចីត្រូវបានធ្វើមូលធនកម្ម។

បន្ទុកប្រាក់កម្ចីផ្សេងៗទៀតទាំងអស់ ត្រូវបានកត់ត្រាក្នុងរបាយការណ៍ចំណេញ-ខាត និងចំណូលលម្អិតផ្សេងៗក្នុងការិយបរិច្ឆេទដែលវាកើតឡើង។

**កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ**
**សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧**

## ២. សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ (ត)

## ២.១៨ ពន្ធលើប្រាក់ចំណេញក្នុងគ្រា និងពន្ធពន្យារលើប្រាក់ចំណេញ

ចំណាយពន្ធប្រចាំការិយបរិច្ឆេទ រួមមានពន្ធលើប្រាក់ចំណេញក្នុងគ្រា និងពន្ធពន្យារលើប្រាក់ចំណេញ។ ពន្ធត្រូវបានកត់ត្រានៅក្នុងចំណេញ-ខាត លើកលែងតែពន្ធនោះទាក់ទិននឹងគណនីមួយចំនួន ដែលបានកត់ត្រាដោយផ្ទាល់ក្នុងមូលធន។

ចំណាយពន្ធលើប្រាក់ចំណេញក្នុងគ្រា ត្រូវបានគណនាតាមមូលដ្ឋានច្បាប់សារពើពន្ធដែលបានអនុម័តជាស្ថាពរ ឬអនុម័តរួចមួយផ្នែកធំ គិតត្រឹមដំណាច់កាលបរិច្ឆេទរាយការណ៍នៅក្នុងប្រទេសកម្ពុជា ជាកន្លែងដែល ក.ស.ស បង្កើតប្រាក់ចំណេញជាប់ពន្ធ។ គណៈគ្រប់គ្រងវាយតម្លៃពីមួយគ្រាទៅមួយគ្រាអំពីស្ថានភាព ដែលបានកត់ត្រានៅក្នុងលិខិតប្រកាសពន្ធទាក់ទិនទៅនឹងសភាពការណ៍ផ្សេងៗដែលបទប្បញ្ញត្តិពន្ធត្រូវធ្វើបំណកស្រាយ។ ក.ស.ស កត់ត្រាសំវិធានធនតាមការសមស្រប តាមមូលដ្ឋាននៃចំនួនដែលរំពឹងថានឹងត្រូវបង់ជូនអាជ្ញាធរពន្ធដារ។

ពន្ធពន្យារលើប្រាក់ចំណេញត្រូវបានកត់ត្រាពេញលេញ ដោយប្រើវិធីសាស្ត្របំណុល លើបណ្តោះអាសន្នដែលកើតឡើងរវាងមូលដ្ឋានពន្ធនៃទ្រព្យសកម្ម និងបំណុល និងតម្លៃយោងរបស់វានៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។ ពន្ធពន្យារលើប្រាក់ចំណេញត្រូវកំណត់ដោយប្រើអត្រាពន្ធដែលបានអនុម័តជាស្ថាពរ ឬបានអនុម័តរួចមួយផ្នែកធំ គិតត្រឹមកាលបរិច្ឆេទតារាងតុល្យការ និងត្រូវបានរំពឹងថានឹងត្រូវអនុវត្ត នៅពេលដែលពន្ធពន្យារលើប្រាក់ចំណេញពាក់ព័ន្ធត្រូវទទួលបាន ឬនៅពេលដែលបំណុលពន្ធពន្យារលើប្រាក់ចំណេញត្រូវទូទាត់។

ពន្ធពន្យារទ្រព្យសកម្មត្រូវបានកត់ត្រា លុះត្រាតែមានភាពប្រាកដថានឹងមានប្រាក់ចំណេញជាប់ពន្ធនាពេលអនាគតអាចប្រើប្រាស់សម្រាប់ទូទាត់ជាមួយនឹងលម្អៀងបណ្តោះអាសន្នបាន។

ពន្ធពន្យារលើប្រាក់ចំណេញត្រូវបានកាត់កងជាមួយនឹងបំណុលពន្ធពន្យារលើប្រាក់ចំណេញ ប្រសិនបើក្រុមហ៊ុនមានសិទ្ធិស្របច្បាប់ដើម្បីកាត់កងបំណុលពន្ធក្នុងឆ្នាំជាមួយនឹងពន្ធក្នុងឆ្នាំ ហើយប្រសិនបើពន្ធនេះត្រូវបានកំណត់ដោយអាជ្ញាធរពន្ធដារតែមួយ ទៅលើអង្គភាពជាប់ពន្ធតែមួយ ឬអង្គភាពជាប់ពន្ធផ្សេងគ្នា នៅពេលដែលមានគោលបំណងទូទាត់សមតុល្យលើមូលដ្ឋានសុទ្ធ។

ពន្ធពន្យារទ្រព្យសកម្មត្រូវបានគណនា ដោយប្រើអត្រាពន្ធ ២០%។

## ២. សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ (ត)

## ២.១៩ អត្ថប្រយោជន៍បុគ្គលិក

កាតព្វកិច្ចអត្ថប្រយោជន៍បុគ្គលិក

ក.ស.ស ប្រតិបត្តិគម្រោងអត្ថប្រយោជន៍នេះដូចខាងក្រោម ៖

វិភាគទានរបស់បុគ្គលិក ១០% នៃប្រាក់បៀវត្សរ៍ប្រចាំខែរបស់ពួកគេ។

វិភាគទានរបស់ ក.ស.ស ១០% នៃប្រាក់បៀវត្សរ៍ប្រចាំខែរបស់បុគ្គលិក។

ក្រុមប្រឹក្សាភិបាលសម្រេចលើចំនួនបន្ថែមដែលត្រូវបញ្ចូលទៅក្នុងគម្រោងនេះ តាមមូលដ្ឋានប្រចាំឆ្នាំ អាស្រ័យទៅតាមលទ្ធផលរបស់ ក.ស.ស ក្នុងឆ្នាំ។

ដើម្បីមានសិទ្ធិទទួលបានអត្ថប្រយោជន៍សោធននិវត្តន៍នេះ បុគ្គលិកត្រូវបំពេញតាមលក្ខណៈវិនិច្ឆ័យដូចខាងក្រោម៖

ជាបុគ្គលិកអចិន្ត្រៃយ៍។

បានបំពេញការងារជូន ក.ស.ស ចំនួន ២៥ ឆ្នាំ ឬ ច្រើនជាងនេះ។

បានចូលរួមវិភាគទុនក្នុងគម្រោងនេះ តាមការកំណត់។

មានប័ណ្ណបុគ្គលិក និង

ប្រសិនបើចូលនិវត្តមុនពេលដល់អាយុចូលនិវត្ត ការចូលនិវត្តនោះត្រូវមានការអនុម័តដោយប្រធានក្រុមប្រឹក្សា-ភិបាល និងអគ្គនាយក។

(ក) បុគ្គលិកដែលបានបម្រើការងាររយៈពេល២៥ឆ្នាំ ឬច្រើនឆ្នាំជាងនេះ មានជម្រើសពីរក្នុងការទទួលបានអត្ថប្រយោជន៍នេះ គឺបើកប្រាក់បង់ផ្តាច់តែមួយដងនៅពេលដល់អាយុចូលនិវត្ត ឬបើកប្រាក់ប្រចាំខែរហូតដល់ពេលទទួលមរណ-ភាព។ ការបង់ប្រាក់ជូនបុគ្គលិកដែលមានសិទ្ធិទទួលបានអត្ថប្រយោជន៍នេះ គឺអាស្រ័យទៅតាមខ និងលក្ខខណ្ឌនានា ដូចខាងក្រោម៖

ចំពោះការបង់ប្រាក់ផ្តាច់៖

បុគ្គលិកដែលបានសម្រេចទទួលយកការបង់ប្រាក់ផ្តាច់នៅពេលដល់អាយុចូលនិវត្ត នឹងទទួលបាននូវចំនួនទឹកប្រាក់ស្មើនឹង ១២,៥ដង នៃប្រាក់បៀវត្សរ៍ខែចុងក្រោយរបស់ពួកគេ។

ចំពោះការបង់ប្រាក់ប្រចាំខែរហូតដល់ពេលទទួលមរណភាព៖

ការបង់ប្រាក់ប្រចាំខែដែលត្រូវបង់ជូនបុគ្គលិកដែលសម្រេចជ្រើសរើសយកអត្ថប្រយោជន៍ប្រចាំខែ រហូតដល់ពេលទទួលមរណភាព គឺអាស្រ័យទៅតាមចំនួនឆ្នាំនៃអតីតភាពការងាររបស់ពួកគេ ដូចបានកំណត់ខាងក្រោម៖

| អតីតភាពការងារ | អត្ថប្រយោជន៍ |
|---|---|
| ២៥ ឆ្នាំ | ទទួលបានការបង់ប្រាក់ប្រចាំខែចំនួន ៧៥% នៃប្រាក់បៀវត្សរ៍ខែចុងក្រោយសុទ្ធរបស់ពួកគេ។ |
| ២៦-៤០ ឆ្នាំ | ទទួលបានការបង់ប្រាក់ប្រចាំខែចំនួន ៧៥% នៃប្រាក់បៀវត្សរ៍ខែចុងក្រោយសុទ្ធរបស់ពួកគេ បូកនឹង ១% បន្ថែម លើឆ្នាំនីមួយៗក្នុងរយៈពេល២៥ឆ្នាំ។ |
| ៤០ឆ្នាំឡើងទៅ | ទទួលបានការបង់ប្រាក់ប្រចាំខែចំនួន ៩០% នៃប្រាក់បៀវត្សរ៍ខែចុងក្រោយសុទ្ធរបស់ពួកគេ។ |

២. សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ (ត)

២.១៩ អត្ថប្រយោជន៍បុគ្គលិក (ត)

(ខ) បុគ្គលិកដែលបានបម្រើការងាររយៈពេលតិចជាង ២៥ ឆ្នាំ នៅពេលចូលនិវត្ត បញ្ឈប់ពីការងារ ឬទទួលមរណភាព គឺមិនមានសិទ្ធិទទួលបានអត្ថប្រយោជន៍សោធននិវត្តន៍នេះទេ ប៉ុន្តែពួកគេមានសិទ្ធិទទួលបានការបង់ប្រាក់មួយចំនួន ដូចខាងក្រោម៖

| អតីតភាពការងារ | អត្ថប្រយោជន៍ |
|---|---|
| តិចជាង ១០ ឆ្នាំ | មិនទទួលបានអត្ថប្រយោជន៍ និងមិនទទួលបានវិភាគទានសរុបមកវិញទេ។ វិភាគទានសរុបនឹងក្លាយទៅជាចំណូលអត្ថប្រយោជន៍។ |
| ១០-២៤ ឆ្នាំ | ទទួលបាន ២០០% នៃវិភាគទានសរុបពី ក.ស.ស និងបុគ្គលិក។ |

(គ) អត្ថប្រយោជន៍ចូលនិវត្តមុនកំណត់

បុគ្គលិកដែលបានចូលនិវត្ត ឬត្រូវបណ្តេញចេញមុនពេលដល់អាយុចូលនិវត្ត នឹងទទួលបានអត្ថប្រយោជន៍ ដូចខាងក្រោម៖

| អតីតភាពការងារ | អត្ថប្រយោជន៍ |
|---|---|
| តិចជាង ១០ ឆ្នាំ | មិនទទួលបានវិភាគទានសរុបរបស់បុគ្គលិកមកវិញទេ។ |
| ១០-២០ ឆ្នាំ | ១២០% នៃវិភាគទានសរុបរបស់បុគ្គលិក និង ១% បន្ថែម លើឆ្នាំនីមួយៗក្នុងរយៈពេល១០ឆ្នាំ។ |
| ២១-៣០ ឆ្នាំ | ១៣៥% នៃវិភាគទានសរុបរបស់បុគ្គលិក និង ១% បន្ថែម លើឆ្នាំនីមួយៗក្នុងរយៈពេល២១ឆ្នាំ។ |
| ៣១-៤០ ឆ្នាំ | ១៥៥% នៃវិភាគទានសរុបរបស់បុគ្គលិក និង ១% បន្ថែម លើឆ្នាំនីមួយៗក្នុងរយៈពេល៣០ឆ្នាំ។ |
| ៤០ឆ្នាំឡើងទៅ | ១៦៤% នៃវិភាគទានសរុបរបស់បុគ្គលិក។ |

(ឃ) អត្ថប្រយោជន៍មរណភាព

បុគ្គលិកដែលទទួលមរណភាព នឹងទទួលបានការបង់ប្រាក់ផ្តាច់តែមួយដង។ អត្ថប្រយោជន៍ដូចខាងក្រោមនេះ គឺអាស្រ័យទៅលើការចូលរួមវិភាគទានសរុបរបស់បុគ្គលិក និងអាស្រ័យទៅលើចំនួនឆ្នាំអតីតភាពការងាររបស់បុគ្គលិកនោះ ៖

| អតីតភាពការងារ | មរណភាពទាក់ទងនឹងការងារ | មរណភាពមិនទាក់ទងនឹងការងារ |
|---|---|---|
| តិចជាង ១០ឆ្នាំ | ១២៥% | ១១៥% |
| ១០-២០ ឆ្នាំ | ១៤៥% | ១៣៥% |
| ២១-៣០ ឆ្នាំ | ១៥៥% | ១៤៥% |
| ៣១-៤០ ឆ្នាំ | ១៦៥% | ១៥៥% |

## ២. សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ (ត)

### ២.១៩ អត្ថប្រយោជន៍បុគ្គលិក (ត)

(ង) អត្ថប្រយោជន៍ពិការភាព៖

បុគ្គលិកដែលបានបម្រើការងារតិចជាង២៥ឆ្នាំ ហើយបានធ្លាក់ខ្លួនពិការ នឹងទទួលបានការបង់ប្រាក់ផ្តាច់តែមួយដង អាស្រ័យទៅតាមការចូលរួមវិភាគទានរបស់ ក.ស.ស និងរបស់បុគ្គលិក ដូចខាងក្រោម៖

| អតីតភាពការងារ | ពិការភាពបណ្តាលមកពីការងារ | ពិការភាពមិនបណ្តាលមកពីការងារ |
|---|---|---|
| តិចជាង ១០ឆ្នាំ | ១២៥% | ១១៥% |
| ១០-២៤ឆ្នាំ | ១២៥% បូក ៣% លើឆ្នាំនីមួយៗក្នុងរយៈពេល១០ឆ្នាំ។ | ១១៥% បូក ៣% លើឆ្នាំនីមួយៗក្នុងរយៈពេល១០ឆ្នាំ។ |

បំណុលដែលបានកត់ត្រានៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ ទាក់ទងនឹងគម្រោងអត្ថប្រយោជន៍ពេលចូលនិវត្តដែលបានកំណត់ គឺជាតម្លៃបច្ចុប្បន្ននៃកាតព្វកិច្ចបានកំណត់ គិតត្រឹមដំណាច់ការិយបរិច្ឆេទរាយការណ៍ ដកតម្លៃសមស្របនៃទ្រព្យតម្កល់ (ប្រសិនបើមាន)។ កាតព្វកិច្ចសោធននិវត្តន៍ត្រូវបានគណនាដោយប្រើវិធីសាស្ត្រប៉ាន់ស្មានឯកតា ឥណទាន (projected unit credit)។ តម្លៃបច្ចុប្បន្ននៃកាតព្វកិច្ចសោធននិវត្តន៍ ត្រូវបានកំណត់ដោយធ្វើអប្បហារលើលំហូរសាច់ប្រាក់ប៉ាន់ស្មាននាពេលអនាគត ដោយប្រើអត្រាការប្រាក់បញ្ញើមធ្យមនៃមូលនិធិដែលបានផ្ញើនៅធនាគារ ដែលបម្រុងទុកសម្រាប់បង់អត្ថប្រយោជន៍សោធននិវត្តន៍ នាកាលបរិច្ឆេទវាយតម្លៃ ដោយសារមិនមានទីផ្សារសញ្ញាប័ណ្ណសាជីវកម្មដែលមានគុណភាពខ្ពស់ និងមិនមានសញ្ញាប័ណ្ណរដ្ឋាភិបាលនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ចំណេញ និងខាតពីការគណនាហានិភ័យដែលកើតពីនិយ័តកម្ម និងបម្រែបម្រួលក្នុងការសន្មតការគណនាហានិភ័យត្រូវបានកត់ត្រាជាបន្ទុក ឬកត់ត្រាខាងខ្វង់ឥណទានក្នុងចំណូលលម្អិតផ្សេងៗ ក្នុងការិយបរិច្ឆេទដែលវាកើតឡើង។ ចំណាយដែលពាក់ព័ន្ធនឹងការផ្តល់អត្ថប្រយោជន៍ទាំងនេះ ត្រូវបានកត់ត្រាជាបន្ទុកក្នុងរបាយការណ៍លទ្ធផល។

ថ្លៃដើមសេវាកម្មក្នុងអតីតកាលត្រូវបានកត់ត្រាភ្លាមក្នុងចំណេញ-ខាត។

### ២.២០ សំវិធានធន និងបំណុលយថាភាព

សំវិធានធនត្រូវបានកត់ត្រានៅពេលដែល ក.ស.ស មានកាតព្វកិច្ចតាមផ្លូវច្បាប់នាពេលបច្ចុប្បន្ន ឬកាតព្វកិច្ចប្រយោលដែលជាលទ្ធផលនៃព្រឹត្តិការណ៍ពីអតីតកាល ហើយវាទំនងជាតម្រូវឱ្យមានការចំណាយធនធានដើម្បីទូទាត់កាតព្វកិច្ចទាំងនោះ ហើយចំនួនទឹកប្រាក់អាចប៉ាន់ស្មានគួរឱ្យជឿជាក់បាន។ សំវិធានធនមិនត្រូវបានកត់ត្រាសម្រាប់ការខាតបង់ពីប្រតិបត្តិការនាពេលអនាគតទេ។

សំវិធានធនត្រូវបានវាស់វែងតាមចំណាយរំពឹងទុកដើម្បីទូទាត់កាតព្វកិច្ច។ ប្រសិនបើតម្លៃពេលវេលានៃទឹកប្រាក់មានចំនួនជាសារវន្ត នោះសំវិធានធនត្រូវវាស់វែងតាមតម្លៃបច្ចុប្បន្នរបស់វា ដោយប្រើអត្រាមុនបង់ពន្ធ ដែលឆ្លុះបញ្ចាំងអំពីការវាយតម្លៃទីផ្សារបច្ចុប្បន្ននូវតម្លៃពេលវេលានៃទឹកប្រាក់ និងហានិភ័យជាក់លាក់ចំពោះកាតព្វកិច្ចទាំងនោះ។ កំណើនសំវិធានធនដោយសារពេលវេលាកន្លងផុត ត្រូវបានកត់ត្រាជាចំណាយការប្រាក់។

**កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ**
**សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧**

## ២. សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ (ត)

### ២.២០ សំវិធានធន និងបំណុលយថាភាព (ត)

បំណុលយថាភាពគឺជាកាតព្វកិច្ចមួយដែលអាចកើតឡើងពីព្រឹត្តិការណ៍អតីតកាល ហើយបំណុលនោះនឹងត្រូវបញ្ជាក់ដោយភាពកើតមាន ឬមិនកើតមាននៃហេតុការណ៍មិនពិតប្រាកដនាពេលអនាគតមួយ ឬច្រើន ដែលមិនស្ថិតនៅក្រោមការគ្រប់គ្រងទាំងស្រុងរបស់ ក.ស.ស។ បំណុលយថាភាពក៏អាចជាកាតព្វកិច្ចនាពេលបច្ចុប្បន្ន ដែលកើតមកពីព្រឹត្តិការណ៍អតីតកាលដែលមិនទាន់បានកត់ត្រា ដោយសារមិនមានភាពប្រាកដថានឹងមានលំហូរធនធានសេដ្ឋកិច្ចចេញ ឬ ចំនួននៃកាតព្វកិច្ចនោះមិនអាចវាស់វែងគួរឱ្យជឿជាក់បាន។ បំណុលយថាភាពមិនត្រូវបានកត់ត្រាទេ ប៉ុន្តែវាត្រូវបានលាតត្រដាងនៅក្នុងកំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ។ នៅពេលមានបម្រែបម្រួលនៃលំហូរចេញអាចកើតមានឡើង ហើយលំហូរចេញនោះមានភាពប្រាកដប្រជា បំណុលយថាភាពនឹងត្រូវបានកត់ត្រាជាសំវិធានធន។

### ២.២១ ការកត់ត្រាប្រាក់ចំណូល

ប្រាក់ចំណូលរួមមាន តម្លៃសមស្របនៃសំវិធានធនសេវាកម្មដែលទទួលបាន និងដែលត្រូវទទួលសម្រាប់សកម្មភាពអាជីវកម្មធម្មតារបស់ ក.ស.ស។ ប្រាក់ចំណូលត្រូវបានបង្ហាញតាមអាករលើតម្លៃបន្ថែម និងអប្បហារត្រូវបានបង្ហាញដូចខាងក្រោម៖

<u>ចំណូលបានពីកំពង់ផែ</u>

ប្រាក់ចំណូលជាចម្បងរួមមាន កម្រៃដែលទទួលបានពីការផ្តល់សេវាកម្ម រួមបញ្ចូលការលើកដាក់ទំនិញ ការដឹកទំនិញ និងការបញ្ជានាវាចូលចំណត។ ប្រាក់ចំណូលពីសំវិធានធននៃសេវាទាំងនេះ ត្រូវបានកត់ត្រានៅពេលដែលបានបំពេញសេវាជូនអតិថិជន។

<u>ចំណូលពីការជួល - ក្រុមហ៊ុនគឺជាភាគីម្ចាស់ទ្រព្យជួល</u>

ភតិសន្យាដែលជាចំណែកនៃហានិភ័យដែលមានលក្ខណៈជាសារវន្ត និងភាពជាម្ចាស់ ត្រូវបានរក្សាទុកដោយភាគីម្ចាស់ទ្រព្យជួល ត្រូវបានចាត់ថ្នាក់ជាភតិសន្យាប្រតិបត្តិ។ ចំណូលពីការជួលរបស់ភតិសន្យាប្រតិបត្តិ ត្រូវបានកត់ត្រាក្នុងរយៈពេលនៃភតិសន្យា តាមមូលដ្ឋានរំលស់ថេរ។

<u>ចំណូលផ្សេងៗ</u>

ចំណូលផ្សេងៗរួមមានកម្រៃពីការចូលឡានធំៗ និងកម្រៃផ្សេងៗទៀត។ ចំណូលផ្សេងៗត្រូវបានកត់ត្រានៅពេលបានបំពេញសេវាណាមួយ។

### ២.២២ ចំណូលការប្រាក់

ចំណូលការប្រាក់ត្រូវបានកត់ត្រាដោយប្រើវិធីសាស្ត្រការប្រាក់មានប្រសិទ្ធភាព និងរួមបញ្ចូលក្នុងចំណូលហិរញ្ញវត្ថុនៅក្នុងចំណេញ-ខាត។

## ២. សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ (ត)

### ២.២៣ ភតិសន្យា-ក្រុមហ៊ុនជាភាគីអ្នកជួល

ទ្រព្យសម្បត្តិជួលដែលស្ថិតក្រោមភតិសន្យាប្រតិបត្តិ ត្រូវបានរួមបញ្ចូលក្នុងទ្រព្យសម្បត្តិវិនិយោគ នៅក្នុងរបាយ-ការណ៍ស្ថានភាពហិរញ្ញវត្ថុ (កំណត់សម្គាល់ ៧)។ សូមមើលកំណត់សម្គាល់ ២.២១ សម្រាប់ការកត់ត្រាចំណូលពីការជួល។

### ២.២៤ ការបែងចែកភាគលាភ

ការបែងចែកភាគលាភទៅឱ្យភាគហ៊ុនិក ក.ស.ស ត្រូវបានកត់ត្រាជាបំណុលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ ក.ស.ស តាមការសមស្រប ក្នុងការិយបរិច្ឆេទដែលក្រុមប្រឹក្សាភិបាល ក.ស.ស បានអនុម័តលើភាគលាភនោះ។

### ២.២៥ ចំណេញក្នុងមួយភាគហ៊ុន

**(ក) ចំណេញក្នុងមួយភាគហ៊ុនជាមូលដ្ឋាន** (Basic Earnings Per Share)

មូលដ្ឋាននៃចំណេញក្នុងមួយភាគហ៊ុន ត្រូវបានគណនាដោយៈ

- យកចំណេញរបស់ម្ចាស់ភាគហ៊ុន ក.ស.ស មិនរាប់បញ្ចូលចំណាយក្នុងការលក់ភាគហ៊ុន ក្រៅពីភាគហ៊ុនធម្មតា
- ចែកជាមួយនឹងចំនួនភាគហ៊ុនធម្មតាមធ្យមដែលនៅសល់ ក្នុងអំឡុងឆ្នាំហិរញ្ញវត្ថុ ដោយកែតម្រូវសម្រាប់ធាតុបន្ថែម នៅក្នុងភាគហ៊ុនធម្មតា ដែលបានបោះផ្សាយក្នុងអំឡុងឆ្នាំ និងមិនរាប់បញ្ចូលភាគហ៊ុន treasury shares។

**(ខ) ចំណេញក្នុងមួយភាគហ៊ុនថយចុះ** (Diluted Earnings Per Share)

ចំណេញក្នុងមួយភាគហ៊ុនថយចុះ កែតម្រូវតួលេខដែលបានប្រើប្រាស់ក្នុងការកំណត់ចំណេញក្នុងមួយភាគហ៊ុនជាមូលដ្ឋាន ដោយគិតទៅលើៈ

- ផលប៉ះពាល់លើការប្រាក់បន្ទាប់ពីដកពន្ធលើប្រាក់ចំណេញ និងចំណាយការប្រាក់ផ្សេងៗទៀត ដែលទាក់ទិននឹងភាគហ៊ុនធម្មតាដែលមានសក្តានុពល និង
- ចំនួនមធ្យមនៃភាគហ៊ុនធម្មតាបន្ថែម ដែលអាចត្រូវបានសន្មតថាមានការផ្ទេរភាគហ៊ុនដែលមានសក្តានុពលទាំងអស់ទៅជាភាគហ៊ុនធម្មតា។ p

### ២.២៦ ការរាយការណ៍តាមផ្នែក

ការរាយការណ៍តាមផ្នែកត្រូវបានរាយការណ៍ឱ្យស៊ីសង្វាក់ជាមួយនឹងការរាយការណ៍ផ្ទៃក្នុង ដែលបានផ្តល់ជូនប្រធានអ្នកសម្រេចចិត្តផ្នែកប្រតិបត្តិការ។ ប្រធានអ្នកសម្រេចចិត្តផ្នែកប្រតិបត្តិការគឺជាក្រុមគណៈគ្រប់គ្រង (រួមទាំងអគ្គនាយក និងអគ្គនាយករងទាំងអស់) ដែលជាអ្នកធ្វើការសម្រេចចិត្តចំពោះការបែងចែកធនធាន និងជាអ្នកធ្វើការវាយតម្លៃលើលទ្ធផលនៃផ្នែកប្រតិបត្តិការ និងជាអ្នកដែលធ្វើការសម្រេចចិត្តផ្នែកយុទ្ធសាស្ត្រ។

**កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ**
**សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧**

## ៣. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ

## ៣.១ កត្តាហានិភ័យហិរញ្ញវត្ថុផ្សេងៗ

ក.ស.ស ត្រូវប្រឈមមុខនឹងហានិភ័យផ្សេងៗដូចជា ហានិភ័យទីផ្សារ (រួមបញ្ចូលហានិភ័យអត្រាការប្រាក់ និងហានិភ័យការប្តូររូបិយប័ណ្ណ) ហានិភ័យឥណទាន និងហានិភ័យសាច់ប្រាក់ងាយស្រួល។ ក.ស.ស គ្រប់គ្រង និងសន្ទតហានិភ័យទាំងនេះ ដោយការតាមដានអត្រាការប្រាក់លើទីផ្សារ ប្រវត្តិឥណទាននៃភាគីដៃគូរបស់ខ្លួន អត្រាប្តូររូបិយប័ណ្ណ និងលំហូរសាច់ប្រាក់។ បច្ចុប្បន្ននេះ ក.ស.ស មិនប្រើប្រាស់ឧបករណ៍ហិរញ្ញវត្ថុនិស្សន្ទ (derivative financial instruments) ដើម្បីការពារហានិភ័យអត្រាការប្រាក់ និងហានិភ័យការប្តូររូបិយប័ណ្ណរបស់ខ្លួននោះទេ។

### (ក) ហានិភ័យទីផ្សារ

### (ក.១) ហានិភ័យអត្រាការប្រាក់

ហានិភ័យអត្រាការប្រាក់គឺជាហានិភ័យដែលបម្រែបម្រួលការប្រាក់លើទីផ្សារនាពេលអនាគត នឹងធ្វើឱ្យប៉ះពាល់ដល់លទ្ធផលនៃប្រតិបត្តិការ និងលំហូរសាច់ប្រាក់របស់ ក.ស.ស។

ក.ស.ស បានទទួលប្រាក់កម្ចី (ក្នុងអត្រាការប្រាក់អថេរ) ពីទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិរបស់ប្រទេសជប៉ុន (JICA) និងធនាគារជប៉ុនសម្រាប់កិច្ចសហប្រតិបត្តិការអន្តរជាតិ (JIBC) តាមរយៈក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ក.ស.ស មិនមានការផ្តោះប្តូរអត្រាការប្រាក់ ឬការការពារផ្សេងទៀតទេ ដោយសារគណៈគ្រប់គ្រងជឿជាក់ថាហានិភ័យអត្រាការប្រាក់នឹងមិនមានផលប៉ះពាល់ជាសារវន្តនោះទេ។

### (ក.២) ហានិភ័យការប្តូររូបិយប័ណ្ណ

ក.ស.ស ប្រឈមមុខនឹងហានិភ័យការប្តូររូបិយប័ណ្ណ ដែលសំខាន់ជាងគេគឺការប្តូរពីប្រាក់រៀល ទៅជាប្រាក់យ៉េន និងទៅជាប្រាក់ដុល្លារអាមេរិក ដោយសារប្រាក់កម្ចីពី JICA និងពី JIBC តាមរយៈក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គឺទទួលបានជាប្រាក់យ៉េន និងប្រាក់ដុល្លារអាមេរិក ក៏ប៉ុន្តែ ក.ស.ស កត់ត្រាគណនេយ្យរបស់ខ្លួនជាប្រាក់រៀល ដែលជារូបិយប័ណ្ណគោល។ បច្ចុប្បន្ននេះ ក.ស.ស មិនប្រើប្រាស់ការការពារ ឬប្រើកិច្ចសន្យាប្តូររូបិយប័ណ្ណនាពេលអនាគត ដើម្បីការពារហានិភ័យនេះទេ។

ភាពងាយទទួលរងនូវផលប៉ះពាល់របស់ ក.ស.ស ពីអត្រាប្តូររូបិយប័ណ្ណ ទៅលើឧបករណ៍ហិរញ្ញវត្ថុជាប្រាក់យ៉េន និងឧបករណ៍ហិរញ្ញវត្ថុជាប្រាក់ដុល្លារអាមេរិករបស់ខ្លួន ត្រូវបានវិភាគដូចខាងក្រោម។ ឧបករណ៍ហិរញ្ញវត្ថុរបស់ ក.ស.ស ត្រូវបានកត់ត្រាជាចម្បងជារូបិយប័ណ្ណបរទេសទាំងពីរនេះ។ ក.ស.ស បានវិភាគបម្រែបម្រួលនៃរូបិយប័ណ្ណទាំងនេះក្នុងរយៈពេលបីឆ្នាំចុងក្រោយ ហើយបានសន្និដ្ឋានថាអត្រាបម្រែបម្រួល ២,៦% សម្រាប់ប្រាក់យ៉េន និង ០,៣% សម្រាប់ប្រាក់ដុល្លារអាមេរិក គឺមានភាពសមហេតុផល។

ប្រសិនបើប្រាក់យ៉េនធ្លាក់ចុះ ឬកើនឡើង ២,៦% (អត្រាប្រែប្រួលសម្រាប់រយៈពេលបីឆ្នាំមុន) ធៀបនឹងប្រាក់រៀលនោះ ប្រាក់ចំណេញប្រចាំឆ្នាំក្រោយបង់ពន្ធនឹងត្រូវកើនឡើង ឬថយចុះ ៨.១៥៦ លានរៀល ដែលជាលទ្ធផលបណ្តាលមកពីចំណេញ/ខាតពីការប្តូរប្រាក់កម្ចី ដែលទទួលបានជាប្រាក់យ៉េន។

ប្រសិនបើប្រាក់ដុល្លារអាមេរិកធ្លាក់ចុះ ឬកើនឡើង ០,៣% (អត្រាប្រែប្រួលសម្រាប់រយៈពេលបីឆ្នាំមុន) ធៀបនឹងប្រាក់រៀល នោះប្រាក់ចំណេញប្រចាំឆ្នាំក្រោយបង់ពន្ធនឹងត្រូវកើនឡើង ឬថយចុះ ៣៧លានរៀល ដែលជាលទ្ធផលបណ្តាលមកពីចំណេញ/ខាតពីការប្តូរប្រាក់កម្ចីដែលទទួលបានជាប្រាក់ដុល្លារអាមេរិក។

## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧

### ៣. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)
### ៣.១ កត្តាហានិភ័យហិរញ្ញវត្ថុផ្សេងៗ (ត)
### (ក) ហានិភ័យទីផ្សារ (ត)
### (ក.២) ហានិភ័យការប្តូររូបិយប័ណ្ណ (ត)

តារាងខាងក្រោមនេះសង្ខេបពីហានិភ័យអត្រាការប្តូររូបិយប័ណ្ណរបស់ ក.ស.ស គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ និង ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦។ ចំនួនទឹកប្រាក់ក្នុងតារាងនេះគឺជាឧបករណ៍ហិរញ្ញវត្ថុតាមតម្លៃយោង និងតាមប្រភេទរូបិយ-ប័ណ្ណ ដោយមានតម្លៃសមមូលនឹងពាន់រៀល។

| | សមមូលនឹងពាន់រៀល | | | |
|---|---|---|---|---|
| | ប្រាក់យ៉េន | ប្រាក់ដុល្លារអាមេរិក | ប្រាក់រៀល | សរុប |
| **ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧** | | | | |
| **ទ្រព្យសកម្មហិរញ្ញវត្ថុ** | | | | |
| គណនីអតិថិជនពាណិជ្ជកម្ម និងគណនីអតិថិជនផ្សេងៗ | - | ២៥.៥៩៣.១១៥ | ១០.៨៧០.៥២៨ | ៣៦.៤៦៣.៦៤៣ |
| ឥណទានផ្តល់ឱ្យបុគ្គលិក | - | - | ៦.៩២៣.៥៣៨ | ៦.៩២៣.៥៣៨ |
| ប្រាក់បញ្ញើរយៈពេលខ្លីនៅធនាគារ | - | ៦៨.៦២៩.០០០ | ៤.៥៦៥.២០១ | ៧៣.១៩៤.២០១ |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូល | - | ៤០.២០៨.៥៧៣ | ១០.៨៧២.៦៥៦ | ៥១.០៨១.២២៩ |
| | - | ១៣៤.៤៣០.៦៨៨ | ៣៣.២៣១.៩២៣ | ១៦៧.៦៦២.៦១១ |
| **បំណុលហិរញ្ញវត្ថុ** | | | | |
| ប្រាក់កម្ចី | (៣៩៨.១៧៩.៨៥៤) | (១២៧.០៥៥.០២៨) | - | (៥២៥.២៣៤.៨៨២) |
| ភាគលាភអប្បបរមាធានាត្រូវបង់ | - | - | (១៤.៧៥៩.៨៩៤) | (១៤.៧៥៩.៨៩៤) |
| គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម និងគណនីអ្នកផ្គត់ផ្គង់ផ្សេងៗ | - | (២២.៣២៣.៩២៦) | (២.៣៧៦.៩៤០) | (២៤.៧០០.៨៦៦) |
| | (៣៩៨.១៧៩.៨៥៤) | (១៤៩.៣៧៨.៩៥៤) | (១៧.១៣៦.៨៣៤) | (៥៦៤.៦៩៥.៦៤២) |
| **ស្ថានភាពសុទ្ធ** | (៣៩៨.១៧៩.៨៥៤) | (១៤.៩៤៨.២៦៦) | ១៦.០៩៥.០៨៩ | (៣៩៧.០៣៣.០៣១) |
| **ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦** | | | | |
| **ទ្រព្យសកម្មហិរញ្ញវត្ថុ** | | | | |
| គណនីអតិថិជនពាណិជ្ជកម្ម និងគណនីអតិថិជនផ្សេងៗ | - | ១៧.៦២០.៧២២ | ៦.៥៤៧.០៦៤ | ២៤.១៦៧.៧៨៦ |
| ប្រាក់បញ្ញើរយៈពេលខ្លីនៅធនាគារ | - | ៨.០៧៤.០០០ | ៥.៤០៥.២២៨ | ១៣.៤៧៩.២២៨ |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូល | - | ៣៤.៥៨៩.២៨០ | ៦២.៣២៤ | ៣៤.៦៥១.៦០៤ |
| | - | ៦០.២៨៤.០០២ | ១២.០១៤.៦១៦ | ៧២.២៩៨.៦១៨ |
| **បំណុលហិរញ្ញវត្ថុ** | | | | |
| ប្រាក់កម្ចី | (៣៤៥.២៥៨.៨០៧) | (១៣៤.៥២០.៣០០) | - | (៤៧៩.៧៧៩.១០៧) |
| គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម និងគណនីអ្នកផ្គត់ផ្គង់ផ្សេងៗ | - | (៦.០៦៨.១៥៧) | (២៦៩.៦៤៣) | (៦.៣៣៧.៨០០) |
| | (៣៤៥.២៥៨.៨០៧) | (១៤០.៥៨៨.៤៥៧) | (២៦៩.៦៤៣) | (៤៨៦.១១៦.៩០៧) |
| **ស្ថានភាពសុទ្ធ** | (៣៤៥.២៥៨.៨០៧) | (៨០.៣០៤.៤៥៥) | ១១.៧៤៤.៩៧៣ | (៤១៣.៨១៨.២៨៩) |

**កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ**
**សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧**

**៣.　ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)**

**៣.១　កត្តាហានិភ័យហិរញ្ញវត្ថុផ្សេងៗ (ត)**

**(ខ)　ហានិភ័យឥណទាន**

**(ខ.១)　ហានិភ័យ**

ក.ស.ស ប្រឈមមុខនឹងហានិភ័យឥណទាន ដែលពាក់ព័ន្ធជាចម្បងទៅនឹងគណនីអតិថិជនពាណិជ្ជកម្ម និងគណនីអតិថិជនផ្សេងៗ ឥណទានផ្តល់ឱ្យបុគ្គលិក ប្រាក់បញ្ញើរយៈពេលខ្លីនៅធនាគារ និងសាច់ប្រាក់នៅធនាគារ។

ដើម្បីគ្រប់គ្រងហានិភ័យលើគណនីអតិថិជនពាណិជ្ជកម្ម និងគណនីអតិថិជនផ្សេងៗ ក.ស.ស តម្រូវឱ្យក្រុមហ៊ុនដឹកជញ្ជូនតាមនាវានីមួយៗតម្កល់ប្រាក់កក់មុននឹងបំពេញសេវាណាមួយឱ្យក្រុមហ៊ុននោះ។ ចំពោះគ្រឹះស្ថានរបស់រដ្ឋាភិបាលមិនតម្រូវឱ្យមានប្រាក់កក់ទេ ដោយសារ ក.ស.ស ជឿជាក់ថាខ្លួនអាចប្រមូលប្រាក់ពីស្ថាប័នទាំងនោះតាមរយៈក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (ដែលជាប្រភពហិរញ្ញវត្ថុនៃគ្រឹះស្ថានរដ្ឋទាំងនោះ)។ ចំពោះក្រុមហ៊ុនដឹកជញ្ជូនតាមនាវាដែលមិនប្រើប្រាស់សេវារបស់ ក.ស.ស ញឹកញាប់គឺមិនតម្រូវឱ្យកក់ប្រាក់ទេ ដោយសារក្រុមហ៊ុនទាំងនៅតម្រូវឱ្យបង់ប្រាក់នៅពេលបំពេញសេវាតែម្តង។ ក.ស.ស មានគោលការណ៍កាត់ប្រាក់កក់ ចំពោះអតិថិជនដែលមិនបានទូទាត់សងបំណុលរបស់ពួកគេទៅតាមខ និងកិច្ចសន្យាឥណទាន។ ហានិភ័យឥណទានរបស់ ក.ស.ស ចំពោះគណនីអតិថិជនពាណិជ្ជកម្ម និងគណនីអតិថិជនផ្សេងៗ ត្រូវបានកំណត់ឱ្យនៅត្រឹមតម្លៃយោងនៃគណនីអតិថិជននោះ ដកសំវិធានធនសម្រាប់ការថយចុះតម្លៃនៃគណនីអតិថិជនផ្អែកតាមការត្រួតពិនិត្យលើចំនួនដែលនៅមិនទាន់ទូទាត់នាដំណាច់ឆ្នាំ។

**(ខ.២)　ទ្រព្យធានា**

ចំពោះគណនីអតិថិជនពាណិជ្ជកម្មខ្លះ ក.ស.ស អាចទទួលទ្រព្យធានាក្នុងទម្រង់ជាការតម្កល់ជាសាច់ប្រាក់ ដែលអាចស្នើឱ្យបង់ប្រាក់បាន ប្រសិនបើភាគីដៃគូខកខានមិនបានបង់ប្រាក់តាមលក្ខខណ្ឌក្នុងកិច្ចព្រមព្រៀង។

**(ខ.៣)　គុណភាពឥណទាន**

គុណភាពឥណទាននៃទ្រព្យសកម្មហិរញ្ញវត្ថុដែលមិនហួសកំណត់ និងមិនថយចុះតម្លៃ អាចត្រូវបានវាស់វែងដោយយោងទៅលើព័ត៌មានក្នុងគ្រាមុនៗ អំពីអត្រាខកខានមិនបានសងបំណុលរបស់ភាគីដៃគូ។

មិនមានការកំណត់អត្រាចំពោះទ្រព្យសកម្មហិរញ្ញវត្ថុរបស់ ក.ស.ស ដោយភ្នាក់ងារវាយតម្លៃឥណទានណាមួយទេ។

## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧

**៣. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)**

**៣.១ កត្តាហានិភ័យហិរញ្ញវត្ថុផ្សេងៗ (ត)**

**(គ) ហានិភ័យសន្ទនីយ**

ក.ស.ស ប្រឈមមុខនឹងហានិភ័យសន្ទនីយ ដែលកើតពីការបង្វិលសាច់ប្រាក់ទូទៅក្នុងសកម្មភាពអាជីវកម្មរបស់ខ្លួន។ ហានិភ័យសន្ទនីយរួមមានហានិភ័យដែលអាចធ្វើឱ្យ ក.ស.ស មិនមានលទ្ធភាពបង្វិលសាច់ប្រាក់ក្នុងសកម្មភាពអាជីវកម្មរបស់ខ្លួនឱ្យទាន់ពេលវេលា។

គោលការណ៍របស់ ក.ស.ស គឺត្រូវរក្សាទុកសាច់ប្រាក់ និងសាច់ប្រាក់សមមូលឱ្យបានគ្រប់គ្រាន់ សម្រាប់ប្រតិបត្តិការរបស់ខ្លួន និងប្រើប្រាស់កញ្ចប់ឥណទាន ជាមួយនឹងមូលនិធិផ្ទាល់ ដើម្បីបង់ការចំណាយវិនិយោគ។

ក.ស.ស មានប្រាក់កម្ចីមិនទាន់ដកយកដូចខាងក្រោមនេះ នាដំណាច់ឆ្នាំៈ

| | **២០១៧**<br>**ពាន់រៀល** | **២០១៦**<br>**ពាន់រៀល** |
|---|---:|---:|
| **អត្រាការប្រាក់ថេរ** | | |
| មានកាលកំណត់លើសពី១ឆ្នាំ | ៥២.៦០៨.៥៦៩ | ១០៣.៨៥៧.០០០ |

តារាងខាងក្រោមនេះវិភាគអំពីបំណុលហិរញ្ញវត្ថុរបស់ ក.ស.ស តាមរយៈពេលដែលនៅសល់ រហូតដល់កាលបរិច្ឆេទផុតកំណត់ គិតត្រឹមកាលបរិច្ឆេទតារាងតុល្យការ។ ចំនួនដែលបានលាតត្រដាងនៅក្នុងតារាងនេះ គឺជាលំហូរសាច់ប្រាក់ក្នុងកិច្ចសន្យាដែលមិនធ្វើអប្បហារ។

| | **ក្រោម ១ ឆ្នាំ**<br>**ពាន់រៀល** | **ពី ១-២ ឆ្នាំ**<br>**ពាន់រៀល** | **ពី ២-៥ ឆ្នាំ**<br>**ពាន់រៀល** | **លើសពី ៥ ឆ្នាំ**<br>**ពាន់រៀល** | **សរុប**<br>**ពាន់រៀល** |
|---|---:|---:|---:|---:|---:|
| **គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧** | | | | | |
| ប្រាក់កម្ចី | ២១.៦៩៧.៥៧៦ | ២១.៨០៨.៤៥៨ | ៧៤.៨១៩.៨១៤ | ៤០៦.៩០៩.០៣៤ | ៥២៥.២៣៤.៨៨២ |
| ភាគលាភអប្បបរមាធានាត្រូវបង់ | ៥.៤០៣.៦៣៤ | ៥.៤០៣.៦៣៤ | ៥.៤០៣.៦៣៤ | - | ១៦.២១០.៩០២ |
| គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម និង គណនីអ្នកផ្គត់ផ្គង់ផ្សេងៗ | ២៤.៧០០.៨៦៧ | - | - | - | ២៤.៧០០.៨៦៧ |
| | ៥១.៨០២.០៧៧ | ២៧.២១២.០៩២ | ៨០.២២៣.៤៤៨ | ៤០៦.៩០៩.០៣៤ | ៥៦៦.១៤៦.៦៥១ |
| **គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦** | | | | | |
| ប្រាក់កម្ចី | ១៦.៥៤៣.៧៣៥ | ២០.២៩៤.៨៧៩ | ៧៦.០៧០.៣២៨ | ៣៦៦.៨៧០.១៦៥ | ៤៧៩.៧៧៩.១០៧ |
| គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម និង គណនីអ្នកផ្គត់ផ្គង់ផ្សេងៗ | ៦.៣៣៧.៧៩៩ | - | - | - | ៦.៣៣៧.៧៩៩ |
| | ២២.៨៨១.៥៣៤ | ២០.២៩៤.៨៧៩ | ៧៦.០៧០.៣២៨ | ៣៦៦.៨៧០.១៦៥ | ៤៨៦.១១៦.៩០៦ |

**កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ**
**សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧**

**៣. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)**

**៣.២ ការគ្រប់គ្រងហានិភ័យដើមទុន**

ទិសដៅរបស់ ក.ស.ស ក្នុងការគ្រប់គ្រងដើមទុន គឺដើម្បីការពារលទ្ធភាពរបស់ខ្លួនក្នុងការបន្តនិរន្តរភាពអាជីវកម្ម ដើម្បីផ្តល់ផលប្រយោជន៍ជូនភាគហ៊ុនិក និងភាគីពាក់ព័ន្ធផ្សេងទៀត និងរក្សារចនាសម្ព័ន្ធមូលធនល្អបំផុត ដើម្បីកាត់បន្ថយចំណាយដើមទុន។

ក.ស.ស មិនមានគោលការណ៍ជាក់លាក់ចំពោះអនុបាតបំណុលធៀបនឹងដើមទុននោះទេ។

**៣.៣ តម្លៃសមស្របរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុវាស់វែងតាមថ្លៃដើមដករំលស់**

វិធីសាស្រ្ត និងការសន្មត ដែលបានប្រើប្រាស់ក្នុងការប៉ាន់ស្មានតម្លៃសមស្របនៃឧបករណ៍ហិរញ្ញវត្ថុ មានដូចខាងក្រោម៖

(ក) *សាច់ប្រាក់ និងសាច់ប្រាក់សមមូល និងប្រាក់បញ្ញើរយៈពេលខ្លីនៅធនាគារ* - តម្លៃយោងនៃគណនីទាំងនេះ មានតម្លៃប្រហាក់ប្រហែលនឹងតម្លៃសមស្រប ដោយសារវាមានរយៈពេលខ្លី។

(ខ) *គណនីអតិថិជន និងគណនីអ្នកផ្គត់ផ្គង់ផ្សេងៗ* - តម្លៃយោងដកសំវិធានធនដែលបណ្តាលមកពីការថយចុះតម្លៃមានតម្លៃប្រហាក់ប្រហែលនឹងតម្លៃសមស្រប ដោយសារគណនីទាំងនេះស្ថិតនៅក្រោមលក្ខខណ្ឌឥណទានធម្មតា និងមានរយៈពេលខ្លី។

(គ) *ឥណទានផ្តល់ឱ្យបុគ្គលិក* - តម្លៃយោងរយៈពេលខ្លី នៃឥណទានផ្តល់ឱ្យបុគ្គលិក ត្រូវបានចាត់ទុកថាមានតម្លៃដូចគ្នាជាមួយតម្លៃសមស្រប ដោយសារឥណទានផ្តល់ឱ្យបុគ្គលិកមានរយៈពេលខ្លី។ ចំពោះឥណទានផ្តល់ឱ្យបុគ្គលិករយៈពេលវែង មានតម្លៃសមស្របចំនួន ៣.៧៤០ លានរៀល គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ ធៀបនឹងតម្លៃយោងដែលមានចំនួន ៥.៣០៥ លានរៀល។ តម្លៃសមស្របត្រូវបានគណនាផ្អែកតាមលំហូរសាច់ប្រាក់អប្បហារ ដោយប្រើអត្រាប្រាក់កម្ចីនាពេលបច្ចុប្បន្ន។ វាត្រូវបានចាត់ទុកថាស្ថិតនៅក្នុងតម្លៃសមស្របកម្រិតទី៣ ក្នុងឋានានុក្រមតម្លៃសមស្រប ដោយសារការរួមបញ្ចូលនូវធាតុចូលដែលមិនអាចអង្កេតបាន រួមមាន ហានិភ័យឥណទានរបស់ភាគីដៃគូជាដើម។

(ឃ) *ភាគលាភអប្បបរមាធានាត្រូវបង់* - តម្លៃយោងរយៈពេលខ្លី នៃភាគលាភអប្បបរមាធានាត្រូវបង់ ត្រូវបានចាត់ទុកថាមានតម្លៃដូចគ្នាជាមួយតម្លៃសមស្រប ដោយសារភាគលាភអប្បបរមាធានាត្រូវបង់មានរយៈពេលខ្លី។ ចំពោះភាគលាភអប្បបរមាធានាត្រូវបង់រយៈពេលវែង មានតម្លៃសមស្របចំនួន ៨.៨៨៩ លានរៀល គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ ធៀបនឹងតម្លៃយោងដែលមានចំនួន ១០.១៦៩ លានរៀល។ តម្លៃសមស្របត្រូវបានគណនាផ្អែកតាមលំហូរសាច់ប្រាក់អប្បហារ ដោយប្រើអត្រាប្រាក់កម្ចីនាពេលបច្ចុប្បន្ន។ វាត្រូវបានចាត់ទុកថាស្ថិតនៅក្នុងតម្លៃសមស្របកម្រិតទី៣ ក្នុងឋានានុក្រមតម្លៃសមស្រប ដោយសារការរួមបញ្ចូលនូវធាតុចូលដែលមិនអាចអង្កេតបាន រួមមានហានិភ័យឥណទានរបស់ភាគីដៃគូជាដើម។

(ង) *ប្រាក់កម្ចី* - តម្លៃសមស្របនៃប្រាក់កម្ចីត្រូវប៉ាន់ស្មានដោយធ្វើអប្បហារលើលំហូរសាច់ប្រាក់ចេញក្នុងកិច្ចសន្យានាពេលអនាគត ដោយប្រើអត្រាប្រាក់កម្ចីនាដំណាច់ឆ្នាំ (កំណត់សម្គាល់ ១៦)។

**កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ**
**សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧**

## ៣. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)
## ៣.៣ តម្លៃសមស្របរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុវាស់វែងតាមថ្លៃដើមដករំលស់ (ត)

ឧបករណ៍ហិរញ្ញវត្ថុដែលវាស់វែងតាមតម្លៃសមស្រប ត្រូវបានវិភាគទៅតាមឋានានុក្រមនៃការវាស់វែងតម្លៃសមស្រប ដូចខាងក្រោម៖

កម្រិត ១ តម្លៃលក់ក្នុងទីផ្សារសកម្ម (មិនកែតម្រូវ) ចំពោះទ្រព្យសកម្ម ឬបំណុលដែលអាចកំណត់បាន។ ក.ស.ស មិនមានកាន់កាប់មូលបត្រចុះបញ្ជីទេ។

កម្រិត ២ ធាតុចូលផ្សេងៗ ក្រៅពីតម្លៃលក់ដែលបានរួមបញ្ចូលក្នុងកម្រិត ១ ដែលអាចអង្កេតទ្រព្យសកម្ម ឬ បំណុលបានដោយផ្ទាល់ (តាមថ្លៃកំណត់) ឬ ដោយប្រយោល (តាមថ្លៃនិស្សន្ទ)។

កម្រិត ៣ ធាតុចូលចំពោះទ្រព្យសកម្ម ឬបំណុល ដែលមិនអាស្រ័យលើទិន្នន័យលើទីផ្សារដែលអាចសង្កេតបាន (ដែលជាធាតុចូលដែលមិនអាចអង្កេតបាន)។

## ៤. ការប៉ាន់ស្មានគណនេយ្យ ការសន្មត និងការវិនិច្ឆ័យសំខាន់ៗ

ការប៉ាន់ស្មាន ការសន្មត និងការវិនិច្ឆ័យ ត្រូវបានវាយតម្លៃជាបន្តបន្ទាប់ ដោយផ្អែកទៅតាមបទពិសោធន៍ក្នុងគ្រាមុន និងកត្តាផ្សេងៗទៀត រួមមានការរំពឹងទុកនៃព្រឹត្តិការណ៍នាពេលអនាគត ដែលគេជឿជាក់ថាមានភាពសមហេតុផលទៅតាមកាលៈទេសៈផ្សេងៗ។ ក.ស.ស ធ្វើការប៉ាន់ស្មាន ការសន្មត និងការវិនិច្ឆ័យដោយគិតពីអនាគតកាល។ តាមនិយមន័យលទ្ធផលនៃការប៉ាន់ស្មានគណនេយ្យ កម្រដូចគ្នានឹងលទ្ធផលពិតជាក់ស្តែងណាស់។ ការប៉ាន់ស្មាន ការសន្មត និងការវិនិច្ឆ័យដែលមានហានិភ័យធំ អាចបណ្តាលឱ្យមាននិយ័តកម្មជាសារវន្តលើតម្លៃយោងរបស់ទ្រព្យសកម្ម និងបំណុលក្នុងឆ្នាំហិរញ្ញវត្ថុបន្ទាប់ ត្រូវបានបង្ហាញដូចខាងក្រោម៖

### (ក) ពន្ធ

ពន្ធ ត្រូវបានគណនាតាមមូលដ្ឋានបំណកស្រាយបទប្បញ្ញត្តិពន្ធដារនាពេលបច្ចុប្បន្ន ដែលបានចូលជាធរមាននាកាលបរិច្ឆេទរាយការណ៍។ គណៈគ្រប់គ្រងវាយតម្លៃទៅតាមការិយបរិច្ឆេទ អំពីស្ថានភាពដែលបានកើតឡើងក្នុងលិខិតប្រកាសពន្ធ ដែលទាក់ទិនទៅនឹងបទប្បញ្ញត្តិពន្ធ និងបំណកស្រាយរបស់វាដែលនៅជាធរមាន។ ក.ស.ស កត់ត្រាសំវិធានធនតាមការសមស្រប ទៅតាមមូលដ្ឋាននៃចំនួនទឹកប្រាក់ដែលរំពឹងថាត្រូវបង់ជូនអាជ្ញាធរពន្ធដារ។

ទោះជាយ៉ាងណាក៏ដោយ បទប្បញ្ញត្តិទាំងអស់នេះមានការផ្លាស់ប្តូរពីមួយគ្រាទៅមួយគ្រា ហើយការកំណត់ចុងក្រោយបំផុតលើចំនួនបំណុលពន្ធ នឹងធ្វើឡើងបន្ទាប់ពីមានការត្រួតពិនិត្យដោយអាជ្ញាធរពន្ធដារ។ នៅពេលដែលលទ្ធផលពន្ធចុងក្រោយខុសគ្នាពីចំនួនដែលបានកត់ត្រាពីដំបូង នោះភាពលម្អៀងនេះនឹងធ្វើឲ្យប៉ះពាល់ដល់សមតុល្យបំណុលពន្ធក្នុងការិយបរិច្ឆេទដែលការកំណត់ពន្ធត្រូវបានធ្វើឡើង។

**កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ**
**សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧**

## ៤. ការប៉ាន់ស្មានគណនេយ្យ ការសន្មត និងការវិនិច្ឆ័យសំខាន់ៗ (ត)

### (ខ) កាតព្វកិច្ចសោធននិវត្តន៍ (ត)

តម្លៃបច្ចុប្បន្ននៃកាតព្វកិច្ចសោធននិវត្តន៍គឺអាស្រ័យទៅតាមកត្តាមួយចំនួន ដែលត្រូវបានកំណត់តាមមូលដ្ឋានដែលពាក់ព័ន្ធនឹងការគណនាហានិភ័យ ដោយប្រើប្រាស់ការសន្មតមួយចំនួន។ ការសន្មតដែលបានប្រើប្រាស់ក្នុងការកំណត់ចំណាយសុទ្ធសម្រាប់ប្រាក់សោធននិវត្តន៍ រួមមានអត្រាអប្បហារ អត្រាកំណើនប្រាក់បៀវត្សរ៍ អត្រាមរណៈ និងអត្រាបោះបង់ការងារ។ បម្រែបម្រួលណាមួយលើការសន្មតទាំងនេះ នឹងធ្វើឱ្យប៉ះពាល់ដល់តម្លៃយោងរបស់កាតព្វកិច្ចសោធននិវត្តន៍នេះ។ ព័ត៌មានបន្ថែមទៀតត្រូវបានលាតត្រដាងនៅក្នុងកំណត់សម្គាល់១៧។

ដោយសារមិនមានទីផ្សារសញ្ញាប័ណ្ណ និងសញ្ញាប័ណ្ណរដ្ឋាភិបាលនៅក្នុងប្រទេសកម្ពុជា ក.ស.ស ប្រើប្រាស់អត្រាការប្រាក់តម្កល់មធ្យមនៃមូលនិធិដែលបានផ្ញើនៅធនាគារ ដែលបម្រុងទុកសម្រាប់សោធននិវត្តន៍ ជាអត្រាអប្បហារដើម្បីកំណត់តម្លៃបច្ចុប្បន្ននៃលំហូរសាច់ប្រាក់ចេញប៉ាន់ស្មាននាពេលអនាគត ដែលតម្រូវឱ្យមានសម្រាប់ការទូទាត់កាតព្វកិច្ចសោធននិវត្តន៍។

នៅពេលដែលអត្រាអប្បហារ បានប្រើប្រាស់ខុសពីការប៉ាន់ស្មានរបស់គណៈគ្រប់គ្រង ០,៥% អត្រាកំណើនប្រាក់បៀវត្សរ៍ បានប្រើប្រាស់ខុសពីការប៉ាន់ស្មានរបស់គណៈគ្រប់គ្រង ២,៥% និងអត្រាមរណៈបានប្រើប្រាស់ខុសពីការប៉ាន់ស្មានរបស់គណៈគ្រប់គ្រង ១០% នោះតម្លៃយោងនៃកាតព្វកិច្ចសោធននិវត្តន៍ អាចនឹងត្រូវផ្លាស់ប្តូរប្រហាក់ប្រហែលនឹងចំនួនខាងក្រោម៖

| | មូលដ្ឋាន | ផលប៉ះពាល់ (sensitivity impact) | | | | | |
|---|---|---|---|---|---|---|---|
| អត្រាអប្បហារ | ៧,០% | ៦,៥% | ៧,៥% | ៧,០% | ៧,០% | ៧,០% | ៧,០% |
| អត្រាកំណើនប្រាក់បៀវត្សរ៍ | ៥,០% | ៥,០% | ៥,០% | ២,៥% | ៧,៥% | ៥,០% | ៥,០% |
| អត្រាមរណៈ | ១០០,០% | ១០០,០% | ១០០,០% | ១០០,០% | ១០០,០% | ៩០,០% | ១១០,០% |
| កាតព្វកិច្ចសោធននិវត្តន៍បានកំណត់ (លានរៀល) | ៤១.០០៨ | ៤៥.០៣៥ | ៣៧.៣៥៧ | ៤០.០៣២ | ៤១.៩៨៤ | ៤៣.៨៧៩ | ៣៨.៣២៥ |
| ផលប៉ះពាល់ (%) | | ១០% | (៩%) | (២%) | ២% | ៧% | (៧%) |

## ៥. ព័ត៌មានប្រតិបត្តិការតាមផ្នែក

ក.ស.ស មានប្រតិបត្តិការតាមផ្នែកដែលត្រូវរាយការណ៍គឺ សេវាផ្នែកកំពង់ផែ។ ប្រធានអ្នកសម្រេចចិត្តផ្នែកប្រតិបត្តិការ (ក្រុមគណៈគ្រប់គ្រង) ត្រួតពិនិត្យរបាយការណ៍គ្រប់គ្រងផ្ទៃក្នុង ដែលបានរាយការណ៍អំពីលទ្ធផលនៃសេវាផ្នែកកំពង់ផែទាំងមូល ដើម្បីវាយតម្លៃអំពីលទ្ធផល និងការបែងចែកធនធាន។ ប្រធានអ្នកសម្រេចចិត្តផ្នែកប្រតិបត្តិការវាយតម្លៃអំពីលទ្ធផលនៃប្រតិបត្តិការតាមផ្នែក ដោយផ្អែកទៅលើទំហំប្រាក់ចំណូលដុល ចំណេញមុនបង់ពន្ធ និងចំណេញសុទ្ធធៀបនឹង ការិយបរិច្ឆេទមុនៗ។ លើសពីនេះ ក.ស.ស ក៏បានបង្កើតតំបន់សេដ្ឋកិច្ចពិសេសថ្មីដែលប្រតិបត្តិការនៅដំណាក់កាលដំបូង សូមមើលកំណត់សម្គាល់ ៧។

ប្រាក់ចំណូលទាំងអស់បានមកពីអតិថិជនខាងក្រៅ។ ក.ស.ស មានទីតាំងស្ថិតនៅក្នុងខេត្តព្រះសីហនុ ហើយរាល់ការលក់ទាំងអស់មានប្រភពចេញពីខេត្តព្រះសីហនុ និងតំបន់ជុំវិញ។

## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧

## ៦. ទ្រព្យសម្បត្តិ និងបរិក្ខារ

| ទ្រព្យសកម្មរយៈពេលវែង | ដីធ្លី ពាន់រៀល | ការកែលម្អដីធ្លី ពាន់រៀល | អគារ ពាន់រៀល | សម្ភារកំពង់ផែ ពាន់រៀល | បរិក្ខារបច្ចេកទេស ពាន់រៀល | បរិក្ខារផ្សេងៗ ពាន់រៀល | គ្រឿងសង្ហារិមនិងបរិក្ខារបំពាក់ ពាន់រៀល | កុំព្យូទ័រនិងបរិក្ខារការិយាល័យ ពាន់រៀល | យានយន្ត ពាន់រៀល | បរិក្ខារកំពង់ផែសមុទ្រ ពាន់រៀល | ការងារកំពុងដំណើរការ ពាន់រៀល | ប៉ាខ្សែត ពាន់រៀល | សរុប ពាន់រៀល |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| **នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦** | | | | | | | | | | | | | |
| តម្លៃចុះបញ្ជីសុទ្ធដើមគ្រា | ២៥២.០៤៥.៦៤០ | ២៤.១៥០.៤៤២ | ១៥៩.៨៧១.៤៦៤ | ៩៩៧.០០២ | ៨.០៧៤.៩០៧ | ៤៣៥.២២៤ | ៤៥៦.០៩០ | ២.៧៥៤.៤៩៦ | ៤.៩៣០.៧៦១ | ១១៩.៧២៣.៦០០ | ៩៦.១៨៧.៩៤៥ | ២១៩.៥៤០ | ៦៦៩.៨៤៧.១១១ |
| ទិញបន្ថែម | - | ១.៩៨៨.៥៣៤ | ១.៥៤៩.៥៨០ | - | ៥៨.០៦៩ | - | ២៤០.២០០ | ១.៤៤០.៧០៣ | ៤.៤៨៧.៦៥៣ | - | ៦៩.៩៩៤.៥៨១ | ២៦៤.២៤៨ | ៨០.០២៣.៥៦៨ |
| រំលស់ | - | (៩៨៦.២១៦) | (៤.៧១៦.៩៩០) | (៩៧.០៥៥) | (១.៣៥០.៦៣៧) | (៥៨.២១៥) | (២៦៩.៣៥២) | (៨៥៥.២៣៥) | (៧៦៦.២៩៥) | (៥.៨៩៦.២៦៩) | - | (១៣០.៦២៣) | (១៥.១២៦.៨៨៧) |
| តម្លៃចុះបញ្ជីសុទ្ធចុងគ្រា | ២៥២.០៤៥.៦៤០ | ២៥.១៥២.៧៦០ | ១៥៦.៧០៤.០៥៤ | ៨៩៩.៩៤៧ | ៦.៧៨២.៣៣៩ | ៣៧៧.០០៩ | ៤២៦.៩៣៨ | ៣.៣៣៩.៩៦៤ | ៨.៦៥២.១១៩ | ១១៣.៨២៧.៣៣១ | ១៦៦.១៨២.៥២៦ | ៣៥៣.១៦៥ | ៧៣៤.៧៤៣.៧៩២ |
| **នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦** | | | | | | | | | | | | | |
| ថ្លៃដើម | ២៥២.០៤៥.៦៤០ | ៤៨.៩០៧.៦៤០ | ២៣១.៤៨៤.១៧៦ | ១១៤.២៩០.៥៧៦ | ២២.៤៥០.២៤១ | ១.២០១.២៥៤ | ២.០៦១.៣៦២ | ៦.៤៩១.៥០៨ | ២៥.៥៨០.៩៩៨ | ២៣៦.៤៩០.៩២១ | ១៦៦.១៨២.៥២៦ | ១.៣៤៨.២២៥ | ១.១០៨.៥៣៥.០៦៧ |
| រំលស់បង្គរ | - | (២៣.៧៥៤.៨៨០) | (៧៤.៧៨០.១២២) | (១១៣.៣៩០.៦២៩) | (១៥.៦៦៧.៩០២) | (៨២៤.២៤៥) | (១.៦៣៤.៤២៤) | (៣.១៥១.៥៤៤) | (១៦.៩២៨.៨៧៩) | (១២២.៦៦៣.៥៩០) | - | (៩៩៥.០៦០) | (៣៧៣.៧៩១.២៧៥) |
| តម្លៃចុះបញ្ជីសុទ្ធ | ២៥២.០៤៥.៦៤០ | ២៥.១៥២.៧៦០ | ១៥៦.៧០៤.០៥៤ | ៨៩៩.៩៤៧ | ៦.៧៨២.៣៣៩ | ៣៧៧.០០៩ | ៤២៦.៩៣៨ | ៣.៣៣៩.៩៦៤ | ៨.៦៥២.១១៩ | ១១៣.៨២៧.៣៣១ | ១៦៦.១៨២.៥២៦ | ៣៥៣.១៦៥ | ៧៣៤.៧៤៣.៧៩២ |
| **នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧** | | | | | | | | | | | | | |
| តម្លៃចុះបញ្ជីសុទ្ធដើមគ្រា | ២៥២.០៤៥.៦៤០ | ២៥.១៥២.៧៦០ | ១៥៦.៧០៤.០៥៤ | ៨៩៩.៩៤៧ | ៦.៧៨២.៣៣៩ | ៣៧៧.០០៩ | ៤២៦.៩៣៨ | ៣.៣៣៩.៩៦៤ | ៨.៦៥២.១១៩ | ១១៣.៨២៧.៣៣១ | ១៦៦.១៨២.៥២៦ | ៣៥៣.១៦៥ | ៧៣៤.៧៤៣.៧៩២ |
| ទិញបន្ថែម (*) | - | ១.០៤២.៣៣៣ | ៦០៦.៣២០ | - | - | - | ២០៨.៩៦០ | ១០៥.១៦០ | ៨.២២៦.៤៦១ | - | ៨១.៧៧៨.១០០ | ២៦៩.៣៦២ | ៩២.២៣៦.៦៩៦ |
| ផ្ទេរ | - | - | - | - | ៦៧៩.៧១៣ | - | - | - | - | ៩០.៣៧៧.២៨៩ | (៩១.០៥៧.០០២) | - | - |
| រំលស់ | - | (១.០៤៤.៥៧៩) | (៤.៧៤០.៨១២) | (៩៧.០៥៥) | (១.៣៦៥.៦៨៩) | (៥៨.០៨៨) | (២៨៩.៥៨៦) | (១.១៦៦.៨៨៦) | (១.១៤៤.០៤៥) | (៧.៨៦០.៩៩៣) | - | (៣៤២.៤១៧) | (១៨.១១០.១៥០) |
| តម្លៃចុះបញ្ជីសុទ្ធចុងគ្រា | ២៥២.០៤៥.៦៤០ | ២៥.១៥០.៥១៤ | ១៥២.៥៦៩.៥៦២ | ៨០២.៨៩២ | ៦.០៩៦.៣៦៣ | ៣១៨.៩២១ | ៣៤៦.៣១២ | ២.២៧៨.២៣៨ | ១៥.៧៣៤.៥៣៥ | ១៩៦.៣៤៣.៦២៧ | ១៥៦.៩០៣.៦២៤ | ២៨០.១១០ | ៨០៨.៨៧០.៣៣៨ |
| **នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧** | | | | | | | | | | | | | |
| ថ្លៃដើម | ២៥២.០៤៥.៦៤០ | ៤៩.៩៤៩.៩៧៣ | ២៣២.០៩០.៤៩៦ | ១១៤.២៩០.៥៧៦ | ២៣.១២៩.៩៥៤ | ១.២០១.២៥៤ | ២.២៧០.៣២២ | ៦.៥៩៦.៦៦៨ | ៣៣.៨០៧.៤៥៩ | ៣២៦.៨៦៨.២១០ | ១៥៦.៩០៣.៦២៤ | ១.៦១៧.៥៨៦ | ១.២០០.៧៧១.៧៦២ |
| រំលស់បង្គរ | - | (២៤.៧៩៩.៤៥៩) | (៧៩.៥២០.៩៣៤) | (១១៣.៤៨៧.៦៨៤) | (១៧.០៣៣.៥៩១) | (៨៨២.៣៣៣) | (១.៩២៤.០១០) | (៤.៣១៨.៤៣០) | (១៨.០៧២.៩២៤) | (១៣០.៥២៤.៥៨៣) | - | (១.៣៣៧.៤៧៦) | (៣៩១.៩០១.៤២៤) |
| តម្លៃចុះបញ្ជីសុទ្ធ | ២៥២.០៤៥.៦៤០ | ២៥.១៥០.៥១៤ | ១៥២.៥៦៩.៥៦២ | ៨០២.៨៩២ | ៦.០៩៦.៣៦៣ | ៣១៨.៩២១ | ៣៤៦.៣១២ | ២.២៧៨.២៣៨ | ១៥.៧៣៤.៥៣៥ | ១៩៦.៣៤៣.៦២៧ | ១៥៦.៩០៣.៦២៤ | ២៨០.១១០ | ៨០៨.៨៧០.៣៣៨ |

ចំណាយការប្រាក់ ដែលត្រូវបានធ្វើមូលធនកម្មលើទ្រព្យសកម្មដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ក្រោមខ្ទង់សំណង់កំពុងសាងសង់ សម្រាប់ដំណាច់ឆ្នាំ២០១៧ មានចំនួន ៨៦៤ លានរៀល (២០១៦ ៖ ១.៦៤៧ លានរៀល)។

**កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ**
**សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧**

## ៦. ទ្រព្យសម្បត្តិ និងបរិក្ខារ (ត)

(*) សូមយោងទៅលើការផ្ទៀងផ្ទាត់ការទិញបន្ថែមជាសាច់ប្រាក់ និងមិនមែនសាច់ប្រាក់ខាងក្រោម (ការទិញទ្រព្យសម្បត្តិ និង បរិក្ខារ) ក្នុងឆ្នាំ។

| | ២០១៧<br>ពាន់រៀល | ២០១៦<br>ពាន់រៀល |
|---|---|---|
| ការទិញ (សាច់ប្រាក់ និងមិនមែនសាច់ប្រាក់) ក្នុងឆ្នាំ | ៩២.២៣៦.៦៩៦ | ៨០.០២៣.៥៦៨ |
| ការសងអ្នកផ្គត់ផ្គង់ (មិនមែនសាច់ប្រាក់) - កំណត់សម្គាល់ ១៩ | (១៨.៦៤៦.៩០៣) | - |
| សាច់ប្រាក់បានបង់ក្នុងឆ្នាំ | ៧៣.៥៨៩.៧៩៣ | ៨០.០២៣.៥៦៨ |

តារាងខាងក្រោមសង្ខេបពីស្ថានភាពស្របច្បាប់នៃដីធ្លី និងតម្លៃយោងរបស់វា។

| | ២០១៧<br>ពាន់រៀល | ២០១៦<br>ពាន់រៀល |
|---|---|---|
| ដីធ្លីដែលមានប័ណ្ណកម្មសិទ្ធិស្របច្បាប់ | ៧៣៥.០០០ | ៧៣៥.០០០ |
| ដីធ្លីដែលមិនមានប័ណ្ណកម្មសិទ្ធិ | ២៥០.១៩៤.៩១០ | ២៥០.១៩៤.៩១០ |
| ដីធ្លីដែលមានប័ណ្ណកម្មសិទ្ធិស្របច្បាប់ ប៉ុន្តែប្រជាពលរដ្ឋកំពុងរស់នៅ | ១.១១៥.៧៣០ | ១.១១៥.៧៣០ |
| | ២៥២.០៤៥.៦៤០ | ២៥២.០៤៥.៦៤០ |

នាកាលបរិច្ឆេទរាយការណ៍នេះ ក.ស.ស កំពុងតែស្ថិតក្នុងដំណើរការស្នើសុំទៅរាជរដ្ឋាភិបាលកម្ពុជា តាមរយៈក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីសុំប័ណ្ណកម្មសិទ្ធិស្របច្បាប់លើដីធ្លីដែលមិនទាន់មានប័ណ្ណកម្មសិទ្ធិ។

## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧

### ៧. ទ្រព្យសម្បត្តិវិនិយោគ

| ទ្រព្យសកម្មរយៈពេលវែង | ដីធ្លី<br>ពាន់រៀល | អគារ<br>ពាន់រៀល | សំណង់កំពុងសាងសង់<br>ពាន់រៀល | សរុប<br>ពាន់រៀល |
|---|---|---|---|---|
| **ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦** | | | | |
| តម្លៃចុះបញ្ជីសុទ្ធដើមគ្រា | ១០២.៤៣២.៨៥៤ | ១៦២.១៨១.៨១៧ | - | ២៦៤.៦១៤.៦៧១ |
| ទិញបន្ថែម | ៥៨១.១៦២ | - | - | ៥៨១.១៦២ |
| រំលស់ | - | (៦.០៥៩.៨៨៣) | - | (៦.០៥៩.៨៨៣) |
| តម្លៃចុះបញ្ជីសុទ្ធចុងគ្រា | ១០៣.០១៤.០១៦ | ១៥៦.១២១.៩៣៤ | - | ២៥៩.១៣៥.៩៥០ |
| **នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦** | | | | |
| ថ្លៃដើម | ១០៣.០១៤.០១៦ | ១៧៤.០៥៥.៣២០ | - | ២៧៧.០៦៩.៣៣៦ |
| រំលស់បង្គរ | - | (១៧.៩៣៣.៣៨៦) | - | (១៧.៩៣៣.៣៨៦) |
| តម្លៃចុះបញ្ជីសុទ្ធ | ១០៣.០១៤.០១៦ | ១៥៦.១២១.៩៣៤ | - | ២៥៩.១៣៥.៩៥០ |
| **ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧** | | | | |
| តម្លៃចុះបញ្ជីសុទ្ធដើមគ្រា | ១០៣.០១៤.០១៦ | ១៥៦.១២១.៩៣៤ | - | ២៥៩.១៣៥.៩៥០ |
| ទិញបន្ថែម | ២៨.៩៦៣.៤៨៩ | ៩៤១.៤៤៣ | ៧០៣.០៦០ | ៣០.៦០៧.៩៩២ |
| រំលស់ | - | (៦.០៧១.៨៧៣) | - | (៦.០៧១.៨៧៣) |
| តម្លៃចុះបញ្ជីសុទ្ធចុងគ្រា | ១៣១.៩៧៧.៥០៥ | ១៥០.៩៩១.៥០៤ | ៧០៣.០៦០ | ២៨៣.៦៧២.០៦៩ |
| **នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧** | | | | |
| ថ្លៃដើម | ១៣១.៩៧៧.៥០៥ | ១៧៤.៩៩៦.៧៦៣ | ៧០៣.០៦០ | ៣០៧.៦៧៧.៣២៨ |
| រំលស់បង្គរ | - | (២៤.០០៥.២៥៩) | - | (២៤.០០៥.២៥៩) |
| តម្លៃចុះបញ្ជីសុទ្ធ | ១៣១.៩៧៧.៥០៥ | ១៥០.៩៩១.៥០៤ | ៧០៣.០៦០ | ២៨៣.៦៧២.០៦៩ |

*ដំណើរការវាយតម្លៃ (បច្ចេកទេស/ធាតុចូល) ប្រើក្នុងការកំណត់តម្លៃសមស្រប*

ទ្រព្យសម្បត្តិវិនិយោគរបស់ ក.ស.ស ត្រូវបានវាយតម្លៃដោយក្រុមហ៊ុនវាយតម្លៃដែលមានការទទួលស្គាល់ដោយគណៈកម្មការមូលបត្រកម្ពុជា និងមានបទពិសោធន៍នាពេលថ្មីៗនេះ ក្នុងទីតាំងនៃទ្រព្យសម្បត្តិវិនិយោគដែលត្រូវបានវាយតម្លៃ។

តម្លៃសមស្របកម្រិតបីរបស់ទ្រព្យសម្បត្តិវិនិយោគ ត្រូវបានទាញយកដោយប្រើប្រាស់វិធីសាស្ត្រការប្រៀបធៀបការលក់ទៅនឹងវិធីសាស្ត្រវាយតម្លៃ។ តម្លៃទ្រព្យសម្បត្តិវិនិយោគដែលប្រើប្រាស់វិធីសាស្ត្រប្រៀបធៀបការលក់ ចាត់ចូលទៅក្នុងធាតុគណនីប្រៀបធៀប។ តម្លៃទាំងនេះ ត្រូវបានកែតម្រូវសម្រាប់ភាពខុសគ្នាក្នុងការសន្មតសំខាន់ៗ ដូចជា ទំហំ និងទីតាំងស្ថានភាព និងកត្តាពាក់ព័ន្ធផ្សេងទៀត។

**កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ**
**សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧**

## ៧. ទ្រព្យសម្បត្តិវិនិយោគ (ត)

គណៈគ្រប់គ្រងជឿជាក់ថាតម្លៃសមស្របរបស់ទ្រព្យសម្បត្តិវិនិយោគ អាចវាស់វែងបានច្បាស់លាស់សម្រាប់តែដីធ្លី ប៉ុណ្ណោះ ដូច្នេះដីធ្លីត្រូវបានដាក់បង្ហាញ ប៉ុន្តែចំពោះអគារវិញ មិនអាចវាស់វែងតម្លៃសមស្របជាក់លាក់បានទេ ដោយសារតែគ្មានប្រតិបត្តិការទីផ្សារប្រហាក់ប្រហែលគ្នា ហើយរកវិធីសាស្ត្រវាយតម្លៃផ្សេង (ការប៉ាន់ស្មានលំហូរសាច់ប្រាក់អប្បហារ) នៅតែមិនអាចវាស់វែងតម្លៃសមស្របបាន។

| | ២០១៧<br>ពាន់រៀល | ២០១៦<br>ពាន់រៀល |
|---|---|---|
| ទ្រព្យសម្បត្តិវិនិយោគតាមតម្លៃសមស្រប សម្រាប់ដីធ្លី | ១.៧០២.១៨៣.២២៤ | ១.៧០២.១៨៣.២២៤ |

តារាងខាងក្រោមនេះ សង្ខេបពីស្ថានភាពស្របច្បាប់នៃដីធ្លី និងតម្លៃយោងរបស់វា។

| | ២០១៧<br>ពាន់រៀល | ២០១៦<br>ពាន់រៀល |
|---|---|---|
| ដីធ្លីដែលមានប័ណ្ណកម្មសិទ្ធិស្របច្បាប់ - តំបន់សេដ្ឋកិច្ចពិសេស(*) | ៨៥.៧៩៣.៥៣៤ | ៨៥.៧៩៣.៥៣៤ |
| ដីធ្លីដែលមានប័ណ្ណកម្មសិទ្ធិស្របច្បាប់ - តំបន់ផ្សេងៗ | ៤១.៥២៧.៤៤១ | ១២.៥៦៣.៩៥២ |
| ដីធ្លីដែលមិនមានប័ណ្ណកម្មសិទ្ធិ | ៤.៦៥៦.៥៣០ | ៤.៦៥៦.៥៣០ |
| | ១៣១.៩៧៧.៥០៥ | ១០៣.០១៤.០១៦ |

នាកាលបរិច្ឆេទរាយការណ៍នេះ ក.ស.ស កំពុងតែដំណើរការស្នើសុំទៅរាជរដ្ឋាភិបាលកម្ពុជា តាមរយៈក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីសុំប័ណ្ណកម្មសិទ្ធិស្របច្បាប់លើដីធ្លីដែលមិនទាន់មានប័ណ្ណកម្មសិទ្ធិ។

(*) នេះគឺជាតម្លៃដីចំនួន៤១ហិកតា ដែលត្រូវបានផ្ទេរជាផ្លូវការមកឱ្យ ក.ស.ស តាមរយៈគណៈកម្មាធិការអន្តរក្រសួង ក្នុងឆ្នាំ២០០២។ ជាងនេះទៅទៀត ក.ស.ស បានដោះស្រាយតំបន់ដែលនៅជុំវិញបន្ថែមលើទំហំដី៤១ហិកតា និងបានទទួលប័ណ្ណកម្មសិទ្ធិស្របច្បាប់នៅលើដីចំនួន២៧ហិកតាបន្ថែមទៀតក្នុងឆ្នាំ២០១២ ដោយតម្លៃនៃដីធ្លីនោះនឹងត្រូវកំណត់ដោយគណៈកម្មាធិការអន្តរក្រសួង។

## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧

### ៧. ទ្រព្យសម្បត្តិវិនិយោគ (ត)

ចំនួនទឹកប្រាក់ខាងក្រោមត្រូវបានកត់ត្រាក្នុងចំណេញ-ខាត៖

| | ២០១៧ ពាន់រៀល | ២០១៦ ពាន់រៀល |
|---|---|---|
| ចំណូលពីការជួល | ២.៨៤៨.១៨០ | ២.៣០១.៥៥១ |
| ចំណាយរំលស់ | (៦.០៥៩.៨៨៣) | (៦.០៧១.៨៧៣) |
| ចំណាយប្រតិបត្តិការផ្ទាល់ដែលកើតចេញពីការវិនិយោគទ្រព្យសម្បត្តិ ដែលបង្កើតឱ្យមានចំណូលពីការជួល | (៣.៣១៦.៩៤៣) | (២.៧១៨.៥១៣) |

តំបន់សេដ្ឋកិច្ចពិសេសកំពុងតែស្ថិតក្នុងដំណាក់កាល នៃការធ្វើប្រតិបត្តិការអាជីវកម្មរបស់ខ្លួន ក្នុងដំណាក់កាលដំបូងនៅឡើយ។

### ៨. ទ្រព្យសកម្មអរូបី

| ទ្រព្យសកម្មរយៈពេលវែង | កម្មវិធី ពាន់រៀល | ការងារកំពុងដំណើរការ ពាន់រៀល | សរុប ពាន់រៀល |
|---|---|---|---|
| **ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦** | | | |
| តម្លៃចុះបញ្ជីសុទ្ធដើមគ្រា | ៩.១២៨.៣២២ | ១៥៥.៦១៩ | ៩.២៨៣.៩៤១ |
| ទិញបន្ថែម | ៧១០.៨៦៤ | ១៨.៥២៤ | ៧២៩.៣៨៨ |
| ផ្ទេរ | ១៧៤.១៤៣ | (១៧៤.១៤៣) | - |
| រំលស់ | (៩៩២.៧៣៨) | - | (៩៩២.៧៣៨) |
| តម្លៃចុះបញ្ជីសុទ្ធចុងគ្រា | ៩.០២០.៥៩១ | - | ៩.០២០.៥៩១ |
| **គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦** | | | |
| ថ្លៃដើម | ១២.៨៧២.៩២៤ | - | ១២.៨៧២.៩២៤ |
| រំលស់បង្គរ | (៣.៨៥២.៣៣២) | - | (៣.៨៥២.៣៣២) |
| តម្លៃចុះបញ្ជីសុទ្ធចុងគ្រា | ៩.០២០.៥៩២ | - | ៩.០២០.៥៩២ |

**កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ**
**សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧**

## ៨. ទ្រព្យសកម្មអរូបី (ត)

| ទ្រព្យសកម្មរយៈពេលវែង | កម្មវិធី ពាន់រៀល | ការងារកំពុងដំណើរការ ពាន់រៀល | សរុប ពាន់រៀល |
|---|---|---|---|
| **ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧** | | | |
| តម្លៃចុះបញ្ជីសុទ្ធដើមគ្រា | ៩.០២០.៥៩២ | - | ៩.០២០.៥៩២ |
| ទិញបន្ថែម | ៥៩៥.០២៣ | - | ៥៩៥.០២៣ |
| រំលស់ | (១.០៥៧.៩១៣) | - | (១.០៥៧.៩១៣) |
| តម្លៃចុះបញ្ជីសុទ្ធចុងគ្រា | ៨.៥៥៧.៧០២ | - | ៨.៥៥៧.៧០២ |
| **គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧** | | | |
| ថ្លៃដើម | ១៣.៤៦៧.៩៤៧ | - | ១៣.៤៦៧.៩៤៧ |
| រំលស់បង្គរ | (៤.៩១០.២៤៥) | - | (៤.៩១០.២៤៥) |
| តម្លៃចុះបញ្ជីសុទ្ធចុងគ្រា | ៨.៥៥៧.៧០២ | - | ៨.៥៥៧.៧០២ |

## ៩. ឥណទានផ្តល់ឱ្យបុគ្គលិក

| | ២០១៧ ពាន់រៀល |
|---|---|
| រយៈពេលខ្លី | ១.៦១៨.៤២៥ |
| រយៈពេលវែង | ៥.៣០៥.១១៣ |
| តម្លៃយោង | ៦.៩២៣.៥៣៨ |

នៅថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ ក.ស.ស បានអនុម័តផ្តល់ឥណទានគ្មានការប្រាក់ ចំនួន ១០.២៦៧ លានរៀល ដែលមានរយៈពេលបួនឆ្នាំឱ្យបុគ្គលិករបស់ខ្លួន រួមទាំងបុគ្គលិកដែលបានចូលនិវត្ត ដើម្បីទិញភាគហ៊ុនអណ្តែត ប្រភេទ "គ" នៅពេលដែល ក.ស.ស ចុះបញ្ជីលក់មូលបត្រជាសាធារណៈលើកដំបូង។

និយ័តកម្មតម្លៃសមស្របលើសមតុល្យឥណទាន ២.៦២២ លានរៀល ត្រូវបានកត់ត្រាដំបូងជាទ្រព្យសកម្មផ្សេងៗ នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ និងដករំលស់ក្នុងចំណេញ-ខាត ក្នុងខ្ទង់ប្រាក់បៀវត្សរ៍ ប្រាក់ឈ្នួល និងចំណាយពាក់ព័ន្ធក្នុងរយៈពេលបួនឆ្នាំ ដោយសារតម្លៃសមស្របរបស់ឥណទាននេះ ត្រូវបានកាត់បន្ថយដោយអត្រាអនុគ្រោះ (គ្មានការប្រាក់) ហើយអត្ថប្រយោជន៍ត្រូវបានផ្តល់ឱ្យបុគ្គលិក។

តម្លៃសមស្របនៃឥណទានផ្តល់ឱ្យបុគ្គលិក គឺអាស្រ័យទៅតាមលំហូរសាច់ប្រាក់អប្បហារ ដោយប្រើអត្រាការប្រាក់មធ្យម ១៥,២៧% ក្នុងមួយឆ្នាំ។ គណៈគ្រប់គ្រងបានវាយតម្លៃថា អត្រាការប្រាក់ ១៥,២៧% គឺជាអត្រាសមស្រប ដែលប្រហាក់ប្រហែលនឹងអត្រាដែលបុគ្គលិកអាចខ្ចីប្រាក់ពីធនាគារពាណិជ្ជនានាជាប្រាក់រៀល ក្នុងរយៈពេល៤ឆ្នាំ។

## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧

### ៩. ឥណទានផ្ដល់ឱ្យបុគ្គលិក (ត)

បម្រែបម្រួលឥណទានផ្ដល់ឱ្យបុគ្គលិក មានដូចខាងក្រោម៖

| | ២០១៧ ពាន់រៀល |
|---|---|
| ឥណទានជាសាច់ប្រាក់ | ១០.២៦៦.៩០៤ |
| ដក៖ និយ័តកម្មតម្លៃសមស្រប | (២.៦២១.៨២៤) |
| ឥណទានដែលត្រូវបានវាស់វែងដំបូងតាមតម្លៃសមស្រប | ៧.៦៤៥.០៨០ |
| | |
| បន្ថែម៖ ចំណូលការប្រាក់ពីអត្រាអប្បហារដែលកត់ត្រាត្រលប់មកវិញ | ៥៦១.៨២១ |
| ដក៖ ការសងឥណទាន | (១.២៨៣.៣៦៣) |
| នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ | ៦.៩២៣.៥៣៨ |

### ១០. សន្និធិ

| ទ្រព្យសកម្មរយៈពេលខ្លី | ២០១៧ ពាន់រៀល | ២០១៦ ពាន់រៀល |
|---|---|---|
| សម្ភារប្រើប្រាស់ | ៨.១៤២.៩១៦ | ៦.៥៤១.៨៧៣ |
| សម្ភារងាយឆេះ | ៥២៧.០៩៨ | ៣២៨.៥៩៤ |
| ប្រេងឥន្ធនៈ និងប្រេងម៉ាស៊ីន | ៥១៦.៥៤៦ | ៦៦៨.៤៣៨ |
| សំវិធានធនសម្រាប់គ្រឿងបន្លាស់ (*) | (៧៤២.៩៩៤) | (៧៤២.៩៩៤) |
| | ៨.៤៤៣.៥៦៦ | ៦.៧៩៥.៩១១ |

(*) គណៈគ្រប់គ្រងធ្វើការវាយតម្លៃលើសន្និធិដែលដំណើរការយឺតតាមពេលវេលាកំណត់ និងពិចារណាទៅលើតម្លៃសំវិធានធន ដែលនៅសល់មានភាពគ្រប់គ្រាន់ និងត្រឹមត្រូវនៅដំណាច់ឆ្នាំ។

សន្និធិដែលបានកត់ត្រាជាចំណាយក្នុងអំឡុងដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ មានទឹកប្រាក់ចំនួន ៥៣.៤៤៤ លានរៀល (២០១៦ ៖ ៤៨.៥៦២ លានរៀល)។

**កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ**
**សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧**

## ១១. គណនីអតិថិជនពាណិជ្ជកម្ម និងគណនីអតិថិជនផ្សេងៗ

| | ២០១៧<br>ពាន់រៀល | ២០១៦<br>ពាន់រៀល |
|---|---|---|
| គណនីអតិថិជនពាណិជ្ជកម្ម | ២៤.៣១៤.៨៤៦ | ១៧.៤៨៧.១១២ |
| គណនីអតិថិជនពាណិជ្ជកម្មផ្សេងៗ៖ | | |
| បុរេប្រទានឱ្យក្រសួងសាធារណការ និងដឹកជញ្ជូន (*) | ១០.៥៥០.០០០ | ៥.០០០.០០០ |
| បុរេប្រទានផ្សេងៗ | ២.៦១៤.៦២៤ | ១.៤៥៧.៨៦២ |
| ឥណទានពន្ធកាត់ទុក | ៩៦១.២៥០ | ៨៨៨.៣៧៦ |
| ចំណាយបង់មុន | ៤៨.៤០៧ | ៤៨.៤០៧ |
| ផ្សេងៗ | ១.២៧៨.២៦៨ | ២២២.៨១៣ |
| | ១៥.៤៥២.៥៤៩ | ៧.៦១៧.៤៥៨ |
| | ៣៩.៧៦៧.៣៩៥ | ២៥.១០៤.៥៧០ |

បុរេប្រទានឱ្យក្រសួងសាធារណការ និងដឹកជញ្ជូន ចំនួន ១០.៥៥០ លានរៀល (២០១៦ ៖ ៥.០០០ លានរៀល) ត្រូវបានរំពឹងថាត្រូវកត់ត្រាលើសពី១២ខែ ហើយគណនីអតិថិជនពាណិជ្ជកម្ម និងគណនីអតិថិជនផ្សេងៗចំនួន ២៩.២១៧ លានរៀលទៀត (២០១៦ ៖ ២០.១០៤ លានរៀល) ត្រូវបានរំពឹងថាត្រូវកត់ត្រាក្នុងរយៈពេល១២ខែ។

(*) ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានចេញលិខិតមួយចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៦ បានស្នើឱ្យ ក.ស.ស ធ្វើបុរេប្រទានជាសាច់ប្រាក់ជូនក្រសួងសាធារណការ និងដឹកជញ្ជូន ដើម្បីជួសជុលកែលម្អ និងពង្រីកផ្នែកខ្លះនៅផ្លូវជាតិលេខ៤ ក្នុងខេត្តព្រះសីហនុ។ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ ក.ស.ស បានធ្វើបុរេប្រទានជាសាច់ប្រាក់ចំនួន ១២.៨៥០លានរៀល។ ក្នុងលិខិតចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១៧ បុរេប្រទានជាសាច់ប្រាក់នឹងត្រូវទូទាត់ ដោយកាត់កងជាមួយនឹងការបែងចែកភាគលាភនាពេលអនាគត។ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ ការបែងចែកភាគលាភដែលមានទឹកប្រាក់ចំនួន ២.៣០០ លានរៀល ត្រូវបានទូទាត់ជាមួយនឹងបុរេប្រទានដែលបានផ្ដល់ជូនក្រសួងសាធារណការ និងដឹកជញ្ជូន។

អតិថិជនរបស់ ក.ស.ស គឺជាភ្នាក់ងារដឹកជញ្ជូនជាតិ និងអន្តរជាតិនានា។ សំវិធានធនសម្រាប់ការថយចុះតម្លៃ ត្រូវបានកត់ត្រាពេញលេញចំពោះចំនួនទឹកប្រាក់ដែលហួសកាលកំណត់សងលើសពីមួយឆ្នាំ។

ហានិភ័យឥណទានអតិបរមាគិតត្រឹមកាលបរិច្ឆេទរាយការណ៍ គឺជាតម្លៃយោងនៃគណនីអតិថិជននីមួយៗដូចបានរៀបរាប់ខាងលើ ដកនឹងសំវិធានធនបុរេប្រទានដែលមិនអាចប្រមូលបាន។

(ក) រាល់គណនីអតិថិជនទាំងអស់ មិនហួសកាលកំណត់សង និងមិនថយចុះតម្លៃ

(ខ) គណនីអតិថិជនផ្សេងៗ មិនហួសកាលកំណត់សង និងមិនថយចុះតម្លៃ លើកលែងតែបុរេប្រទានជាក់លាក់។ អាយុកាលរបស់វាមានរយៈពេលលើសពីមួយឆ្នាំ និងសំវិធានធនសម្រាប់បុរេប្រទានដែលមិនអាចប្រមូលមកវិញបានត្រូវបានផ្ដល់គ្រប់ចំនួន។

## ១២. ប្រាក់បញ្ញើរយៈពេលខ្លីនៅធនាគារ

ប្រាក់បញ្ញើរយៈពេលខ្លីនៅធនាគារ គឺជាប្រាក់បញ្ញើមានកាលកំណត់ ដែលបានផ្ញើនៅគ្រឹះស្ថានហិរញ្ញវត្ថុនានាក្នុងរយៈពេលពី៤ខែ និង១២ខែ ហើយទទួលបានការប្រាក់ចន្លោះពី ៣,៥០% ទៅ ៦,00% ក្នុងមួយឆ្នាំ (២០១៦ ៖ ចន្លោះពី ៣,៥០% ទៅ ៦,00% ក្នុងមួយឆ្នាំ) ។

## ១៣. សាច់ប្រាក់ និងសាច់ប្រាក់សមមូល

| | ២០១៧<br>ពាន់រៀល | ២០១៦<br>ពាន់រៀល |
|---|---|---|
| ទ្រព្យសកម្មរយៈពេលខ្លី | | |
| សាច់ប្រាក់ក្នុងដៃ | ១.២៧៥.២៥២ | ១.៩៨៦.២៨៦ |
| សាច់ប្រាក់នៅធនាគារ | ៤៩.៨០៥.៩៧៧ | ៣២.៦៦៥.៣១៨ |
| | ៥១.០៨១.២២៩ | ៣៤.៦៥១.៦០៤ |

សាច់ប្រាក់នៅធនាគារត្រូវបានដាក់ផ្ញើនៅធនាគារពាណិជ្ជក្នុងស្រុក។ គណនីចរន្តមិនមានការប្រាក់ទេ។

**កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ**
**សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧**

## ១៤. ដើមទុន និងបុព្វលាភភាគហ៊ុន

| | ភាគហ៊ុនប្រភេទ "ក" | | ភាគហ៊ុនប្រភេទ "ខ" | | ភាគហ៊ុនប្រភេទ "គ" | | បុព្វលាភ ភាគហ៊ុន | ដើមទុន | សរុប |
|---|---|---|---|---|---|---|---|---|---|
| | ចំនួនភាគហ៊ុន | ពាន់រៀល | ចំនួនភាគហ៊ុន | ពាន់រៀល | ចំនួនភាគហ៊ុន | ពាន់រៀល | ពាន់រៀល | ពាន់រៀល | ពាន់រៀល |
| **ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦** | | | | | | | | | |
| នៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១៦ | - | - | - | - | - | - | - | ៤២៨.៨៥៩.៨៣៦ | ៤២៨.៨៥៩.៨៣៦ |
| នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ | - | - | - | - | - | - | - | ៤២៨.៨៥៩.៨៣៦ | ៤២៨.៨៥៩.៨៣៦ |
| **ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧** | | | | | | | | | |
| នៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១៧ | - | - | - | - | - | - | - | ៤២៨.៨៥៩.៨៣៦ | ៤២៨.៨៥៩.៨៣៦ |
| ការផ្ទេរដើមទុនទៅជាភាគហ៊ុន (ក) | ៣៦៤.៥៣០.៨៦១ | ៣៦៤.៥៣០.៨៦១ | ៦៤.៣២៨.៩៧៥ | ៦៤.៣២៨.៩៧៥ | - | - | - | (៤២៨.៨៥៩.៨៣៦) | - |
| សាច់ប្រាក់បានពីការចេញភាគហ៊ុនថ្មី (ខ) | - | - | - | - | ២១.៤៤២.៩៩២ | ២១.៤៤២.៩៩២ | ៦៧.៧១៥.២៣៥ | - | ៨៩.១៥៨.២២៧ |
| នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ | ៣៦៤.៥៣០.៨៦១ | ៣៦៤.៥៣០.៨៦១ | ៦៤.៣២៨.៩៧៥ | ៦៤.៣២៨.៩៧៥ | ២១.៤៤២.៩៩២ | ២១.៤៤២.៩៩២ | ៦៧.៧១៥.២៣៥ | - | ៥១៨.០១៨.០៦៣ |

(ក) យោងតាមមាត្រា ៥ នៃលក្ខន្តិកៈ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៧ ដើមទុនដែលមានស្រាប់ចំនួន ៤២៨.៨៥៩.៨៣៦.០០០ រៀល ត្រូវបានបែងចែកទៅជាភាគហ៊ុនប្រភេទ "ក" ចំនួន ៣៦៤.៥៣១.៨៦១ ហ៊ុន ដើមទុនប្រភេទ ខ ចំនួន ៦៤.៣២៨.៩៧៥ ហ៊ុន ដោយមានតម្លៃចារិក ១.០០០ រៀល ក្នុងមួយភាគហ៊ុន។ ទាំងភាគហ៊ុនប្រភេទ "ក" និងភាគហ៊ុនប្រភេទ "ខ" ត្រូវបានកាន់កាប់ដោយរាជរដ្ឋាភិបាលកម្ពុជា ដែលតំណាងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ភាគហ៊ុនប្រភេទ "ក" មិនសម្រាប់បែងចែកភាគលាភទេ ហើយក៏មិនមានសិទ្ធិបោះឆ្នោតដែរ លើកលែងតែលក្ខខណ្ឌមួយចំនួនដូចបានលម្អិតក្នុងមាត្រា ៩ នៃលក្ខន្តិកៈចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៧។ ភាគហ៊ុនប្រភេទ "ខ" មានសិទ្ធិបោះឆ្នោត និងសម្រាប់បែងចែកភាគលាភ ដែលត្រូវបានអនុម័តដោយក្រុមប្រឹក្សាភិបាល។

## ១៤. ដើមទុន និងបុព្វលាភភាគហ៊ុន (ត)

(ខ) សេចក្តីលម្អិតនៃភាគហ៊ុនប្រភេទ "គ" មានដូចខាងក្រោម៖

| **ភាគហ៊ុនិក** | **ចំនួនភាគហ៊ុន** |
|---|---|
| ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិរបស់ប្រទេសជប៉ុន (JICA) | ១១.៥៧៩.២១៦ |
| គម្រោងភាគហ៊ុនរបស់បុគ្គលិក | ២.១៤៤.២៩៩ |
| អ្នកវិនិយោគផ្សេងៗ | ៧.៧១៩.៤៧៧ |
| | ២១.៤៤២.៩៩២ |

នៅថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៧ ក.ស.ស បានចុះបញ្ជីក្នុងផ្សារមូលបត្រកម្ពុជា (ហៅកាត់ថា "ផ.ម.ក") ដោយជោគជ័យ។ ចំនួនភាគហ៊ុនថ្មីដែលបានបោះផ្សាយក្នុងប្រភេទ "គ" មានចំនួន ២១.៤៤២.៩៩២ ភាគហ៊ុន ដែលមានតម្លៃចារិក ១.០០០ រៀលក្នុងមួយភាគហ៊ុន ដោយបានដាក់លក់ក្នុងតម្លៃ ៥.០៤០ រៀល ក្នុងមួយភាគហ៊ុន។ ភាគហ៊ុនប្រភេទ "គ" ដែលបានបោះផ្សាយទាំងអស់ ត្រូវបានបង់ប្រាក់រួចរាល់ទាំងស្រុង។

| | **២០១៧**<br>**ពាន់រៀល** |
|---|---|
| **នៅថ្ងៃទី០១ ខែមករា** | - |
| សាច់ប្រាក់បានមកពីការបោះផ្សាយភាគហ៊ុនប្រភេទ "គ" | ១០៨.០៧២.៦៨០ |
| ចំណាយប្រតិបត្តិការ | (៤.៧៣៣.៦១១) |
| សាច់ប្រាក់ – សុទ្ធ | ១០៣.៣៣៩.០៦៩ |
| | |
| ផ្ទេរចំណាត់ថ្នាក់ឡើងវិញទៅជាភាគលាភអប្បបរមាធានាត្រូវបង់ | (១៤.១៨០.៨៤២) |
| ផ្ទេរចំណាត់ថ្នាក់ឡើងវិញទៅជាបុព្វលាភភាគហ៊ុន | (៦៧.៧១៥.២៣៥) |
| **នៅថ្ងៃទី៣១ ខែធ្នូ** | ២១.៤៤២.៩៩២ |

**កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ**
**សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧**

## ១៤. ដើមទុន និងបុព្វលាភភាគហ៊ុន (ត)

ដើម្បីជាការលើកទឹកចិត្តសម្រាប់អ្នកវិនិយោគ ភាគហ៊ុនិកភាគហ៊ុនប្រភេទ "គ" (មានសិទ្ធិបោះឆ្នោតទាំងអស់) មានសិទ្ធិទទួលបានភាគលាភអប្បបរមាធានាត្រូវបង់ចំនួន ៥% ក្នុងមួយឆ្នាំ សម្រាប់រយៈពេលបីឆ្នាំ (ជាសាច់ប្រាក់ ឬ ជាភាគហ៊ុន ទៅតាមការសម្រេចចិត្តរបស់ ក.ស.ស តែប៉ុណ្ណោះ) នៃភាគហ៊ុនប្រភេទ "គ" សរុប គុណនឹងតម្លៃដាក់លក់ពីកាលបរិច្ឆេទចុះបញ្ជីលក់មូលបត្រលើកដំបូង ក្នុងខែមិថុនា ឆ្នាំ២០១៧។ ប្រសិនបើការទូទាត់ការបង់ភាគលាភជាភាគហ៊ុន គឺវាអាស្រ័យទៅលើតម្លៃទីផ្សារភាគហ៊ុនពេលបិទទ្វារ មុនពេល ex-dividend day។ មិនមានការធានាចំពោះចំនួនភាគហ៊ុនថេរទេ (មានតែចំនួនភាគហ៊ុនអថេរ)។ ក្នុងករណីដែលមិនមានមូលនិធិគ្រប់គ្រាន់ អភិបាលទាំងអស់ត្រូវប្រកាស និងបង់ភាគលាភទៅអ្នកវិនិយោគរបស់ខ្លួនក្នុងរយៈពេល ១២ខែពីកាលបរិច្ឆេទចុះបញ្ជីលក់មូលបត្រលើកដំបូង។ ក្នុងករណីដែលភាគលាភអប្បបរមាធានាត្រូវបង់ មិនត្រូវបានបង់/បែងចែកពេញលេញក្នុងឆ្នាំណាមួយទេនោះ ចំនួនទឹកប្រាក់ដែលនៅសល់ត្រូវកត់ត្រាបង្គរទៅឆ្នាំក្រោយៗទៀត រហូតដល់ពេលដែលភាគលាភអប្បបរមាធានាត្រូវបង់ អាចទូទាត់បានពេញលេញ។

តម្លៃបច្ចុប្បន្ននៃភាគលាភអប្បបរមាធានាត្រូវបង់ ដែលមានទឹកប្រាក់ចំនួន ១៤.១៨០ លានរៀល (ការកត់ត្រាដំបូង) ត្រូវបានរំពឹងថាត្រូវទូទាត់សម្រាប់រយៈពេលបីឆ្នាំ ចាប់ពីកាលបរិច្ឆេទចុះបញ្ជី។ រាជរដ្ឋាភិបាលកម្ពុជា ដែលជាភាគហ៊ុនិកដើមទុនមានសិទ្ធិបោះឆ្នោតប្រភេទ "ខ" និង ដើមទុនមិនមានសិទ្ធិបោះឆ្នោតប្រភេទ "ក" មិនមានសិទ្ធិទទួលភាគលាភអប្បបរមាធានាត្រូវបង់នេះទេ។

បម្រែបម្រួលភាគលាភអប្បបរមាធានាត្រូវបង់ មានដូចខាងក្រោម៖

| | **២០១៧** |
|---|---:|
| | **ពាន់រៀល** |
| នៅថ្ងៃទី០១ ខែមករា | - |
| បានកត់ត្រាដំបូងតាមតម្លៃបច្ចុប្បន្ន | ១៤.១៨០.៨៤៣ |
| ចំណាយការប្រាក់បូកបន្ថែម (កំណត់សម្គាល់ ២៦) | ៥៧៩.០៥១ |
| នៅថ្ងៃទី៣១ ខែធ្នូ | ១៤.៧៥៩.៨៩៤ |

## ១៥. ទុនបម្រុងផ្សេងៗ

មាត្រា ៣៤ នៃលក្ខន្តិកៈចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៧ បានចែងថា ប្រាក់ចំណេញរបស់ ក.ស.ស បន្ទាប់ពីកាត់កងការខាតយោង (ប្រសិនបើមាន) ត្រូវបានបែងចែកទៅក្នុងទុនបម្រុងទូទៅ និងទុនបម្រុងស្របច្បាប់។

## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧

### ១៦. ប្រាក់កម្ចី

| | ២០១៧<br>ពាន់រៀល | ២០១៦<br>ពាន់រៀល |
|---|---|---|
| ប្រាក់កម្ចីពីៈ | | |
| ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ – (JICA) – ឥណទានលេខ CP-P3 | ៨៥.០៩៤.៤៩១ | ៨៩.០៥៥.៥៥៦ |
| ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ – (JBIC) – ឥណទានលេខ CP-P4 | ១២៧.០៥៥.០២៨ | ១៣៤.៥២០.២៩៩ |
| ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ – (JBIC) – ឥណទានលេខ CP-P6 | ៨.៥១៧.៣១១ | ៨.៧០៩.១២១ |
| ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ – (JBIC) – ឥណទានលេខ CP-P8 | ១២៦.៧៥៤.៧៥៧ | ១២២.៩៦៣.៨៦០ |
| ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ – (JBIC) – ឥណទានលេខ CP-P10 | ១៧៧.៨១៣.២៩៥ | ១២៤.៥៣០.២៧១ |
| | ៥២៥.២៣៤.៨៨២ | ៤៧៩.៧៧៩.១០៧ |

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងប្រាក់កម្ចីជាមួយ JICA និង JBIC ទាក់ទិនទៅនឹងប្រតិបត្តិការដែលពាក់ព័ន្ធនឹង ក.ស.ស។ ក.ស.ស ក៏បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងប្រាក់កម្ចី ជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ផងដែរ ដោយប្រាក់កម្ចីត្រូវបាន JICA និង JBIC ចំណាយដោយផ្ទាល់ឱ្យអ្នកផ្គត់ផ្គង់របស់ ក.ស.ស។ ក.ស.ស បានសងប្រាក់ដោយផ្ទាល់ទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាស្រ័យទៅតាមកាលវិភាគសងប្រាក់។

កាលកំណត់របស់ប្រាក់កម្ចីទាំងនេះមានដូចខាងក្រោមៈ

| | ២០១៧<br>ពាន់រៀល | ២០១៦<br>ពាន់រៀល |
|---|---|---|
| **ប្រាក់កម្ចីរយៈពេលខ្លី** | | |
| មិនលើសមួយឆ្នាំ | ២១.៦៩៧.៥៧៦ | ១៦.៥៤៣.៧៣៥ |
| **ប្រាក់កម្ចីរយៈពេលវែង** | | |
| លើសមួយឆ្នាំ ប៉ុន្តែមិនលើសពីរឆ្នាំ | ១៨.៦៧៧.៨៦១ | ២០.២៩៤.៨៧៨ |
| លើសពីរឆ្នាំ ប៉ុន្តែមិនលើសប្រាំឆ្នាំ | ៧៧.៦១៥.៣១៧ | ៧៦.០៧០.៣២៨ |
| លើសពីប្រាំឆ្នាំឡើងទៅ | ៤០៧.២៤៤.១២៨ | ៣៦៦.៨៧០.១៦៦ |
| | ៥០៣.៥៣៧.៣០៦ | ៤៦៣.២៣៥.៣៧២ |
| | ៥២៥.២៣៤.៨៨២ | ៤៧៩.៧៧៩.១០៧ |

## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧

### ១៦. ប្រាក់កម្ចី (ត)

តម្លៃយោង និងតម្លៃសមស្របរបស់ប្រាក់កម្ចីរយៈពេលខ្លី និងរយៈពេលវែងមានដូចខាងក្រោម៖

| | ២០១៧<br>ពាន់រៀល | ២០១៦<br>ពាន់រៀល |
|---|---|---|
| តម្លៃយោង | | |
| រយៈពេលខ្លី | ២១.៦៩៣.៥៧៦ | ១៦.៥៤៣.៧៣៥ |
| រយៈពេលវែង | ៥០៣.៥៣៧.៣០៦ | ៤៦៣.២៣៥.៣៧២ |
| តម្លៃសមស្រប | | |
| រយៈពេលខ្លី | ១៨.៣៨៣.៣៣៩ | ១៤.១០១.៥០១ |
| រយៈពេលវែង | ៣៦២.១៩១.៧៦៤ | ៣៦១.១៤១.៣៥៨ |

តម្លៃសមស្របត្រូវបានគណនាអាស្រ័យទៅតាមលំហូរសាច់ប្រាក់អប្បហារ ដោយប្រើអត្រាប្រាក់កម្ចីនាពេលបច្ចុប្បន្ន។ វាត្រូវបានចាត់ថ្នាក់ជាតម្លៃសមស្របកម្រិតទី៣ ក្នុងឋានានុក្រមតម្លៃសមស្រប ដោយសារមានការរួមបញ្ចូលនូវធាតុចូលដែលមិនអាចអង្កេតបាន រួមមាន ហានិភ័យឥណទានរបស់ភាគីដៃគូជាដើម។

ប្រាក់កម្ចីជារូបិយប័ណ្ណផ្សេងៗក្រៅពីរូបិយប័ណ្ណគោល មានដូចខាងក្រោម៖

| | ២០១៧<br>ពាន់រៀល | ២០១៦<br>ពាន់រៀល |
|---|---|---|
| ប្រាក់យ៉េន | ៣៩៨.១៧៩.៨៥៤ | ៣៤៥.២៥៨.៨០៧ |
| ប្រាក់ដុល្លារអាមេរិក | ១២៧.០៥៥.០២៨ | ១៣៤.៥២០.៣០០ |
| | ៥២៥.២៣៤.៨៨២ | ៤៧៩.៧៧៩.១០៧ |

ប្រាក់កម្ចីទាំងអស់មានរយៈពេល៣០ឆ្នាំ ហើយអត្រាការប្រាក់ប្រចាំឆ្នាំនៃប្រាក់កម្ចីនីមួយៗ មានដូចខាងក្រោម៖

| | ២០១៧ | ២០១៦ |
|---|---|---|
| ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ – (JICA) – ឥណទានលេខ CP-P3 | ៣,០០% | ៣,០០% |
| ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ – (JBIC) – ឥណទានលេខ CP-P4 | ៣,៧០% | ៣,៧០% |
| ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ – (JBIC) – ឥណទានលេខ CP-P6 | ៣,០០% | ៣,០០% |
| ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ – (JBIC) – ឥណទានលេខ CP-P8 | ៣,០០% | ៣,០០% |
| ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ – (JBIC) – ឥណទានលេខ CP-P10 | ២,៥០% | ២,៥០% |

## ១៧. ភាតព្វកិច្ចអត្ថប្រយោជន៍សោធននិវត្តន៍

ចំនួនទឹកប្រាក់ដែលបានកត់ត្រានៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ មានដូចខាងក្រោម៖

| | **២០១៧** | **២០១៦** |
|---|---|---|
| បំណុលរយៈពេលវែង | **ពាន់រៀល** | **ពាន់រៀល** |
| តម្លៃបច្ចុប្បន្ននៃកាតព្វកិច្ចអត្ថប្រយោជន៍ដែលបានកំណត់ | ៤១.០០៨.២៥៥ | ៤០.៣០១.៤១១ |
| ស្ថានភាពមិនមានមូលនិធិ | ៤១.០០៨.២៥៥ | ៤០.៣០១.៤១១ |
| បំណុលសុទ្ធដែលបានកត់ត្រា | ៤១.០០៨.២៥៥ | ៤០.៣០១.៤១១ |

បម្រែបម្រួលនៃកាតព្វកិច្ចអត្ថប្រយោជន៍ដែលបានកំណត់ក្នុងឆ្នាំនេះ មានដូចខាងក្រោម៖

| | **២០១៧** | **២០១៦** |
|---|---|---|
| | **ពាន់រៀល** | **ពាន់រៀល** |
| គិតត្រឹមថ្ងៃទី០១ ខែមករា | ៤០.៣០១.៤១១ | ៣៩.៤៩៦.៧៨៨ |
| ចំណាយលើសេវាកម្មបច្ចុប្បន្ន | ១.១៤៨.០០០ | ១.១៩៥.០០០ |
| ចំណាយការប្រាក់ | ៣.០០៦.០០០ | ២.៨៧០.០០០ |
| អត្ថប្រយោជន៍បានបង់ | (៣.៤៤៧.១៥៦) | (៣.២៦០.៣៧៧) |
| គិតត្រឹមថ្ងៃទី៣១ ខែធ្នូ | ៤១.០០៨.២៥៥ | ៤០.៣០១.៤១១ |

ទឹកប្រាក់ដែលបានកត់ត្រានៅក្នុងចំណេញ-ខាត មានដូចខាងក្រោម៖

| | **២០១៧** | **២០១៦** |
|---|---|---|
| | **ពាន់រៀល** | **ពាន់រៀល** |
| ចំណាយលើសេវាកម្មបច្ចុប្បន្ន | ១.១៤៨.០០០ | ១.១៩៥.០០០ |
| ចំណាយការប្រាក់ | ៣.០០៦.០០០ | ២.៨៧០.០០០ |
| ចំនួនទឹកប្រាក់សរុបដែលបានកត់ត្រាក្នុងគណនីប្រាក់បៀវត្សរ៍ ប្រាក់ឈ្នួល និង ចំណាយពាក់ព័ន្ធ (កំណត់សម្គាល់ ២២) | ៤.១៥៤.០០០ | ៤.០៦៥.០០០ |

ការសន្មតការគណនាហានិភ័យសំខាន់ៗ មានដូចខាងក្រោម៖

| | **២០១៧** | **២០១៦** |
|---|---|---|
| មធ្យមភាគនៃការរំពឹងទុកនៃចំនួនឆ្នាំបម្រើការងារ | ២០ | ២០ |
| អត្រាអប្បហារ | ៧% | ៧% |
| អត្រាកំណើនប្រាក់បៀវត្សរ៍ | ៥% | ៥% |

**កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ**
**សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧**

## ១៧. ភាតព្វកិច្ចអត្ថប្រយោជន៍សោធននិវត្តន៍ (ត)

**អត្រាមរណៈ**

ដោយសារមិនមានអត្រាមរណៈត្រូវបានចេញផ្សាយនៅក្នុងប្រទេសកម្ពុជា ក.ស.ស បានប្រើប្រាស់តារាងអត្រាអាយុកាលរំពឹងទុកនៃមរណៈរបស់ប្រទេសថៃឆ្នាំ២០០៨ ហើយបានកែសម្រួលដើម្បីឱ្យសមស្របទៅនឹងអាយុកាលរំពឹងទុករបស់ប្រជាជនកម្ពុជា។ តារាងអត្រាមរណៈរបស់ប្រទេសថៃឆ្នាំ២០០៨ គឺជាតារាងអត្រាមរណៈដែលបានចេញផ្សាយចុងក្រោយគេបំផុតនៅក្នុងប្រទេសថៃ និងនៅអត្រាដដែលគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧។

## ១៨. ចំណូលពន្យារ

ក.ស.ស បានជួលផ្នែកខ្លះនៃដីរបស់ខ្លួនក្នុងតំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ ក្រោមកិច្ចសន្យាភតិសន្យាប្រតិបត្តិរយៈពេល៥០ឆ្នាំ។ ចំណាយបង់មុនត្រូវបានកត់ត្រាក្នុងខ្ទង់ឥណទានក្នុងរបាយការណ៍ចំណេញ-ខាត តាមមូលដ្ឋានថេរលើរយៈពេលនៃភតិសន្យា។

| | ២០១៧<br>ពាន់រៀល | ២០១៦<br>ពាន់រៀល |
|---|---:|---:|
| នៅថ្ងៃទី០១ ខែមករា | ៦.០៦១.៥៥៦ | ៦.២១៤.៧២៥ |
| បន្ថែម | ២៣២.១០៩ | - |
| កត់ត្រាក្នុងខ្ទង់ឥណទានក្នុងចំណេញ-ខាត | (៣៦៧.៥៨៥) | (១៣៣.៨៣៧) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | ២.២៥៥ | (១៩.៣៣២) |
| នៅថ្ងៃទី៣១ ខែធ្នូ | ៥.៩២៨.៣៣៥ | ៦.០៦១.៥៥៦ |
| | | |
| រយៈពេលខ្លី | ១៣៣.២២១ | ១៣៣.២២១ |
| រយៈពេលវែង | ៥.៧៩៥.១១៤ | ៥.៩២៨.៣៣៥ |
| នៅថ្ងៃទី៣១ ខែធ្នូ | ៥.៩២៨.៣៣៥ | ៦.០៦១.៥៥៦ |

## ១៩. គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម និងគណនីអ្នកផ្គត់ផ្គង់ផ្សេងៗ

| | ២០១៧ ពាន់រៀល | ២០១៦ ពាន់រៀល |
|---|---|---|
| គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម (*) | ២២.១៤១.៧២៥ | ៥.៨៦២.៧៣៩ |
| ប្រាក់រង្វាន់បង្គរ | ៨.៥៩០.៧២១ | ៧.០៦៤.០៦៧ |
| អាករលើតម្លៃបន្ថែមត្រូវបង់ | ១.០៦៥.១៦៣ | ១.០៨៧.២៥៧ |
| ប្រាក់កក់របស់អតិថិជន | ១.២៣១.៣២៧ | ៩៣៩.២៤៣ |
| ពន្ធលើប្រាក់បៀវត្សរ៍ត្រូវបង់ | ៣០០.៤២២ | ២៨៥.៥២១ |
| បំណុលផ្សេងៗ | ២.៥៥៩.១៤២ | ៤៧៥.០៦០ |
| | ១៣.៧៤៦.៧៧៥ | ៩.៨៥១.១៤៨ |
| | ៣៥.៨៨៨.៥០០ | ១៥.៧១៣.៨៨៧ |

ប្រាក់កក់របស់អតិថិជនចំនួន ១.២៣១ លានរៀល (២០១៦ ៖ ៩៣៩ លានរៀល) ត្រូវបានរំពឹងថាត្រូវទូទាត់ក្នុងរយៈពេលលើសពី១២ខែ ហើយគណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម និងគណនីអ្នកផ្គត់ផ្គង់ផ្សេងៗចំនួន ៣៤.៦៥៧ លានរៀលទៀត (២០១៦ ៖ ១៤.៧៧៥ លានរៀល) ត្រូវបានរំពឹងថាត្រូវទូទាត់ក្នុងរយៈពេល១២ខែ។

(*) រួមបញ្ចូលនៅក្នុងគណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្មនេះ មានទឹកប្រាក់ត្រូវសងដែលមិនទាន់ទូទាត់ចំនួន ១៨.៦៤៦.៩០៣ ពាន់រៀល សម្រាប់ការទិញបរិក្ខារកំពង់ផែសមុទ្រ។

## ២០. ចំណូល

| | ២០១៧ ពាន់រៀល | ២០១៦ ពាន់រៀល |
|---|---|---|
| ចំណូលបានពីកំពង់ផែ | ២១៨.១៤៨.៩៩១ | ២០៣.០៨៧.៦៧៨ |
| ចំណូលបានមកពីការជួលតំបន់សេដ្ឋកិច្ចពិសេស | ២.៨៤៨.១៨០ | ២.៣០១.៥៥១ |
| ចំណូលផ្សេងៗ | ៦.៤០០.៦៦៤ | ៣.៥៩២.០២០ |
| | ២២៧.៣៩៧.៨៣៥ | ២០៨.៩៨១.២៤៩ |

**កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ**
**សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧**

## ២១. សម្ភារប្រើប្រាស់

| | ២០១៧ ពាន់រៀល | ២០១៦ ពាន់រៀល |
|---|---|---|
| ចំណាយលើសម្ភារងាយឆេះ | ៣០.៤៣២.០២៤ | ២២.១២៥.១៥៦ |
| គ្រឿងបន្លាស់ | ១២.៧១០.៨២០ | ១៦.៥២០.២៦០ |
| សម្ភារឃ្លាំង | ៥.៦៥២.១០៦ | ៤.០៥៨.០១៨ |
| ប្រេងឥន្ធនៈ និងប្រេងម៉ាស៊ីន | ២.៨០០.០៣៩ | ២.៧០៥.១៨៦ |
| សម្ភារផ្គត់ផ្គង់ការិយាល័យ | ១.៨១៩.៧៦១ | ២.២២៦.៧២១ |
| សម្ភារប្រើប្រាស់ផ្សេងៗ | ៩៧៤.៩០៥ | ៩៦៦.៧៤០ |
| | ៥៤.៣៨៩.៦៥៥ | ៤៨.៦០២.០៨១ |

## ២២. ចំណាយលើប្រាក់បៀវត្សរ៍ ប្រាក់ឈ្នួល និងចំណាយពាក់ព័ន្ធ

| | ២០១៧ ពាន់រៀល | ២០១៦ ពាន់រៀល |
|---|---|---|
| ប្រាក់បៀវត្សរ៍បុគ្គលិក | ៤៤.៦៩២.៥៧១ | ៤០.៥១៤.០៥៥ |
| ប្រាក់រង្វាន់ | ៨.៦៣៧.២៨១ | ៧.០៧៤.៦៩៧ |
| ចំណាយអត្ថប្រយោជន៍សោធននិវត្តន៍ (កំណត់សម្គាល់ ១៧) | ៤.១៥៤.០០០ | ៤.០៦៥.០០០ |
| លាភការរបស់ក្រុមប្រឹក្សាភិបាល | ១.៥២៣.៣៥៥ | ១.០១៤.៩២០ |
| ចំណាយសន្តិសុខសង្គមផ្សេងៗ | ២៧៣.២៧៧ | ៣២៩.០០៦ |
| ប្រាក់ឈ្នួលសម្រាប់អ្នកម៉ៅការ | ១៣៩.៨៩៤ | ១.៣៤៤.៣១២ |
| ចំណាយផ្សេងៗពាក់ព័ន្ធនឹងបុគ្គលិក | ២.២១៤.៥០៨ | ១.០៣៥.៤៥៤ |
| | ៦១.៦៣៤.៨៨៦ | ៥៥.៣៧៧.៤៤៤ |

## ២៣. ចំណាយរំលស់ទ្រព្យសម្បត្តិ និងបរិក្ខារ និងរំលស់ទ្រព្យសកម្មអរូបី

| | ២០១៧ ពាន់រៀល | ២០១៦ ពាន់រៀល |
|---|---|---|
| ទ្រព្យសម្បត្តិ និងបរិក្ខារ (កំណត់សម្គាល់ ៦) | ១៨.១១០.១៥០ | ១៥.១២៦.៨៨៧ |
| ទ្រព្យសម្បត្តិវិនិយោគ (កំណត់សម្គាល់ ៧) | ៦.០៧១.៨៧៣ | ៦.០៥៩.៨៨៣ |
| ទ្រព្យសកម្មអរូបី (កំណត់សម្គាល់ ៨) | ១.០៥៧.៩១៣ | ៩៩២.៧៣៨ |
| | ២៥.២៣៩.៩៣៦ | ២២.១៧៩.៥០៨ |

## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧

### ២៤. ចំណាយផ្សេងៗ

| | ២០១៧<br>ពាន់រៀល | ២០១៦<br>ពាន់រៀល |
|---|---|---|
| វិភាគទាន និងការធ្វើអំណោយ (*) | ៧.៦៥៤.១១២ | ៥.៥២៩.០៨៨ |
| ចំណាយប្រតិបត្តិការតំបន់សេដ្ឋកិច្ចពិសេស | ៣.៣១៦.៩៤៣ | ២.៧១៨.៥១៣ |
| ការទទួលភ្ញៀវ និងបដិសណ្ឋារកិច្ច | ២.៩៣៧.២១៩ | ៣.៤៨៥.៤៨៥ |
| ចំណាយរដ្ឋបាល | ២.៧០២.៩៣៤ | ២.៥៨៥.៨៥៣ |
| ការបណ្តុះបណ្តាល និងសិក្ខាសាលា | ១.២១៩.៦៧៦ | ១.២០១.៣៣៩ |
| បេសកកម្ម | ១.០៩៤.៦៧៦ | ៩៨៦.៣៨៤ |
| ការបោះពុម្ព | ៩៤៤.០៥១ | ៦៧៨.០២០ |
| សេវាប្រៃសណីយ៍ | ៧០០.៩៤៣ | ៦៥៩.០៧៥ |
| កម្រៃសេវាវិជ្ជាជីវៈ និងចំណាយពាក់ព័ន្ធ | ៥១២.៣៩៧ | ៧០៤.០៣៥ |
| ទឹកភ្លើង | ១៨៥.០៩៩ | ១៨៩.៨៦០ |
| ការជួលឧបករណ៍ | ១៧៦.០៩៦ | ១៤៤.២៧២ |
| សម្ភារថែទាំសុខភាព | ១៦៩.២៧៨ | ១៦៩.៣៩៧ |
| ពន្ធ | ១៩២.២១០ | ១.៥៣១.៤៦០ |
| ចំណាយផ្សេងៗ | ៩១.៥១៣ | ៣៩.០១៨ |
| | ២១.៨៩៧.១៤៧ | ២០.៦២១.៧៩៩ |

(*) រួមបញ្ចូលនៅក្នុងខ្ទង់ចំណាយវិភាគទាន និងការធ្វើអំណោយ ការធ្វើវិភាគទានសង្គមដែលមានទឹកប្រាក់ចំនួន ១.៩៨៣ លានរៀល (៣១ ធ្នូ ២០១៦ ៖ សូន្យ) គឺជាទឹកប្រាក់ចំនួន ៧% នៃប្រាក់ចំណេញរបស់ ក.ស.ស (ក្រុមរបាយការណ៍គណៈគ្រប់គ្រង) អនុលោមទៅតាមមាត្រា ៣៤ នៃលក្ខន្តិកៈចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៧។

### ២៥. ខាតផ្សេងៗ - សុទ្ធ

| | ២០១៧<br>ពាន់រៀល | ២០១៦<br>ពាន់រៀល |
|---|---|---|
| ចំណេញពីការប្តូររូបិយប័ណ្ណ | ១.៣២៦.៣៣៩ | ១.៣២១.៨២៥ |
| ខាតពីការប្តូររូបិយប័ណ្ណ | (២.០១៣.៩១៤) | (២.៩៦០.៨៤៨) |
| ខាតពីការប្តូររូបិយប័ណ្ណ - សុទ្ធ | (៦៨៧.៥៧៥) | (១.៦៣៩.០២៣) |

## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧

### ២៦. ចំណាយហិរញ្ញវត្ថុ - សុទ្ធ

| | ២០១៧<br>ពាន់រៀល | ២០១៦<br>ពាន់រៀល |
|---|---|---|
| ចំណូលហិរញ្ញវត្ថុ៖ | | |
| ចំណូលការប្រាក់ពីប្រាក់បញ្ញើនៅធនាគារ (ក) | ១.៤១៣.២៦៣ | ២៩៣.៦៤៨ |
| ចំណូលការប្រាក់ពីការកត់ត្រាអប្បហារតេណទានផ្តល់ឱ្យបុគ្គលិកត្រលប់មកវិញ | ៥៦១.៨២១ | - |
| | ១.៩៧៥.០៨៤ | ២៩៣.៦៤៨ |
| ចំណាយហិរញ្ញវត្ថុ ៖ | | |
| ចំណាយការប្រាក់លើប្រាក់កម្ចី (ខ) | (១១.១៩៥.៤០១) | (១២.០៥៥.៥៤៦) |
| ខាតពីការប្តូររូបិយវត្ថុរបស់ប្រាក់កម្ចី (គ) | (១០.៧៦២.៣៤០) | (៧.០០៦.៥៩៨) |
| ចំណាយការប្រាក់ពីការបូកបន្ថែមភាគលាភជានាត្រូវបង់ | (៥៦៩.០៥១) | - |
| | (២២.៥២៦.៧៩២) | (១៩.០៦២.១៤៤) |
| ចំណាយហិរញ្ញវត្ថុ - សុទ្ធ | (២០.៥៥១.៧០៨) | (១៨.៧៦៨.៤៩៦) |

(ក) ចំណូលការប្រាក់គឺជាចំណូលពីគណនីប្រាក់បញ្ញើសន្សំ និងប្រាក់បញ្ញើមានកាលកំណត់ ដែលផ្ញើនៅធនាគារក្នុងស្រុកក្នុងឆ្នាំ។

(ខ) ចំណាយការប្រាក់គឺជាការប្រាក់លើប្រាក់កម្ចី ដែលទទួលបានពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមរយៈប្រាក់កម្ចីដែលទទួលបានពី JICA និង JBIC។

(គ) ក.ស.ស មានប្រាក់កម្ចីជាប្រាក់យ៉េនជប៉ុន និងជាប្រាក់ដុល្លារអាមេរិក (កំណត់សម្គាល់១៦)។ ដោយសារតែការធ្លាក់ចុះប្រាក់រៀលធៀបនឹងប្រាក់យ៉េនជប៉ុន វាបណ្តាលឱ្យមានការខាតពីការប្តូររូបិយប័ណ្ណជាសារវន្ត លើប្រាក់កម្ចីជាប្រាក់យ៉េន។ អត្រាប្តូរដែលត្រូវបានផ្សព្វផ្សាយដោយធនាគារជាតិ នៃ កម្ពុជា នាដំណាច់ការិយបរិច្ឆេទរាយការណ៍ មានដូចខាងក្រោម៖

| | ២០១៧ | ២០១៦ | ២០១៥ |
|---|---|---|---|
| ប្រាក់យ៉េន/ប្រាក់រៀល | ៣៥,៩២ | ៣៤,៨៥ | ៣៣,៧៩ |
| ប្រាក់ដុល្លារអាមេរិក/ប្រាក់រៀល | ៤.០៣៧ | ៤.០៣៧ | ៤.០៥០ |

**កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ**
**សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧**

## ២៧. ចំណាយពន្ធលើប្រាក់ចំណេញ

### (ក) ចំណាយពន្ធលើប្រាក់ចំណេញ

| | ២០១៧<br>ពាន់រៀល | ២០១៦<br>ពាន់រៀល |
|---|---|---|
| ពន្ធលើប្រាក់ចំណេញក្នុងឆ្នាំ | ៤.៣០៨.៧៩៩ | ៩.១២៥.៧០៣ |
| ពន្ធពន្យារ | ៧.៦១៧.២០០ | - |
| និយ័តកម្មពន្ធក្នុងឆ្នាំ | ៧៨៩.៣១៧ | - |
| ចំណាយពន្ធលើប្រាក់ចំណេញ | ១២.៧១៥.៣១៦ | ៩.១២៥.៧០៣ |

### (ខ) ការផ្ទៀងផ្ទាត់ពន្ធលើប្រាក់ចំណេញ និងចំណេញគណនេយ្យ

| | ២០១៧<br>ពាន់រៀល | ២០១៦<br>ពាន់រៀល |
|---|---|---|
| ចំណេញគណនេយ្យមុនបង់ពន្ធលើប្រាក់ចំណេញ | ៣៧.៨៥៤.៦៣២ | ៣៥.៨៤៦.១៧៥ |
| ចំណាយពន្ធលើប្រាក់ចំណេញ (*) | ៣.៧៨៥.៤៦៣ | ៧.១៦៩.២៣៥ |
| ផលប៉ះពាល់ពន្ធនៃចំណាយមិនអាចកាត់កង | ៥២៣.៣៣៦ | ១.៩៥៦.៤៦៨ |
| | ៤.៣០៨.៧៩៩ | ៩.១២៥.៧០៣ |
| ពន្ធលើប្រាក់ចំណេញក្នុងឆ្នាំ | ៤.៣០៨.៧៩៩ | ៩.១២៥.៧០៣ |

(*) យោងតាមច្បាប់សារពើពន្ធកម្ពុជា ក.ស.ស ត្រូវបង់ពន្ធលើប្រាក់ចំណេញ ២០%។ អនុលោមតាមអនុក្រឹតលេខ ០១ អនក្រ.តត ចុះថ្ងៃទី០១ ខែមករា ឆ្នាំ២០១៥ ក.ស.ស ទទួលបានការលើកទឹកចិត្តពន្ធចំនួនបីឆ្នាំ ដែលផ្តល់ដោយគណៈកម្មការមូលបត្រកម្ពុជា។ ដោយសារ ក.ស.ស បានចុះបញ្ជីក្នុង ផ.ម.ក ក្នុងខែមិថុនា ឆ្នាំ២០១៧។ ការលើកទឹកចិត្តនេះគឺកាត់បន្ថយចំនួនពន្ធលើប្រាក់ចំណេញ ៥០% ដែលត្រូវបង់សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧។

### (គ) សមតុល្យពន្ធពន្យារ

| | ២០១៧<br>ពាន់រៀល | ២០១៦<br>ពាន់រៀល |
|---|---|---|
| ពន្ធពន្យារទ្រព្យសកម្ម | ១៦.៥៧២.៦៨០ | ៨.៤៤២.១៧៥ |
| បំណុលពន្ធពន្យារ | (២៤.១៨៩.៨៨០) | (៨.៤៤២.១៧៥) |
| ពន្ធពន្យារលើប្រាក់ចំណេញ-សុទ្ធ | (៧.៦១៧.២០០) | - |

**កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ**
**សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧**

## ២៧. ចំណាយពន្ធលើប្រាក់ចំណេញ (ត)

### (គ) សមតុល្យពន្ធពន្យារ (ត)

បម្រែបម្រួលសមតុល្យពន្ធពន្យារ មានដូចខាងក្រោម៖

| | ២០១៧<br>ពាន់រៀល | ២០១៦<br>ពាន់រៀល |
|---|---|---|
| នៅថ្ងៃទី០១ ខែមករា | - | - |
| កត់ត្រាជាបន្ទុកក្នុងចំណេញ-ខាត | (៧.៦១៧.២០០) | - |
| នៅថ្ងៃទី៣១ ខែធ្នូ | (៧.៦១៧.២០០) | - |

### (i) ពន្ធពន្យារទ្រព្យសកម្ម

| | អត្ថប្រយោជន៍សោធននិវត្តន៍<br>ពាន់រៀល | បន្ទុកប្រាក់ខ្ចាន់<br>ពាន់រៀល | ចំណូលពន្យារ<br>ពាន់រៀល | ខាតដាច់ពន្ធយោងមកពីតំបន់សេដ្ឋកិច្ចពិសេស<br>ពាន់រៀល | សរុប<br>ពាន់រៀល |
|---|---|---|---|---|---|
| **នៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១៦** | - | - | - | - | - |
| កត់ត្រាជាបន្ទុកក្នុងចំណេញ-ខាត | ៨.០៦០.២៨២ | ១៦០.៨០៤ | ២២១.០៨៩ | - | ៨.៤៤២.១៧៥ |
| **នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦** | ៨.០៦០.២៨២ | ១៦០.៨០៤ | ២២១.០៨៩ | - | ៨.៤៤២.១៧៥ |
| កត់ត្រាជាបន្ទុកក្នុងចំណេញ-ខាត | ១៤១.៣៦៩ | ១.៧០៥.៩៣៩ | ៩៦៤.៥៧៨ | ៥.៣១៨.៦១៩ | ៨.១៣០.៥០៥ |
| **នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧** | ៨.២០១.៦៥១ | ១.៨៦៦.៧៤៣ | ១.១៨៥.៦៦៧ | ៥.៣១៨.៦១៩ | ១៦.៥៧២.៦៨០ |

### (ii) ចំណូលពន្ធពន្យារ

| | រំលស់ពន្លឿនពន្ធ<br>ពាន់រៀល | សរុប<br>ពាន់រៀល |
|---|---|---|
| **នៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១៦** | - | - |
| កត់ត្រាជាបន្ទុកក្នុងចំណេញ-ខាត | (៨.៤៤២.១៧៥) | (៨.៤៤២.១៧៥) |
| **នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦** | (៨.៤៤២.១៧៥) | (៨.៤៤២.១៧៥) |
| កត់ត្រាជាបន្ទុកក្នុងចំណេញ-ខាត | (១៥.៧៤៧.៧០៥) | (១៥.៧៤៧.៧០៥) |
| **នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧** | (២៤.១៨៩.៨៨០) | (២៤.១៨៩.៨៨០) |

## ២៧. ចំណាយពន្ធលើប្រាក់ចំណេញ (ត)

### (គ) សមតុល្យពន្ធពន្យារ (ត)

សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ ក.ស.ស បានកត់ត្រាពន្ធពន្យារទ្រព្យសកម្ម ស្មើនឹងចំនួនបំណុលពន្ធពន្យាររបស់ខ្លួន ហើយពន្ធពន្យារទ្រព្យសកម្មដែលនៅសល់ (សុទ្ធ) មិនត្រូវបានកត់ត្រាទេ ដោយសារ ក.ស.ស មិនមានកាលានុវត្តភាពគម្រោងពន្ធ ដែលអាចបង្កើតប្រាក់ចំណេញជាប់ពន្ធនាពេលអនាគតបាន។

### (ឃ) បញ្ហាពន្ធផ្សេងៗ

លិខិតប្រកាសពន្ធរបស់ ក.ស.ស តម្រូវឱ្យមានការត្រួតពិនិត្យតាមការិយបរិច្ឆេទដោយអាជ្ញាធរពន្ធដារពាក់ព័ន្ធ។ អាចមានការបកស្រាយខុសៗគ្នាទៅលើផ្នែកខ្លះនៃច្បាប់ និងបញ្ញត្តិពន្ធ ដូចនេះ ចំនួនទឹកប្រាក់ពន្ធដែលបានរាយការណ៍នៅក្នុងរបាយការណ៍លទ្ធផលអាចមានផ្លាស់ប្តូរនៅពេលក្រោយ បន្ទាប់ពីមានការកំណត់ចុងក្រោយដោយអាជ្ញាធរពន្ធដារពាក់ព័ន្ធ។

## ២៨. ចំណេញក្នុងមួយភាគហ៊ុន

### (ក) ចំណេញក្នុងមួយភាគហ៊ុនជាមូលដ្ឋាន (basic earnings per share)

ចំណេញក្នុងមួយភាគហ៊ុនជាមូលដ្ឋាន ត្រូវបានគណនាដោយយកប្រាក់ចំណេញរបស់ម្ចាស់ភាគហ៊ុនរបស់ ក.ស.ស ចែកនឹងចំនួនភាគហ៊ុនធម្មតាមធ្យមដែលបានបោះផ្សាយក្នុងឆ្នាំ។

| | ២០១៧ | ២០១៦ |
|---|---|---|
| ប្រាក់ចំណេញរបស់ភាគហ៊ុនិក (ពាន់រៀល) | ២៥.១៣៩.៣១៦ | ២៦.៧២០.៤៧២ |
| ចំនួនភាគហ៊ុនមធ្យម | ៧៦.៥៥១.៤៨០ | ៦៤.៣២៨.៩៧៥ |
| ចំណេញក្នុងមួយភាគហ៊ុនជាមូលដ្ឋាន (ពាន់រៀល) | ៣២៨,៤០ | ៤១៥,៣៧ |

### (ខ) ចំណេញក្នុងមួយភាគហ៊ុនថយចុះ (diluted earnings per share)

ចំណេញក្នុងមួយភាគហ៊ុនថយចុះ ត្រូវបានគណនាដោយកែប្រែចំនួនមធ្យមនៃភាគហ៊ុនធម្មតាដែលមាន ដោយសន្មតថាមានការផ្ទេរភាគហ៊ុនដែលមានសក្តានុពលទាំងអស់ទៅជាភាគហ៊ុនធម្មតា។ ក.ស.ស មិនមានភាគហ៊ុនដែលមានសក្តានុពលអាចផ្ទេរទៅជាភាគហ៊ុនធម្មតានោះទេ នាដំណាច់ការិយបរិច្ឆេទនេះ។ ដូចនេះ ចំណេញក្នុងមួយភាគហ៊ុនថយចុះ គឺមានតម្លៃស្មើនឹងចំណេញក្នុងមួយភាគហ៊ុនជាមូលដ្ឋាន។

## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧

### ២៩. សាច់ប្រាក់បានពីប្រតិបត្តិការ

| | ២០១៧<br>ពាន់រៀល | ២០១៦<br>ពាន់រៀល |
|---|---|---|
| ចំណេញមុនបង់ពន្ធ | ៣៧.៨៥៤.៦៣២ | ៣៥.៨៤៦.១៧៥ |
| និយ័តកម្ម៖ | | |
| រំលស់ទ្រព្យសម្បត្តិ និងបរិក្ខារ និងរំលស់ទ្រព្យសកម្មអរូបី | ២៥.២៣៩.៩៣៦ | ២២.១៧៩.៥០៨ |
| ចំណាយហិរញ្ញវត្ថុ - សុទ្ធ | ២០.៥៥១.៧០៨ | ១៨.៧៦៨.៤៩៦ |
| ចំណាយកាតព្វកិច្ចអត្ថប្រយោជន៍សោធននិវត្តន៍ | ៤.១៥៤.០០០ | ៤.០៦៥.០០០ |
| ចំណាក់បុគ្គលិកផ្សេងៗ ពាក់ព័ន្ធនឹងឥណទានផ្តល់ឱ្យបុគ្គលិក | ៣២៧.៧២៨ | - |
| *បម្រែបម្រួលដើមទុនបង្វិល៖* | | |
| សន្និធិ | (១.៦៤៧.៦៥៥) | (២.៦៤១.០៦៤) |
| គណនីអតិថិជនពាណិជ្ជកម្ម និងគណនីអតិថិជនផ្សេងៗ | (១១.២២៤.០៧១) | (៤.៣៦៥.១៤៥) |
| គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម និងគណនីអ្នកផ្គត់ផ្គង់ផ្សេងៗ | ១.៥២៧.៧១០ | ៤.៨១៥.៤៤២ |
| ចំណូលពន្យារ | (១៣៣.២២១) | (១៥៣.១៦៩) |
| សាច់ប្រាក់បានពីប្រតិបត្តិការ | ៧៦.៦៥០.៧៦៧ | ៧៨.៥១៥.២៤៣ |

ផ្នែកនេះបង្ហាញពីការវិភាគបំណុលសុទ្ធ និងបម្រែបម្រួលបំណុលសុទ្ធ ក្នុងឆ្នាំនីមួយៗដែលបានបង្ហាញ។

| | ២០១៧<br>ពាន់រៀល | ២០១៦<br>ពាន់រៀល |
|---|---|---|
| សាច់ប្រាក់ និងសាច់ប្រាក់សមមូល | ៥១.០៨១.២២៩ | ៣៤.៦៥១.៦០៤ |
| ប្រាក់បញ្ញើនៅធនាគាររយៈពេលខ្លី | ៧៣.១៩៤.២០១ | ១៣.៤៧៩.២២៨ |
| ប្រាក់កម្ចី – ត្រូវសងក្នុងរយៈពេលមួយឆ្នាំ | (២១.៦៩៧.៥៧៦) | (១៦.៥៤៣.៧៣៥) |
| ប្រាក់កម្ចី – ត្រូវសងក្នុងរយៈពេលលើសពីមួយឆ្នាំ | (៥០៣.៥៣៧.៣០៦) | (៤៦៣.២៣៥.៣៧២) |
| បំណុលសុទ្ធ | (៤០០.៩៥៩.៤៥២) | (៤៣១.៦៤៨.២៧៥) |
| | | |
| សាច់ប្រាក់ និងប្រាក់បញ្ញើនៅធនាគាររយៈពេលខ្លី | ១២៤.២៧៥.៤៣០ | ៤៨.១៣០.៨៣២ |
| បំណុលដុល – អត្រាការប្រាក់ថេរ | (៥២៥.២៣៤.៨៨២) | (៤៧៩.៧៧៩.១០៧) |
| បំណុលសុទ្ធ | (៤០០.៩៥៩.៤៥២) | (៤៣១.៦៤៨.២៧៥) |

## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧

### ២៩. សាច់ប្រាក់បានពីប្រតិបត្តិការ (ត)

| | ទ្រព្យសកម្មផ្សេងៗ | | បំណុលពីសកម្មភាពហិរញ្ញប្បទាន | | |
|---|---|---|---|---|---|
| | សាច់ប្រាក់ និង សាច់ប្រាក់ សមមូល ពាន់រៀល | ប្រាក់បញ្ញើនៅធនាគារ រយៈពេលខ្លី ពាន់រៀល | ប្រាក់កម្ចីត្រូវសងក្នុងរយៈ ពេលមួយឆ្នាំ ពាន់រៀល | ប្រាក់កម្ចីត្រូវសងសង ក្នុងរយៈពេល លើសពីមួយឆ្នាំ ពាន់រៀល | សរុប ពាន់រៀល |
| **បំណុលសុទ្ធនៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១៧** | ៣៤.៦៥១.៦០៤ | ១៣.៤៧៩.២២៨ | (១៦.៥៤៣.៧៣៥) | (៤៦៣.២៣៥.៣៧២) | (៤៣១.៦៤៨.២៧៥) |
| លំហូរសាច់ប្រាក់ | ១៦.៤២៩.៦២៥ | ៥៩.៧១៤.៩៧៣ | ១៦.៨៨៤.៥៦៨ | (៤០.៣៩២.៦០២) | ៥២.៦៣៦.៥៦៤ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | (៣៤០.៨៣៣) | (១០.៤២១.៥០៧) | (១០.៧៦២.៣៤០) |
| បម្រែបម្រួលមិនមែនសាច់ប្រាក់ផ្សេងៗ | - | - | (២១.៦៩៧.៥៧៦) | ១០.៥១២.១៧៥ | (១១.១៨៥.៤០១) |
| **បំណុលសុទ្ធនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧** | ៥១.០៨១.២២៩ | ៧៣.១៩៤.២០១ | (២១.៦៩៧.៥៧៦) | (៥០៣.៥៣៧.៣០៦) | (៤០០.៩៥៩.៤៥២) |

### ៣០. ប្រតិបត្តិការភាគីពាក់ព័ន្ធ

### (ក) ប្រតិបត្តិការ និងសមតុល្យភាគីពាក់ព័ន្ធ

ក.ស.ស ស្ថិតក្រោមការគ្រប់គ្រងផ្នែកហិរញ្ញវត្ថុរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងស្ថិតនៅក្រោមការគ្រប់គ្រងផ្នែកបច្ចេកទេសរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន។

ប្រតិបត្តិការ និង សមតុល្យភាគីពាក់ព័ន្ធសំខាន់ៗជាមួយក្រសួងសាធារណការ និងដឹកជញ្ជូន ទាក់ទិននឹងបុរេប្រទានត្រូវបានលាតត្រដាងក្នុងកំណត់សម្គាល់ ១១ និងជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទាក់ទិននឹងប្រាក់កម្ចី ត្រូវបានលាតត្រដាងក្នុងកំណត់សម្គាល់ ១៦។

### (ខ) ការទូទាត់ជូនគណៈគ្រប់គ្រងសំខាន់ៗ

ការទូទាត់ជូនគណៈគ្រប់គ្រងសំខាន់ៗ សម្រាប់ដំណាច់ឆ្នាំនេះ មានដូចខាងក្រោម៖

| | ២០១៧ ពាន់រៀល | ២០១៦ ពាន់រៀល |
|---|---|---|
| *ក្រុមប្រឹក្សាភិបាល* | | |
| ប្រាក់បៀវត្សរ៍ កម្រៃ និងចំណាយពាក់ព័ន្ធផ្សេងៗ | ១.៣៩៦.៨០០ | ៣៤៩.២០០ |
| | | |
| បុគ្គលិកថ្នាក់គ្រប់គ្រងសំខាន់ៗ | | |
| ប្រាក់បៀវត្សរ៍ និងចំណាយផ្សេងៗ | ១.៧៨៥.៤៣៧ | ១.៥០៧.៨៧៤ |
| អត្ថប្រយោជន៍សោធននិវត្តន៍ (*) | ១៦៥.៩៤៩ | ១៥១.២៩៣ |

បុគ្គលិកថ្នាក់គ្រប់គ្រងសំខាន់ៗ រួមមានអគ្គនាយក និងនាយកប្រតិបត្តិ ដែលជាអ្នកសម្រេចចិត្តជាយុទ្ធសាស្ត្រលើការដឹកនាំ លើផ្នែកហិរញ្ញវត្ថុ និងប្រតិបត្តិការរបស់ ក.ស.ស ។

**កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ**
**សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧**

## ៣០. ប្រតិបត្តិការភាគីពាក់ព័ន្ធ (ត)

### (ខ) ការទូទាត់ជូនគណៈគ្រប់គ្រងសំខាន់ៗ (ត)

(*) ផែនការអត្ថប្រយោជន៍សោធននិវត្តន៍ ត្រូវបានដាក់ឱ្យប្រតិបត្តិក្នុងអង្គភាពទាំងមូល ក្នុងនោះបុគ្គលិកថ្នាក់គ្រប់គ្រងសំខាន់ៗក៏មានសិទ្ធិទទួលផែនការអត្ថប្រយោជន៍នេះ ដូចគ្នានឹងបុគ្គលិក ក.ស.ស ដទៃទៀតដែរ។

### (គ) ឥណទានផ្តល់ឱ្យគណៈគ្រប់គ្រងសំខាន់ៗ

ក.ស.ស បានផ្តល់ឥណទានឱ្យបុគ្គលិក រួមទាំងគណៈគ្រប់គ្រងសំខាន់ៗ និងក្រុមប្រឹក្សាភិបាលផងដែរ ដើម្បីទិញ ភាគហ៊ុនប្រភេទ "គ" របស់ខ្លួន នៅពេលបោះផ្សាយលក់មូលបត្រសាធារណៈលើកដំបូង នៅថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៧។ ឥណទាននេះមិនមានការប្រាក់ និងមានរយៈពេលបួនឆ្នាំ។ ឥណទាននេះនឹងត្រូវទូទាត់សងតាមមូលដ្ឋានប្រចាំខែ ដោយកាត់កងពីប្រាក់បៀវត្សរ៍ប្រចាំខែរបស់គណៈគ្រប់គ្រងសំខាន់ៗ (កំណត់សម្គាល់ ៩)។ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ ឥណទានផ្តល់ឱ្យគណៈគ្រប់គ្រងសំខាន់ៗ មានទឹកប្រាក់ចំនួន ៣.៩០២ លានរៀល។

## ៣១. កិច្ចសន្យា

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ ក.ស.ស មានកិច្ចសន្យាទាក់ទិននឹងការទិញទ្រព្យសម្បត្តិ និងបរិក្ខារ ដែលមិនទាន់ទូទាត់ចំនួន ៥២.៦០៨លានរៀល សម្រាប់ការទិញទ្រព្យសម្បត្តិ និងបរិក្ខារដែលត្រូវបង់ក្នុងដំណាក់កាលផ្សេងៗ រហូតដល់ឆ្នាំ២០១៨។

# ផ្នែកទី ៧

## ព័ត៌មានអំពីប្រតិបត្តិការជាមួយភាគីជាប់ពាក់ព័ន្ធ

## ១-ប្រតិបត្តិការជាមួយនាគហ៊ុនិក ដោយបញ្ជាក់ពីឈ្មោះនាគហ៊ុនិក ប្រភេទប្រតិបត្តិការ និងកាលបរិច្ឆេទ

ចាប់តាំងពី ឆ្នាំ១៩៩៩ រហូតដល់ ឆ្នាំ២០១៧ នេះ ទីភ្នាក់ងារ JICA បានផ្តល់ប្រាក់កម្ចីសម្បទានសរុប ប្រមាណ ១៩.៦០០.០០០.០០០ យ៉េនជប៉ុន ប្រហាក់ប្រហែលនឹង (US$ ១៧៨.៥០០.០០០) ដល់កំពង់ផែស្វយ័តក្រុងព្រះសីហនុ សម្រាប់ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធផ្នែករឹង និងផ្នែកទន់ រួមមាន៖

**១.១.គម្រោងស្តារបន្ទាន់កំពង់ផែក្រុងព្រះសីហនុ (២០០២-២០០៥)** ប្រើប្រាស់ប្រាក់កម្ចី ODA លេខ: CP-P3 ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៩ ទឹកប្រាក់សរុប ៤.១៨២.០០០.០០០ យ៉េនជប៉ុន (៣៣,៧ លានដុល្លា) សម្រាប់ការអភិវឌ្ឍន៍ និងសាងសង់ចំណតផែកុងតឺន័រ ប្រវែង ២៤០ម៉ែត្រ ទីលានកុងតឺន័រ ៨,៥ ហិកតា ព្រមទាំងបូមស្តារអាង និងឃ្លងនាវាជម្រៅ ១១ម៉ែត្រ និងសាងសង់បរិយាកណ្ឌផែមួយផ្សេងទៀត។

**១.២.គម្រោងពង្រីកបន្ទាន់កំពង់ផែក្រុងព្រះសីហនុ (២០០៥-២០០៩)** ប្រើប្រាស់ប្រាក់កម្ចី ODA លេខ: CP-P4 ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០០៤ ទឹកប្រាក់សរុប ៤.៣១៣.០០០.០០០ យ៉េនជប៉ុន (៣៧,៤ លានដុល្លា) សម្រាប់ការអភិវឌ្ឍន៍ និងសាងសង់ចំណតផែកុងតឺន័របន្ថែម ប្រវែង ១៦០ម៉ែត្រ ទីលានកុងតឺន័រ ៣,៥ ហិកតា សាងសង់អាគាររដ្ឋបាលច្រកចេញចូលតែមួយ ព្រមទាំងពង្រីង និងបូមស្តារអាង និងឃ្លងនាវា បន្ថែមជម្រៅ ១១ម៉ែត្រ។ ក្រៅពីនេះ បានបំពាក់បន្ថែមនូវគ្រឿងចក្រទំនើបសម្រាប់លើកដាក់កុងតឺន័រ ប្រភេទ QC ០២ គ្រឿង និងប្រភេទ RTG ០៥ គ្រឿង រថយន្តដឹកកុងតឺន័រ ០៨គ្រឿង ព្រមទាំងតម្លើងប្រព័ន្ធ កុំព្យូទ័រស្វ័យប្រវត្តិកម្ម (Container Terminal Management System) (1set) ។

**១.៣.គម្រោងសិក្សាលទ្ធភាពអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេសកំពង់ផែក្រុងព្រះសីហនុ (២០០៧-២០០៩)** ប្រើប្រាស់ប្រាក់កម្ចី ODA លេខ: CP-P6 ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០០៦ ទឹកប្រាក់សរុប ៣១៨.០០០.០០០ យ៉េនជប៉ុន (២,៨ លានដុល្លា) សម្រាប់សិក្សាលទ្ធភាព និងគំនូសប្លង់វិស្វកកម្មនៃគម្រោង អភិវឌ្ឍន៍តំបន់សេដ្ឋកិច្ចពិសេសកំពង់ផែក្រុងព្រះសីហនុ ។

**១.៤.គម្រោងសាងសង់តំបន់សេដ្ឋកិច្ចពិសេសកំពង់ផែក្រុងព្រះសីហនុ (២០០៩-២០១២)** ប្រើប្រាស់ប្រាក់កម្ចី ODA លេខ: CP-P8 ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៨ ទឹកប្រាក់សរុប ៣.៦៥១.០០០.០០០ យ៉េនជប៉ុន (៣២,៩ លានដុល្លា) សម្រាប់សាងសង់ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត តំបន់សេដ្ឋកិច្ចពិសេសកំពង់ផែក្រុង ព្រះសីហនុ ដូចជា អាគាររដ្ឋបាលច្រកចេញ-ចូលតែ១ ស្ថានីយ៍ភស្តុភារកុងតឺន័រ (CFS) ផ្លូវថ្នល់ចូល និងផ្លូវ ថ្នល់ក្នុងតំបន់ SEZ ដីជួលសម្រាប់សាងសង់រោងចក្រ ៤៥ហិកតា រោងចក្រសម្រាប់ជួល ០១ខ្នង អាគារស្នាក់ នៅសម្រាប់បុគ្គលិក-កម្មករ អាងចម្រោះទឹកកខ្វក់ ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត អគ្គិសនី និងទូរគមនាគមន៍ ។ ល ។

**១.៥.គម្រោងអភិវឌ្ឍចំណតផែពហុបំណងកំពង់ផែក្រុងព្រះសីហនុ (២០១៥-២០១៨)** ប្រើប្រាស់ប្រាក់កម្ចី ODA លេខ: CP-P10 ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០០៩ ទឹកប្រាក់សរុប ៧.១៧៦.០០០.០០០ យ៉េនជប៉ុន (៧៤,២ លានដុល្លា)៖

បន្ថែមលើបរិយាកាសនេះ **កសស** បានកំពុងសាងសង់ចំណតផែពហុបំណងដែលមានបណ្តោយ ប្រវែង ៣៣០ម៉ែត្រ និងជម្រៅទឹក ១៣,៥ម៉ែត្រ សម្រាប់ប្រតិបត្តិការលើកដាក់ទំនិញរាយ និងទំនិញទូទៅ និងសាងសង់មូលដ្ឋានផ្គត់ផ្គង់ការរុករករ៉ែប្រេងក្នុងដែនសមុទ្រ ដើម្បីជម្រុញលើកទឹកចិត្តដល់ការនាំចេញផលិតផលកសិកម្មកម្ពុជា ចំណាំងឈើ ចំណិតដំឡូងមីក្រៀម ជាពិសេស ដើម្បីឆ្លើយតបនឹងការពង្រីកយុទ្ធសាស្ត្រនាំអង្ករចេញរបស់រាជរដ្ឋាភិបាលកម្ពុជា និងបម្រើសេវាភស្តុភារកម្មសម្រាប់ការរុករកប្រេងក្នុងដែនសមុទ្រកម្ពុជា ក៏ដូចជាជួយជម្រុញដល់កំណើនសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា ។

## ហេដ្ឋារចនាសម្ព័ន្ធគម្រោងដែលប្រើប្រាស់ប្រាក់កម្ចី ODA ជប៉ុន (២០០០-២០១៨)




ក្រៅពីនេះ ក្នុងអំឡុងដំណើរទស្សនកិច្ចរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នៅប្រទេសជប៉ុន នាថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៧ បានចុះហត្ថលេខាលើពិធីប្តូរសារ (Exchange Note) និងកិច្ចព្រមព្រៀងប្រាក់កម្ចី (Loan Agreement) លេខៈ CP-P21 នៅថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៧ រវាងរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលជប៉ុន។ តម្លៃគម្រោងសរុប ២៣.៥០២.000.000 យ៉េនជប៉ុន ប្រហាក់ប្រហែលនឹង (២០៣ លានដុល្លាអាមេរិក) ។

- គម្រោងសាងសង់ចំណតផែកុងតឺន័រកំពង់ផែក្រុងព្រះសីហនុ (២០២០-២០២៣)

សាងសង់ចំណតផែកុងតឺន័រថ្មី ប្រវែង ៣៥០ម៉ែត្រ ជម្រៅទឹក ១៤,៥ម៉ែត្រ ទីលានកុងតឺន័រ និងឋបនីយភណ្ឌ ព្រមទាំងការងារបូមស្តារ អាងនាវា និងឃ្លងនាវាជម្រៅ ១៤,៥ម៉ែត្រ ដែលអាចអនុញ្ញាតឱ្យនាវាកុងតឺន័រចំណុះ ៦០.០០០ DWT សមត្ថភាព ៥.០០០ TEUs ចូលចតបាន ដោយរួមបញ្ចូលទាំងការបំពាក់គ្រឿងចក្រលើកដាក់កុងតឺន័រទំនើបប្រភេទ QC ចំនួន ០៣ គ្រឿង និងប្រភេទ RTG ចំនួន ០៩ គ្រឿង និងឧបករណ៍លើកដាក់ទំនិញកុងតឺន័រមួយចំនួន ។ ល។ ដោយប្រើប្រាស់ប្រាក់កម្ចីសម្បទានរបស់ JICA (តម្លៃប៉ាន់ស្មានសរុប ២៣.៥០២.០០០.០០០ យ៉េនជប៉ុន ប្រហាក់ប្រហែលនឹង ២០៣ លានដុល្លារអាមេរិក) ។

### ២-ប្រតិបត្តិការសំខាន់ៗជាមួយអភិបាល ឬបុគ្គលិកជាន់ខ្ពស់ ឬប្រតិបត្តិការសំខាន់ៗជាមួយបុគ្គលដែលអភិបាល ឬបុគ្គលិកជាន់ខ្ពស់មានផលប្រយោជន៍

គិតត្រឹមឆ្នាំ២០១៧ នេះ ពុំមានប្រតិបត្តិការប្រភេទនេះកើតឡើងចំពោះ **កសស** ទេ ។

### ៣-ប្រតិបត្តិការសំខាន់ៗជាមួយសមាជិកគ្រួសារផ្ទាល់របស់អភិបាល និងបុគ្គលិកជាន់ខ្ពស់

គិតត្រឹមឆ្នាំ២០១៧ នេះ ពុំមានប្រតិបត្តិការប្រភេទនេះកើតឡើងចំពោះ **កសស** ទេ ។

### ៤-ប្រតិបត្តិការសំខាន់ៗជាមួយបុគ្គលដែលមានទំនាក់ទំនងជាមួយអភិបាលរបស់ កសស ក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬ ក្រុមហ៊ុនហូលឌីងរបស់ កសស ដែលទំនាក់ទំនងរបស់បុគ្គលទាំងនោះកើតមាននៅក្នុងប្រតិបត្តិការ ឬការចាត់ចែងណាមួយដែលធ្វើឡើងដោយ កសស

គិតត្រឹមឆ្នាំ២០១៧ នេះ ពុំមានប្រតិបត្តិការប្រភេទនេះកើតឡើងចំពោះ **កសស** ទេ ។

### ៥-ប្រតិបត្តិការសំខាន់ៗជាមួយបុគ្គលធ្លាប់ជាអភិបាល ឬបុគ្គលជាប់ពាក់ព័ន្ធជាមួយបុគ្គលធ្លាប់ជាអភិបាលក្នុងរយៈពេល ០២ (ពីរ) ឆ្នាំចុងក្រោយ

គិតត្រឹមឆ្នាំ២០១៧ នេះ ពុំមានប្រតិបត្តិការប្រភេទនេះកើតឡើងចំពោះ **កសស** ទេ ។

### ៦-ប្រតិបត្តិការសំខាន់ៗជាមួយអភិបាលដែលទទួលបានផលប្រយោជន៍ ឬកម្រៃវិជ្ជាជីវៈ សម្រាប់សេវាដែលខ្លួន បានផ្តល់តាមរយៈក្រុមហ៊ុនណាមួយដល់ កសស

គិតត្រឹមឆ្នាំ២០១៧ នេះ ពុំមានប្រតិបត្តិការប្រភេទនេះកើតឡើងចំពោះ **កសស** ទេ ។

### ៧-ប្រតិបត្តិការសំខាន់ៗជាមួយភាគីជាប់ពាក់ព័ន្ធផ្សេងទៀត

គិតត្រឹមឆ្នាំ២០១៧ នេះ ពុំមានប្រតិបត្តិការប្រភេទនេះកើតឡើងចំពោះ **កសស** ទេ ។

# ផ្នែកទី ៨

# ការពិភាក្សា និងការចាត់តាំងរបស់គណៈគ្រប់គ្រង

## ១-ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ

**កសស** គឺជាកំពង់ផែអន្តរជាតិសមុទ្រទឹកជ្រៅតែមួយគត់ នៃព្រះរាជាណាចក្រកម្ពុជាដែលកំពុងធ្វើអាជីវកម្ម លើផ្ទៃដីទំហំប្រមាណ ១២៥ហិចតា ដែលមានទីតាំងនៅក្រុងព្រះសីហនុនៃខេត្តព្រះសីហនុ ហើយដែលត្រូវបានតភ្ជាប់ដោយបណ្តាញដឹកជញ្ជូនចំរុះ។ កំណត់ក្នុង **អនុក្រឹត្យលេខ ៥០ អនក្រ/បក ចុះថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ ១៩៩៨ កសស** មានតួនាទីជាប្រតិបត្តិករផែ ដូចមានលម្អិតនូវអាជីវកម្ម និងសេវាកម្មក្នុងផ្នែកទី១ ចំណុច ទី២ ខាងលើនៃរបាយការណ៍ឆ្នាំ២០១៧ នេះ ។

សម្រាប់ឆ្នាំ២០១៧ បរិមាណកុងតឺន័ររបស់ **កសស** មានការកើនឡើងចំនួន ៥៩.៦៥២ TEUs ស្មើនឹង ១៤,៩១% បើធៀបនឹងឆ្នាំ២០១៦ ហើយគិតជាបរិមាណតោនមានកំណើន១៥,២០% ស្មើនឹង ៣៨០.២៣០តោន។ ចំណែកទំនិញរាយឆ្លងកាត់មានការថយចុះចំនួន ១៧០.៦១៧តោន ស្មើនឹង ៤៤,៩៨% សម្រាប់ឆ្នាំ២០១៧ បើធៀបនឹងឆ្នាំ២០១៦ ចំពោះនាវាឆ្លងកាត់ **កសស** មានការថយចុះចំនួន ១៧ នាវា ប្រមាណជា ១,២៩% ធៀបនឹងឆ្នាំ២០១៦ ។

ការពិភាក្សា និងការវិភាគរបស់ថ្នាក់ដឹកនាំលើស្ថានភាពហិរញ្ញវត្ថុរបស់ **កសស** និងលទ្ធផលប្រតិបត្តិការខាងក្រោមនេះ ធ្វើឡើងផ្អែកលើរបាយការណ៍ព័ត៌មានហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួចរាល់ដោយសវនករឯករាជ្យសម្រាប់ឆ្នាំ២០១៧ និងឆ្នាំ២០១៦ ដូចបង្ហាញក្នុងផ្នែកទី៦ នៃរបាយការណ៍ប្រចាំឆ្នាំ២០១៧ នេះ ។

**កសស មានប្រភពចំណូលសំខាន់ដូចខាងក្រោម ៖**

- **ចំណូលពីសេវាកម្មផែ** (Port Charges for Vessel Services)៖ គឺជាចំណូលដែលបានមកពីសេវាកម្មនាវាចរណ៍ និងការចូលចតនាវា រួមមាន ចំណូលលើចំណុះផ្ទុក សំចតផែ ប្រឡាយ ថ្លៃឈ្នួលកណ្តាលធារកិច្ច ថ្លៃឈ្នួលនាវាសណ្តោង ថ្លៃឈ្នួលពាក់-ដោះពួរ ថ្លៃឈ្នួលបើក-បិទឃ្លប់នាវា និងថ្លៃឈ្នួលប្រមូលសំរាម ។
- **ចំណូលពីសេវាកម្មលើកដាក់កុងតឺន័រពីនាវាទៅទីលានកុងតឺន័រ** (Stevedoring Charges)៖ គឺជាចំណូលដែលបានមកពីសេវាកម្មលើកដាក់ទំនិញរាយ ឬកុងតឺន័រចូល ឬចេញពីនាវានៅលើស្ពានផែ ។
- **ចំណូលពីសេវាកម្មលើកដាក់កុងតឺន័រនៅលើទីលាន** (LOLO Charges)៖ គឺជាចំណូលដែលបានមកពីសេវាកម្មលើកដាក់ទំនិញរាយ ឬកុងតឺន័រ ចូល ឬចេញនៅលើទីលាន ។
- **ចំណូលពីថ្លៃឈ្នួលស្តុកទំនិញ ឬកុងតឺន័រ** (Storage Fees)៖ គឺជាចំណូលដែលបានមកពីការស្តុកទំនិញរាយ ឬកុងតឺន័រនៅក្នុងឃ្លាំង និងលើទីលាន ។
- **ចំណូលដឹកជញ្ជូន** (Transportation Charges)៖ គឺជាចំណូលដែលបានមកពីសេវាកម្មដឹកជញ្ជូនទំនិញ ឬកុងតឺន័រក្នុង បរិវេណផែ ។
- **ចំណូលពីតំបន់សេដ្ឋកិច្ចពិសេស** (Special Economic Zone)៖ គឺជាចំណូលដែលទទួលបានពីការជួលដីធ្វើរោងចក្រ អគារ ពីតំបន់សេដ្ឋកិច្ចពិសេសរបស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ ។

**កសស** កត់ត្រាបញ្ជីគណនេយ្យ និងរបាយការណ៍ហិរញ្ញវត្ថុជាប្រាក់រៀល ដែលជារូបិយប័ណ្ណជាតិរបស់ខ្លួន ចំណែកប្រតិបត្តិការដែលជារូបិយប័ណ្ណអន្តរជាតិផ្សេងៗ ត្រូវបានបង្ហាញជាប្រាក់រៀលដោយប្រើអត្រាប្តូរផ្លូវការជាមធ្យមប្រចាំថ្ងៃរបស់ធនាគារជាតិនៃកម្ពុជា តាមកាលបរិច្ឆេទនៃប្រតិបត្តិការនីមួយៗ ។

## ក-ការវិភាគចំណូល

### ក.១. ការវិភាគចំណូល

<u>សម្រាប់ដំណាច់ការិយបរិច្ឆេទ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៧ ប្រៀបធៀបនឹង</u>

<u>ដំណាច់ការិយបរិច្ឆេទ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៦</u>

| បរិយាយ | សម្រាប់ការិយចរិច្ឆេទ ឆ្នាំ២០១៧ | សម្រាប់ការិយចរិច្ឆេទ ឆ្នាំ២០១៦ | បំរែបំរួល | |
|---|---|---|---|---|
| | ពាន់រៀល | ពាន់រៀល | ពាន់រៀល | % |
| ចំណូល | ២២៧.៣៩៧.៨៣៥ | ២០៨.៩៨១.២៤៩ | ១៨.៤១៦.៥៨៦ | ៨,៨១% |

សម្រាប់ឆ្នាំ២០១៧ ចំណូលរបស់ **កសស** បានកើនឡើង ចំនួន ១៨.៤១៦.៥៨៦.០០០រៀល ស្មើនឹង ៨,៨១% ដោយកើនឡើងពី ២០៨.៩៨១.២៤៩.០០០រៀល សម្រាប់ឆ្នាំ២០១៦ ដល់ ២២៧.៣៩៧.៨៣៥.០០០ រៀល សម្រាប់ឆ្នាំ២០១៧ ។ ការកើនឡើងនៃចំណូលនេះបានមកពីសេវាកម្មលើកដាក់កុងតឺន័រពីនាវាទៅទីលាន (Stevedoring Charges) ចំណូលពីសេវាកម្មលើកដាក់កុងតឺន័រនៅលើទីលាន (LOLO Charges) និង ចំណូលពីថ្លៃឈ្នួលស្តុកទំនិញ ឬកុងតឺន័រជាដើម ។

## ក.២. ការវិភាគចំណូលតាមផ្នែក

### តារាងប្រៀបធៀបប្រាក់ចំណូលតាមផ្នែកទៅនឹងប្រាក់ចំណូលសរុបសម្រាប់ ឆ្នាំ២០១៧ និង ឆ្នាំ២០១៦

| បរិយាយ | សម្រាប់ការិយបរិច្ឆេទ ឆ្នាំ២០១៧ | | សម្រាប់ការិយបរិច្ឆេទ ឆ្នាំ២០១៦ | |
|---|---|---|---|---|
| | ពាន់រៀល | ភាគរយធៀបនឹងចំណូលសរុប | ពាន់រៀល | ភាគរយធៀបនឹងចំណូលសរុប |
| ចំណូលលើកដាក់ (Stevedoring and LOLO) | ១៦៨.៥០៤.៩៤១ | ៧៤,១០% | ១៤៨.៦៧៥.៩២៤ | ៧១,១៤% |
| ចំណូលពីសេវាកម្មផែ | ៤៩.៦៤៤.០៤៩ | ២១,៨៣% | ៥៤.៤១១.៧៥៥ | ២៦,០៤% |
| ចំណូលស្តុក ឃ្លាំង និងទីលាន | ៤.៤០៦.៦១៥ | ១,៩៤% | ១.៩៥៨.៦៩០ | ០,៩៤% |
| ចំណូលដឹកជញ្ជូន | ៧៥៤.២៥៤ | ០,៣៣% | ១៥៤.៧៣៥ | ០,០៧% |
| ចំណូលនាវាទេសចរណ៍ | ៣៨១.៥០១ | ០,១៧% | ៥៦០.៩១០ | ០,២៧% |
| ចំណូលពីតំបន់ សេដ្ឋកិច្ចពិសេស | ២.៨៤៨.១៨០ | ១,២៥% | ២.៣០១.៥៥១ | ១,១០% |
| ចំណូលជួលទីតាំង | ៥៨៨.០៤២ | ០,២៦% | ៦៧០.៥៨៤ | ០,៣២% |
| ចំណូលផ្សេងៗទៀត | ២៧០.២៥២ | ០,១២% | ២៤៧.១០០ | ០,១២% |
| ចំណូលសរុប | **២២៧.៣៩៧.៨៣៥** | **១០០,០០%** | **២០៨.៩៨១.២៤៩** | **១០០,០០%** |

សម្រាប់ឆ្នាំ២០១៧ ក៏ដូចជាឆ្នាំ២០១៦ មានចំណូលសំខាន់ ៣ប្រភេទដែលមានចំនួនប្រមាណ ៩៨% នៃចំណូលអាជីវកម្ម និងសេវាកម្ម សរុបរបស់ **កសស** ។ ចំណូលទាំងនោះរួមមាន ៖ ចំណូលលើកដាក់ ( ចំណូលលើកដាក់ពីនាវាទៅទីលានកុងតឺន័រ (Steverdoring ) និងចំណូលលើកដាក់លើទីលាន (LOLO) ) ចំណូលពីសេវាកម្មផែ (Port Charges for Vessel Services) និងចំណូលស្តុកឃ្លាំង និងទីលាន ។

សម្រាប់ដំណាច់ការិយបរិច្ឆេទ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៧ ប្រៀបធៀបនឹងដំណាច់ការិយបរិច្ឆេទ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៦

| បរិយាយ | សម្រាប់ការិយបរិច្ឆេទឆ្នាំ២០១៧ | សម្រាប់ការិយបរិច្ឆេទឆ្នាំ២០១៦ | បំរែបំរួល | |
|---|---|---|---|---|
| | ពាន់រៀល | ពាន់រៀល | ពាន់រៀល | % |
| **ចំណូលលើកដាក់(Stevedoring and LOLO)** | ១៦៨.៥០៤.៩៤១ | ១៤៨.៦៧៥.៩២៤ | ១៩.៨២៩.០១៨ | **១៣,៣៤%** |
| **ចំណូលពីសេវាកម្មផែ** | ៤៩.៦៤៤.០៤៩ | ៥៤.៤១១.៧៥៥ | -៤.៧៦៧.៧០៦ | **-៨,៧៦%** |
| **ចំណូលស្តុក ឃ្លាំង និងទីលាន** | ៤.៤០៦.៦១៥ | ១.៩៥៨.៦៩០ | ២.៤៤៧.៩២៥ | **១២៤,៩៨%** |

ចំណូលពីការលើកដាក់ពីនាវាទៅទីលានកុងតឺន័រ (Steverdoring) និងការលើកដាក់នៅលើទីលាន (LOLO) មានការកើនឡើងប្រមាណ ១៣,៣៤% ស្មើនឹង ១៩.៨២៩.០១៨.០០០រៀល ប្រៀបធៀបរវាងឆ្នាំ២០១៧ ដែលមានចំណូលស្មើនឹង ១៦៨.៥០៤.៩៤១.០០០រៀល និងឆ្នាំ២០១៦ ដែលមានចំណូលស្មើនឹង ១៤៨.៦៧៥.៩២៤.០០០រៀល ។ កំណើននេះ គឺបណ្តាលមកពីការកើនឡើងនៃទំនិញកុងតឺន័រឆ្លងកាត់មានចំនួន ៥៩.៦៥២TEUs ស្មើនឹង ១៤,៩១% សម្រាប់ឆ្នាំ២០១៧ នេះ ។

ចំពោះចំណូលពីសេវាកម្មផែ (Port Charges for Vessel Services) មានការថយចុះពី -៥៤.៤១១.៧៥៥.០០០រៀល សម្រាប់ឆ្នាំ២០១៦ ដល់ ៤៩.៦៤៤.០៤៩.០០០រៀល សម្រាប់ឆ្នាំ២០១៧ គឺប្រមាណ ៨,៧៦% ស្មើនឹង (៤.៧៦៧.៧០៦.០០០រៀល) ។ ចំណូលសេវាកម្មផែ នេះគឺអាស្រ័យលើចំនួន និងចំណុះផ្ទុកនាវាដែលឆ្លងកាត់ **កសស** ហើយឆ្នាំ២០១៧ នេះ នាវាដែលឆ្លងកាត់ **កសស** មានការថយចុះចំនួន ១៧ នាវា ដោយមាន ១.៣២២ នាវា សម្រាប់ឆ្នាំ២០១៦ និង ១.៣០៥ នាវា សម្រាប់ ឆ្នាំ២០១៧ នេះ ។

ចំណូលពីសេវាកម្មស្តុកឃ្លាំង និងទីលានមានការកើនឡើង ចំនួន ២.៤៤៧.៩២៥.០០០រៀល ស្មើនឹង ១២៤,៩៨% បើធៀបនឹងឆ្នាំ២០១៦ ដែលមានចំណូល ១.៩៥៨.៦៩០.០០០រៀល និងឆ្នាំ២០១៧ មានចំណូល ៤.៤០៦.៦១៥.០០០រៀល ។ ការកើនឡើងនៃចំណូលស្តុកនេះ គឺបណ្តាលមកពី ទំនិញដែលឆ្លងកាត់ឃ្លាំង និងទីលានរបស់ **កសស** មានកំណើន ១៤,១៥% ស្មើនឹង ៧២៧.៤២១តោន សម្រាប់ឆ្នាំ២០១៧ នេះ ។

## ខ-ការវិភាគគំលាតចំណេញដុល

**កសស** បានរៀបចំរបាយការណ៍លទ្ធផលរបស់ខ្លួន ក្នុងទម្រង់ជារបាយការណ៍លទ្ធផលតាមយថាប្រភេទ ដូចនេះពុំមានការបង្ហាញឱ្យឃើញនៅចំណេញដុលនោះទេ។ ប៉ុន្តែក្នុងទម្រង់របាយការណ៍នេះអាចឱ្យយើងធ្វើការពិភាក្សា និងវិភាគលើចំណេញប្រតិបត្តិការបានដោយទទួលបានពីចំណូលសរុប ដកនឹងចំណាយប្រតិបត្តិការ។

ចំណាយប្រតិបត្តិការនឹងលើកមកពិភាក្សា និងវិភាគនៅផ្នែកខាងក្រោមគឺ ចំណុច គ-ការវិភាគចំណេញមុនបង់ពន្ធ ។

## គ- ការវិភាគចំណេញមុនបង់ពន្ធ

ចំណេញមុនបង់ពន្ធគឺជាលទ្ធផលដែលទទួលបានពីចំណូលសរុបដកនឹងចំណាយប្រតិបត្តិ និងចំណូល ឬចំណាយការប្រាក់សុទ្ធ ។ ក្នុងការវិភាគនៃចំណាយប្រតិបត្តិការ យើងនឹងលើកយកចំណាយសម្ភារះផ្គត់ផ្គង់ ចំណាយប្រាក់បៀវត្សរ៍ ប្រាក់ឈ្នួល និងចំណាយពាក់ព័ន្ធ ចំណាយរំលស់ (ទ្រព្យសម្បត្តិ និងបរិក្ខារ និងទ្រព្យសកម្មអរូបី) ចំណាយជួសជុល និងថែទាំ ចំណាយផ្សេងៗ និងចំណេញ (ឬខាត) ផ្សេងៗ សុទ្ធ ដូចខាងក្រោម៖

## សម្រាប់ដំណាច់ការិយបរិច្ឆេទ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៧ ប្រៀបធៀបនឹងដំណាច់ការិយបរិច្ឆេទ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៦

| បរិយាយ | សម្រាប់ការិយបរិច្ឆេទ ឆ្នាំ២០១៧ | សម្រាប់ការិយបរិច្ឆេទ ឆ្នាំ២០១៦ | បំរែបំរួល | |
|---|---|---|---|---|
| | ពាន់រៀល | ពាន់រៀល | ពាន់រៀល | % |
| **ចំណូលសរុប** | **២២៧.៣៩៧.៨៣៥** | **២០៨.៩៨១.២៤៩** | **១៨.៤១៦.៥៨៦** | **៨,៨១%** |
| ចំណាយសម្ភារៈផ្គត់ផ្គង់ | (៥៤.៣៨៩.៦៥៥) | (៤៨.៦០២.០៨១) | ៥.៧៨៧.៥៧៤ | ១១,៩១% |
| ចំណាយប្រាក់បៀវត្ស ប្រាក់ឈ្នួល និងចំណាយពាក់ព័ន្ធ | (៦១.៦៣៤.៨៨៦) | (៥៥.៣៧៧.៤៤៤) | ៦.២៥៧.៤៤២ | ១១,៣០% |
| ចំណាយរំលស់ (ទ្រព្យសម្បត្តិ និងបរិក្ខារ និងទ្រព្យសកម្មអរូបី) | (២៥.២៣៩.៩៣៦) | (២២.១៧៩.៥០៨) | ៣.០៦០.៤២៨ | ១៣,៨០% |
| ចំណាយជួសជុល និងថែទាំ | (៥.១៤២.២៩៦) | (៥.៩៤៦.៧២៣) | (៨០៤.៤២៧) | -១៣,៥៣% |
| ចំណាយផ្សេងៗ | (២១.៨៩៧.១៤៧) | (២០.៦២១.៧៩៩) | ១.២៧៥.៣៤៨ | ៦,១៨% |
| ចំណេញ/(ខាត)ផ្សេងៗ-សុទ្ធ | (៦៨៧.៥៧៥) | (១.៦៣៩.០២៣) | (៩៥១.៤៤៨) | -៥៨,០៥% |
| ចំណូល /(ចំណាយ)ហិរញ្ញប្បទាន-សុទ្ធ | (២០.៥៩១.៧០៨) | (១៨.៧៦៨.៤៩៦) | ១.៧៨៣.២១២ | ៩,៥០% |
| **ចំណេញមុនបង់ពន្ធ** | **៣៧.៨៥៤.៦៣២** | **៣៥.៨៤៦.១៧៥** | **២.០០៨.៤៥៧** | **៥,៦០%** |

សម្រាប់ ឆ្នាំ២០១៧ **កសស** មានចំណាយសម្ភារៈផ្គត់ផ្គង់ ៥៤.៣៨៩.៦៥៥.០០០រៀល ដែលមានការកើនឡើងចំនួន ៥.៧៨៧.៥៧៤.០០០រៀល ស្មើនឹង ១១,៩១% បើធៀបនឹងឆ្នាំ២០១៦ ដែលមានចំណាយ ៤៨.៦០២.០៨១.០០០រៀល ។ កត្តាចម្បងដែលបណ្តាលឱ្យមានកើនឡើងនេះ គឺដោយសារចំណាយលើសម្ភារងាយឆេះ (ប្រេងឥន្ធនៈ) មានការកើនឡើងដល់ ៣៧,៥៤% ស្មើនឹង ៨.៣០៦.៨៦៨.០០០រៀល ហើយសម្ភារៈឃ្លាំង និងគ្រឿងបន្លាស់ក៏មានការកើនឡើង ៣៩,២៨% និងប្រេងម៉ាស៊ីនកើន ៣,៥១% ផងដែរ។

សម្រាប់ចំណាយប្រាក់បៀវត្សរ៍ ប្រាក់ឈ្នួល និងចំណាយពាក់ព័ន្ធ ក៏មានកំណើនប្រមាណ ១១,៣០% ស្មើនឹង ៦.២៥៧.៤៤២.០០០រៀល បើធៀបនឹងឆ្នាំ២០១៧ ដែលមានចំណាយ ៦១.៦៣៤.៨៨៦.០០០រៀល និងឆ្នាំ២០១៦ ដែលមានចំណាយ ៥៥.៣៧៧.៤៤៤.០០០រៀល ។ ដោយមូលដ្ឋានក្នុងការគណនាប្រាក់បៀវត្សរ៍គោលរបស់ **កសស** គឺយោងទៅលើទិន្នផល (ចំណូលពីការលើកដាក់) ពោលគឺនៅពេលចំណូលពីការលើកដាក់កើនឡើង ចំណាយបៀវត្សរ៍នឹងកើនឡើង ផ្ទុយទៅវិញបើចំណូលពីការលើកដាក់មានការថយចុះ ចំណាយលើប្រាក់បៀវត្សរ៍នឹងត្រូវថយចុះដូចគ្នា ហើយយើងសង្កេតឃើញថា ចំណូលលើកដាក់មានការកើនឡើងប្រមាណ ១៣,៣៤% សម្រាប់ឆ្នាំ២០១៧នេះ ។ កត្តាមួយទៀតដែលធ្វើឱ្យចំណាយនេះកើនឡើងគឺចំណាយលើប្រាក់រង្វាន់បុគ្គលិក ដោយមានកំណើនប្រមាណ ២២% ស្មើនឹង ១.៥៦២.៥៨៤.០០០រៀល បើធៀបនឹងឆ្នាំ២០១៦ ។

ចំណាយរំលស់ រួមមានរំលស់ទ្រព្យសម្បត្តិ និងបរិក្ខារ និងរំលស់ទ្រព្យសកម្មអរូបីនៅក្នុងឆ្នាំ២០១៧ ចំនួន ២៥.២៣៩.៩៣៦.០០០រៀល មានកំណើន ៣.០៦០.៤២៨.០០០រៀល ស្មើនឹង ១៣,៨០% នៅក្នុងឆ្នាំ២០១៧ ធៀបនឹងឆ្នាំ២០១៦ ដែលមានចំនួន ២២.១៧៩.៥០៨.០០០រៀល ។ កត្តាសំខាន់ដែលធ្វើឱ្យមានការកើនឡើងនេះ គឺដោយសារចំណាយរំលស់ទ្រព្យសម្បត្តិ និងបរិក្ខារ មានការកើនឡើងដល់ ២.៩៨៣.២៦៣.០០០រៀល ស្មើនឹង ១៩.៧២% ដោយសារ **កសស** បានបំពាក់រថចល័តលើគែមផែសម្រាប់ស្ទូចកុងតឺន័រ ចំនួន ០២គ្រឿង និងរថស្ទូចសម្រាប់លើកដាក់កុងតឺន័រដែលអាចចល័តលើទីលាន ចំនួន ០៩គ្រឿង នៅក្នុងឆ្នាំ២០១៧នេះ។

ចំណែកចំណាយជួសជុល និងថែទាំ (សំណង់) មានចំនួនតិចជាងឆ្នាំ២០១៦ ដោយមានចំណាយសរុបស្មើនឹង ៥.១៤២.២៩៦.០០០រៀល សម្រាប់ឆ្នាំ២០១៧ និង ៥.៩៤៦.៧២៣.០០០រៀល សម្រាប់ឆ្នាំ២០១៦ ពោលគឺ ថយចុះប្រមាណ ១៣,៥៣% ស្មើនឹង ៨០៤.៤២៧.០០០រៀល ។

ចំពោះចំណាយផ្សេងៗ មានកំណើន ៦,១៨% ស្មើនឹង ១.២៧៥.៣៤៨.០០០រៀល ពោលគឺកើនឡើងពី ២០.៦២១.៧៩៩.០០០រៀល សម្រាប់ឆ្នាំ២០១៦ ទៅ ២១.៨៩៧.១៤៧.០០០រៀល សម្រាប់ឆ្នាំ២០១៧ ។ ចំណាយផ្សេងៗ ក្នុងនោះរួមមានចំណាយវិភាគទាន និងការធ្វើអំណោយ ចំណាយប្រតិបត្តិការតំបន់សេដ្ឋកិច្ចពិសេស ចំណាយការទទួលភ្ញៀវ និងបដិសណ្ឋារកិច្ច ចំណាយសេវា ប្រៃសណីយ៍ ចំណាយផ្នែកសេវាវិជ្ជាជីវៈ ចំណាយការបង់ពន្ធផ្សេងៗ និងពាក់ព័ន្ធ ចំណាយសម្ភារៈថែទាំសុខភាព និងចំណាយផ្សេងៗទៀត ។ ចំណាយសំខាន់ៗដែលចូលរួមការប្រែប្រួលនេះមានដូចជា៖ ចំណាយវិភាគទាន និងការធ្វើអំណោយមានកំណើន ៣៨,៤៣% ស្មើនឹង ២.១២៥.០២៤.០០០រៀល (ដោយក្នុងនេះបានរួមបញ្ចូលទឹកប្រាក់ចំនួន ១.៩៨៣ លានរៀល ដែលជាប្រាក់សម្រាប់មូលនិធិសង្គម ដូចបានចែងក្នុងមាត្រា ៣៤ នៃលក្ខន្តិកៈរបស់ **កសស**) ។ រីឯចំណាយប្រតិបត្តិការតំបន់សេដ្ឋកិច្ចពិសេសមានកំណើន ២២,០១% ស្មើនឹង ៥៩៨.៤៣០.០០០រៀល ចំណាយលើការបោះពុម្ពមានកំណើន ៣៩.២៤% ស្មើនឹង ២៦៦.០៣១.០០០រៀល បើធៀបនឹងឆ្នាំ២០១៦ ។ ចំណែកចំណាយការទទួលភ្ញៀវ និងបដិសណ្ឋារកិច្ចមានការថយចុះ ១៥,៧៣% ស្មើនឹង ៥៤៨.២៦៦.០០០រៀល ចំណាយកម្រៃផ្នែកសេវាវិជ្ជាជីវៈ និងចំណាយពាក់ព័ន្ធមានការថយចុះ ១៩១.៦៣៨.០០០រៀល ស្មើនឹ ២៧,២២% និងចំណាយលើពន្ធផ្សេងៗ ថយចុះ ១.៣៣៩.២៥០.០០០រៀល ស្មើនឹង ៨៧,៤៥% បើធៀបនឹង ឆ្នាំ២០១៦ ។

ចំណេញ/(ខាត) ផ្សេងៗ-សុទ្ធ (Realized Foreign Exchange Gain-Loss) គឺសំដៅលើការចំណេញ ឬខាតពីការប្តូររូបិយប័ណ្ណក្នុងការិយបរិច្ឆេទ ដែលសម្រាប់ឆ្នាំ២០១៧នេះ មានការខាតពីការប្តូររូបិយប័ណ្ណ ចំនួន

៦៨៧.៥៧៥.០០០រៀល ដែលមានការថយចុះប្រមាណ ៥៨,០៥% ស្មើនឹង ៩៥១.៤៤៨.០០០រៀល បើធៀបនឹងឆ្នាំ ២០១៦ គឺមានការខាតរហូតដល់ ១.៦៣៩.០២៣.០០០រៀល ។

ចំណែក ចំណូល/(ចំណាយ) ហិរញ្ញប្បទាន-សុទ្ធ សម្រាប់ឆ្នាំ២០១៧ មានចំណាយចំនួន ២០.៥៥១.៧០៨.០០០រៀល ដែលកើនឡើងប្រមាណ ៩,៥០% បើធៀបនឹងឆ្នាំ២០១៦ ដែលមានចំណាយចំនួន ១៨.៧៦៨.៤៩៦.០០០រៀល ។ យើងសង្កេតឃើញថាសម្រាប់ឆ្នាំ២០១៧ មានចំណូលហិរញ្ញប្បទានចំនួន ១.៩៧៥.០៨៤.០០០រៀល ដែលរួមមានការប្រាក់បញ្ញើនៅធនាគារចំនួន ១.៤១៣.២៦៣.០០០រៀល និងចំណូលការប្រាក់ពីអប្បហារឥណទានបុគ្គលិកចំនួន ៥៦១.៨២១.០០០រៀល រីឯចំណាយហិរញ្ញប្បទានមានចំនួន ២២.៥២៦.៧៩២.០០០រៀល ។ ចំណែកឆ្នាំ២០១៦ មានចំណូលហិរញ្ញប្បទានចំនួន ២៩៣.៦៤៨.០០០ រៀល ជាចំណូលការប្រាក់បញ្ញើនៅធនាគារ ហើយចំណាយហិរញ្ញប្បទានមានចំនួន ១៩.០៦២.១៤៤.០០០រៀល។ កត្តាចម្បងដែលធ្វើឱ្យចំណាយហិរញ្ញប្បទាន-សុទ្ធ ក្នុងឆ្នាំ២០១៧ មានការកើនឡើងគឺដោយសារការខាតសុទ្ធពីការប្តូររូបិយប័ណ្ណលើប្រាក់កម្ចីកើនឡើងចំនួន ៣.៧៥៥.៧៤២.០០០រៀល ស្មើនឹង ៥៣,៦០% ដោយនៅក្នុងឆ្នាំ ២០១៧ មានចំនួន ១០.៧៦២.៣៤០.០០០រៀល ធៀបនឹងឆ្នាំ២០១៦ ដែលមានត្រឹមតែ ៧.០០៦.៥៩៨.០០០ រៀល ។

ជាសរុប ចំណេញមុនបង់ពន្ធ សម្រាប់ឆ្នាំ២០១៧ របស់ **កសស** មានចំនួន ៣៧.៨៥៤.៦៣២.០០០រៀល បើធៀបនឹងឆ្នាំ២០១៦ ដែលមានចំនួន ៣៥.៨៤៦.១៧៥.០០០រៀល កើនឡើងប្រមាណ ៥,៦០% ស្មើនឹង ២.០០៨.៤៥៧.០០០រៀល ។

### ឃ- ការវិភាគចំណេញក្រោយបង់ពន្ធ

**កសស** ស្ថិតនៅក្រោមច្បាប់នៃក្រុមហ៊ុនពាណិជ្ជកម្មក្នុងវិស័យពន្ធដារ និងអាករ ហេតុដូចនេះ **កសស** មានកាតព្វកិច្ចក្នុងការបង់ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំក្នុងអត្រា ២០% ប៉ុន្តែក្រោយពី **កសស** បានបោះផ្សាយលក់មូលបត្រកម្មសិទ្ធិលើកដំបូងជាសាធារណៈ កាលពីថ្ងៃទី ៨ ខែមិថុនា ឆ្នាំ២០១៧ គឺ **កសស** ទទួលបានការ លើកទឹកចិត្តដោយបានការបន្ធូរបន្ថយពន្ធលើប្រាក់ចំណេញចំនួន ៥០% នៃពន្ធលើប្រាក់ចំណេញត្រូវបង់ប្រចាំឆ្នាំក្នុងរយៈពេល៣ឆ្នាំ។

## សម្រាប់ដំណាច់ការិយបរិច្ឆេទ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៧ ប្រៀបធៀបនឹងដំណាច់ការិយបរិច្ឆេទ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៦

| បរិយាយ | សម្រាប់ការិយបរិច្ឆេទ ឆ្នាំ២០១៧ | សម្រាប់ការិយបរិច្ឆេទ ឆ្នាំ២០១៦ | បំរែបំរួល | |
|---|---|---|---|---|
| | ពាន់រៀល | ពាន់រៀល | ពាន់រៀល | % |
| ចំណេញមុនបង់ពន្ធ (ក) | ៣៧.៨៥៤.៦៣២ | ៣៥.៨៤៦.១៧៥ | ២.០០៨.៤៥៧ | ៥,៦០% |
| ចំណាយពន្ធលើប្រាក់ចំណេញ (ខ) | (១២.៧១៥.៣១៦) | (៩.១២៥.៧០៣) | ៣.៥៨៩.៦១៣ | ៣៩,៣៤% |
| ចំណេញក្នុងការិយបរិច្ឆេទ | ២៥.១៣៩.៣១៦ | ២៦.៧២០.៤៧២ | (១.៥៨១.១៥៦) | -៥,៩២% |
| អត្រាពន្ធប្រសិទ្ធភាពលើប្រាក់ចំណេញ (ខ)/(ក) | ៣៣,៥៩% | ២៥,៤៦% | | |

**កសស** មានចំណេញក្រោយបង់ពន្ធចំនួន ២៥.១៣៩.៣១៦.០០០រៀល សម្រាប់ដំណាច់ឆ្នាំ២០១៧ និង ២៦.៧២០.៤៧២.០០០រៀល សម្រាប់ដំណាច់ឆ្នាំ២០១៦ ដែលមានទឹកប្រាក់ថយចុះចំនួន ១.៥៨១.១៥៦.០០០រៀល ស្មើនឹង ៥,៩២% ។ កត្តាដែលធ្វើឱ្យប្រាក់ចំណេញក្រោយបង់ពន្ធថយចុះ គឺដោយសារការខាតពីអត្រាប្តូរប្រាក់ ឆ្នាំ២០១៧ កើនឡើងច្រើនជាង ឆ្នាំ២០១៦ ហើយធ្វើឱ្យចំណេញក្នុងការិយបរិច្ឆេទឆ្នាំ២០១៧ ថយចុះ។

អត្រាពន្ធប្រសិទ្ធភាពលើប្រាក់ចំណេញសម្រាប់ដំណាច់ឆ្នាំ ២០១៧ មានចំនួន ៣៣,៥៩% មានការកើនឡើងបើធៀបនឹងដំណាច់ឆ្នាំ២០១៦ មានតែ ២៥,៦៤% ការកើនឡើងនេះ បណ្តាលមកពីចំណាយពន្ធលើប្រាក់ចំណេញមានការកើនឡើង ៣.៥៨៩.៦១៣.០០០រៀល ស្មើនឹង ៣៩,៣៤% ។

## ង-ការវិភាគពីកត្តា និងនិន្នាការដែលប៉ះពាល់ស្ថានភាព និងលទ្ធផលហិរញ្ញវត្ថុ

កត្តាមួយចំនួនអាចមានឥទ្ធិពលលើស្ថានភាព និងលទ្ធផលហិរញ្ញវត្ថុរបស់ **កសស** ដូចជា៖

- **កត្តានានាដែលធ្វើឱ្យមានកំរិតលើការធ្វើពាណិជ្ជកម្មអន្តរជាតិ**

ដោយសារប្រភពចំណូលចម្បងរបស់ **កសស** បានមកពីចរាចរណ៍ទំនិញឆ្លងកាត់ដែលជាការធ្វើពាណិជ្ជកម្មអន្តរជាតិ ដូចនេះកត្តានានាដែលមានផលប៉ះពាល់ដល់ពាណិជ្ជកម្មអន្តរជាតិ នឹងមានឥទ្ធិពលលើអាជីវកម្មរបស់ **កសស** ដែលកត្តាទាំងនោះមានដូចជា ស្ថានភាពសេដ្ឋកិច្ចក្នុងស្រុក ក្នុងតំបន់ និងសាកលលោក ស្ថិរភាពសង្គម បញ្ហាសន្តិសុខ ឬកិច្ចសហប្រតិបត្តិការនាវាចរតាមសមុទ្រ ។ យោងតាមមូលនិធិ រូបិយប័ណ្ណអន្តរជាតិ (IMF) សេដ្ឋកិច្ចពិភពលោកនឹងបន្តកំណើនជាមួយនឹងអត្រា ៣,៦% សម្រាប់ឆ្នាំ ២០១៧ ចំណែកសេដ្ឋកិច្ចកម្ពុជានឹងមានកំណើនប្រមាណ ៧,១% យោងតាមធនាគារអភិវឌ្ឍអាស៊ី (ADB)។ នេះបង្ហាញថាស្ថានភាពសេដ្ឋកិច្ចកម្ពុជា នៅតែមានភាពរឹងមាំងដែលជាកត្តាវិជ្ជមានចំពោះអាជីវកម្មកំពង់ផែ។ ម្យ៉ាងវិញទៀតគិតត្រឹមឆ្នាំ២០១៧នេះ មិនមានកត្តាអវិជ្ជមានលើបញ្ហាសន្តិសុខក្នុងប្រទេស ឬក្នុងតំបន់ បញ្ហាការធ្វើចរាចរណ៍តាមផ្លូវសមុទ្រ ឬកិច្ចសហប្រតិបត្តិការនានារវាងកំពង់ផែក្នុងតំបន់កើតមានឡើយ ។

- **សមត្ថភាពនិងប្រសិទ្ធភាពបំពេញការងាររបស់ កសស**

សម្រាប់ឆ្នាំ២០១៧ **កសស** បានបង្កើនសមត្ថភាពលើកដាក់កុងតឺន័ររហូតដល់ ៦៥០.000TEUs បន្ទាប់ពីការដាក់ឱ្យប្រើប្រាស់រថចល័តលើគែមផែចំនួន ០២ គ្រឿងបន្ថែមទៀត។ កត្តានេះធ្វើឱ្យសមត្ថភាព និងប្រសិទ្ធភាពការងារមានការកើនឡើងក្នុងការបំពេញសេវាកម្មរបស់ខ្លួន។

- **ស្ថានភាពបណ្តាញដឹកជញ្ជូនក្នុងស្រុក**

សម្រាប់ឆ្នាំ២០១៧ នេះ បណ្តាញដឹកជញ្ជូនក្នុងស្រុក ពិសេសផ្លូវជាតិលេខ ៤ ដែលតភ្ជាប់ពី **កសស** ទៅរាជធានីភ្នំពេញ ពុំមានបង្កជាឧបសគ្គដល់ការដឹកជញ្ជូនទំនិញឡើយ ទោះបីជាក្នុងរដូវ វស្សាមានភ្លៀងធ្លាក់ និងរងទឹកជំនន់តិចតួចក្តី ក៏ការដឹកជញ្ជូនទំនិញឆ្លងកាត់តាមផ្លូវជាតិនេះដំណើរការជាធម្មតា ។ រីឯការដឹកជញ្ជូនតាមផ្លូវដែកបច្ចុប្បន្នក្រុមហ៊ុន Royal Railway ឆ្លងកាត់ **កសស** យ៉ាងតិច ៤ ជើង ក្នុងមួយសប្តាហ៍ក្នុងការនាំទំនិញចេញចូល ហើយការដឹកជញ្ជូនតាមផ្លូវដែកនេះក៏ប្រព្រឹត្តទៅដោយរលូនតាមធម្មតាមិនមានបញ្ហាធ្វើឱ្យខកខានដំណើរនោះទេ ។

- **កិច្ចសហប្រតិបត្តិការរវាងផែក្នុងតំបន់**

កិច្ចសហប្រតិបត្តិការរវាងផែក្នុងតំបន់ ពិសេសគឺការតភ្ជាប់ជាមួយកំពង់ផែមេក្នុងតំបន់មានសារៈសំខាន់ក្នុងការសំរួលចរាចរណ៍ទំនិញរវាង **កសស** និងទីផ្សារអន្តរជាតិសំខាន់ៗ ដោយមានឥទ្ធិពលលើចំណាយ និង រយៈពេលដឹកជញ្ជូន ដែលជាលទ្ធផលធ្វើឱ្យមានផលប៉ះពាល់លើភាពប្រកួតប្រជែងរបស់ឧស្សាហកម្មនានា។ ក្នុងករណីនេះ **កសស** បានខិតខំរក្សាទំនាក់ទំនងល្អជាមួយបណ្តាកំពង់ផែសំខាន់ៗក្នុងតំបន់ ដើម្បីធានាឱ្យប្រតិបត្តិការមានភាពរលូន។

- **រំលស់**

ដោយអាជីវកម្មរបស់ **កសស** មានការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធច្រើន ចំណាយលើរំលស់លើហេដ្ឋារចនាសម្ព័ន្ធផែដូចជា ចំណតនាវា គ្រឿងចក្រ អគារ មានទំហំធំដែលអាចប៉ះពាល់ដល់អាជីវកម្មរបស់ **កសស**។ ដូចនេះ **កសស** ចាំបាច់ត្រូវមានការត្រួតពិនិត្យលើគោលនយោបាយរំលស់ឱ្យបានសមស្រប និងធ្វើការកែតម្រូវ

តាមការចាំបាច់រៀងរាល់ការិយបរិច្ឆេទរបាយការណ៍ហិរញ្ញវត្ថុ ។ សម្រាប់ឆ្នាំ២០១៧នេះ ពុំមានការកែសម្រួល ឬការស្នើឱ្យមានការកែសម្រួលគោលនយោបាយរំលស់នេះពីសវនករឯករាជ្យឡើយ។

## ២-កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេញ

### ក-ការវិភាគពីលក្ខខណ្ឌនៃតម្រូវការ និងការផ្គត់ផ្គង់

សកម្មភាពអាជីវកម្មរបស់ **កសស** មានទំនាក់ទំនងដោយផ្ទាល់ជាមួយសេដ្ឋកិច្ចជាតិ សេដ្ឋកិច្ចតំបន់ និងសេដ្ឋកិច្ចសាកលលោក ។ ជាពិសេសនៅពេលសេដ្ឋកិច្ចជាតិមានបម្រែបម្រួល និងមានឥទ្ធិពលដោយផ្ទាល់ទៅលើអាជីវកម្ម សេវាកម្មកំពង់ផែ ពោលគឺនៅពេលសេដ្ឋកិច្ចជាតិកើនឡើងនាំឱ្យអាជីវកម្ម សេវាកម្ម កំពង់ផែក៏កើនឡើង ស្របនឹងនេះផលចំណូលរបស់ **កសស** ក៏មានកំណើនដូចគ្នា ផ្ទុយទៅវិញ បើសេដ្ឋកិច្ចជាតិថយចុះ នឹងមានផលអវិជ្ជមានទៅលើផលចំណូល **កសស** ផងដែរ ។ យោងតាមរបាយណ៍របស់ ធនាគារអភិវឌ្ឍអាស៊ី (ADB) សេដ្ឋកិច្ចកម្ពុជានៅតែបន្តកំណើនរបស់ខ្លួនដែលមានអត្រារំពឹងទុក ៧,១% ចំណែកសេដ្ឋកិច្ចពិភពលោកមានកំណើន ៣,៦% បើយោងតាមរបាយការណ៍របស់មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) ។ ហេតុដូចនេះ ក្នុងឆ្នាំ២០១៧ ទាំងមូលមិនមានផលប៉ះពាល់អវិជ្ជមាន លើអាជីវកម្មរបស់ **កសស** ឡើយ ។

### ខ-ការវិភាគពីការឡើងចុះនៃថ្លៃវត្ថុធាតុដើម

ប្រេងឥន្ធនៈ ជាវត្ថុធាតុដើមចម្បងបំផុតក្នុងការបម្រើសេវាកម្មកំពង់ផែ ដោយជាតម្រូវការសំខាន់សម្រាប់ប្រតិបត្តិការគ្រឿងចក្រ ។ ការឡើងថ្លៃរបស់ប្រេងឥន្ធនៈនឹងប៉ះពាល់ដល់ផលចំណេញរបស់ **កសស** ដោយ **កសស** នៅតែរក្សាតម្លៃសេវារបស់ខ្លួនដដែល ទោះជាតម្លៃរបស់ប្រេងឥន្ធនៈមានការឡើងថ្លៃក៏ដោយ ។ ហេតុដូចនេះ **កសស** បានអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវនីតិវិធីលទ្ធកម្ម ដើម្បីធានាឱ្យបាននូវតម្លៃរបស់វត្ថុធាតុដើមទាំងនេះមានភាពសមស្រប និងប្រកួតប្រជែងក្នុងតម្លៃទីផ្សារ ។

### គ-ការវិភាគលើពន្ធ

**កសស** ស្ថិតនៅក្រោមច្បាប់នៃក្រុមហ៊ុនពាណិជ្ជកម្មក្នុងវិស័យពន្ធដារ និងអាករ ហេតុដូចនេះ **កសស** មានកាតព្វកិច្ចត្រូវបង់ពន្ធអាករ ទៅតាមច្បាប់ និងបញ្ញត្តិជាធរមាន ។ **កសស** ត្រូវបង់ពន្ធអាករ ទៅតាមរបបពិត និងជាសហគ្រាសជាប់ពន្ធធំ ដែលបានកំណត់ដោយអគ្គនាយកដ្ឋានពន្ធដារ ។ ចំពោះពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ **កសស** ត្រូវមានកាតព្វកិច្ចបង់ក្នុងអត្រា ២០% ប៉ុន្តែ ដោយទទួលបានការលើកទឹកចិត្តក្នុងវិស័យមូលបត្រ **កសស** ទទួលបានការបន្ធូរបន្ថយពន្ធលើប្រាក់ចំណេញចំនួន ៥០% នៃពន្ធលើប្រាក់ចំណេញត្រូវបង់ប្រចាំឆ្នាំក្នុងរយៈពេល៣ឆ្នាំ ។ ដូច្នេះ ក្រោយពីបញ្ចប់ការអនុគ្រោះនេះ **កសស** នឹងអនុវត្តកាតព្វកិច្ចពន្ធលើប្រាក់ចំណេញដូចធម្មតាវិញ ។ ចំណែកពន្ធផ្សេងៗ **កសស** បានអនុវត្តតាមកាតព្វកិច្ចរបស់ខ្លួនតាមច្បាប់ពន្ធដាររបស់ព្រះរាជាណាចក្រកម្ពុជា ។

## ៣-ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល

ចំណូលសំខាន់របស់ **កសស** មានចំណូលលើកដាក់ និងចំណូលពីសេវាកម្មផែ ដែលរួមចំណែកប្រមាណ ៩៨% នៃចំណូលសរុបសម្រាប់ឆ្នាំ២០១៧ ហើយកត្តាចម្បងដែលជំរុញឱ្យមានការកើនឡើងនៃ ប្រាក់ចំណូល គឺកំណើននៃនាវា និងទំនិញឆ្លងកាត់កំពង់ផែ ជាពិសេសទំនិញកុងតឺន័រ ដែលជាប្រភពចំណូលដ៏សំខាន់របស់ **កសស** ។ ការលូតលាស់ក្នុងវិស័យកសិកម្ម វិស័យពាណិជ្ជកម្ម វិស័យសំណង់ និងវិស័យឧស្សាហកម្ម គឺបានឆ្លុះបញ្ចាំងនូវស្ថានភាពសេដ្ឋកិច្ចជាតិរបស់ប្រទេសកម្ពុជា ហើយស្របនឹងនេះ ក៏មានឥទ្ធិពលជាវិជ្ជមានលើអាជីវកម្ម សេវាកម្ម និងផលចំណូលរបស់ **កសស** ផងដែរ ។

## ៤-ផលប៉ះពាល់នៃការប្តូររូបិយបណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ (Commodity)

**- ផលប៉ះពាល់ពីអត្រាប្តូរប្រាក់**

**កសស** បានទទួលប្រាក់កម្ចីបន្តតាមរយៈក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ពី JICA និង JBIC ដោយតម្រូវឱ្យ **កសស** សងប្រាក់ដើម និងការប្រាក់ជាប្រាក់យ៉េនជប៉ុន និងប្រាក់ដុល្លារអាមេរិក នៅពេលដែលរូបិយវត្ថុមុខងាររបស់ **កសស** គឺជាប្រាក់រៀល ។ ដូចនេះ បំរែបំរួលអត្រាប្តូរប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាមេរិក ប្រាក់រៀលធៀបនឹងប្រាក់យ៉េនជប៉ុន និងប្រាក់ដុល្លារធៀបនឹងប្រាក់យ៉េនជប៉ុន នឹងប៉ះពាល់ដល់កម្រិតប្រាក់ចំណេញរបស់ **កសស** ។

**- ផលប៉ះពាល់ពីអត្រាការប្រាក់**

បច្ចុប្បន្ន **កសស** មិនមានកម្ចីណាដែលមានអត្រាការប្រាក់ប្រែប្រួលនោះទេ ។ **កសស** បានទទួលប្រាក់កម្ចីពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលជាកម្ចីបន្តពី JICA និង JBIC ក្នុងអត្រាការប្រាក់ចាប់ពី ២,៥% ដល់ ៣,៧% ។ ហេតុដូចនេះ សម្រាប់ឆ្នាំ២០១៧ នេះ មិនមានផលប៉ះពាល់ពីបម្រែបម្រួលអត្រាការប្រាក់នេះទេ ។

**-ផលប៉ះពាល់ពីការប្រែប្រួលតម្លៃប្រេងឥន្ធនៈ**

ការប្រែប្រួលតម្លៃប្រេងឥន្ធនៈនឹងមានផលប៉ះពាល់ដល់ផលចំណេញរបស់ **កសស** ដោយប្រតិបត្តិការកំពង់ផែ ពឹងផ្អែកយ៉ាងខ្លាំងទៅលើគ្រឿងចក្រដែលប្រើប្រាស់ប្រេងឥន្ធនៈ ។ ហេតុដូចនេះ **កសស** បានពង្រឹងប្រសិទ្ធភាពលើកដាក់ និងការគ្រប់គ្រងទីលានកុងតឺន័រ ដើម្បីកាត់បន្ថយការរើឬការបំលាស់ទីកុងតឺន័រដែលមិនចាំបាច់ ដើម្បីកាត់បន្ថយចំណាយប្រតិបត្តិការ និងលើកកំពស់សេវាកម្មរបស់ខ្លួន ។

## ៥-ផលប៉ះពាល់នៃអតិផរណា

**កសស** បានរក្សានូវតម្លៃសេវាកម្មរបស់ខ្លួនថេរ ដោយមិនធ្វើការប្រែប្រួល ឬកែសម្រួលទៅតាមការប្រែប្រួលនៃអតិផរណាឡើយ ហើយនៅតែរក្សាបាននូវស្ថេរភាពហិរញ្ញវត្ថុបានយ៉ាងប្រសើរ ។

## ៦-គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុ របស់រដ្ឋាភិបាល

គោលនយោបាយ សេដ្ឋកិច្ច សារពើពន្ធនិងរូបិយវត្ថុ របស់រដ្ឋាភិបាលមានឥទ្ធិពលយ៉ាងខ្លាំងលើអាជីវកម្មរបស់ **កសស** ដោយសារគោលនយោបាយនេះមានទិសដៅគាំទ្រនិងលើកស្ទួយវិស័យ ពាណិជ្ជកម្មអន្តរជាតិ និងផ្តល់ផលវិជ្ជមានដល់អាជីវកម្មរបស់ **កសស** ។ គោលនយោបាយសំខាន់ៗរបស់រាជរដ្ឋាភិបាលរួមមាន ៖

- គោលនយោបាយលើកស្ទួយវិស័យឧស្សាហកម្ម រាជរដ្ឋាភិបាលមានគំរោងប្រែក្លាយខេត្តព្រះសីហនុឱ្យទៅជាមជ្ឈមណ្ឌលពាណិជ្ជកម្ម ឡូជីស្ទីក និងផលិតកម្ម តាមរយៈការកសាងហេដ្ឋារចនាសម្ព័ន្ធផែ ពង្រីកផ្លូវជាតិលេខ ៤ និងគម្រោងសាងសង់ផ្លូវល្បឿនលឿនពីភ្នំពេញ-ខេត្តព្រះសីហនុ និងហេដ្ឋារចនាសម្ព័ន្ធព្រលានយន្តហោះអន្តរជាតិខេត្តព្រះសីហនុផងដែរ ។
- វិស័យឧស្សាហកម្មរ៉ែ ថាមពល ការរុករកប្រេងក្នុងដែនសមុទ្រកម្ពុជាកំពុងមានការអភិវឌ្ឍន៍ ហើយ **កសស** បានត្រៀមខ្លួនជាស្រេចក្នុងការគាំទ្រវិស័យទាំងនោះ
- គោលនយោបាយជម្រុញការដឹកជញ្ជូនតាមផ្លូវទឹក
- គោលនយោបាយនាំចេញអង្ករចេញទៅទីផ្សារក្រៅប្រទេស កំពុងផ្តល់ផលវិជ្ជមានដល់ **កសស**
- គោលនយោបាយលើកស្ទួយពាណិជ្ជកម្មអន្តរជាតិ ដោយខិតខំកាត់បន្ថយឧបសគ្គនានា ចំពោះការធ្វើពាណិជ្ជកម្មរវាងកម្ពុជានិងបណ្តាប្រទេសជាដៃគូក្នុងសាកលលោក
- រាជរដ្ឋាភិបាលតាមរយៈធនាគារជាតិ បានអនុវត្តគោលនយោបាយរូបិយវត្ថុតាមរយៈយន្តការ ទីផ្សារប្តូរប្រាក់សេរីតែស្ថិតនៅក្រោមអន្តរាគមន៍ដើម្បីរក្សា ស្ថិរភាពរូបិយប័ណ្ណជាតិ ហើយលំនឹងរូបិយវត្ថុនេះបានរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចកម្ពុជា ដែលបានកសាងទំនុកចិត្ត ចំពោះវិនិយោគិន និងជម្រុញការធ្វើអាជីវកម្មវិស័យឯកជន
- ការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រ ដល់សហគ្រាសបោះផ្សាយលក់មូលបត្រនៅកម្ពុជាបាន នឹងកំពុងជម្រុញឱ្យសហគ្រាសរដ្ឋ និងក្រុមហ៊ុនឯកជនចូលទីផ្សារមូលបត្រកាន់តែច្រើន ដែលចូលរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ។

# ផ្នែកទី ៩

## ព័ត៌មានចាំបាច់ផ្សេងទៀតសម្រាប់ការ
## ការពារវិនិយោគិន

នៅក្នុងឆ្នាំ២០១៧ នេះ ពុំមានព័ត៌មានចាំបាច់ផ្សេងទៀតសម្រាប់ការការពារវិនិយោគិនទេ។

# ហត្ថលេខារបស់អភិបាលកំពង់ផែស្វយ័តក្រុងព្រះសីហនុ

ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៨
បានអាន និងឯកភាព

ហត្ថលេខា
**លូ គីមឈន់**
អភិបាល

ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៨
បានអាន និងឯកភាព

ហត្ថលេខា
**គឹករ៉េត សំរេច**
អភិបាល

ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៨
បានអាន និងឯកភាព

ហត្ថលេខា
**ផាន់ ផល្លា**
អភិបាល

ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៨
បានអាន និងឯកភាព

ហត្ថលេខា
**យន្ត មីន**
អភិបាល

ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៨
បានអាន និងឯកភាព

ហត្ថលេខា
**ស៊ុយ សាន**
អភិបាល

ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៨
បានអាន និងឯកភាព

ហត្ថលេខា
**សុខ សុត៌ាក្ត**
អភិបាល

ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៨
បានអាន និងឯកភាព

ហត្ថលេខា
**លូ លីខេង**
អភិបាល



(855) 34 933 416 | 34 933 511

pasinfo@pas.gov.kh

(855) 34 933 693

www.pas.gov.kh